ខុមហ្វ្រែល COMFREL

ការឃ្លាំមើល និងការផ្តល់ពិន្ទុ

លទ្ធផលនៃការបំពេញ/អនុវត្តន៍គោលនយោបាយ

រាជរដ្ឋាភិបាលនីតិកាលទី៥ ឆ្នាំទី៣

- *វាយតម្លៃគោលនយោបាយមានសូចនាករ*
- *ផ្តល់ពិន្ទុគោលនយោបាយមិនមានសូចនាករ*

មីនា 2017

របាយការណ៍

ស្តីពី

ការឃ្លាំមើល និងការផ្តល់ពិន្ទុលើលទ្ធផល
នៃការបំពេញ/អនុវត្តន៍គោលនយោបាយ
របស់រាជរដ្ឋាភិបាលនីតិកាលទី៥ ឆ្នាំទី៣

ខែមីនា ឆ្នាំ២០១៧

Vision : A democratic society that democratization in particular democratic elections are promoted and qualified to bring benefits to people.
ការកសាងសង្គមប្រជាធិបតេយ្យ ១ ដែលការលើកកម្ពស់ការបោះឆ្នោតប្រជាធិបតេយ្យ ជាពិសេសការបោះឆ្នោតប្រកបដោយគុណភាព ធានានូវផលប្រយោជន៍ជូនប្រជាពលរដ្ឋ។

ថ្ងៃទី០៩ ខែមិនា ឆ្នាំ២០១៧

សេចក្តីប្រកាសព័ត៌មាន
ស្តីពី
ការឃ្លាំមើល និងការផ្តល់ពិន្ទុលើលទ្ធផលនៃការបំពេញ/អនុវត្តន៍គោលនយោបាយ របស់រាជរដ្ឋាភិបាលនីតិកាលទី៥ ឆ្នាំទី៣

ឆ្នាំទី៣នៃនីតិកាលទី៥ រាជរដ្ឋាភិបាល ដែលដឹកនាំដោយគណបក្សប្រជាជនកម្ពុជា បានសម្រេចពេញលេញនូវការបំពេញ/អនុវត្តន៍គោលនយោបាយចំនួន០៦ (៣៧,៥%)នៃ១៦ ចំណុចនៃគោលនយោបាយដែលមានសូចនាករច្បាស់លាស់ រួមមានដូចជា៖ កំណើនសេដ្ឋកិច្ច៧%ក្នុងមួយឆ្នាំ ការកាត់បន្ថយភាពក្រីក្រក្នុងអត្រា០១%ក្នុងមួយឆ្នាំ ការបញ្ឈប់ការផ្តល់សម្បាទានដីសេដ្ឋកិច្ច ការកសាងគោលនយោបាយជាតិសស្តីពីលំនៅដ្ឋាន ការរៀបចំគោលនយោបាយដឹកជញ្ជូនទីក្រុង និងការបង្កើតគោលនយោបាយជាតិ ស្តីពីមុខរបរ និងការងារ។

ចំណែកឯគោលនយោបាយចំនួន០៧ រាជរដ្ឋាភិបាលអនុវត្ត ឬ/និងសម្រេចបានខ្លះ។ គោលនយោបាយទាំងនោះមានដូចជា ការនាំអង្ករចេញឲ្យបាន០១លានតោន ការរក្សាផ្ទៃនេសាទទឹកសាប ការចុះបញ្ជីដីធ្លី ប្រជាជនទទួលសេវាទឹកស្អាត ការពង្រីកការផ្គត់ផ្គង់អគ្គិសនីពីបណ្តាញជាតិឲ្យដល់ភូមិ គោលដៅចំនួនទេសចរណ៍ពីក្រៅប្រទេសឆ្នាំ២០១៨ និងការបន្ត កសាងអនុវិទ្យាល័យឲ្យបានគ្រប់ឃុំ។ ចំពោះគោលដៅចំនួនទេសចរណ៍ពីក្រៅប្រទេស រាជរដ្ឋាភិបាលបានសម្រេចគោលដៅដែលបានកំណត់ក្នុងឆ្នាំ២០១៥រួចមកហើយ។ ដោយសារតែគោលដៅក្នុងដំណាក់កាលទី២ រាជរដ្ឋាភិបាលបានកំណត់ដល់ឆ្នាំ២០១៨ ដូចនេះយើងអាចសន្និដ្ឋានបានថា រាជរដ្ឋាភិបាលសម្រេចបានខ្លះក្នុងឆ្នាំ២០១៦។

ប៉ុន្តែគោលនយោបាយចំនួន០៣ រាជរដ្ឋាភិបាលបានអនុវត្ត តែមិនអាចសម្រេចបាន ឬបានតិចតួចតាមការសន្យារបស់ខ្លួន។ គោលនយោបាយទាំងនោះមានដូចជា គោលនយោបាយការរក្សាផ្ទៃដីដែលគ្របដណ្តប់ដោយព្រៃឈើ ការកែលម្អផ្លូវលំជនបទពី៣០០ ទៅ៤០០គីឡូម៉ែត្រក្នុង១ឆ្នាំ និងការដាក់ឲ្យដំណើរការរបបប្រាក់សោធននិវត្តន៍សម្រាប់កម្មករ និយោជិតក្នុងវិស័យឯកជន។

ការផ្តល់ពិន្ទុសម្រាប់ឆ្នាំទី៣លើគោលនយោបាយដែលមិនមានសូចនាករច្បាស់លាស់ មានប្រជាពលរដ្ឋចំនួន៤២៩នាក់ (៤០%ជាស្ត្រី) នៃ១៤ខេត្ត/រាជធានីបានចូលរួមផ្តល់ពិន្ទុ ក្នុងនោះប្រមាណ១៩%ពេញចិត្ត ប្រមាណ៦២%ពេញចិត្តខ្លះ និងប្រមាណ១៩%មិនពេញចិត្តនឹងលទ្ធផលការបំពេញ/អនុវត្តគោលនយោបាយទាំងនោះ។

បើពិនិត្យពីការផ្តល់ពិន្ទុលើវិស័យនីមួយៗវិញ គេឃើញថាវិស័យការពារជាតិសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ក្នុងចំណោមប្រជាពលរដ្ឋបានផ្តល់ពិន្ទុ មានប្រជាពលរដ្ឋ ចំនួន១៨%ពេញចិត្ត, ៦០%ពេញចិត្តខ្លះ និង២១%មិនពេញ

ចិត្ត។ ចំណែកឯវិស័យពង្រឹងរដ្ឋបាលសាធារណៈ វិមជ្ឈការ និងវិសហមជ្ឈការ ការពង្រឹងផ្នែកច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងការប្រឆាំងអំពើពុករលួយត្រូវបានផ្តល់ពិន្ទុដោយប្រជាពលរដ្ឋចំនួន១៧%ពេញចិត្ត, ៦០%ពេញចិត្តខ្លះ និង២២%មិនពេញចិត្ត។ វិស័យការអភិវឌ្ឍន៍សេដ្ឋកិច្ចវិញ ក៏ត្រូវបានប្រជាពលរដ្ឋចំនួន១៩%ពេញចិត្ត, ៦៣%ពេញចិត្តខ្លះ និង១៩% មិនពេញចិត្ត។ ជាមួយគ្នានោះដែរ វិស័យការអភិវឌ្ឍន៍វិស័យអប់រំ សុខាភិបាល ការងារ វប្បធម៌ និងសង្គមកិច្ចត្រូវបានប្រជាពលរដ្ឋចំនួន២០% ពេញចិត្ត, ៦៣% ពេញចិត្តខ្លះ និង ១៥% មិនពេញចិត្ត។ ក្នុងចំណោម វិស័យទាំង០៤ ការបំពេញ/អនុវត្តគោលនយោបាយវិស័យការពង្រឹងរដ្ឋបាលសាធារណៈ វិមជ្ឈការ និងវិសហមជ្ឈការ ការពង្រឹងផ្នែកច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងការប្រឆាំងអំពើពុករលួយមានប្រជាពលរដ្ឋច្រើនជាងគេមិនពេញចិត្ត ខណៈដែលការអភិវឌ្ឍន៍វិស័យអប់រំ សុខាភិបាល ការងារ វប្បធម៌ និងសង្គមកិច្ចត្រូវបានពេញចិត្តច្រើនជាងគេវិញ។

បើពិនិត្យមើលថវិកាជាតិដែលគ្រោងចំណាយឆ្នាំ២០១៦ ចំនួន៤.៣៦៥លានដុល្លារសហរដ្ឋអាមេរិកវិញ រាជរដ្ឋាភិបាលគ្រោងចំណាយលើវិស័យនីមួយៗគឺ សង្គមកិច្ច និងសេដ្ឋកិច្ចប្រមាណ២៨% វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈចំនួន១៦%, និងវិស័យរដ្ឋបាលទូទៅចំនួន១០% នៃថវិកាជាតិសរុបដែលរួមបញ្ចូលទាំងថវិកាមិនទាន់បែងចែង។ ហើយការចំណាយលើវិស័យរដ្ឋបាលទូទៅធ្លាក់ចុះបន្តិចបន្តួច បើធៀបនឹងការចំណាយឆ្នាំ២០១៥។

សម្រាប់ឆ្នាំទី៣នេះ ចំនួនសមាជិករាជរដ្ឋាភិបាល និងអនុរដ្ឋលេខាធិការកើនឡើងបន្ថែមទៀត។ ក្នុងរយៈពេល ៧ខែ ដើមឆ្នាំ ២០១៦ សមាជិកថ្មីចំនួន ១៥រូបត្រូវបានតែងតាំងជា ទេសរដ្ឋមន្ត្រី និងរដ្ឋលេខាធិការ ខណៈដែលសមាជិក ០២រូបបានបញ្ចប់ដំណែង។ ក្រៅពីសមាជិករាជរដ្ឋាភិបាល គេក៏នៅតែឃើញមានការកើនឡើងនូវអនុរដ្ឋលេខាធិការចំនួន ៣០រូប នៅតាមបណ្តាក្រសួងចំនួន១៦ និងទីប្រឹក្សារាជរដ្ឋាភិបាលចំនួន១០រូបដែលមានឋានៈស្មើនឹងសមាជិករាជរដ្ឋាភិបាល។ មានការផ្លាស់ប្តូររដ្ឋមន្ត្រីថ្នាក់ដឹកនាំក្រសួងចំនួន០៨ ប៉ុន្តែការផ្លាស់ប្តូរនេះ ត្រូវបានគេមើលឃើញថា ជាការផ្លាស់ប្តូរស្ថាប័នដើម្បីដឹកនាំរវាងរដ្ឋមន្ត្រីទាំងនោះ ដោយសារដំណែងរដ្ឋមន្ត្រីចំនួន ០៦ ត្រូវបានប្រគល់ឲ្យអតីតរដ្ឋមន្ត្រីនៃនីតិកាលទី៥នេះដដែល។

ក្នុងរយៈពេលដូចគ្នានេះ រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យចំនួន៨៧៣អនុក្រឹត្យ និងប្រកាសចំនួន២៥៤ប្រកាស។ ប្រមាណ០៣%នៃអនុក្រឹត្យទាំងនោះ ស្តីអំពីការធ្វើអនុបយោគទ្រព្យ សម្បត្តិសាធារណៈរបស់រដ្ឋ ទៅជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ និងការផ្ទេរតណទានថវិកា។ ចំណែកអនុក្រឹត្យផ្សេងទៀត អំពីការជូនមេដាយ និងតែងតាំង ផ្ទេរភារកិច្ចមន្ត្រីរាជការជាដើម។

បើទោះបីគោលនយោបាយមានសូចនាករច្បាស់លាស់ត្រូវបានរដ្ឋាភិបាលសម្រេចបានចំនួន០៦ ឬស្មើនឹង៣៧% ដូចគ្នានឹងឆ្នាំ២០១៥ ប៉ុន្តែគោលនយោបាយខ្លះដែលបានសម្រេចបាននៅឆ្នាំ២០១៥បែរជារាជរដ្ឋាភិបាលបំពេញ/អនុវត្តសម្រេចបានខ្លះនៅឆ្នាំ២០១៦វិញ ដូចជាគោលនយោបាយគោលដៅទទួលចំនួនភ្ញៀវទេសចរបរទេសត្រូវបានរាជរដ្ឋាភិបាលសម្រេចបានខ្លះក្នុងឆ្នាំ២០១៦ ហើយគោលនយោបាយការកសាងគោលនយោបាយជាតិស្តីពីលំនៅដ្ឋានត្រូវបានបំពេញ/អនុវត្តសម្រេចបានឆ្នាំ២០១៦។

សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង:

១.លោក **គឹម ឈន**	អ្នកសម្របសម្រួលជាន់ខ្ពស់នៃកម្មវិធី	០១២ ៩៤ ២០ ១៩
២.លោក **សៀន ប៊ុនវិទ្ធ**	មន្ត្រីផ្នែកអង្កេត	០១១ ៥៣ ៥៣ ៥៤

<u>បេសកកម្ម</u> ៖ បេសកកម្មរបស់ខុមប្រ្ចៀល គឺជួយបង្កើតបរិយាកាសគួរជាទីពេញចិត្ត និងមានព័ត៌មានគ្រប់គ្រាន់ ទី១/**ដើម្បីឱ្យមានដំណើរការបោះឆ្នោតដោយសេរី និងយុត្តិធម៌** តាមរយៈការបញ្ជុះបញ្ចូល តស៊ូមតិ ដើម្បីទទួលបាននូវក្របខ័ណ្ឌច្បាប់សមរម្យ, ការអប់រំដើម្បីផ្តល់ព័ត៌មានដល់អ្នកបោះឆ្នោត អំពីសិទ្ធិ និងសកម្មភាពចូលរួមសង្កេតការណ៍របស់ពួកគេ ដែលអាចរារាំងនូវភាពមិនប្រក្រតី ព្រមទាំងផ្តល់នូវរបាយការណ៍អង្កេតយ៉ាងទូលំទូលាយ និងឆាប់រហ័ស ដើម្បីអាចឲ្យមានការវាយតម្លៃលើដំណើរការ បោះឆ្នោតមួយដែលមិនលំអៀង និងមិនប្រកាន់បក្សពួក ទី២/**ដើម្បីឱ្យមានអត្ថន័យនៃដំណាក់កាលក្រោយពេលបោះឆ្នោត** តាមរយៈការអប់រំ និងវេទិកាសាធារណៈក្នុងគោលបំណងជំរុញលើកទឹកចិត្ត ប្រជាពលរដ្ឋឱ្យចូលរួមក្នុងកិច្ចការនយោបាយ និងការធ្វើសេចក្តីសំរេចនានា ការតស៊ូមតិ/បញ្ជុះបញ្ចូលដើម្បីឱ្យមានការកែទម្រង់ ដំណើរការបោះឆ្នោតដែលបង្កើននូវគណនេយ្យភាព (ការទទួលខុសត្រូវ) របស់មន្ត្រីជាប់ឆ្នោត ព្រមទាំងផ្តល់នូវរបាយការណ៍អង្កេតយ៉ាងទូលំទូលាយ និងឆាប់រហ័ស ដើម្បីអាចឱ្យមានការវាយតម្លៃមួយដែលមិនលំអៀង និងប្រកាន់បក្សពួក ទៅលើការបំពេញកម្មវិធីនយោបាយ និងដំណើរការអនុវត្តន៍ការងាររបស់មន្ត្រីជាប់ឆ្នោត។

Phnom Penh, 09th March 2016

Vision : A democratic society that democratization in particular democratic elections are promoted and qualified to bring benefits to people.
ការចាប់ផ្តើមពីការកែលម្អ ការកសាងសមត្ថភាពរួម ការផ្តល់អត្ថន័យដ៏ល្អ ដើម្បីអ្នកគ្រប់គ្រងបានកែលម្អ ។ ការកសាងសង្គមប្រជាធិបតេយ្យ

Press Release

'Assessment and Voters' Scorecard on the Third Year Fulfillment of Political Platform of the Fifth Mandate of Government'

During the third year of the fifth mandate of the National Assembly (NA), the Royal Government of Cambodia (RGC), led by the Cambodian People's Party (CPP), has fulfilled six (37.5%) of 16 political platforms with precise indicators. They are: annual 7% economic growth, annual 1% poverty reduction, halting of economic land concessions, national housing policy design transportation policy creation, and the creation of a national policy related to jobs and careers.

While another seven political platforms related to one million tons of rice exports, water for family fishing, land title registration, people's access to running water, village electricity supplies, target number of foreign tourists by 2018, and secondary school construction in all communes have only been partly fulfilled and/or implemented by the RGC. For 2015 target number of foreign tourist was fulfilled. In 2016 this promise is being implemented to reach that years' target.

Three political platform promises have been implemented, but when compared to the previous performance the RGC is unlikely to fulfill them. For example, maintenance of existing forest cover, annual 300km to 400km of rural roads improvement and implementation of retirement allowance in the private sector.

For the third year, voters' scorecard on the fulfillment of political platform with imprecise indicators, showed that 19% of 429 participants (40% are female) are satisfied, 62% of them are partly satisfied, while 19% are not satisfied.

Looking at the score of each of the four sectors, it can be shown that the first sector on national defence security and public order is satisfied by 18% of participants, partly satisfied by 60% and not satisfied by 21%. The second sector on improvement of public administration, decentralization and deconcentration, law and justice, and anti-corruption activities is satisfied by 17% of participants, partly satisfied by 60% and not satisfied by 22%. The third sector on economic development is satisfied by 19% of participants, partly satisfied by 63% and not satisfied by 19%. And the last sector on development of education, health, labor, culture and social affairs is satisfied by 20% of participants, partly satisfied by 63% and not satisfied by 15% of them. This shows that the fulfillment of the second sector, if compared to others, is not satisfied, while development of education, health, labor, culture fulfillment is satisfied by most participants.

Reviewing the 2016 national budget, the RGC planned to spend US $4,365 million, 16% of which is not allocated. The RGC planned to allocate to social affairs and the economic sector about 28% of the budget each. About 16 % of the budget is allocated to national defence, security and public order,

ទីស្នាក់ការកណ្តាល ៖ ផ្ទះលេខ ១៣៨ ផ្លូវ ១២២ សង្កាត់ ទឹកល្អក់ ១ ខណ្ឌ ទួលគោក រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
Central Office : #138, Street. 122, Teuk Laak I, Tuol Kork, Phnom Penh, CAMBODIA.
P.O. Box 1145, **Phone** : (855) 23 884 150 **Fax**: (855) 23 885 745 **E-mail** : comfrel@online.com.kh **Website**: www.comfrel.org

and around 10% to general administration. The budget allocation to general administration, if compared to 2015, has decreased slightly.

To fulfill and implement its political platforms in the third year, the RGC has increased its cabinet members and under secretaries of state. In the first seven months 15 more officials were appointed as cabinet members, senior minsters or secretaries of state, while only two ministers had been removed. The number of undersecretaries of state has increased by 30 in 16 ministries, while only two had been removed. Also, Royal Government of Cambodia's advisor, ranked as members of the cabinet, has increased by 10. It is noted that minsters were switched between 8 ministries, but this is considered as changing institution to lead, as six ministerial positions were given to former minsters.

During this seven month period the RGC had issued 873 sub degrees and 254 announcements. Around 03% of sub degrees concern the transferring of public property to the private property of state, and transference of budgets. The reamainder concerned the awarding of medals, commendations and promotion of government officials.

For Further information please contact:

1. ***Mr. Kim Chhorn*** Senior Program Coordinator 012 94 20 19
2. ***Mr. Sean Bunrith*** Monitoring Officer 011 53 53 54

<u>បេសកកម្ម</u> ៖ បេសកកម្មរបស់ខុមប្រ្ចៀល គឺជួយបង្កើតបរិយាកាសគួរជាទីពេញចិត្ត និងមានព័ត៌មានគ្រប់គ្រាន់ ទី១/**ដើម្បីឱ្យមានដំណើរការបោះឆ្នោតដោយសេរី និងយុត្តិធម៌** តាមរយៈការបញ្ចុះបញ្ចូល តស៊ូមតិ ដើម្បីទទួលបាននូវក្របខ័ណ្ឌច្បាប់សមរម្យ, ការអប់រំដើម្បីផ្តល់ព័ត៌មានដល់អ្នកបោះឆ្នោត អំពីសិទ្ធិ និងសកម្មភាពចូលរួមសង្កេតការណ៍របស់ពួកគេ ដែលអាចវាវាំងនូវភាពមិនប្រក្រតី ព្រមទាំងផ្តល់នូវរបាយការណ៍អង្កេតយ៉ាងទូលំទូលាយ និងឆាប់រហ័ស ដើម្បីអាចឲ្យមានការវាយតម្លៃលើដំណើរការ បោះឆ្នោតមួយដែលមិនលំអៀង និងមិនប្រកាន់បក្សពួក ទី២/**ដើម្បីឱ្យមានអត្ថន័យនៃដំណាក់កាលក្រោយពេលបោះឆ្នោត** តាមរយៈការអប់រំ និងវេទិកាសាធារណៈក្នុងគោលបំណងជំរុញលើកទឹកចិត្ត ប្រជាពលរដ្ឋឱ្យចូលរួមក្នុងកិច្ចការនយោបាយ និងការធ្វើសេចក្តីសំរេចនានា ការតស៊ូមតិ/បញ្ចុះបញ្ចូលដើម្បីឱ្យមានការកែទម្រង់ ដំណើរការបោះឆ្នោតដែលបង្កើននូវគណនេយ្យភាព (ការទទួលខុសត្រូវ) របស់មន្ត្រីជាប់ឆ្នោត ព្រមទាំងផ្តល់នូវរបាយការណ៍អង្កេតយ៉ាងទូលំទូលាយ និងឆាប់រហ័ស ដើម្បីអាចឱ្យមានការវាយតម្លៃមួយដែលមិនលំអៀង និងប្រកាន់បក្សពួក ទៅលើការបំពេញកម្មវិធីនយោបាយ និងដំណើរការអនុវត្តន៍ការងាររបស់មន្ត្រីជាប់ឆ្នោត។

មាតិកា

I.ខ្លឹមសារសង្ខេប 1

II.សេចក្តីផ្តើម 2

III.ភ្ជាប់ទី និងការកិច្ចរាជរដ្ឋាភិបាល 3

IV.ការប្រមូលសមាសភាពសមាជិករាជរដ្ឋាភិបាល 3

V.អនុក្រឹត្យរបស់រាជរដ្ឋាភិបាល និងប្រកាសរបស់ក្រសួងឆ្នាំ២០១៦ 5

VI.បម្រែបម្រួលថវិកាថ្នាក់ជាតិគ្រោងចំណាយឆ្នាំ២០១៤-២០១៧ 6

VII.ការរកឃើញ និងការផ្តល់ពិន្ទុលើលទ្ធផលនៃការបំពេញ/អនុវត្តន៍គោលនយោបាយ 6

១. ការបំពេញ/អនុវត្តន៍គោលនយោបាយមានសូចនាករច្បាស់លាស់ 9

០១. ខិតខំសម្រេចឲ្យបាននូវកំណើនសេដ្ឋកិច្ចជាមធ្យម៧% ក្នុងមួយឆ្នាំ ដើម្បីធ្វើឲ្យកម្ពុជាអាចចាកចេញផុតពីប្រទេសមានចំណូលទាប ឈានឡើងជាប្រទេសមានចំណូលមធ្យមកម្រិតទាប យ៉ាងយូរនៅឆ្នាំ២០១៨ និងក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០។ 9

០២. សម្រេចឲ្យបានគោលដៅកាត់បន្ថយអត្រានៃភាពក្រីក្រជាង១% ក្នុងមួយឆ្នាំ។ 10

០៣. បន្តខិតខំសម្រេចនូវគោលនយោបាយ ជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករឲ្យបាន១លានតោននៅឆ្នាំ២០១៥ សំដៅប្រែក្លាយកម្ពុជា ទៅជាប្រទេសផលិតស្បៀងនាំមុខមួយនៅលើពិភពលោក។ 11

០៤. រក្សាផ្ទៃនេសាទទឹកសាបសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាលក្ខណៈគ្រួសារ ពង្រឹងតំបន់អភិរក្ស បង្កើនការការពារធនធានជលផល លុបបំបាត់បទល្មើសនេសាទគ្រប់រូបភាព។ 12

០៥. រក្សាផ្ទៃដីដែលគ្របដណ្ដប់ដោយព្រៃឈើ ដោយបង្កើនការការពារធនធានព្រៃឈើ ពិសេសការពង្រឹងការអនុវត្តន៍ច្បាប់ ស្តីពីព្រៃឈើ ការទប់ស្កាត់បង្ក្រាបបទល្មើសព្រៃឈើ ជំរុញការដាំដើមឈើឡើងវិញ និងបង្កើនសមត្ថភាពសហគមន៍ព្រៃឈើនៅលើមូលដ្ឋានារីភាព និងប្រសិទ្ធភាពគ្រប់គ្រង។ 14

០៦. បញ្ឈប់ការផ្ដល់សម្បទានដីសេដ្ឋកិច្ច។ 17

០៧. សម្រេចឲ្យបាន១០០% នូវការចុះបញ្ជីដីតាមផែនការនៃបទបញ្ជាលេខ០១ របស់រាជរដ្ឋាភិបាលជិត២លានហិចតា នៅរវាងដើមឆ្នាំ២០១៤ ក្នុងក្របខណ្ឌនៃការអនុវត្តន៍ «នយោបាយចាស់ សកម្មភាពថ្មីលើវិស័យដីធ្លី» និងសម្រេចឲ្យបាន៧០% ដល់ឆ្នាំ២០១៨ លើបរិមាណក្បាលដីដែលត្រូវចុះបញ្ជីសរុប៦ ទៅ៧លានក្បាលដីនៅទូទាំងប្រទេស។ 19

០៨. កសាងគោលនយោបាយជាតិ ស្តីពីសិទ្ធិលំនៅស្ថាន ដើម្បីដោះស្រាយលំនៅស្ថានជូនប្រជាពលរដ្ឋក្រីក្រ សម្រាប់ការរស់នៅប្រកបដោយសុវត្ថិភាព សុខុមាលភាព និងភាពថ្លៃថ្នូរ។ 20

០៩. កែលម្អផ្លូវលំជនបទជាជំហានៗ ពីផ្លូវក្រាលក្រួសក្រហម ទៅជាផ្លូវក្រាលកៅស៊ូ ឬផ្លូវបេតុងឲ្យបានពី ៣០០ ទៅ៤០០គីឡូម៉ែត្រក្នុង១ឆ្នាំ តាមស្តង់ដារឯកភាពជាតិមួយ។ 22

១០. រៀបចំគោលនយោបាយដឹកជញ្ជូនទីក្រុង ជាពិសេសរាជធានីភ្នំពេញសម្រាប់រយៈពេលមធ្យម និងរយៈពេលវែង ដើម្បីពង្រីកហេដ្ឋារចនាសម្ព័ន្ធ កសាងមធ្យោបាយដឹកជញ្ជូន ដើម្បីរួមជាប្រយោជន៍សម្រាប់ដោះស្រាយបញ្ហាការកកស្ទះចរាចរណ៍ និងពង្រឹងសណ្ដាប់ធ្នាប់ចរាចរណ៍ទីក្រុង។ 23

១១. ដល់ឆ្នាំ២០១៨ ប្រជាពលរដ្ឋចំនួន៨៥% ដែលរស់នៅរាជធានីខេត្ត និងប្រជាពលរដ្ឋចំនួន៦០% ដែលរស់នៅតាមបណ្តាឃុំ បានទទួលសេវាទឹកស្អាតដែលមានគុណភាពល្អ និងថ្លៃសមរម្យប្រើប្រាស់។...24

១២. ពីឆ្នាំ២០១៣ ដល់២០១៨ គឺពង្រីកការផ្គត់ផ្គង់អគ្គិសនីពីបណ្តាញជាតិឲ្យដល់ភូមិចំនួន៨០% នៃចំនួនភូមិទាំងអស់។.....25

១៣. ខិតខំសម្រេចគោលដៅទទួលទេសចរណ៍ពីក្រៅប្រទេសនៅឆ្នាំ២០១៥ ប្រមាណ៤,៥លាននាក់ ឆ្នាំ២០១៨ កើនដល់៦,១លាននាក់ រួមជាមួយទេសចរណ៍ក្នុងស្រុកប្រមាណ១០,៥លាននាក់។.....27

១៤.បន្តកសាងអនុវិទ្យាល័យឲ្យបានគ្រប់ឃុំ(ឃុំមួយអនុវិទ្យាល័យមួយ) ដែលនៅមិនទាន់មានអនុវិទ្យាល័យ។.....29

១៥. រៀបចំគោលនយោបាយជាតិ ស្តីពីមុខរបរ និងការងារស្របទៅនឹងការវិវឌ្ឍន៍នៃសង្គម-សេដ្ឋកិច្ច។...30

១៦. ការដាក់ឲ្យដំណើរការរបបប្រាក់សោធននិវត្តន៍ សម្រាប់កម្មករ និយោជិតក្នុងវិស័យឯកជនឲ្យទទួលបានរបបប្រាក់សោធននិវត្តន៍ដូចមន្ត្រីរាជការដែរ ចាប់ពីឆ្នាំ២០១៥។.....30

២. ការផ្តល់ពិន្ទុការបំពេញ/អនុវត្តន៍គោលនយោបាយ.....31

ក. វិស័យទី១ៈការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ 32

ខ. វិស័យទី២ៈ ការពង្រឹងរដ្ឋបាលសាធារណៈ វិមជ្ឈការ និងវិសហមជ្ឈការ ការពង្រឹងផ្នែកច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងការប្រឆាំងពើពុករលួយ 32

គ. វិស័យទី3ៈ ការអភិវឌ្ឍន៍សេដ្ឋកិច្ច.....33

ឃ. វិស័យទី4ៈ ការអភិវឌ្ឍន៍វិស័យអប់រំ សុខាភិបាល ការងារ វប្បធម៌ និងសង្គមកិច្ច.....33

ង. គោលនយោបាយទាំង៨វិស័យៈ.....34

VIII.**សេចក្តីសន្និដ្ឋាន**.....37

- **វិធីសាស្ត្រ និងទំហំនៃរបាយការណ៍**.....39

•តារាងបង្ហាញពីការផ្តល់ពិន្ទុ និងការប្រៀបធៀបការបំពេញ/អនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាល....40

- **កំណែទម្រង់សំខាន់ៗទាំង ៣ ប្រចាំឆ្នាំ ២០១៦**.....41
- **លក្ខណៈគោលនយោបាយ និងគោលនយោបាយរាជរដ្ឋាភិបាល នីតិកាលទី៥ (សង្ខេប)**.....45
- **ទម្រង់សំនួរផ្តល់ពិន្ទុលើលទ្ធផល នៃការបំពេញ/អនុវត្តន៍គោលនយោបាយ មិនមានសូចនាករច្បាស់លាស់របស់រាជរដ្ឋាភិបាល**.....70
- **តារាងប្រៀបធៀបលទ្ធផលជាមធ្យមនៃការផ្តល់ពិន្ទុលើកទី១ និងទី២ ចំពោះការអនុវត្តន៍/បំពេញគោលនយោបាយ របស់រាជរដ្ឋាភិបាលឆ្នាំ២០១៥ និងឆ្នាំ២០១៦ នៃខេត្ត/រាជធានីនីមួយៗ**.....78
- **រូបភាពសកម្មភាពវេទិកាម្ចាស់ឆ្នោត**.....83
- **តារាងព័ត៌មានទំនាក់ទំនងរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋានៃរាជរដ្ឋាភិបាលនីតិកាលទី៥ (ឆ្នាំទី៣)**.....87

- **អត្ថបទសារព័ត៌មានចុះផ្សាយអំពីរបាយការណ៍ៃ** 94

I. ខ្លឹមសារសង្ខេប

រាជរដ្ឋាភិបាលនៃរដ្ឋសភានីតិកាលទី៥ ដែលដឹកនាំដោយគណបក្សប្រជាជនកម្ពុជាបាន និងកំពុងអនុវត្តគោលនយោបាយរបស់ខ្លួន ដែលមាន០៤វិស័យធំៗ មានដូចជា៖ ១. ការការពារជាតិសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ២. ការពង្រឹងរដ្ឋបាលសាធារណៈ វិមជ្ឈការ និងវិសហមជ្ឈការ ការពង្រឹងផ្នែកច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងការប្រឆាំងអំពើពុករលួយ ៣. ការអភិវឌ្ឍន៍សេដ្ឋកិច្ច និង៤. ការអភិវឌ្ឍន៍វិស័យអប់រំសុខាភិបាល ការងារ វប្បធម៌ និងសង្គមកិច្ច បានរយៈពេល០៣ឆ្នាំមកហើយ។ ការអនុវត្តគោលនយោបាយនេះ រាជរដ្ឋាភិបាលក៏បានបន្តអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់ទី៣ កំណើនការងារ សមធម៌ និងប្រសិទ្ធភាពនៅកម្ពុជា។

ក្នុងគោលបំណងបង្កើនតម្លាភាព និងជំរុញឱ្យរាជរដ្ឋាភិបាលមានការទទួលខុសត្រូវខ្ពស់ ខុមប្រ្ទេលបានធ្វើការសង្កេត និងលើកទឹកចិត្តឱ្យម្ចាស់ឆ្នោត វាយតម្លៃលើការអនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាលតាមរយៈការធ្វើការសិក្សា និងវិភាគលើរបាយការណ៍នានា ព័ត៌មានទទួលបានពីការសង្កេត និងវេទិកាផ្តល់ឱកាសឲ្យប្រជាពលរដ្ឋផ្តល់ពិន្ទុលើការអនុវត្តន៍គោលនយោបាយនោះ។

គិតត្រឹមឆ្នាំទី៣នេះ ចំនួនសមាជិករាជរដ្ឋាភិបាលបានកើនឡើងដល់ប្រមាណ២៥៦រូប។ សមាជិកមួយចំនួនបានផ្លាស់ប្តូរស្ថាប័នដឹកនាំនៅក្នុងក្រសួងចំនួន០៨។ អនុរដ្ឋលេខាធិការកើនឡើងបន្ថែមចំនួន៣០រូប នៅក្នុងក្រសួងចំនួន១៦ ខណៈ០២រូបបានបញ្ចប់ដំណែង និងទីប្រឹក្សារាជរដ្ឋាភិបាលកើនឡើងបន្ថែមចំនួន១០រូប ដែលមានឋានៈស្មើនឹងសមាជិករាជរដ្ឋាភិបាល។

ក្នុងរយៈពេលនេះដែរ រាជរដ្ឋាភិបាលកម្ពុជាដែលដឹកនាំដោយគណបក្សប្រជាជនកម្ពុជា បានចេញអនុក្រឹត្យចំនួន៨៧៣អនុក្រឹត្យ ដែលភាគច្រើននៃអនុក្រឹត្យទាំងនោះ អំពីការជូនមេដាយ និងតែងតាំង ផ្ទេរភារកិច្ចមន្ត្រីរាជការ។ ក្នុងចំណោមអនុក្រឹត្យទាំងនោះ គេពិនិត្យឃើញមានអនុក្រឹត្យប្រមាណ០៣%ភាគរយ អំពីការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋទៅជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ និងការផ្ទេរឥណទានថវិកា។ ចំណែកឯប្រកាសវិញ ក្នុងរយៈពេលដូចគ្នានេះ រាជរដ្ឋាភិបាលបានចេញប្រកាសចំនួន២៥៤ប្រកាស ដែលភាគច្រើនចេញដោយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

សម្រាប់ឆ្នាំទី៣ រាជរដ្ឋាភិបាលត្រូវបានសភាអនុម័តឲ្យគ្រោង ចំណាយថវិកាប្រមាណ៤.៣៦៥លានដុល្លារសហរដ្ឋអាមេរិក កើនឡើង១៤% បើប្រៀបធៀបនឹងឆ្នាំ២០១៥។ ការបែងចែកចំណាយ ហាក់ដូចជាមិសូវខុសប្លែកពីឆ្នាំមុនទេ គឺផ្តល់អាទិភាពខ្ពស់ចំពោះការចំណាយលើវិស័យសង្គមកិច្ច និងសេដ្ឋកិច្ច ខណៈដែលវិស័យរដ្ឋបាលទូទៅ ត្រូវបានកាត់បន្ថយការចំណាយប្រមាណ២% បើប្រៀបធៀបនឹងឆ្នាំ២០១៥។

ក្នុងឆ្នាំទី៣ រាជរដ្ឋាភិបាលនៃរដ្ឋសភានីតិកាលទី៥ ដែលដឹកនាំដោយគណបក្សប្រជាជនកម្ពុជាគ្រោងចំណាយថវិកាថ្នាក់ជាតិប្រមាណ៤.៣៦៥លានដុល្លារសហរដ្ឋអាមេរិក។ ក្នុងចំណោមគោលនយោបាយដែលមានសូចនាករច្បាស់លាស់ចំនួន១៦ចំណុច រាជរដ្ឋាភិបាលបានសម្រេចការបំពេញ/អនុវត្តន៍គោលនយោបាយចំនួន០៦ចំណុច(៣៧%) និងសម្រេចបានខ្លះចំនួន៧ចំណុច។ ខណៈដែលគោលនយោបាយចំនួន០៣ចំណុចផ្សេងទៀត រាជរដ្ឋាភិបាលបានអនុវត្ត តែមិនអាចសម្រេចបានតាមការសន្យារបស់ខ្លួន។ ចំពោះលទ្ធផលការបំពេញ/អនុវត្តន៍គោលនយោបាយ មិនមានសូចនាករច្បាស់លាស់វិញ ត្រូវបានប្រជាពលរដ្ឋចំនួនប្រមាណ ១៩% ពេញចិត្ត ប្រមាណ៦២%ពេញចិត្តខ្លះ ប៉ុន្តែប្រជាពលរដ្ឋប្រមាណ១៩% មិនពេញចិត្តនឹងលទ្ធផលនៃការ

បំពេញ/អនុវត្តន៍គោលនយោបាយទាំងនោះ។

II. សេចក្តីផ្តើម

គិតត្រឹមឆ្នាំ២០១៦ រាជរដ្ឋាភិបាលដែលដឹកនាំដោយគណបក្សប្រជាជនកម្ពុជា បាននឹងកំពុងបន្តអនុវត្តគោលនយោបាយរបស់ខ្លួនមិនតិចជាងរយៈពេលបីឆ្នាំនោះទេសម្រាប់នីតិកាលទី៥។ ឆ្នាំ២០១៦ គឺជាឆ្នាំទី៣នៃការអនុវត្តន៍/បំពេញ និងឃ្លាំមើល និងវាយតម្លៃគោលនយោបាយទាំងបួនវិស័យនេះ។ ក្នុងឆ្នាំទី១ (ខែកញ្ញាឆ្នាំ២០១៣ ដល់ឆ្នាំ២០១៤) ចំពោះគោលនយោបាយមានសូចនាករច្បាស់លាស់ចំនួន១៦ចំណុច រាជរដ្ឋាភិបាលបានសម្រេចពេញលេញនូវការបំពេញ/អនុវត្តន៍គោលនយោបាយចំនួន០៦ (៣៧,៥%) រួមមានដូចជា៖ កំណើនសេដ្ឋកិច្ច៧%ក្នុងមួយឆ្នាំ ការកាត់បន្ថយភាពក្រីក្រក្នុងអត្រា០១%ក្នុងមួយឆ្នាំ ការបញ្ឈប់ការផ្តល់ដីសម្បទានសេដ្ឋកិច្ច ការរៀបចំគោលនយោបាយដឹកជញ្ជូនទីក្រុង និងគោលដៅនៃចំនួនទេសចរណ៍ពីក្រៅប្រទេស។ ចំណែកគោលនយោបាយចំនួន០៧ រួមមានការការក្សាផ្ទៃនេសាទទឹកសាប ការចុះបញ្ជីដីធ្លី ការកសាងគោលនយោបាយជាតិ ស្តីពីសិទ្ធិលំនៅស្ថាន ប្រជាពលរដ្ឋទទួលសេវាទឹកស្អាត ពង្រីកការផ្គត់ផ្គង់អគ្គិសនីពីបណ្តាញជាតិឲ្យដល់ភូមិ បន្ត កសាងអនុវិទ្យាល័យឲ្យបានគ្រប់ឃុំ និងការរៀបចំគោលនយោបាយជាតិ ស្តីពីមុខរបរ និងការងារត្រូវបានអនុវត្ត ឬ/និងសម្រេចបានខ្លះ។ ឯគោលនយោបាយចំនួន០៣ រាជរដ្ឋាភិបាលបានអនុវត្ត តែមិនអាចសម្រេចបានតាមការសន្យារបស់ខ្លួន។ គោលនយោបាយទាំងបីនោះមានដូចជា គោលនយោបាយនាំចេញអង្ករឲ្យបាន១លានតោន នៅឆ្នាំ២០១៥ ការការក្សាផ្ទៃដីដែលគ្របដណ្តប់ដោយព្រៃឈើ និងការដាក់ឲ្យដំណើរការរបបប្រាក់សោ ធននិវត្តន៍សម្រាប់កម្មករ និយោជិតក្នុងវិស័យឯកជន។

ចំណែកក្នុងឆ្នាំទី២ (ឆ្នាំ២០១៤ ដល់២០១៥) រាជរដ្ឋាភិបាល បានសម្រេចការបំពេញ/អនុវត្តន៍គោលនយោបាយចំនួន០៦ចំណុច(៣៧,៥%) គោលនយោបាយនោះរួមមាន៖ កំណើនសេដ្ឋកិច្ច៧%ក្នុងមួយឆ្នាំ ការកាត់បន្ថយភាពក្រីក្នុងអត្រា០១%ក្នុងមួយឆ្នាំ ការបញ្ឈប់ការផ្តល់ដីសម្បទានសេដ្ឋកិច្ច ការរៀបចំគោលនយោបាយដឹកជញ្ជូនទីក្រុង គោលដៅនៃចំនួនទេសចរណ៍ពីក្រៅប្រទេស និងការបង្កើតគោលនយោបាយជាតិ ស្តីពីមុខរបរ និងការងារ។ ចំណែកគោលនយោបាយ៧ចំណុចផ្សេងទៀត សម្រេចបានខ្លះ ដូចជា៖ ការការក្សាផ្ទៃនេសាទទឹកសាប ការចុះបញ្ជីដីធ្លី ការកសាងគោលនយោបាយជាតិ ស្តីពីសិទ្ធិលំនៅស្ថាន ប្រជាពលរដ្ឋទទួលសេវាទឹកស្អាត ពង្រីកការផ្គត់ផ្គង់អគ្គិសនីពីបណ្តាញជាតិឲ្យដល់ភូមិ ការបន្ត កសាងអនុវិទ្យាល័យឲ្យបានគ្រប់ឃុំ ការនាំអង្ករចេញឲ្យបាន០១លានតោននៅឆ្នាំ២០១៥។ ខណៈដែលគោលនយោបាយចំនួន០៣ រាជរដ្ឋាភិបាលបានអនុវត្ត តែមិនអាចសម្រេចបាន ឬបានតិចតួចតាមការសន្យារបស់ខ្លួន។ គោលនយោបាយទាំងនោះមានដូចជា គោលនយោបាយការការក្សាផ្ទៃដី ដែលគ្របដណ្តប់ដោយព្រៃឈើ ការកែលម្អផ្លូវលំជនបទជាដំហានៗ និងការដាក់ឲ្យដំណើរការរបបប្រាក់សោធននិវត្តន៍សម្រាប់កម្មករ និយោជិតក្នុងវិស័យឯកជន។

ចំពោះការផ្តល់ពិន្ទុលើការអនុវត្តន៍/បំពេញគោលនយោបាយ ដែលមិនមានសូចនាករច្បាស់លាស់ចំនួន ៣៣ចំណុចវិញ មានប្រជាពលរដ្ឋចំនួនភាគច្រើននៃ៤៤,៤% ពេញចិត្តខ្លះចំពោះការបំពេញ/អនុវត្តន៍គោលនយោបាយ ប៉ុន្តែប្រជាពលរដ្ឋរហូតដល់៥៥,៦% មិនពេញចិត្តនឹងការអនុវត្តន៍គោលនយោបាយទាំងនោះនៅក្នុងឆ្នាំទី១កន្លងទៅនេះ។

ក្នុងឆ្នាំទី២វិញ ការផ្តល់ពិន្ទុលើលទ្ធផលនៃការបំពេញ/អនុវត្តន៍គោលនយោបាយ ដោយប្រជាពលរដ្ឋនៅ២៤រាជធានី/ខេត្ត មានប្រជាពលរដ្ឋចូលរួមផ្តល់ពិន្ទុចំនួនប្រមាណ២៦%ពេញចិត្ត ប្រមាណ៦២%ពេញចិត្ត

ខ្ះ និងប្រមាណ១២%មិនពេញចិត្ត ចំពោះការបំពេញ/អនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាល នីតិកាលទី៥។

ដូចគ្នានឹងឆ្នាំទី១ និងទី២ដែរ ក្នុងឆ្នាំទី៣ (២០១៥-២០១៦) នេះ ដើម្បីបន្តបង្កើនតម្លាភាព និងជំរុញឱ្យរាជរដ្ឋាភិបាលមានការទទួលខុសត្រូវនូវអ្វីដែលបានសន្យា ខុមហ្ស្រ៊ីលបានធ្វើការសង្កេត ផ្តល់មធ្យោបាយ និងលើកទឹកចិត្តឱ្យម្ចាស់ឆ្នោតវាយតម្លៃលើការអនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាល។

សម្រាប់ការសង្កេត ខុមហ្ស្រ៊ីលបានសិក្សាលើរបាយការណ៍ព័ត៌មាន និងទិន្នន័យដែលពាក់ព័ន្ធនឹងគោលនយោបាយដែលមានសូចនាករច្បាស់លាស់របស់រាជរដ្ឋាភិបាល។ ដោយឡែក ការផ្តល់ពិន្ទុវិញ ខុមហ្ស្រ៊ីលរៀបចំទម្រង់វាយតម្លៃដាក់ពិន្ទុដោយម្ចាស់ឆ្នោតទៅលើចំណុចនៃគោលនយោបាយ តាមរយៈវេទិកានៅតាមខេត្ត នានា និងរាជធានីភ្នំពេញ ដោយប្រើប្រាស់វិធីសាស្ត្រពិភាក្សាជាក្រុម ដែលអ្នកចូលរួមធ្វើការផ្តល់ពិន្ទុចំនួនពីរលើក។ ការផ្តល់ពិន្ទុលើកទី១ ធ្វើឡើងមុនពេលកិច្ចពិភាក្សា ហើយការផ្តល់ពិន្ទុលើកទី២ ធ្វើឡើងនៅក្រោយពេលពិភាក្សា និងវាគ្មិនចែករំលែក វិភាគលើទិន្នន័យបឋមរបស់ស្ថាប័ន ឬអង្គការសង្គមស៊ីវិលដែលធ្វើការពាក់ព័ន្ធនឹងវិស័យទាំងនោះ។

III. ត្តនាទី និងការកិច្ចរាជរដ្ឋាភិបាល

រាជរដ្ឋាភិបាល គឺជាអង្គការនីតិប្រតិបត្តិដែលមានភារកិច្ចដាក់ចេញ និងអនុវត្តនូវគោលយោបាយដែលរដ្ឋសភាបានអនុម័តឲ្យស្របតាមគោលការណ៍ដែលចែងក្នុងរដ្ឋធម្មនុញ្ញ។ រាជរដ្ឋាភិបាលត្រូវទទួលខុសត្រូវចំពោះមុខរដ្ឋសភាលើការអនុវត្តន៍គោលនយោបាយ និងសកម្មភាពរបស់ខ្លួន។ សមាសភាពរាជរដ្ឋាភិបាលរួមមាន៖ នាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការ។ ដោយឡែក អនុរដ្ឋលេខាធិការ បើទោះបីមិនត្រូវបានចាត់បញ្ចូលជាសមាសភាពរាជរដ្ឋាភិបាល ប៉ុន្តែអនុរដ្ឋលេខាធិការនឹងត្រូវបានបញ្ចប់តំណែងក្នុងករណីដែលរាជរដ្ឋាភិបាលត្រូវបានលាលែង ឬរំលាយ។

រាជរដ្ឋាភិបាលដឹកនាំដោយនាយករដ្ឋមន្ត្រី ដែលត្រូវដឹកនាំ និងចាត់ចែងការងាររបស់គណៈរដ្ឋមន្ត្រី និងរាល់សកម្មភាពរបស់រាជរដ្ឋាភិបាលលើគ្រប់វិស័យ។ អង្គប្រជុំគណៈរដ្ឋមន្ត្រី ដែលដឹកនាំដោយនាយករដ្ឋមន្ត្រី គឺសម្រេចដោះស្រាយរាល់កិច្ចការទូទៅរបស់រាជរដ្ឋាភិបាល។ ការចរចា និងចុះហត្ថលេខាលើកិច្ចព្រមព្រៀងរវាងរដ្ឋ និងរដ្ឋដទៃ គឺជាការងាររបស់រាជរដ្ឋាភិបាល ក្រោមការដឹកនាំរបស់នាយករដ្ឋមន្ត្រី។ ក្នុងនាមរាជរដ្ឋាភិបាល នាយករដ្ឋមន្ត្រីមានសិទ្ធិចេញលិខិតបទដ្ឋានដូចជា អនុក្រឹត្យ សេចក្តីសំរេច និងសារាចររបស់គណៈរដ្ឋមន្ត្រី ដើម្បីលើកសំណើ ឬ/និងតែងតាំង ផ្លាស់ប្តូរ បញ្ចប់ភារកិច្ច សមាជិករាជរដ្ឋាភិបាល និងមន្ត្រីជាន់ខ្ពស់ស៊ីវិល និងយោធិន និងដើម្បីណែនាំការអនុវត្តន៍សកម្មភាពរបស់រាជរដ្ឋាភិបាល។

IV. ការប្រៀបធៀបសមាសភាពសមាជិករាជរដ្ឋាភិបាល

រាជរដ្ឋាភិបាលនីតិកាលទី៥ មានក្រសួងចំនួន២៨ និងរដ្ឋលេខាធិការដ្ឋានចំនួនមួយ។ សមាជិករាជរដ្ឋាភិបាលរួមមាន នាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការ[1]។ រាជរដ្ឋាភិបាលនេះនៅតែមានចំនួនច្រើន បើប្រៀបធៀបជាមួយបណ្តាប្រទេសនៅក្នុងតំបន់។ គិតត្រឹមខែកក្កដា ឆ្នាំ២០១៦ បានតែងតាំងសមាជិកថ្មីចំនួន១៥ ខណៈដែលសមាជិករាជរដ្ឋាភិបាលចំនួន០២រូបត្រូវបានបញ្ចប់មុខតំណែង។

[1] មាត្រា៤ វាក្យខ័ណ្ឌទី១ មាត្រា៤នៃច្បាប់ ស្តីពីការរៀបចំ និងប្រព្រឹត្តិទៅនៃគណៈរដ្ឋមន្ត្រី

គិតត្រឹមឆ្នាំ២០១៦នេះ សមាជិករាជរដ្ឋាភិបាលមានចំនួនប្រមាណ២៥៦រូប។ សមាជិកមួយចំនួនបានផ្លាស់ប្តូរស្ថាប័នថ្នាក់ដឹកនាំ។ ក្រសួងដែលត្រូវបានផ្លាស់ប្តូរថ្នាក់ដឹកនាំមានចំនួន០៨ដូចជា៖ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ក្រសួងពាណិជ្ជកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងសាធារណការ និងដឹកជញ្ជូន ក្រសួងរៀបចំដែនដីនគររូបនីយកម្ម និងសំណង់ ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ និងក្រសួងធម្មការ និងសាសនា។





ការផ្លាស់ប្តូរនេះត្រូវបានគេមើលឃើញថាមានលក្ខណៈជាការផ្លាស់ប្តូរស្ថាប័នដើម្បីដឹកនាំ ច្រើនជាងផ្លាស់ប្តូរថ្នាក់ដឹកនាំ ដោយសារក្នុងចំណោមតំណែងរដ្ឋមន្ត្រីក្រសួងចំនួន០៨ មាន០៦តំណែងត្រូវបានប្រគល់ឲ្យអតីតរដ្ឋមន្ត្រីនៃនីតិកាលទី៥នេះដដែល។

អនុរដ្ឋលេខាធិការត្រូវបានកើនឡើងបន្ថែមទៀតចំនួន៣០រូប (ស្រីចំនួន០៣រូប) តាមបណ្តាក្រសួងមួយចំនួន។ ខណៈដែលអនុរដ្ឋលេខាធិការចំនួន០២រូប បានបញ្ចប់តំណែង។

ចំនួនទីប្រឹក្សារាជរដ្ឋាភិបាលដែមានឋានៈសមាជិករាជរដ្ឋាភិបាល ក៏មានការកើនឡើងបន្ថែមចំនួន១០ (ស្រីចំនួន០២រូប)។ នេះមិនទាន់រាប់បញ្ចូលដល់ការកើនឡើងចំនួនទីប្រឹក្សានាយករដ្ឋមន្ត្រី ក្រសួង និងថ្នាក់ដឹកនាំក្រសួងផ្សេងៗ ដែលត្រូវបានតែងតាំងមានឋានៈស្មើរដ្ឋមន្ត្រី រដ្ឋលេខាធិការ និងអនុរដ្ឋលេខាធិការនោះទេ។ ការកើនឡើងនេះ គឺដោយសារតែគ្មានបទបញ្ញត្តិនៃច្បាប់ចែងកំណត់អំពីចំនួនអនុរដ្ឋលេខាធិការ និងទីប្រឹក្សារាជរដ្ឋាភិបាល ដែលត្រូវបានស្នើតែងតាំងដោយរាជរដ្ឋាភិបាល ឬ/និងនាយករដ្ឋមន្ត្រី។

ចំនួនកើនឡើងអនុរដ្ឋលេខាធិការតាមក្រសួងនានា៖

ល.រ	ក្រសួង	ចំនួនកើនឡើង
០១	ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ	០១
០២	ក្រសួងរៀបចំដែនដីនគររូបនីយកម្ម និងសំណង់	០៤
០៣	ក្រសួងធម្មការ និងសាសនា	០១ (ស្រី)
០៤	ក្រសួងសាធារណការ និងដឹកជញ្ជូន	០៤ (ស្រី០១)
០៥	ក្រសួងសិប្បកម្ម និងឧស្សាហកម្ម	០១
០៦	ក្រសួងការពារជាតិ	០១

០៧	ក្រសួងមហាផ្ទៃ	០២
០៨	ក្រសួងព័ត៌មាន	០២
០៩	ក្រសួងទេសចរណ៍	០១
១០	ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ	០១
១១	ក្រសួងពាណិជ្ជកម្ម	០៣
១២	ក្រសួងរ៉ែ និងថាមពល	០២
១៣	ក្រសួងអប់រំ យុវជន និងកីឬ្ឌា	០១
១៤	ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍	០១
១៥	ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ	០៣
១៦	ទីស្តីការគណៈរដ្ឋមន្ត្រី	០២
	ចំនួនសរុប	៣០រូប (ស្រី០២)

ចំនួនកើនឡើងទីប្រឹក្សារាជរដ្ឋាភិបាល៖

ល.រ	ទីប្រឹក្សារាជរដ្ឋាភិបាលឋានៈស្មើ៖	ចំនួនកើនឡើង
០១	ឧបនាយរដ្ឋមន្ត្រី	០២ (ស្រី ០១)
០២	ទេសរដ្ឋមន្ត្រី	០១
០៣	រដ្ឋមន្ត្រី	០៤
០៤	រដ្ឋលេខាធិការ	០៣ (ស្រី ០១)
	ចំនួនសរុប	១០ រូប (ស្រី ០២)

V. អនុក្រឹត្យរបស់រាជរដ្ឋាភិបាល និងប្រកាសរបស់ក្រសួងឆ្នាំ២០១៦

ក្នុងឆ្នាំ២០១៦ គិតត្រឹមខែកក្កដា រាជរដ្ឋាភិបាលកម្ពុជាដែលដឹកនាំដោយគណបក្សប្រជាជនកម្ពុជា បានចេញអនុក្រឹត្យចំនួន៨៧៣អនុក្រឹត្យ ដែលភាគច្រើននៃអនុក្រឹត្យទាំងនោះ អំពីការជូនមេដាយ និងតែងតាំង ផ្ទេរភារកិច្ចមន្ត្រីរាជការ។ ក្នុងចំណោម អនុក្រឹត្យទាំងនោះ គេពិនិត្យឃើញមានអនុក្រឹត្យចំនួន០៣% អំពីការធ្វើអនុបយោគទ្រព្យសម្បត្តិសាធារណៈរបស់រដ្ឋ ទៅជាទ្រព្យសម្បត្តិឯកជនរបស់រដ្ឋ និងការផ្ទេរឥណទានថវិកា។ ចំណែកឯប្រកាសវិញ ក្នុងរយៈពេលដូចគ្នានេះ រាជរដ្ឋាភិបាលបានចេញប្រកាសចំនួន២៥៤ប្រកាស ដែលភាគច្រើនចេញដោយក្រសួងសេដ្ឋកិច្ច និងហរិញ្ញវត្ថុ និង



ក្រសួងឧស្សាហកម្ម និងសិប្បកម្ម។

VI. បម្រែបម្រួលថវិកាថ្នាក់ជាតិគ្រោងចំណាយឆ្នាំ២០១៤-២០១៧

វិស័យថវិកាចំណាយ	ជាលានដុល្លា (USD)				ជាភាគរយ (%)				បម្រែបម្រួល
	2014	2015	2016	2017	2014	2015	2016	2017	
រដ្ឋបាលទូទៅ	280.31	420.27	427.6	539.16	8.2	11.18	9.79	10.68	
ការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ	468.17	610.27	711.05	860.38	13.8	16.24	16.29	17.05	
សង្គមកិច្ច	791.47	1,045.66	1,209.66	1,439.02	23.3	27.82	27.71	28.51	
សេដ្ឋកិច្ច	302.9	1,073.78	1,288.97	1,349.16	8.9	28.57	29.53	26.73	
ចំណាយមិនទាន់ចែងចែក	1556.04	608.82	728.35	858.9	45.8	16.2	16.68	17.02	
ចំណាយសរុបរួម	3398.9	3,758.81	4,365.62	5,046.61					

បើមើលពីថវិកាដែលគ្រោងនឹងចំណាយឆ្នាំ២០១៦ ចំនួនប្រមាណ៤៣៦៥លានដុល្លារសហរដ្ឋអាមេរិក ដែលបានកើនឡើងប្រមាណជា១៤% ធៀបនឹងឆ្នាំ២០១៥ រាជរដ្ឋាភិបាលគ្រោងចំណាយថវិកាលើវិស័យ សេដ្ឋកិច្ចប្រមាណ២៩% សង្គមកិច្ចប្រមាណ២៧% ការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ប្រមាណ១៦% និងរដ្ឋបាលទូទៅប្រមាណ៩% នៃថវិកាជាតិ។ បើប្រៀបធៀបនឹងឆ្នាំ២០១៥ ថវិកាដែលគ្រោងចំណាយលើវិស័យទាំង០៤នេះ មិនមានការប្រែប្រួលច្រើននោះទេ។ ថវិកាគ្រោងចំណាយលើវិស័យ រដ្ឋបាលទូទៅ បានធ្លាក់ចុះប្រមាណ២%។ នេះមានន័យថា រដ្ឋបាលបានកាត់បន្ថយការចំណាយលើផ្នែកការងាររដ្ឋបាល ដើម្បីបន្តបំពេញ/អនុវត្តន៍គោលនយោបាយរបស់ខ្លួន ស្របពេលដែលវិស័យអភិវឌ្ឍន៍សេដ្ឋកិច្ចកើនឡើងប្រមាណ១%។ ចំណែកឯថវិកាថ្នាក់ជាតិគ្រោងចំណាយមិនទាន់ចែងចែកកើនឡើងតិចតួចគឺ ០,៤%។

VII. ការរកឃើញ និងការផ្តល់ពិន្ទុលើលទ្ធផលនៃការបំពេញ/អនុវត្តន៍គោលនយោបាយ

សម្រាប់ឆ្នាំទី៣ នៃនីតិកាលទី៥នៃរដ្ឋសភា ច្បាប់ស្តីពីហិរញ្ញវត្ថុ ស្តីពីការគ្រប់គ្រងឆ្នាំ២០១៦ ត្រូវបានរដ្ឋសភាអនុម័ត ដោយមានតែតំណាងរាស្ត្រនៃគណបក្សប្រជាជនកម្ពុជាចំនួន៦៦រូប ដែលបានបោះឆ្នោតគាំទ្រ។ មាត្រា២នៃច្បាប់នេះបានបញ្ជាក់ថា ចំនួនទឹកប្រាក់ជាអតិបរមានៃឥណទានចំណាយថវិកាថ្នាក់ជាតិ សម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦ គឺមានចំនួនប្រមាណ៤៣៦៥,៦២លានដុល្លារសហរដ្ឋអាមេរិក បើប្រៀបធៀបនឹងឆ្នាំ២០១៥ កើនឡើងចំនួន១៤% ស្មើនឹងប្រមាណ៦០០លានដុល្លាអាមេរិក។ នេះមានន័យថា រាជរដ្ឋាភិបាលដឹកនាំដោយគណបក្សប្រជាជនកម្ពុជា នឹងបន្តអនុវត្តគោលនយោបាយរបស់ខ្លួនក្នុងឆ្នាំទី៣ ដោយប្រើប្រាស់ខ្នង់ថវិកាដូចមានចែងក្នុងមាត្រា២នៃច្បាប់ ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៦។ ដូចគ្នានឹងឆ្នាំ២០១៥ ថវិកាប្រមាណ១៦% ត្រូវបានគ្រោងចំណាយលើវិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ខណៈដែលប្រមាណ២៧%ផ្សេងទៀត ត្រូវបានគ្រោងចំណាយលើវិស័យសង្គមកិច្ច។ ចំណែកឯវិស័យរដ្ឋបាលទូទៅ និងវិស័យសេដ្ឋកិច្ច រាជរដ្ឋាភិបាលបានបន្ថែមការចំណាយប្រមាណ០១%បន្ថែមទៀត។ ថវិកាថ្នាក់ជាតិគ្រោងចំណាយមិនទាន់ចែងចែក មានចំនួន១៦% ដែលស្មើរតែដូចគ្នានឹងឆ្នាំ២០១៥។ បើប្រៀបធៀបជាមួយឆ្នាំ២០១៤ វិស័យអប់រំ ត្រូវបានបន្ថែមថវិកាប្រមាណជិត១០០លានដុល្លារអាមេរិក។[2]

[2] https://www.cambodiadaily.com/news/cpp-lawmakers-push-through-3-8-billion-national-budget-73314/

តារាងបង្ហាញពីការវាយតម្លៃការបំពេញ/អនុវត្តន៍គោលនយោបាយមានសូចនាករច្បាស់លាស់

ល.រ	គោលនយោបាយមានសូចនាករច្បាស់លាស់ រាជរដ្ឋាភិបាលបានបំពេញ/អនុវត្តក្នុងឆ្នាំទី៣ នីតិកាលទី៥	លទ្ធផលសម្រេចបាន		
		សម្រេចបាន	សម្រេចបានខ្លះ	មិនសម្រេចបាន
១	ខិតខំសម្រេចឲ្យបាននូវកំណើនសេដ្ឋកិច្ចជាមធ្យម៧%ក្នុងមួយឆ្នាំដើម្បីធ្វើឲ្យកម្ពុជាអាចចាកចេញផុតពីប្រទេសមានចំណូលទាប ឈានឡើងជាប្រទេសមានចំណូលមធ្យមកម្រិតទាបយ៉ាងយូរនៅឆ្នាំ២០១៨ និងក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០។	✓		
២	សម្រេចឲ្យបានគោលដៅកាត់បន្ថយអត្រានៃភាពក្រីក្រជាង១%ក្នុងមួយឆ្នាំ។	✓		
៣	បន្តខិតខំសម្រេចនូវគោលនយោបាយជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករឲ្យបាន១លានតោន នៅឆ្នាំ២០១៥ សំដៅប្រែក្លាយកម្ពុជាទៅជាប្រទេសផលិតស្បៀងនាំមុខមួយនៅលើពិភពលោក។		✓	
៤	រក្សាផ្ទៃនេសាទទឹកសាប សម្រាប់ប្រជាជនធ្វើនេសាទជាលក្ខណៈគ្រួសារ ពង្រឹងតំបន់អភិរក្ស បង្កើនការការពារធនធានជលផល លុបបំបាត់បទល្មើសនេសាទគ្រប់រូបភាព។		✓	
៥	រក្សាផ្ទៃដីដែលគ្របដណ្ដប់ដោយព្រៃឈើ ដោយបង្កើនការការពារធនធានព្រៃឈើ ពិសេសការពង្រឹងការអនុវត្តន៍ច្បាប់ ស្ដីពីព្រៃឈើ ការទប់ស្កាត់បង្ក្រាបបទល្មើសព្រៃឈើ ជំរុញការដាំដើមឈើឡើងវិញ និងបង្កើនសមត្ថភាពសហគមន៍ព្រៃឈើ នៅលើមូលដ្ឋាន ធានាវិរភាព និងប្រសិទ្ធភាពគ្រប់គ្រង។			✓
៦	បញ្ឈប់ការផ្ដល់សម្បទានដីសេដ្ឋកិច្ច។	✓		
៧	សម្រេចឲ្យបាន១០០% នូវការចុះបញ្ជីដី តាមផែនការនៃបទបញ្ជាលេខ ០១ របស់រាជរដ្ឋាភិបាលជិត២លានហិកតា នៅរវាងដើមឆ្នាំ២០១៤ក្នុងក្របខណ្ឌនៃការអនុវត្ត «នយោបាយចាស់ សកម្មភាពថ្មីលើវិស័យដីធ្លី» និងសម្រេចឲ្យបាន៧០% ដល់ឆ្នាំ២០១៨ លើបរិមាណក្បាលដីដែលត្រូវចុះបញ្ជីសរុប៦ ទៅ៧លានក្បាលដីនៅទូទាំងប្រទេស។		✓	
៨	កសាងគោលនយោបានជាតិ ស្ដីពីសិទ្ធិលំនៅស្ថាន ដើម្បីដោះស្រាយលំនៅស្ថានជូនប្រជាពលរដ្ឋក្រីក្រសម្រាប់ការរស់នៅប្រកបដោយសុវត្ថិភាព សុខុមាលភាព និងភាពថ្លៃថ្នូរ។	✓		
៩	កែលម្អផ្លូវលំជនបទជាធំហានៗ ពីផ្លូវក្រាលក្រួសក្រហម ទៅជាផ្លូវក្រាលកៅស៊ូឬផ្លូវបេតុងឲ្យបានពី៣០០ ទៅ៤០០គីឡូម៉ែត្រក្នុង១ឆ្នាំ តាមស្តង់ដារឯកភាពជាតិមួយ។			✓
១០	រៀបចំគោលនយោបាយដឹកជញ្ជូនទីក្រុង ជាពិសេសរាជធានីភ្នំពេញសម្រាប់រយៈពេលមធ្យម និងរយៈពេលវែង ដើម្បីពង្រីកហេដ្ឋារចនាសម្ព័ន្ធ កសាងមធ្យោបាយដឹងជញ្ជូន។	✓		

១១	ដល់ឆ្នាំ២០១៨ ប្រជាជនចំនួន៨៥% ដែលរស់នៅរាជធានីខេត្ត និងប្រជាពលរដ្ឋចំនួន៦០% ដែលរស់នៅតាមបណ្តាឃុំ បានទទួលសេវាទឹកស្អាត ដែលមានគុណភាពល្អ និងថ្លៃសមរម្យប្រើប្រាស់។		✓	
១២	ពីឆ្នាំ២០១៣ ដល់២០១៨ គឺពង្រីកការផ្គត់ផ្គង់អគ្គិសនី ពីបណ្តាញជាតិឲ្យដល់ភូមិចំនួន៨០% នៃចំនួនភូមិទាំងអស់។		✓	
១៣	ខិតខំសម្រេចគោលដៅទទួលទេសចរណ៍ ពីក្រៅប្រទេសនៅឆ្នាំ២០១៥ប្រមាណ៨,៥លាននាក់ឆ្នាំ២០១៨ កើនដល់៦,១លាននាក់ រួមជាមួយទេសចរណ៍ក្នុងស្រុកប្រមាណ១០,៥លាននាក់។		✓	
១៤	បន្តកសាងអនុវិទ្យាល័យឲ្យបានគ្រប់ឃុំ ដែលនៅមិនទាន់មានអនុវិទ្យាល័យ។		✓	
១៥	រៀបចំគោលនយោបាយជាតិ ស្តីពីមុខរបរ និងការងារស្របទៅនឹងការវិវឌ្ឍន៍នៃសង្គម សេដ្ឋកិច្ច។	✓		
១៦	ការដាក់ឲ្យដំណើរការរបបប្រាក់សោធននិវត្តន៍ សម្រាប់កម្មករ និយោជិតក្នុងវិស័យឯកជន ឲ្យទទួលបានរបបប្រាក់សោធនិវត្តន៍ ដូចមន្ត្រីរាជការដែរចាប់ពីឆ្នាំ២០១៥។			✓

តារាងបង្ហាញពីលទ្ធផលមធ្យមនៃការពេញចិត្តលើការបំពេញ/អនុវត្តន៍គោលនយោបាយ

ល.រ	វិស័យនៃគោលនយោបាយ	[3] %មិនព	[4] %ពេញ	[5] %ពេញ
០១	ការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ	21.80	60.13	18.06
០២	ការពង្រឹងរដ្ឋបាលសាធារណៈ វិមជ្ឈការ និងវិសហមជ្ឈការ ការពង្រឹងផ្នែកច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងការប្រឆាំងអំពំពើពុករលួយ	22.60	60.17	17.23
០៣	ការអភិវឌ្ឍន៍សេដ្ឋកិច្ច	17.27	63.21	19.52
០៤	ការអភិវឌ្ឍន៍វិស័យអប់រំ សុខាភិបាល ការងារ វប្បធម៌ និងសង្គមកិច្ច	`15.71	63.32	20.97
០៥	គោលនយោបាយរាជរដ្ឋាភិបាលនីតិកាលទី៥ (ទាំងបួនវិស័យ)	19.35	61.71	18.94

[3] តម្លៃនៃការផ្តល់ពិន្ទុអញ្ញត្តិទី១(មិនពេញចិត្តទាល់តែសោះ ឬពេញចិត្តតិចតួច)

[4] ផលបូកតម្លៃនៃការផ្តល់ពិន្ទុអញ្ញត្តិទី ២(ពេញចិត្តខ្លះ) និងទី៣(ពេញចិត្តមធ្យម ឬពាក់កណ្តាល)

[5] ផលបូកបញ្ចូល តម្លៃនៃការផ្តល់ពិន្ទុអញ្ញត្តិទី៤(ពេញចិត្តច្រើន) និងទី៥(ពេញចិត្តស្ទើរទាំងស្រុង ឬទាំងស្រុង)

១. ការបំពេញ/អនុវត្តន៍គោលនយោបាយមានសូចនាករច្បាស់លាស់

០១. ខិតខំសម្រេចឲ្យបាននូវកំណើនសេដ្ឋកិច្ចជាមធ្យម៧% ក្នុងមួយឆ្នាំ ដើម្បីធ្វើឲ្យកម្ពុជាអាចចាកចេញផុតពីប្រទេសមានចំណូលទាប ឈានឡើងជាប្រទេសមានចំណូលមធ្យមកម្រិតទាប យ៉ាងយូរនៅឆ្នាំ២០១៨ និងក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០។[6]

តាមគោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជាបានសន្យាថា នឹងខិតខំប្រឹងប្រែងសម្រេចឱ្យបាននូវកំណើនសេដ្ឋកិច្ចមធ្យម៧% ដើម្បីឱ្យប្រទេសចាកចេញពីចំណូលទាប ទៅប្រទេសមានចំណូលមធ្យមកម្រិតទាបយ៉ាងយូរនៅក្នុងឆ្នាំ២០១៨ខាងមុខនេះនិងក្លាយជាប្រទេសមានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០។

ផ្អែកលើកំណើនសេដ្ឋកិច្ចថេរក្នុងរយៈពេលប៉ុន្មានឆ្នាំចុងក្រោយ និងការកើនឡើងនូវផលទុកសរុបរបស់ប្រជាពលរដ្ឋ កម្ពុជាបានប្រែក្លាយខ្លួនជាប្រទេសមានចំណូលមធ្យមកំរិតទាបតាំងពីឆ្នាំ២០១៥។

ស្ថាប័នហិរញ្ញវត្ថុអន្តរជាតិមួយចំនួន បានព្យាករស្ថានភាពកំណើនសេដ្ឋកិច្ចកម្ពុជា។ ធនាគារពិភពលោកបានព្យាករថា សេដ្ឋកិច្ចកម្ពុជាក្នុងឆ្នាំ២០១៦ នឹងមានកំណើនក្នុងរង្វង់៧% ពោលគឺ៦,៩% យោងតាមការព្យាករណ៍កាលពីដើមឆ្នាំ២០១៦។[7] របាយការណ៍ព្យាករណ៍ឆ្នាំ២០១៦ របស់ធនាគារអភិវឌ្ឍន៍អាស៊ី និងរបាយការណ៍របស់មូលនិធិរូបិយប័ណ្ណអន្តរជាតិបានបង្ហាញថា សេដ្ឋកិច្ចកម្ពុជានឹងមានកំណើន៧% សម្រាប់ឆ្នាំ២០១៦។[8]

យោងតាមរបាយការណ៍របស់ក្រសួងហិរញ្ញវត្ថុ ស្តីអំពីវឌ្ឍនភាពម៉ាក្រូសេដ្ឋកិច្ចពាក់កណ្តាលឆ្នាំ២០១៦ បានបង្ហាញថា ទស្សនៈវិស័យសេដ្ឋកិច្ចកម្ពុជានៅបន្តរឹងមាំ ខណៈដែលផលិតផលក្នុងស្រុកសរុប (GDP) ត្រូវបានព្យាករថា មានកំណើនប្រមាណជា៧% ក្នុងឆ្នាំ២០១៦ និងឆ្នាំ២០១៧។ ម្យ៉ាងទៀត យោងតាមរបាយការណ៍ វឌ្ឍនភាពម៉ាក្រូសេដ្ឋកិច្ចកម្ពុជាបានសិក្សាទៅលើសូចនាករឆមាសទី១ឆ្នាំ២០១៦ ដើម្បីយកមកព្យាករដែលមានដូចជា៖ វិស័យឧស្សាហកម្ម វិស័យទេសចរណ៍ វិស័យកសិកម្ម និងពន្ធដារ។ល។ វិស័យទាំងនេះបានចូលរួមចំណែកយ៉ាងធំ ក្នុងការជំរុញឱ្យមានកំណើនសេដ្ឋកិច្ចកើនឡើង និងរីកលូតលាស់ជាងឆ្នាំទៅ២០១៥។ វិស័យកសិកម្មបានវិលត្រឡប់មករកភាពដើមវិញ បន្ទាប់ពីជួបគ្រោះធម្មជាតិនៅក្នុងឆ្នាំ២០១៥ ចំណែកឯវិស័យកាត់ដេរវិញ ត្រូវបានសំគាល់ឃើញថាមានភាពកើនឡើងយ៉ាងខ្លាំងក្លា ដែលជាសញ្ញាបង្ហាញពីការកើនឡើងផលិតកម្ម។ ដោយឡែកវិស័យទេសចរណ៍នៅក្នុងឆ្នាំនេះ មានការធ្លាក់ចុះបន្តិចបន្តួចដែលជាមូលហេតុទាញឱ្យមានការធ្លាក់ចុះនូវវិស័យសេវាកម្ម។ របាយការណ៍ក៏បានឲ្យដឹងដែរថា ទស្សនៈវិស័យសេដ្ឋកិច្ចកម្ពុជាសម្រាប់ឆ្នាំ២០១៦ និងឆ្នាំ២០១៧ អាចនឹងមិនសម្រេចបានតាមការព្យាករណ៍ទុក ប្រសិនបើសេដ្ឋកិច្ចចិនធ្លាក់ចុះយ៉ាងគំហុក ឬអស្ថិរភាពនៃទីផ្សារហិរញ្ញវត្ថុអន្តរជាតិធ្លាក់ចុះក្នុងស្ថានភាពធ្ងន់ធ្ងរភ្លាមៗ បន្ទាប់ពីការសម្រេចដកខ្លួនរបស់ចក្រភពអង់គ្លេសពីសហភាពអឺរ៉ុប (Brexit)។

ដោយឡែកប្រធានសមាគមសេដ្ឋកិច្ចកម្ពុជាយល់ឃើញថា កំណើន៧%នេះជាតួលេខម៉ាក្រូសេដ្ឋកិច្ចដែលអាចបង្ហាញស្ថានភាពមធ្យមសេដ្ឋកិច្ច តែមិនមែនឆ្លុះបញ្ចាំងពីតថភាពសេដ្ឋកិច្ចកម្ពុជាទាំងស្រុងឡើយ។

---

[6] *"Political Platforms of the Royal Government of Cambodia of the Fifth Legislature of the National Assembly"*, Royal Government of Cambodia, (Sept 2013), at 15.

[7] Global Economic Prospects, page 23 ,World Bank on June 2016

[8] Outlook 2016 Update, page 188, Asian Development Bank

សេចក្តីសន្និដ្ឋាន រាជរដ្ឋាភិបាលកម្ពុជាប្រាកដជាអាចសម្រេចបាននូវការរក្សាកំណើនសេដ្ឋកិច្ចឲ្យនៅត្រឹមរវាង៧%ក្នុងឆ្នាំទី៣នេះ ប៉ុន្តែផលនៃកំណើនសេដ្ឋកិច្ចនេះ មិនទាន់បានបែងចែកឲ្យប្រជាពលរដ្ឋប្រកបដោយសមភាពនោះទេ។

០២. សម្រេចឲ្យបានគោលដៅកាត់បន្ថយអត្រានៃភាពក្រីក្រជាង១% ក្នុងមួយឆ្នាំ។[9]

រាជរដ្ឋាភិបាលកម្ពុជា និងសមាជិកអង្គការសហប្រជាជាតិជាច្រើនប្រទេសទៀត បានសម្រេចទទួលយកនូវគោលដៅអភិវឌ្ឍន៍ប្រកបដោយនិរន្តរភាព សម្រាប់១៥ឆ្នាំទៅមុខទៀត។ ការលុបបំបាត់ភាពក្រីក្រគ្រប់រូបភាព និងការលុបបំបាត់ភាពស្រេកឃ្លាន គឺជាចំណុចសំខាន់ៗនៃគោលដៅអភិវឌ្ឍន៍នេះ។ ក្នុងរយៈពេលមួយឆ្នាំចុងក្រោយនេះ កម្ពុជាបានប្រែក្លាយជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកំរិតទាប តាមរយៈកំណើនសេដ្ឋកិច្ច នារយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ។ ចំណែកអត្រាភាពក្រីក្រ បើទោះបីជាមានការធ្លាក់ចុះពី៥០% ក្នុងឆ្នាំ២០០៧ ទៅ២០%ក្នុងឆ្នាំ២០១២។ ប្រជាពលរដ្ឋកម្ពុជាច្រើនជាង៧០% នៅតែរស់ពឹងផ្អែកប្រាក់ចំណូលតិចជាង៣ដុល្លារជាប្រចាំថ្ងៃ។ នេះមានន័យថា ពួកគេងាយនឹងវិលត្រឡប់ទៅរកភាពក្រីក្រវិញ ដែលមានប្រាក់ចំណូលប្រចាំថ្ងៃក្រោម១,២៥ដុល្លាអាមេរិក។[10]

រាជរដ្ឋាភិបាលធ្លាប់បានអះអាង ក្នុងកិច្ចប្រជុំកំពូលអង្គការសហប្រជាតិឆ្នាំ២០១៥ថា គិតត្រឹមឆ្នាំ២០១៣ អត្រាភាពក្រីក្របានធ្លាក់មកត្រឹម១៦% ដែលធ្វើឲ្យកម្ពុជាសម្រេចបាននូវគោលដៅអភិវឌ្ឍន៍សហវត្សរ៍កាត់បន្ថយភាពក្រីក្រមុនឆ្នាំ២០១៥។ ស្ថិតិរបស់ធនាគារអភិវឌ្ឍន៍អាស៊ីចេញផ្សាយឆ្នាំ២០១៦ បានបង្ហាញថា ក្នុងឆ្នាំ២០១៤ កម្ពុជាមានប្រជាពលរដ្ឋចំនួន១៣,៥ភាគរយរស់នៅក្រោមបន្ទាត់ភាពក្រីក្រ។[11]

នៅក្នុងឱកាសបើកសន្និសីទ អបអរសាទរសមិទ្ធិផល៥ឆ្នាំនៃកម្មវិធីសន្តិសុខស្បៀង សម្រាប់អនាគត (Feed the Future) នៃកិច្ចផ្តួចផ្តើមរបស់រដ្ឋាភិបាលសហរដ្ឋអាមេរិក ដើម្បីលុបបំបាត់ភាពអត់ឃ្លាន និងធានាសន្តិសុខស្បៀងសម្រាប់ពិភពលោក នាខែមិថុនា ឆ្នាំ២០១៦ រាជរដ្ឋាភិបាលយល់ឃើញថា ការអភិវឌ្ឍន៍វិស័យកសិកម្ម ជាផ្នែកមួយយ៉ាងសំខាន់សំរាប់ការកាត់បន្ថយភាពអត់ឃ្លាន ក៏ដូចជាការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋដែលរស់នៅតាមជនបទ។ ពីព្រោះ វិស័យកសិកម្មបានរួមចំណែកប្រមាណ២៦% នៃផលិតផលសរុបក្នុងស្រុក។ ជាងនេះ ប្រជាពលរដ្ឋចំនួន៨៥% រស់នៅជនបទ ក្នុងនោះប្រជាពលរដ្ឋ៦០% កំពុងប្រកបរបរកសិកម្ម ហើយមេគ្រួសារនៃគ្រួសារក្រីក្រ ជាកសិករមានរហូតដល់៧៥%។ ម្យ៉ាងវិញទៀត ការចុះផ្សាយរបស់ធនាគារអភិវឌ្ឍន៍អាស៊ី ក៏បានយល់ឃើញថា ក្រៅពីការប្រមូលផលស្រូវ វិស័យទេសចរណ៍ វិស័យកាត់ដេរ ព្រមទាំងសំណង់ ក៏បានចូលរួមចំណែកក្នុងការជួយកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋកម្ពុជាផងដែរ ហើយវាត្រូវបានគេរំពឹងថា នឹងបន្តផ្តល់ភាពវិជ្ជមានបន្ថែមទៀតនៅក្នុងឆ្នាំ២០១៦នេះ។

សេចក្តីសន្និដ្ឋាន រាជរដ្ឋាភិបាលកម្ពុជាសម្រេចបានការកាត់បន្ថយភាពក្រីក្របាន ក្នុងអត្រា១%ក្នុងមួយឆ្នាំ ប៉ុន្តែលក្ខខណ្ឌជីវភាព និងការរស់នៅរបស់ប្រជាពលរដ្ឋ មិនទាន់ត្រូវបានធានាថា បានចាកចេញពីភាពក្រីក្រប្រកបដោយនិរន្តរភាពនោះទេ។

---

[9] *Supra* note 10, at 17.
[10] https://www.adb.org/countries/cambodia/main
[11] Basic 2016 Statistics, page2, ADB, April 2016

០៣. បន្តខិតខំសម្រេចនូវគោលនយោបាយ ជំរុញផលិតកម្មស្រូវ និងការនាំចេញអង្ករឲ្យបាន១លានតោន នៅឆ្នាំ២០១៥ សំដៅប្រែក្លាយកម្ពុជា ទៅជាប្រទេសផលិតស្បៀងនាំមុខមួយនៅលើពិភពលោក។[12]

Export Statistic
(January- October 2016)
by Metric Tons

Monthly	2013	2014	2015	2016
1. january	25.728	21.536	35.921	44.033
2. February	24.089	27.037	37.676	51.912
3. March	45.413	35.757	75.867	66.275
4. April	23.276	35.961	51.719	39.550
5. May	28.350	27.971	41.842	32.558
6. June	29.105	29.666	40.800	33.862
7. July	31.411	26.060	28.492	24.087
8. August	29.358	29.871	29.819	27.799
9. September	29.395	35.511	26.969	41.429
10. October	28.031	35.418	39.064	60.016
11. November	37.855	31.137	48.748	58.168
12. December	46.847	51.136	81.479	---
Yearly Export	378.858	387.061	538.396	479.689

ក្នុងរយៈពេល៣ខែដើមឆ្នាំ២០១៦ ការនាំចេញអង្កររបស់ប្រទេសកម្ពុជាបានកើនឡើងជាង៨% បើធៀបនឹងរយៈពេល៣ខែដូចគ្នានៅក្នុងឆ្នាំ២០១៥។ ផ្ទុយមកវិញ នៅពាក់ពាក់កណ្តាលឆ្នាំ២០១៦ គឺចាប់ពីខែមេសា រហូតដល់ខែកក្កដា ការនាំចេញទៅអង្ករលក់នៅស្រុកក្រៅ មានការថយចុះយ៉ាងខ្លាំង ពោលគឺរយៈពេល៨ខែឆ្នាំ២០១៦ នេះ កម្ពុជានាំចេញអង្ករបាន៣២០ ០៧៦តោន គឺធ្លាក់ចុះ៦% បើធៀបនឹងរយៈពេលដូចគ្នា កាលពីឆ្នាំ២០១៥។[13]

ទិន្នន័យចុងក្រោយបានបង្ហាញថា គិតត្រឹមខែវិច្ឆិកា ឆ្នាំ២០១៦ កម្ពុជាបាននាំអង្ករចេញទៅទីផ្សារបរទេសចំនួនម្រមាណ៤៧៩.៦៨៩តោន យោងតាមរបាយការណ៍របស់សហព័ន្ធស្រូវអង្ករកម្ពុជា (CRF)។ ប្រៀបធៀបរយៈពេលដូចគ្នាឆ្នាំ២០១៥ ការនាំចេញអង្ករនេះ កើនឡើង ២២.៧៧៣តោនស្មើនឹង៥%។[14] ប្រភេទអង្ករដែលឈរលំដាប់លេខ១ នៅលើទីផ្សារអន្តរជាតិមានដូចជា៖ អង្ករផ្កាម្លិះ អង្ករផ្កាវ៉ែលូ។

ប្រភពពីសហព័ន្ធស្រូវអង្ករកម្ពុជាបានឲ្យដឹងថា កាលពីខែតុលាឆ្នាំ២០១៦ កម្ពុជាបានចុះអនុស្សរណៈយោគយល់គ្នាថ្មីមួយជាមួយប្រទេសចិន ដោយផ្តល់កូតានាំចេញអង្ករពីប្រទេសកម្ពុជាពី១០ម៉ឺនតោន ទៅ២០ ម៉ឺនតោនប្រចាំឆ្នាំ។[15]

ដំណាំស្រូវអង្ករថយចុះ នៅចន្លោះពាក់កណ្តាលឆ្នាំ២០១៦ ដោយសារតែគ្រោះរាំងស្ងួត ដីគ្មានជីរជាតិ ធ្វើឱ្យប៉ះពាល់ដល់ការលូតលាស់នៃដំណាំស្រូវ ដែលមិនអាចមានលទ្ធភាពផលិតអង្ករសំរាប់ផ្គត់ផ្គង់ទីផ្សារអឺរ៉ុបបាននោះទេ ហើយប្រទេសថៃក៏បានទម្លាក់តម្លៃអង្ករទាបជាងកម្ពុជា។ កត្តាផ្សេងទៀត បណ្តាលមកពីការក្សីយធននៃរោងម៉ាស៊ីនកិនស្រូវមួយចំនួនធំ ខ្វះទុនសំរាប់ផ្គត់ផ្គង់ផលិតកម្មស្រូវ និងការប្រមូលទិញស្រូវស្តុក ដែលជាហេតុនាំឱ្យម្ចាស់រោងម៉ាស៊ីនស្រូវមួយចំនួនបានខ្ចីបុលពីធនាគារ ដែលមានអត្រាការប្រាក់ប្រចាំឆ្នាំខ្ពស់ ប្រមាណ៨%ទៅ១២%។

ពាក់ព័ន្ធនឹងបញ្ហាខាងលើ សហគមន៍អឺរ៉ុបព្រមានឈប់ទិញអង្ករពីកម្ពុជា ដោយសារអង្ករដែលលក់ចេញជាអង្ករមិនសុទ្ធល្អ។ ដូចនេះយើងសង្កេតឃើញថា វាក៏ជាកត្តាធំមួយដែលបង្អាក់ដល់ការនាំចេញអង្ករលក់

---

[12] *Supra* note 10, at 21.

[13] http://www.crf.org.kh/?page=api_document_detail&menu1=1041&menu2=&menu3=&menu4=&menu5=&id=67&lg=en

[14] http://www.crf.org.kh/?page=api_document_detail&menu1=1041&menu2=&menu3=&menu4=&menu5=&id=67&lg=en

[15] http://www.crf.org.kh/?page=api_location_detail&id=1092&lg=kh#sthash.YVba0jla.dpuf

ទៅទីផ្សារអន្តរជាតិ ដែលធ្វើឱ្យទិន្នផលផលិតកម្មអង្ករបស់កម្ពុជានាពេលនេះបានធ្លាក់ចុះ។[16] បន្ថែមលើសពីនេះទៀត សហព័ន្ធស្រូវអង្ករ និងក្រុមហ៊ុននាំចេញអង្ករយល់ថា ឧបសគ្គនៃការចំណាយថ្លៃដឹកជញ្ជូនខ្ពស់ ខណៈហេដ្ឋារចនាសម្ព័ន្ធនៅតែខ្វះ គឺជាមូលហេតុចម្បងដែលជំរុញឲ្យមានវិបត្តិធ្លាក់ចុះតម្លៃស្រូវ ព្រមទាំងជះឥទ្ធិពលដល់ទីផ្សារអង្ករបស់កម្ពុជា មិនអាចប្រកួតប្រជែងតម្លៃជាមួយប្រទេសថៃ និងវៀតណាម។ របាយការណ៍បានឲ្យដឹងថា ការចំណាយទៅលើថ្លៃដើមដឹកជញ្ជូនខ្ពស់ចាប់ពី២៥ដុល្លារ ទៅ៣០ដុល្លារក្នុងមួយតោន ខណៈក្នុងប្រទេសថៃ និងវៀតណាម ការចំណាយត្រឹមតែជាង១០ដុល្លារប៉ុណ្ណោះ។[17]

ក្នុងអំឡុងពេលត្រីមាសទីពីរឆ្នាំ២០១៦ តម្លៃស្រូវមានការធ្លាក់ចុះរហូតបណ្តាលឲ្យប្រជាកសិករនៅតាមបណ្តាខេត្តមួយចំនួនធ្វើការតវ៉ា រហូតមានការយកទិន្និផលស្រូវចាក់លើផ្លូវថ្នល់ជាដើម ដើម្បីទាមទារឲ្យរាជរដ្ឋាភិបាលស្វែងរកដំណោះស្រាយជូនពួកគេ។ ឆ្លើយតបនឹងការតវ៉ានេះ រាជរដ្ឋាភិបាលកម្ពុជាបានចាត់ទុកថាបញ្ហាធ្លាក់ចុះតម្លៃស្រូវនៅកម្ពុជាក៏បណ្តាមកពីរងឥទ្ធិពលពីបណ្តាប្រទេសប្រកួតប្រជែងក្នុងតំបន់ជាមួយ។ ដើម្បីចូលរួមដោះស្រាយបញ្ហានេះ រាជរដ្ឋាភិបាលបានបញ្ចេញប្រាក់បំរុងទុកចំនួន២លានដុល្លារអាមេរិក ដើម្បីរក្សាស្ថិរភាពតម្លៃស្រូវនៅលើទីផ្សារ និងជំរុញការទិញស្រូវនៅក្នុងប្រទេស ហើយធនាគារអភិវឌ្ឍន៍ជនបទ (RDB) បានផ្តល់ឱកាសឲ្យរោងម៉ាស៊ីនកិនស្រូវក្នុងស្រុកទាំងអស់ អាចស្នើសុំកម្ចីដែលអត្រាការប្រាក់ ០,៦៦ ភាគរយក្នុងមួយខែ ជាមួយនឹងលក្ខខណ្ឌដែលអ្នកយកកម្ចីចាំបាច់ ត្រូវទិញស្រូវពីកសិករលើពីតម្លៃ ៩០០រៀលក្នុងមួយគីឡូក្រាម។ រដ្ឋាភិបាលគ្រោងនឹងខ្ចីមូលនិធិពីចិន៣០០លានដុល្លារ ដើម្បីធ្វើឃ្លាំងស្តុក និងសម្ងួតស្រូវផ្ទាល់ខ្លួន។[18]

សេចក្តីសន្និដ្ឋាន បើទោះបីជាក្នុងរយៈពេល១១ខែ ឆ្នាំ២០១៦ ការនាំអង្ករបស់ប្រទេសកម្ពុជាមានការលើកឡើងជាងឆ្នាំ២០១៥ប្រមាណ០៥% ប៉ុន្តែរាជរដ្ឋាភិបាលសម្រេចខ្លះនូវគោលដៅនាំចេញអង្ករ ក្នុងឆ្នាំ២០១៦នេះ ព្រោះក្នុងរយៈពេល១១ខែ ការនាំចេញអង្ករមិនដល់ចំនួន៥០%នៃគោលដៅនាំចេញចំនួន០១លានតោន។

០៤. រក្សាផ្ទៃនេសាទទឹកសាបសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាលក្ខណៈគ្រួសារ ពង្រឹងតំបន់អភិរក្ស បង្កើនការការពារធនធានជលផល លុបបំបាត់បទល្មើសនេសាទគ្រប់រូបភាព។[19]

កំណែទម្រង់នេសាទ ដែលមានលក្ខណៈស៊ីជម្រៅ និងមានទ្រង់ទ្រាយធំ ត្រូវបានធ្វើឡើងក្នុងឆ្នាំនីតិកាលទី៤នៃរដ្ឋសភាក្នុងឆ្នាំ២០១២ ដោយលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានសន្យាជាមួយប្រជាពលរដ្ឋកម្ពុជាថា លោកនឹងលុបចោលប្រព័ន្ធឡូត៍នេសាទអាជីវកម្មឯកជនឲ្យអស់ និងរៀបចំដាក់ផ្ទៃទឹកសាបសម្រាប់សហគមន៍ប្រជានេសាទទូទៅជុំវិញបឹងទន្លេសាប ដើម្បីទទួលផលដោយផ្ទាល់ចំនួន៦៥% និងចំនួន៣៥% រក្សាទុកសម្រាប់ជាតំបន់អភិរក្សវិស័យជលផលក្នុងបឹងទន្លេសាប។[20] ជាលទ្ធផល ឡូត៍នេសាទឯកជនទាំង៣៧

---

[16] http://www.crf.org.kh/?page=api_document_detail&menu1=1041&menu2=&menu3=&menu4=&menu5=&id=67&lg=en

17 http://www.rfa.org/khmer/news/economy/Cambodia-Rice-Federation-push-government-to-resolve-exportation-rice-12072016082917.html?searchterm:utf8:ustring=%E1%9E%9F%E1%9F%92%E1%9E%9A%E1%9E%BC%E1%9E%9C

[18] https://goo.gl/adVku2

[19] [19] *Supra* note 10, at 21.

[20] *Fishery Reform on the Tonle Sap Lake: risks and opportunities for innovation*, 17(2), June 2013 at 1, Cambodia Development Review, (CDRI).

ឡូត៍ក្នុងបឹងទន្លេសាប និង៨០ឡូត៍នេសាទនៅទូទាំងប្រទេស ត្រូវបានលុបចោលដោយអនុក្រឹត្យក្នុងឆ្នាំ២០១២ ។

ផ្នែកទិន្នន័យក្នុងរបាយការណ៍បូកសរុបការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឆ្នាំ២០១៤ ដល់ឆ្នាំ ២០១៥ សហគមន៍នេសាទទឹកសាបចំនួន៤៧៧សហគមន៍ ត្រូវបានបង្កើត និងចងក្រងឡើងដោយមួយចំនួន បានចុះបញ្ជីត្រឹមត្រូវតាមច្បាប់ និងបានចូលរួមយ៉ាងសកម្មក្នុងការគ្រប់គ្រង និងអភិរក្សធនធានជលផលនៅ កម្ពុជា ចំណែកឯសហគមន៍មួយចំនួនទៀត កំពុងរៀបចំសំណុំឯកសារស្នើសុំចុះបញ្ជី ខណៈសហគមន៍មួយ ចំនួនផ្សេងទៀតកំពុងដំណើរការចុះហត្ថលេខានៅថ្នាក់ក្រោមជាតិ[21]។ បើប្រៀបធៀបនឹងឆ្នាំមុនចំនួនសហគមន៍ នេសាទទឹកសាប មិនមានការកើនឡើងទោះទេ ប៉ុន្តែការចុះបញ្ជីសហគមន៍នេសាទបានកើនឡើងពី៣៦០ ឆ្នាំ២០១៤ ដល់៣៧៧ ឆ្នាំ២០១៥។ នៅឆ្នាំ២០១៥ សហគមន៍នេសាទចំនួន៨៥ ត្រូវបានពង្រឹងសមត្ថភាព បន្ថែម។

របាយការណ៍របស់ក្រសួងកសិកម្ម ក៏បានទទួលស្គាល់ចំណុចខ្វះខាត និងបញ្ហាប្រឈមមួយចំនួនទាក់ ទងការរក្សាផ្ទៃទឹកសាប និងលុបបំបាត់បទល្មើសនេសាទផងដែរ។ បញ្ហាទាំងនោះមានដូចជា៖ ការបន្តកើតមាន បទល្មើស និងការទន្ទ្រានយកដីក្នុងដែននេសាទធ្វើជាកម្មសិទ្ធិឯកជន ការអនុវត្តន៍ច្បាប់ និងកិច្ចសហប្រតិ បត្តិ ការរបស់អាជ្ញាធរនៅមានកម្រិត ទន្ទឹមនឹងសហគមន៍នេសាទ ពុំមានធនធានគ្រប់គ្រាន់សម្រាប់អនុវត្តផែនការ សកម្មភាពរបស់ខ្លួន។ ក្នុងឆ្នាំ២០១៥ បទល្មើសជលផលត្រូវបានបង្ក្រាបចំនួន៩.៣៧៤ករណី កើនឡើងចំនួន ២៨៨ករណីធៀបនឹងឆ្នាំ២០១៤។

ប្រភពរូបភាព៖ សារព័ត៌មានដើមអំពិល

ក្នុងត្រីមាសទី១ ឆ្នាំ២០១៦ សំណុំ រឿងបទល្មើសជលផលទឹកសាប មាន ចំនួន៧៣៤ករណី ខណៈពេលដែលផល នេសាទទឹកសាបមានការធ្លាក់ចុះ រហូត មិនអាចសម្រេចតាមផែនការ។ ផលនេ សាទដោយ ដាយត្រីធ្វើអាជីវកម្មអនុវត្ត បាន៨,៧៥% នៃ១២.០០០តោន ចំណែកផលនេសាទគ្រួសារ ក្នុងដែន នេសាទអនុវត្ត បាន១៩,៧៧%នៃផែន ការ១៤៤.០០០តោន។

ក្នុងឆ្នាំ២០១៦ ឧបករណ៍នេសាទដែលត្រូវបានក្រសួងហាមឃាត់តាំងពីឆ្នាំ២០១២ នៅតែបន្តសកម្ម ភាព ដែលបានធ្វើឲ្យប៉ះពាល់ដល់ធនធានជលផល និងប្រភេទជីវចម្រុះផ្សេងៗទៀត។ ក្រសួងកសិកម្មរុក្ខា ប្រមាញ់ និងនេសាទ បានណែនាំក្នុងសារាចរណែនាំចុះថ្ងៃទី៥ ខែកក្កដា ក្រសួងកសិកម្មបានណែនាំ បង្ក្រាប និងចាប់ជនល្មើសជលផលមកផ្តន្ទាទោស។ ចុងឆ្នាំ២០១៦នេះ រាជរដ្ឋាភិបាលបានប្រកាសចាប់ផ្តើមយុទ្ធនាការ បង្ក្រាបបទល្មើសនេសាទ ដោយការដឹកនាំដោយរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ។

[21] របាយការណ៍បូកសរុបការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ២០១៤-២០១៥ ទំព័រ២០

ក្នុងគោលនយោបាយនីតិកាលទី៥ រាជរដ្ឋាភិបាលបានសន្យាថា នឹងរក្សាផ្ទៃនេសាទទឹកសាបសម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាលក្ខណៈគ្រួសារ ពង្រឹងតំបន់អភិរក្ស បង្កើនការការពារធនធានជលផល លុបបំបាត់បទល្មើសនេសាទគ្រប់រូបភាព។ ជាការពិតណាស់រាជរដ្ឋាភិបាលបានលុបបំបាត់ការធ្វើអាជីវកម្មលក្ខណៈ ឯកជនលើឡូត៍នេសាទទូទាំងប្រទេស ដើម្បីឲ្យប្រជាពលរដ្ឋនេសាទ ប៉ុន្តែគេឃើញមានបញ្ហាប្រឈមអំពីការថែរក្សាផ្ទៃទឹកសាប និងគ្រប់គ្រងធានធានជលផលនៅក្នុងផ្ទៃទឹកទាំងនោះ។ សហគមន៍អ្នកនេសាទខេត្តសៀមរាប ឱ្យដឹងថា ពេលបច្ចុប្បន្នបទល្មើសនេសាទត្រីដោយប្រើកាណូតធំៗក្នុងបឹងទន្លេសាប នៅតែកើតមានជាច្រើនកន្លែង ប៉ុន្តែសមត្ថកិច្ចហាក់មានការបង្ក្រាបតិចតួចបំផុត។[22]

សេចក្តីសន្និដ្ឋាន រាជរដ្ឋាភិបាលសម្រេចបានខ្លះនូវគោលនយោបាយរក្សាផ្ទៃនេសាទទឹកសាប សម្រាប់ប្រជាពលរដ្ឋធ្វើនេសាទជាលក្ខណៈគ្រួសារ ពង្រឹងតំបន់អភិរក្ស បង្កើនការការពារធនធានជលផល លុបបំបាត់បទល្មើសនេសាទគ្រប់រូបភាព ព្រោះគេឃើញមានបទល្មើសនេសាទ ភាពកំសោយនៃការអនុវត្តន៍ច្បាប់ពីសំណាក់អាជ្ញាធរពាក់ព័ន្ធ នៅតែបន្តកើតមានឡើង។

០៥. រក្សាផ្ទៃដីដែលគ្របដណ្តប់ដោយព្រៃឈើ ដោយបង្កើនការការពារធនធានព្រៃឈើ ពិសេសការពង្រឹងការអនុវត្តន៍ច្បាប់ ស្តីពីព្រៃឈើ ការទប់ស្កាត់បង្ក្រាបបទល្មើសព្រៃឈើ ជំរុញការដាំដើមឈើឡើងវិញ និងបង្កើនសមត្ថភាពសហគមន៍ព្រៃឈើនៅលើមូលដ្ឋានានាវិភាព និងប្រសិទ្ធភាពគ្រប់គ្រង។[23]

ឆ្នាំ	(%) ឈើព្រៃគម្រប	(%) ស្រោងព្រៃ	(%) ល្បោះព្រៃ	(%) ទឹក	(%) ព្រៃមែនម្ជិន	(%) ភពក
១៩៧៣	៧២.១១	៨១.៨៨	៣០.២៣	២.៨៧	២៤.២៩	០.៧៣
១៩៨៩	៦៧.៩២	៣៨.៩៩	២៨.៩២	២.៦៨	២៩.៣៥	០.១០
២០០០	៦៦.៦៥	៣៤.៥២	៣២.១៣	៣.២០	៣០.០១	០.១៣

[22] http://www.rfa.org/khmer/news/social-economy/some-Siemreap-residents-abandand-fishing-career-01082016083524.html

[23] *Supra* note 10, at 21-22.

២០០៨	៦៣.០៥	៣០.៦៦	៣២.៣៩	២.៥១	៣៣.៩៥	០.៤៩
២០០៩	៦០.១៨	២២.៥៥	៣៧.៦៣	២.៤៥	៣៦.៨១	០.៥៦
២០១៤	៤៧.៦៨	១៦.៤៥	៣១.២៣	៣.៦៧	៤៨.៤១	០.២៤

ភាគរយគម្របដីនៃប្រទេសកម្ពុជាបានមកពីការវិភាគតាមរូបភាពផ្កាយរណប

សម្បត្តិព្រៃឈើនៅកម្ពុជា នៅតែបន្តបំផ្លិចបំផ្លាញយ៉ាងធ្ងន់ធ្ងរ នៅក្នុងឆ្នាំ២០១៣ ហើយនៅតែបន្តនៅក្នុងឆ្នាំ២០១៤ ទៀត ជាពិសេសនៅក្នុងតំបន់ដែលរដ្ឋាភិបាលបានផ្តល់សិទ្ធិទៅឲ្យក្រុមហ៊ុន ក្នុងហានៈជាដីសម្បទានសេដ្ឋកិច្ច នូវដីដែលជាតំបន់អភិរក្សព្រៃឈើ ដូចជាឧទ្យានជាតិ និងតំបន់សម្រាប់អភិរក្សសត្វព្រៃជាដើម។[24]

ទិន្នន័យរបស់អង្គការទិន្នន័យសម្រាប់ការអភិវឌ្ឍន៍ (ODC) បានឲ្យដឹងថា គម្របព្រៃឈើសរុបក្នុងប្រទេសកម្ពុជាបានថយចុះពីប្រមាណ៧២ភាគរយ ក្នុងឆ្នាំ១៩៧៣ មកនៅត្រឹម៤៨ភាគរយ ក្នុងឆ្នាំ២០១៤ ខណៈពេលដែលព្រៃស្រោងបានថយចុះពី ៤២ភាគរយ មកនៅត្រឹម១៦ភាគរយ នៅក្នុងរយៈពេលដូចគ្នា។ កម្រិតនៃគម្របព្រៃល្បោះ រាប់បញ្ចូលទាំងផ្ទៃដីដំណាំមួយចំនួនផងនោះ មានស្ថេរភាពបន្តិចនៅក្នុងរយៈពេលដូចគ្នា ដោយប្រែប្រួលពី៣០ភាគរយ នៅក្នុងឆ្នាំ១៩៧៣ មក៣១ភាគរយ នៅក្នុងឆ្នាំ២០១៤។[25]



របាយការណ៍សិក្សាស្រាវជ្រាវ ចេញផ្សាយឆ្នាំ២០១៥ ស្តីអំពីការកើនឡើងនៃគម្រោងអភិវឌ្ឍន៍កសិកម្មឧស្សាហកម្ម បំផ្លាញព្រៃឈើកម្ពុជាយ៉ាងធំធេង បានបង្ហាញថា ព្រៃឈើកម្ពុជាកំពុងបាត់បង់ក្នុងកំរិត២០០០ គីឡូម៉ែត្រការ៉េក្នុងមួយឆ្នាំ ដោយសារក្រុមហ៊ុនជំនួញផ្នែកកសិកម្មកំពុងប្រមូលយកផលពីព្រៃឈើ ក្នុងតំបន់អភិរក្ស និងសួនឧទ្យានជាតិដោយប្រើប្រាស់គ្រប់មធ្យោបាយខុសច្បាប់។[26]

កម្ពុជាស្ថិតនៅក្នុងចំណោមប្រទេសកាប់បំផ្លាញព្រៃឈើធ្ងន់ធ្ងរ នេះបើតាមការរកឃើញនៅរបាយការណ៍ថ្មីមួយឆ្នាំ២០១៥ ចេញដោយអង្គការមូលនិធិសត្វព្រៃពិភពលោក (WWF)។របាយការណ៍របស់អ្នកសិក្សាស្រាវជ្រាវ នៅសាកលវិទ្យាល័យជាតិអូស្ត្រាលី ដែលបានចេញផ្សាយកាលពីដើមឆ្នាំ២០១៥ ស្តីអំពីការសិក្សាលំអិតអំពីអាស៊ីបាននិយាយថា រាជរដ្ឋាភិបាលបានផ្តល់ផលប្រយោជន៍

[24] Zsombor Peter, *New Maps Show Heavy Deforestation In 2013*, The Cambodia Daily, Jan 16, 2015.
[25] https://opendevelopmentcambodia.net/km/profiles/forest-cover/#Method
[26] http://www.phnompenhpost.com/national/elcs-tied-destruction-forests-new-report

តាមរយៈការកាប់ឈើខុសច្បាប់ដល់ឈ្មួញអ្នកមានទ្រព្យសម្បត្តិ ដែលមានទំនាក់ទំនងផ្ទៃកនយោបាយ ជាថ្នូរនឹងការធានានឹងការក្តោបក្តាប់អំណាចរបស់គណបក្សកាន់អំណាច។

ដើមខែមករា ឆ្នាំ២០១៧ អង្គការ NASA EARTH OBSERVATORY បានឲ្យដឹងថា កម្ពុជាជាប្រទេសមួយមានអត្រានៃការបាត់បង់ព្រៃឈើរហ័សជាងគេលើពិភពលោក។ ក្នុងទសវត្សចុងក្រោយនេះ ព្រៃក្រាស់ ឬស្តុក ត្រូវបានកាប់ឆ្ការ ហើយដីតំបន់នោះភាគច្រើនត្រូវបានគេយកទៅប្រើប្រាស់ជាដីចម្ការកៅស៊ូ ឬចម្ការផ្សេង។ របាយការណ៍បានឲ្យដឹងទៀតថា ពីឆ្នាំ២០០១ ដល់២០១៤ អត្រាបាត់បង់ ព្រៃឈើកម្ពុជាបានកើនឡើងដល់១៤,៤% នេះមានន័យថា កម្ពុជាបានបាត់បង់ព្រៃឈើក្នុងផ្ទៃដីទំហំ១,៤៤លានហិចតា។



ឆ្នាំ២០១៥

ការកែប្រែផ្ទៃដីពីដីព្រៃ ទៅជាដីចម្ការត្រូវបានអង្គការនេះបង្ហាញ តាមរយៈការប្រៀបធៀបរូបថតពីផ្កាយ



ប្រៀបធៀបគម្របព្រៃឈើកម្ពុជា១៩៦៥ ដល់ ២០១៤

រណប ដែលបានថតកាលពីឆ្នាំ២០០០ និង រូបថតនៅឆ្នាំ២០១៥ ដែលបង្ហាញថា ព្រៃឈើកាលពីឆ្នាំ២០០០ ក្នុងតំបន់ព្រំប្រទល់ខេត្តកំពង់ធំ និងកំពង់ចាម ត្រូវបានកែប្រែជាដីចម្ការ ហេដ្ឋារចនាសម្ព័ន្ធ និងដីស្រែរបស់ប្រជាពលរដ្ឋជាដើម។ ការកើនឡើងនូវតម្លៃទីផ្សារកៅស៊ូ នៅលើពិភពលោក ជាហេតុផលសំខាន់មួយ ដែលនាំឲ្យមានការកើនឡើងយ៉ាងគំហុកនូវការកែប្រែដីព្រៃដើមដាំដុះដំណាំកៅស៊ូ។[27] រាជរដ្ឋាភិបាលកម្ពុជាបានចាត់ទុកផ្ទៃដីដែលដាំដុះដំណាំកៅស៊ូ ជាផ្ទៃដីគម្របផ្ទៃឈើផងដែរ។ ទាក់ទងនឹងការបង្ហាញនេះ របាយការណ៍បានលើកឡើងថា ផ្ទៃដីសម្បទានសេដ្ឋកិច្ចលើវិស័យកសិកម្មដែលបានផ្តល់ជូនដោយរាជរដ្ឋាភិបាលដល់ក្រុមហ៊ុនក្នុងស្រុក និងក្រៅស្រុក បានបាត់បង់ព្រៃឈើច្រើនជាងផ្ទៃដីដែលមិនស្ថិតនៅក្នុងគំរោងសម្បទានប្រមាណពី២៩% ទៅ១០៥%។

ឆ្នាំ២០១៥

ណប ដែលបានថតកាលពីឆ្នាំ២០០០ និង រូបថតនៅឆ្នាំ២០១៥ ដែលបង្ហាញថា ព្រៃឈើកាលពីឆ្នាំ២០០០ ក្នុងតំបន់ព្រំប្រទល់ខេត្តកំពង់ធំ និងកំពង់ចាម ត្រូវបានកែប្រែជាដីចម្ការ ហេដ្ឋារចនាសម្ព័ន្ធ និងដីស្រែរបស់ប្រជាពលរដ្ឋជាដើម។ ការ

ប្រៀបធៀបគម្របព្រៃឈើកម្ពុជា១៩៦៥ ដល់ ២០១៤

ការកើនឡើងនូវតម្លៃទីផ្សារកៅស៊ូ នៅលើពិភពលោក ជាហេតុផលសំខាន់មួយ ដែលនាំឲ្យមានការកើនឡើងយ៉ាងគំហុកនូវការកែប្រែដីព្រៃដើមដាំដុះដំណាំកៅស៊ូ។[27] រាជរដ្ឋាភិបាលកម្ពុជាបានចាត់ទុកផ្ទៃដីដែលដាំដុះដំណាំកៅស៊ូ ជាផ្ទៃដីគម្របផ្ទៃឈើផងដែរ។ ទាក់ទងនឹងការបង្ហាញនេះ របាយការណ៍បានលើកឡើងថា ផ្ទៃដីសម្បទានសេដ្ឋកិច្ចលើវិស័យកសិកម្មដែលបានផ្តល់ជូនដោយរាជរដ្ឋាភិបាលដល់ក្រុមហ៊ុនក្នុងស្រុក និងក្រៅស្រុក បានបាត់បង់ព្រៃឈើច្រើនជាងផ្ទៃដីដែលមិនស្ថិតនៅក្នុងគំរោងសម្បទានប្រមាណពី២៩% ទៅ១០៥%។

របាយការណ៍ក្រសួងកសិកម្ម នៅឆ្នាំ១៩៦៥ ធនធានគម្របព្រៃឈើកម្ពុជាគ្របដណ្តប់ចំនួន៧៣,០៤% នៃផ្ទៃដីកម្ពុជាសរុប។ ការវាយតម្លៃថ្នាក់ជាតិ ស្តីពីគម្របព្រៃឈើត្រូវបានធ្វើក្នុងរយៈពេល០៥ឆ្នាំម្តង ចាប់តាំងពីឆ្នាំ១៩៩៣មក។ របាយការណ៍បានបង្ហាញថា ក្នុងឆ្នាំ២០១៤ គម្របព្រៃឈើកម្ពុជាមានប្រមាណ៤៩% នៃផ្ទៃដីសរុប ខណៈឆ្នាំ២០១០មានចំនួនប្រមាណ៥៧%។ ក្នុងរយៈពេល៥ឆ្នាំ ពីឆ្នាំ២០១០ ដល់ឆ្នាំ២០១៤ គម្របព្រៃឈើកម្ពុជាមានការធ្លាក់ចុះយ៉ាងខ្លាំងស្មើនឹងប្រមាណ៨%។

[27] http://km.rfi.fr/cambodia/nasa-cambodia-forests-are-disappearing-11-01-2017?ns_campaign=reseaux_sociaux&ns_source=FB&ns_mchannel=social&ns_linkname=editorial&aef_campaign_ref=partage_user&aef_campaign_date=2017-01-11

ក្នុងឆ្នាំ២០១៦ រាជរដ្ឋាភិបាល បានដាក់តំបន់មួយចំនួនជាតំបន់ព្រៃការពារ និងអភិរក្សព្រៃឈើ ក្នុងនោះក៏មានតំបន់ព្រៃឡង់ផងដែរ ហើយបានអំពាវនាវឲ្យសកម្មជនការពារបរិស្ថាន ពលរដ្ឋ និងសហគមន៍ចូលរួមសហការជាមួយរដ្ឋាភិបាល ដើម្បីការពារតំបន់ព្រៃការពារទាំងអស់នោះកុំឲ្យមានការកាប់បំផ្លាញខុសច្បាប់។ ក្រោយមកបន្តិច ក្រសួងបរិស្ថានបានប្រកាស ក្នុងទិវាបរិស្ថានពិភពលោកកាលពីថ្ងៃទី៥ ខែមិថុនា ២០១៦ ថា សកម្មភាពកាប់ឈើដោយខុសច្បាប់លែងមានទៀតហើយ។

ប៉ុន្តែយោងសេចក្តីប្រកាសព័ត៌មាន បណ្តាញសហគមន៍ការពារព្រៃឡង់ទាំង៨ខេត្ត គឺខេត្តព្រះវិហារ ស្ទឹងត្រែង ក្រចេះ និងខេត្តកំពង់ធំ បានឲ្យដឹងនៅថ្ងៃទី៦ ខែមិថុនាថា សកម្មភាពកាប់បំផ្លាញឈើដោយជនអនាធិបតេយ្យ និងក្រុមហ៊ុនអាជីវកម្មអារឈើកំពុងកើតមានជាហូរហែ ហើយសកម្មភាពដឹកឈើចេញពីតំបន់ព្រៃឡង់កំពុងកើតមានខ្លាំងក្លាដដែល ហើយសកម្មជនមួយចំនួន ត្រូវបានជនល្មើសគំរាមបាញ់សម្លាប់ទៀតផង។

យោងតាមរបាយការណ៍បូកសរុបការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទឆ្នាំ២០១៤ ដល់ឆ្នាំ២០១៦។ ក្នុងឆ្នាំ២០១៤ បទល្មើសព្រៃឈើ សត្វព្រៃ និងការកាប់រានដីព្រៃនៅកម្ពុជាមានចំនួន២៤០០ករណី ក្នុងនោះ បានបញ្ជូនទៅតុលាការចំនួន១.៧៧១ករណី ពិន័យអន្តរការណ៍ចំនួន៦២៩ករណី[28]។ ចំនួនសំណុំរឿងបញ្ជូនទៅតុលាការដូចគ្នាទាំងស្រុង បើប្រៀបធៀបនឹងឆ្នាំ២០១៤ លើកលែងតែចំនួនករណីពិន័យអន្តរការណ៍ដែលកើនឡើងពី៥៦៨ ដល់៦២៩ករណី។[29] ក្នុងឆ្នាំ២០១៥ បទល្មើសខាងលើមានចំនួន២១៨៩ករណី ក្នុងនោះសំណុំរឿងបញ្ជូនទៅតុលាការចំនួន១៥៤៦ករណី និងពិន័យអន្តរការណ៍ចំនួន៦៤៣ករណី។ បើប្រៀបធៀបឆ្នាំ២០១៤ ចំនួនករណីបញ្ជូនទៅតុលាការមានការធ្លាក់ចុះ ទន្ទឹមនឹងករណីបទល្មើសបានធ្លាក់ចុះចំនួន២១១ករណី។[30]

ការសន្និដ្ឋាន រដ្ឋាភិបាលនីតិកាលទី៥នៃរដ្ឋសភា មិនបានសម្រេច/បានតិចតួច ស្ទើរគ្មានប្រសិទ្ធភាព គោលនយោបាយរក្សាផ្ទៃដីដែលគ្របដណ្តប់ដោយព្រៃឈើ ដោយបង្កើនការការពារធនធានព្រៃឈើ ពិសេសការពង្រឹងការអនុវត្តន៍ច្បាប់ ស្តីពីព្រៃឈើ ការទប់ស្កាត់បង្ក្រាបបទល្មើសព្រៃឈើ ជំរុញការដាំដើមឈើឡើងវិញ និងបង្កើនសមត្ថភាពសហគមន៍ព្រៃឈើនៅលើមូលដ្ឋាន ធានាវិរភាព និងប្រសិទ្ធភាពគ្រប់គ្រង។

០៦. បញ្ឈប់ការផ្តល់សម្បទានដីសេដ្ឋកិច្ច។[31]

ចាប់តាំងពីឆ្នាំ១៩៩៣ រហូតដល់ឆ្នាំ២០១២ រាជរដ្ឋាភិបាលកម្ពុជាបានអនុវត្តគម្រោងដីសម្បទានសេដ្ឋកិច្ច ដើម្បីចូលរួមចំណែកក្នុងកំណើនសេដ្ឋកិច្ចរបស់ខ្លួន។ ការផ្តល់ដីសម្បទានសេដ្ឋកិច្ចធ្វើឲ្យមានជម្លោះដីធ្លីរវាងប្រជាពលរដ្ឋនៅមូលដ្ឋាន និងក្រុមហ៊ុនទទួលបានសិទ្ធិអនុវត្តគម្រោងលើដីសម្បទានសេដ្ឋកិច្ច ដែលជម្លោះនោះឈានទៅដល់វិបត្តិជម្លោះដីធ្លីនៅកម្ពុជាអស់រយៈពេលជាច្រើនឆ្នាំមកហើយ។

---

[28] របាយការណ៍បូកសរុបការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ២០១៤-២០១៥ ទំព័រ ២៣

[29] ម៉ែ ទិត្យថារ៉ា, *ក្រសួងថារយៈពេល១ឆ្នាំ បង្ក្រាបបទល្មើសព្រៃឈើជាងពីរពាន់ករណី និងផ្តន្ទាទោសជនល្មើស៧នាក់* ភ្នំពេញប៉ុស្ត៍ ថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៤។

[30] របាយការណ៍បូកសរុបការងារកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ២០១៤-២០១៦

[31] *Supra* note 10, at 22.



យោងតាមរយៈរបាយការណ៍ស៊ើបអង្កេតរបស់អង្គការលីកាដូ កម្ពុជាដែលចេញផ្សាយពីដើមឆ្នាំ ២០១៤ បានបង្ហាញថា ទំហំដីជាង ២,២លានហិចតា ត្រូវបានកាត់ផ្តល់ ឲ្យក្រុមហ៊ុនធំៗមួយចំនួនជាដីសម្បទានសេដ្ឋកិច្ច (ELCs)។[32] របាយការណ៍ដដែលនេះបាន បញ្ជាក់ទៀតថា បើរាប់គិតចាប់ពីឆ្នាំ២០០០ រហូតដល់ឆ្នាំ២០១៣កន្លងទៅនេះ មានប្រជាជនកម្ពុជាប្រហែលកន្លះលាននាក់បាន និងកំពុងរងគ្រោះដោយវិបត្តិដីធ្លីនៅកម្ពុជា។ ជាងនេះទៅទៀតក្នុងឆ្នាំ២០១៣ ការផ្តល់ដីសម្បទានសេដ្ឋកិច្ចនេះ បានផ្តល់ផលប៉ះពាល់យ៉ាងខ្លាំងដល់ប្រជាជនចំនួនប្រមាណ៤២០.០០០នាក់។

របាយការណ៍របស់មជ្ឈមណ្ឌលស្រាវជ្រាវតស៊ូមតិ និងទំនាក់ទំនងបានបង្ហាញថា គិតត្រឹមចុងឆ្នាំ២០១៥ កម្ពុជាមានក្រុមហ៊ុនដីសម្បទានសេដ្ឋកិច្ចចំនួន២៦៧ ដែលកំពុងប្រតិបត្តិការវិនិយោគ។[33] ដីសម្បទានសេដ្ឋកិច្ចចំនួន១៥៨ បានបង្កឲ្យមានវិវាទដីធ្លីក្នុង១៨ខេត្ត ដែលខេត្តរតនគិរី មណ្ឌលគិរី និងកំពង់ធំត្រូវបានគេមើលឃើញកើតមានជំលោះដីធ្លីច្រើនជាងគេ រវាងប្រជាពលរដ្ឋ និងក្រុមសម្បទានដីសេដ្ឋកិច្ច។



របាយការណ៍ខាងលើបានបង្ហាញថា ឆ្នាំ២០១១គឺជាឆ្នាំដែលរាជរដ្ឋាភិបាលបានផ្តល់ដីសម្បទានសេដ្ឋកិច្ច ឲ្យក្រុមហ៊ុនច្រើនជាងគេ គឺមានចំនួនរហូតដល់ទៅ៤៣ទីតាំងដីសម្បទានសេដ្ឋកិច្ច។ បើទោះបីរាជរដ្ឋាភិបាលបានប្រកាសឈប់អាជ្ញាប័ណ្ណផ្តល់ដីសម្បទានសេដ្ឋកិច្ច ចាប់តាំងពីឆ្នាំ២០១២។ របាយការណ៍ក៏បានរកឃើញថា ក្នុងឆ្នាំ២០១៥ មានដីសម្បទានសេដ្ឋកិច្ចចំនួន១[34]ករណីផងដែរ ។[35] ស្ថាប័នដែលផ្តល់ដីសម្បទានសេដ្ឋកិច្ចច្រើនជាងគេ គឺក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទដែលបានផ្តល់ដីសម្បទានសេដ្ឋកិច្ចចំនួន

[32] "2014 Brings a New Wave of Cambodian Land Conflicts", Licadho-Cambodia *Statement Released*, April 2014. *See also*, http://www.rfa.org/english/news/cambodia/land-04012014170055.html; cited on October 07, 2014.
[33] *Ibid.*
[34] ក្រុមហ៊ុនសម្បទានសេដ្ឋកិច្ចដែលបានប្តូរឈ្មោះ ប៉ុន្តែអនុវត្តន៍គម្រោងការនៅកន្លែងដដែល ក្នុងនាមជាក្រុមហ៊ុនកាត់ដីសម្បទានសេដ្ឋនៅកម្ពុជាឆ្នាំ២០១៥
[35] របាយការណ៍ស្តីពីការវិភាគស្ថិតិដីសម្បទានសេដ្ឋនៅកម្ពុជាឆ្នាំ២០១៥, ទំព័រទី៨ និងទី៩

១៤។ ស្ថាប័នចំនួន៣ទៀត ដែលបានផ្តល់ដីសម្បទានសេដ្ឋកិច្ចរួមមាន៖ ក្រសួងបរិស្ថាន ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងគណៈកម្មាធិការខេត្ត។

ចាប់តាំងពីឆ្នាំ២០១៤ ដល់ឆ្នាំ២០១៦ រាជរដ្ឋាភិបាលបានដាក់ចេញនូវវិធានការត្រួតពិនិត្យ និងវិនិច្ឆ័យឡើងវិញនូវលក្ខខណ្ឌ និងរយៈពេលផ្តល់ដីសម្បទានសេដ្ឋកិច្ចឲ្យក្រុមហ៊ុនទាំងនោះ។ រាជរដ្ឋាភិបាលបានសម្រេចជាគោលការណ៍ ក្នុងការកាត់បន្ថយរយៈពេលនៃការអនុវត្តន៍គម្រោងវិនិយោគ អភិវឌ្ឍន៍សម្បទានដីសេដ្ឋកិច្ចទាំងអស់ នៅត្រឹមយ៉ាងយូរ៥០ឆ្នាំ។ ដើមឆ្នាំ២០១៦ រាជរដ្ឋាភិបាលបានប្រកាសថា ការត្រួតពិនិត្យ និងវិនិច្ឆ័យដីសម្បទានត្រូវបានបញ្ចប់ ហើយសន្យាថា ផ្ទៃដីប្រមាណជិត១លានហិកតា នឹងត្រូវបានប្រើប្រាស់ជាដីសម្បទានសង្គមកិច្ច ដើម្បីផ្តល់ជូនគ្រួសារក្រីក្រ។ លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានលើកឡើងថា ត្រួតពិនិត្យ និងវិនិច្ឆ័យឡើងវិញនូវលក្ខខណ្ឌ និងរយៈពេលផ្តល់ដីសម្បទានសេដ្ឋកិច្ចបានបញ្ចប់ជាមួយទំហំផ្ទៃដី១ ០៩០០០០ ហិកតាដែលត្រូវបាន អនុញ្ញាតឲ្យបន្តអនុវត្តគម្រោងសម្បទានសេដ្ឋកិច្ច ខណៈដែលផ្ទៃដីប្រមាណជិត១លានហិកតា ត្រូវបានដកហូតយកមកវិញ ដើម្បីចែកជូនគ្រួសារប្រជាពលរដ្ឋក្រីក្រដែលមានផ្ទៃដីតិចតួច ឬគ្មានផលទាល់តែសោះ។[36]

សេចក្តីសន្និដ្ឋានយើងសង្កេតឃើញថា ការបញ្ឈប់ការផ្តល់សម្បទានសេដ្ឋកិច្ចទៅឲ្យក្រុមហ៊ុន គឺរដ្ឋាភិបាលសម្រេចធ្វើបាន ប៉ុន្តែមានការសង្ស័យអំពីការផ្តល់ដីសម្បទានសេដ្ឋកិច្ចមួយកន្លែងនៅឆ្នាំ២០១៥ នេះបើយោងលើរបាយការណ៍ស្រាវជ្រាវចុងក្រោយ។

០៧. សម្រេចឲ្យបាន១០០% នូវការចុះបញ្ជីដីតាមផែនការនៃបទបញ្ជាលេខ០១ របស់រាជរដ្ឋាភិបាលជិត២លានហិចតា នៅរវាងដើមឆ្នាំ២០១៤ ក្នុងក្របខណ្ឌនៃការអនុវត្តន៍ «នយោបាយចាស់ សកម្មភាពថ្មីលើវិស័យដីធ្លី» និងសម្រេចឲ្យបាន៧០% ដល់ឆ្នាំ២០១៨ លើបរិមាណក្បាលដីដែលត្រូវចុះបញ្ជីសរុប៦ ទៅ៧លានក្បាលដីនៅទូទាំងប្រទេស។[37]

[36] https://www.cambodiadaily.com/news/pm-pledges-1m-hectares-of-elc-land-to-poor-109007/

[37] *Supra* note 10, at 23.

ខែវិច្ឆិកា ឆ្នាំ២០១៤នេះ ក្នុងសិក្ខាសាលាអន្តរជាតិលើកទី៦ ស្តីពីគោលនយោបាយដីធ្លីទូលំទូលាយ មូលដ្ឋានគ្រឹះក្នុងការអភិវឌ្ឍន៍ទីក្រុង និងជនបទប្រកបដោយចីរភាព អតីតរដ្ឋមន្ត្រីក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់បានឲ្យដឹងថា រដ្ឋាភិបាលបានចេញប័ណ្ណកម្មសិទ្ធិជាង ៣,៧លានប័ណ្ណជូនប្រជាពលរដ្ឋ ដែលស្មើនឹងប្រមាណ៥០% នៃក្បាលដីទូទាំងប្រទេស និងមានផែនការចុះបញ្ជីដីឲ្យបានចំនួន៧០ភាគរយ ក្នុងឆ្នាំ២០១៨ និងឲ្យបាន១០០ភាគរយក្នុងឆ្នាំ២០២៣។[38]

ខែកញ្ញា ឆ្នាំ២០១៥ ក្នុងសវនាការ រវាងប្រធានគណៈកម្មការទី១នៃរដ្ឋសភា លោករដ្ឋមន្ត្រីរូបនេះបានអះអាងថា គិតត្រឹមឆ្នាំ២០១៥នេះ ក្រសួងបានចែកប័ណ្ណកម្មសិទ្ធិដីធ្លីឲ្យប្រជាជនទូទាំងប្រទេសចំនួន៤លានប័ណ្ណ ស្មើនឹង៥៧%។

របាយការណ៍បូកសរុបការងារឆ្នាំ២០១៥ របស់ក្រសួងរៀបចំដែនដី នគរនីយកម្ម និងសំណង់ ចេញផ្សាយឆ្នាំ២០១៦ បានឲ្យដឹងថា ប័ណ្ណកម្មសិទ្ធិសរុបចំនួន៦១៩១៤០ប័ណ្ណ ត្រូវបានចែកជូនប្រជាពលរដ្ឋ តាម រយៈការអនុវត្តន៍បទបញ្ជាលេខ០១នៃវិស័យដីធ្លី។ របាយការណ៍បានបង្ហាញទៀតថា តាមរយៈការអនុវត្តន៍កម្មវិធីអនុវិស័យ រដ្ឋបាលដីធ្លីតាំងពីឆ្នាំ២០០២ ក្បាលដីចំនួន៣.៥៩៤.១៤០ ត្រូវបានចុះបញ្ជី និងចែកប័ណ្ណកម្មសិទ្ធជូនប្រជាពលរដ្ឋបានចំនួន២ ៩១៦៦៣២ប័ណ្ណ។

របាយការណ៍បូកសរុបលទ្ធផលការងារឆ្នាំ២០១៦បានឲ្យដឹងថា គិតដល់ចុងឆ្នាំ២០១៦ ប័ណ្ណកម្មសិទ្ធិចំនួន៤.៤៥១.៨១៧ក្បាលដី ត្រូវបានចែកជូនប្រជាពរដ្ឋ ដែលចំនួននេះស្មើនឹង៦៣,៦%នៃក្បាលដីប៉ាន់ស្មានសរុប៧លានក្បាលដី។

យោងតាមទិន្នន័យរបាយការណ៍ខាងលើ រាជរដ្ឋាភិបាលសម្រេចបានខ្លះនូវផែនការចុះបញ្ជីដីសម្រេចឲ្យបាន៧០% ដល់ឆ្នាំ២០១៨ លើបរិមាណក្បាលដីដែលត្រូវចុះបញ្ជីសរុបពី៦ ទៅ៧លានក្បាលដីនៅទូទាំងប្រទេស។ យោងតាមសន្ទស្សន៍នៃការកើនឡើង ក្នុងការអនុវត្តន៍ក្នុងរយៈពេលបីឆ្នាំកន្លងមកនេះ ប្រសិនបើគ្មានការប្រែប្រួលទេនោះ រាជរដ្ឋាភិបាលនឹងសម្រេចបានតាមផែនការរបស់ខ្លួនក្នុងឆ្នាំ២០១៨ជាមិនខាន។

០៨. កសាងគោលនយោបាយជាតិ ស្តីពីសិទ្ធិលំនៅស្ថាន ដើម្បីដោះស្រាយលំនៅស្ថានជូនប្រជាពលរដ្ឋក្រីក្រ សម្រាប់ការរស់នៅប្រកបដោយសុវត្ថិភាព សុខុមាលភាព និងភាពថ្លៃថ្នូរ។[39]

តាមទិន្នន័យជំរឿនប្រជាពលរដ្ឋឆ្នាំ២០០៨ កម្ពុជានឹងមានប្រជាជនប្រមាណ១៨លាននាក់ នៅឆ្នាំ២០៣០ គឺអាចកើនប្រមាណ៣ ឬ៤លាននាក់បន្ថែមទៀត ហើយកំណើននេះភាគច្រើនកើនឡើងនៅតាមទី

[38] Lay Samean, *Ministry of Land Management and Urban Planning and Construction plans to complete 100% of Land Registration by 2023*, VOD News, 12 November 2014
[39] *Supra* note 10, at 24.

ប្រជុំជនធំៗដែលមានសក្តានុពលវិស័យសេដ្ឋកិច្ច។ ការធ្វើជំរឿននេះ ក៏បានបង្ហាញផងដែរនូវនិន្នាការនៃការថយចុះទំហំគ្រួសារដែលអាចប៉ាន់ប្រមាណថា រហូតដល់ឆ្នាំ២០៣០ កម្ពុជាអាចត្រូវការលំនៅដ្ឋានថ្មីប្រមាណ ១,១លានបន្ថែមទៀត ដោយមិនរាប់បញ្ចូលលំនៅដ្ឋានបច្ចុប្បន្ន។[40]

កាលពីចុងឆ្នាំ២០១៤ គោលនយោបាយជាតិ ស្តីពីសិទ្ធិលំនៅដ្ឋានត្រូវបានអនុម័ត ក្រោយពីគណៈរដ្ឋមន្ត្រីនៃរាជរដ្ឋាភិបាលកម្ពុជានីតិកាលទី៥យកមកប្រជុំសម្រេច។ យោងតាមការអះអាងរបស់ក្រសួង យើងអាចសន្និដ្ឋានបានថា គោលនយោបាយជាតិនេះមានគោលបំណងផ្តល់លទ្ធភាព និងមធ្យោបាយដល់ប្រជាពលរដ្ឋទូទៅនូវការទទួលបានលំនៅដ្ឋាន សមរម្យ ឬការជួសជុសកែលំនៅដ្ឋានដោយយកចិត្តទុកដាក់ ជាពិសេសដល់ក្រុមគ្រួសារដែលមានប្រាក់ចំណូលមធ្យម និងទាប និងក្រុមជនងាយរងគ្រោះ ឬរស់នៅបណ្តោះអាសន្ន មិនរៀបរយ តាមរយៈការសហការជាមួយដៃគូអភិវឌ្ឍន៍ សង្គមស៊ីវិល និងសប្បុរសជន។

នៅខែសីហាឆ្នាំ២០១៥នេះ ច្បាប់ស្តីពីភតិសន្យាពិសេសត្រូវបានដាក់ឲ្យប្រើប្រាស់ ដើម្បីជួយសំរួលដល់ការលំបាករបស់ប្រជាពលរដ្ឋពាក់ព័ន្ធនឹងការជួលផ្ទះសំបែង។ ច្បាប់នេះក៏ជាឧបករណ៍គតិយុត្តមួយដែលផ្តល់នូវកាលានុវត្តភាព ជួយជម្រុញដល់ការអនុវត្តន៍គោលនយោបាយជាតិ ស្តីពីលំនៅដ្ឋាន និងរួមចំណែកទាក់ទាញការវិនិយោគពីវិស័យឯកជន ក្នុងការសាងសង់បន្ទប់ជួលមានតំលៃឈ្នួលសមរម្យ ដែលជាយន្តការឆ្លើយតបនឹងគោលនយោបាយជាតិ ស្តីពីសិទ្ធិលំនៅស្ថានដែលផ្តោតលើ ទី១ៈប្រជាពលរដ្ឋដែលមានប្រាក់ចំណូលមធ្យម ទី២ៈប្រជាពលរដ្ឋក្រីក្រ និងទី៣ ប្រជាពលរដ្ឋដែលងាយរងគ្រោះ។ ប៉ុន្តែតាមការសង្កេតជាក់ស្តែងរហូតដល់ពេលបច្ចុប្បន្ន ច្បាប់នេះហាក់ដូចជាមិនទាន់ត្រូវបានគេយកទៅអនុវត្តជាទូទៅនោះទេ ពោលគឺការព្រមព្រៀងនៃកិច្ចសន្យាជួលផ្ទះជាការសម្រេចចិត្តរវាងភាគីអ្នកជួល និងម្ចាស់ផ្ទះ។

នៅឆ្នាំ២០១៥ រាជរដ្ឋាភិបាលកម្ពុជាតាមរយៈក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់បាន និងកំពុងរៀបចំយន្តការ និងគោលនយោបាយសាងសង់លំនៅឋានសម្រាប់ជួល និងលក់ជូនប្រជាជនក្រីក្រ និងមានប្រាក់ចំណូលមធ្យមនៅកម្ពុជា។

ក្នុងឆ្នាំ២០១៦នេះ ក្រសួងគ្រប់គ្រងដែនដី និងនគរូបនីយកម្មបាន និងកំពុងរៀបចំអនុវត្តគម្រោងសាកល្បងនៃការសាងសង់ផ្ទះសម្រាប់ប្រជាពលរដ្ឋក្រីក្រ ឬមានប្រាក់ចំណូលមធ្យម។ គម្រោងសំណង់លំនៅឋាននេះ ជាគម្រោងវិនិយោគក្នុងតម្លៃប្រមាណ១០០លានដុល្លារ របស់ក្រុមហ៊ុន WorldBridge International ផ្ទះល្វែងក្នុងគម្រោងរបស់រាជរដ្ឋាភិបាលនោះ នឹងមានតម្លៃចាប់ពី ២៥០០០ ដុល្លារ ទៅ ៣០០០០ ដុល្លារ ក្នុងផ្ទះ ១ល្វែង។ អ្នកជំនាញអចលនទ្រព្យនិយាយថា គម្រោងនេះនឹងជួយសម្រួលប្រជាពលរដ្ឋមានប្រាក់ចំណូលមធ្យម និងទាប និងមន្ត្រីរាជការដើម្បីមានលទ្ធភាពទិញផ្ទះ និងធ្វើឲ្យជីវភាពកាន់តែប្រសើរ។ បើទោះបីជាគម្រោងបាន និងកំពុងដំណើរកំណើរសាងសង់ក៏ដោយ តម្លាភាពនៃនីតិវិធីក្នុងការស្នើសុំរបស់មន្ត្រីរាជការ ឬប្រជាពលរដ្ឋក្រីក្រ ឬមធ្យមដើម្បីទិញផ្ទះនោះ នៅតែជាបញ្ហាដែលគួរយកចិត្តទុកដាក់។

ការសន្និដ្ឋាន រាជរដ្ឋាភិបាលសម្រេចបានការកសាងគោលនយោបាយជាតិ ស្តីពីលំនៅដ្ឋាន ប៉ុន្តែយើងមិនទាន់ដឹងថា ប្រជាពលរដ្ឋក្រីក្រ ជាពិសេសជនងាយរងគ្រោះពីការបណ្តេញចេញដោយបង្ខំនឹងទទួលបានផលប្រយោជន៍ពីគោលនយោបាយនោះក្នុងកម្រិតណានោះទេ។

[40] May Titthara, *Million-home dilemma* , The Phnom Penh Post, 12 May, 2014.

០៩. កែលម្អផ្លូវលំជនបទជាជំហានៗ ពីផ្លូវក្រាលគ្រួសក្រហម ទៅជាផ្លូវក្រាលកៅស៊ូ ឬផ្លូវបេតុងឲ្យបានពី ៣០០ ទៅ៤០០គីឡូម៉ែត្រក្នុង១ឆ្នាំ តាមស្តង់ដារឯកភាពជាតិមួយ។

ក្នុងវិស័យកែលម្អផ្លូវលំជនបទ រាជរដ្ឋាភិបាលដែលមានក្រសួងអភិវឌ្ឍន៍ជនបទបានអនុវត្តគម្រោងកែលំអជួសជុល និងស្ថាបនាផ្លូវជនបទ(Rural Road Improvement Project-RRIP) ដែលមានរយៈពេល៥ឆ្នាំ (ឆ្នាំ២០១១ ដល់ឆ្នាំ២០១៦)។ ទន្ទឹមនឹងនេះដែរ រាជរដ្ឋាភិបាលកម្ពុជាបានចាប់ផ្តើមអនុវត្តគំរោងកែលម្អផ្លូវជនបទជំហានទី២ (Rural Road Improvement Project-RRIP2) ដែលមានរយៈពេល៦ឆ្នាំ គឺគិតតាំងពីឆ្នាំ ២០១៥ ដល់ឆ្នាំ២០២០ ហើយគម្រោងនេះគ្រោងនឹងចំណាយថវិកាសរុបចំនួន១៩២,៧១លានដុល្លារអាមេរិក ដែលជាថវិការបស់រាជរដ្ឋាភិបាលប្រមាណ០៩% និងជំនួយរបស់ដៃគូអភិវឌ្ឍន៍ ព្រមទាំងស្ថាប័នផ្សេងៗដូចជា៖ ធនាគារអភិវឌ្ឍន៍អាស៊ី ឥណទានរបស់សាធារណរដ្ឋកូរ៉េ សាធារណរដ្ឋបារាំង តាមរយៈទីភ្នាក់ងារអភិវឌ្ឍន៍បារាំង(AFD) គម្រោងសាកល្បងភាពធន់នឹងបម្រែបម្រួលអាកាសធាតុ (PPCR) ជំនួយឥតសំណងរបស់រាជ រដ្ឋាភិបាលអូស្ត្រាលី និងជំនួយឥតសំណងរបស់មូលនិធិអភិវឌ្ឍន៍ណ័រឌិក។

ក្នុងឆ្នាំ២០១៤ ក្រសួងអភិវឌ្ឍន៍ជនបទបានអនុវត្តគម្រោងសាងសង់ផ្លូវដែលជាហិរញ្ញប្បទាន រវាងធនាគារអភិវឌ្ឍន៍អាស៊ី និងរដ្ឋាភិបាលកម្ពុជា ហើយសម្រេចបានប្រវែង៥០៥,៧០គីឡូម៉ែត្រ និងនៅសល់តិចតួចកំពុងអនុវត្ត ដើម្បីបញ្ចប់ដោយចំណាយថវិកាអស់ប្រមាណជាង២៤លានដុល្លារសហរដ្ឋអាមេរិក។[41] របាយការណ៍វឌ្ឍនភាពការងារប្រចាំខែវិច្ឆិកា ឆ្នាំ២០១៥ របស់ក្រសួងអភិវឌ្ឍន៍ជនបទ ក៏ដូចជារបាយការណ៍របស់នាយកដ្ឋានផ្លូវលំជនបទបានឲ្យដឹងថា ក្នុងរយៈពេល១១ខែ ឆ្នាំ២០១៥នេះ ដោយអនុវត្តគម្រោងកែលម្អផ្លូវជនបទ (Rural Road Improvement Project-RRIP) ផ្លូវលំជនបទប្រវែង១៧,៩គីឡូម៉ែត ត្រូវបានក្រាលកៅស៊ូ និងប្រវែង២,៦គីឡូម៉ែត្រត្រូវបានចាក់បេតុង ខណៈពេលដែលផ្លូវក្រាលគ្រួសក្រហមមានប្រវែង ប្រមាណ ៦៤៤គីឡូម៉ែត្រ។

យោងតាមសេចក្តីប្រកាសព័ត៌មានរបស់ក្រសួងអភិវឌ្ឍន៍ជនបទ គិតដល់ដើមឆ្នាំ២០១៦ ត្រឹមខែកុម្ភៈ ផ្លូវជនបទចំនួន៥៣ខ្សែ ស្មើនឹង២១១,៣៧៩គីឡូមែត្រ ត្រូវបានស្រង់ចូលទិន្នន័យ។ ទន្ទឹមនឹងនេះ គេបានធ្វើបច្ចុប្បន្នភាពទិន្នន័យផ្លូវជនបទបានចំនួន១២៨ខ្សែ ស្មើនឹង៧០៧,៥៧៨គ.ម។ ដោយឡែក ក្នុងឆ្នាំ២០១៦នេះ ក្រសួងអភិវឌ្ឍន៍ជនបទ មានផែនការចុះស្រង់ទិន្នន័យផ្លូវជនបទថ្មីៗបន្ថែមទៀតចំនួន៧៣០ខ្សែ ស្មើនឹង ១.៣៩៥ គ.ម។[42]

យោងរបាយការណ៍របស់ក្រសួងអភិវឌ្ឍន៍ជនបទ ជាលទ្ធផលពីឆ្នាំ២០១៣ ដល់ឆ្នាំ២០១៦ ក្រសួងបានសម្រេចនូវការកែលម្អផ្លូវជនបទប្រវែង១១៩២,៣គីឡូម៉ែត្រ ក្នុងនោះក្រាលកៅស៊ូពីរជាន់ (DBST) បានប្រវែង៥៨២,៧៨គីឡូម៉ែត្រ ក្រាលកៅស៊ូមួយជាន់ (SBST) បានប្រវែង៥៤៤,១១ គីឡូម៉ែត្រ និងក្រាលបេតុងបានប្រវែង៦៥,៤១ គីឡូម៉ែត្រ។

---

[41] *របាយការណ៍ប្រចាំខែធ្នូ ឆ្នាំ២០១៤ របស់គម្រោងកែលម្អផ្លូវជនបទ* ក្រសួងអភិវឌ្ឍន៍ជនបទ រាជរដ្ឋាភិបាលកម្ពុជាទំព័រ១។

[42] https://goo.gl/6EwDws

ក្នុងឆ្នាំ២០១៦នេះ គេឃើញមានការចាប់ផ្តើមអនុវត្តគម្រោងកែលម្អផ្លូវ គម្រោងកែលម្អផ្លូវជនបទជំហាន២ ដើម្បីកែលម្អផ្លូវជនបទ ពីក្រាលក្រួសក្រហម ទៅក្រាលកៅស៊ូ។ ខែវិច្ឆិកា ឆ្នាំ២០១៦ រដ្ឋាភិបាលបានបើកការដ្ឋានស្ថាបនាផ្លូវជនបទក្រាលកៅស៊ូ និងចាក់បេតុងប្រវែង១.២០០គីឡូម៉ែត្រ នៅក្នុងខេត្តចំនួន១០រួមមាន ៖ ខេត្តកំពង់ចាម ត្បូងឃ្មុំ សៀមរាប ពោធិ៍សាត់ បាត់ដំបង បន្ទាយមានជ័យ កំពង់ឆ្នាំង កំពង់ស្ពឺ កំពង់ធំ និងខេត្តតាកែវ។ របាយការណ៍នៅក្នុងទំព័រហ្វេសប៊ុក (Facebook)

Cambodia: Inauguration of Rural Roads Improvement Project and Ground Breaking of Rural Roads Improvement Project II
Source: ADB

លោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បង្ហាញថា គម្រោងសាងសង់ផ្លូវជនបទក្រាលកៅស៊ូ២ជាន់ និងចាក់បេតុងនេះ ចំណាយថវិកាសរុបជាង១៩២លាន (១៩២.៧១០.០០០) ដុល្លារអាមេរិក ក្នុងនោះថវិការបស់ រដ្ឋាភិបាលកម្ពុជា ជាង១៧លាន (១៧.៧៩០.០០០) ដុល្លារអាមេរិក។

សេចក្តីសន្និដ្ឋាន រាជរដ្ឋាភិបាលកម្ពុជាសម្រេចមិនបាននូវគោលនយោបាយរបស់ខ្លួន ដែលបានសន្យាថា កែលម្អផ្លូវលំជនបទជាជំហានៗ ពីផ្លូវក្រាលក្រួសក្រហម ទៅជាផ្លូវក្រាលកៅស៊ូ ឬផ្លូវបេតុងឲ្យបានពី៣០០ ទៅ៤០០គីឡូម៉ែត្រក្នុង១ឆ្នាំ តាមស្តង់ដារឯកភាពជាតិមួយ។

១០. រៀបចំគោលនយោបាយដឹកជញ្ជូនទីក្រុង ជាពិសេសរាជធានីភ្នំពេញសម្រាប់រយៈពេលមធ្យម និងរយៈពេលវែង ដើម្បីពង្រីកហេដ្ឋារចនាសម្ព័ន្ធ កសាងមធ្យោបាយដឹកជញ្ជូន ដើម្បីរួមជាប្រយោជន៍ សម្រាប់ដោះស្រាយបញ្ហាការកកស្ទះចរាចរណ៍ និងពង្រឹងសណ្តាប់ធ្នាប់ចរាចរណ៍ទីក្រុង។[43]

សម្រាប់វិស័យដឹកជញ្ជូន នៅរាជធានីភ្នំពេញបច្ចុប្បន្ននេះ រដ្ឋាភិបាលកំពុងយកចិត្តទុកដាក់ ដាក់ឲ្យដំណើរការសេវាកម្មដឹកជញ្ជូនសាធារណៈ ដើម្បីបញ្ចៀសការកកស្ទះចរាចរណ៍ធ្ងន់ធ្ងរ ជាពិសេសពេលព្រឹក និងពេលល្ងាច។ រហូតមកដល់ពេលនេះ រដ្ឋាភិបាលកម្ពុជាមិនទាន់មានគោលនយោបាយដាក់ឲ្យដំណើរការមធ្យោបាយដឹកជញ្ជូនសាធារណៈ ភ្ជាប់ពីរាជធានីភ្នំពេញទៅកាន់ខេត្តផ្សេងៗនៅឡើយទេ។ មធ្យោបាយដឹកជញ្ជូនរដ្ឋ គឺនៅមានកំរិតខ្សោយខ្លាំង បើធៀបជាមួយប្រទេសមួយចំនួនធំនៅក្នុងតំបន់អាស៊ាន។

ឆ្នាំ២០១៤ គឺឆ្នាំដំបូងបំផុត ដែលរដ្ឋាភិបាលបានចាប់ផ្តើមដាក់ឲ្យដំណើរការមធ្យោបាយដឹកជញ្ជូនសាធារណៈនៅរាជធានីភ្នំពេញ ដោយមានជំនួយបច្ចេកទេស សម្ភារៈ និងថវិកាពីរដ្ឋាភិបាលនៃប្រទេសជប៉ុន។

គិតត្រឹមឆ្នាំ២០១៥ រថយន្តក្រុងសាធារណៈចំនួន៧៤គ្រឿង ត្រូវបានដាក់ពង្រាយដំណើរលើផ្លូវ០៣ខ្សែ ដើម្បីដឹកជញ្ជូនសាធារណជននៅតាមបណ្តាមហាវិថីធំៗ។

ក្នុងឆ្នាំ២០១៥នេះ សាលារាជធានីភ្នំពេញគ្រោងនឹងពង្រីកជើងធ្វើដំណើរនៃសេវាកម្មនេះ ដោយបាន

[43] *Supra* note 10, at 27.

និងកំពុងសហការជាមួយអង្គការJICA ដើម្បីរៀបចំនីតិវិធីស្នើសុំរថយន្តក្រុងថ្មីចំនួន១៤០គ្រឿងពីប្រទេសជប៉ុន និង១០០គ្រឿងពីប្រទេសចិន។[44]

ក្នុងឆ្នាំ២០១៦ តាមរយៈបានផ្តល់រថយន្តក្រុងចំនួន៥០ គ្រឿងក្នុងជំហានដំបូងដល់កម្ពុជាដោយទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA) សាលារាជធានីភ្នំពេញបានមានផែនការពង្រីកខ្សែរត់រថយន្តក្រុង៥ខ្សែបន្ថែមទៀត នៅពេលទទួលបានរថយន្តទាំងនោះ នៅឆ្នាំ២០១៧ ដើម្បីសម្រួលការកកស្ទះចរាចរណ៍ និងបង្កើនកំណើនអ្នកធ្វើដំណើរក្នុងរាជធានីភ្នំពេញ។

រាជធានីភ្នំពេញបច្ចុប្បន្ន មានខ្សែរថយន្តក្រុងចំនួន៣ខ្សែ ដែលមានរថយន្តសរុប៥៧គ្រឿង ដែលគិតត្រឹមរយៈពេល១១ខែ ដើមឆ្នាំ២០១៦ មានអ្នកដំណើរបានប្រើប្រាស់ជិត២,២លានដង។[45] ក្នុងចំណោមនោះជនពិការ និងសិស្សានុសិស្សត្រូវអនុញ្ញាតឲ្យធ្វើដំណើរតាមរថយន្តក្រុងសាធារណៈដោយឥតគិតថ្លៃ។

ម្យ៉ាងវិញទៀត សាលារាជធានីភ្នំពេញគ្រោងនឹងពង្រីកចំនួន៥ខ្សែទៀត នៅក្នុងឆ្នាំ២០១៧ ហើយកើនរហូតដល់១០ខ្សែបន្ថែមទៀត ក្នុងឆ្នាំ២០២០។

សេចក្តីសន្និដ្ឋាន រាជរដ្ឋាភិបាលសម្រេចបានការរៀបចំគោលនយោបាយដឹកជញ្ជូនទីក្រុង ជាពិសេសសំរាប់រាជធានីភ្នំពេញ ព្រោះគេសង្កេតឃើញមានគម្រោងពង្រាយរថយន្តដឹកជញ្ជូនសាធារណៈបន្ថែមទៀតតាមបណ្តោយផ្លូវសំខាន់នៅក្នុងរាជធានីភ្នំពេញ។

១១. ដល់ឆ្នាំ២០១៨ ប្រជាពលរដ្ឋចំនួន៨៥% ដែលរស់នៅរាជធានីខេត្ត និងប្រជាពលរដ្ឋចំនួន៦០% ដែលរស់នៅតាមបណ្តាឃុំបានទទួលសេវាទឹកស្អាតដែលមានគុណភាពល្អ និងថ្លៃសមរម្យប្រើប្រាស់។[46]

យោងតាមសេចក្តីប្រកាសព័ត៌មានរបស់អង្គការ (UNICEF) ចេញផ្សាយនៅដើមឆ្នាំ២០១៤ បានឲ្យដឹងថា ប្រជាពលរដ្ឋកម្ពុជាប្រមាណ៦,៣លាននាក់ គឺស្មើនឹង៤២ភាគរយនៃប្រជាជនសរុប១៥លាននាក់ កំពុងខ្វះខាតទឹកស្អាតសម្រាប់ប្រើប្រាស់ ហើយចំនួនប្រជាជន៣,៩លាននាក់ ស្មើនឹង២៦%នៃចំនួន (៦,៣លាននាក់) ប្រជាពលរដ្ឋដែលខ្វះទឹកស្អាតបរិភោគ និងប្រើប្រាស់ គឺជាប្រជាពលរដ្ឋក្រីក្រ និងរស់នៅទីជនបទ។[47]

សិស្សសាលានៅខេត្តបាត់ដំបងលាងដៃជាមួយនឹងទឹកស្អាត។ រូបថត KUNO Shinichi/JICA

របាយការណ៍ របស់វេទិកាគំនិតផ្តួចផ្តើមចងក្រងបញ្ជីកំណែទម្រង់ (គ.ច.ប)បានបង្ហាញថា ក្នុងពេលបច្ចុប្បន្នការផ្គត់ផ្គង់ទឹកស្អាត នៅតំបន់ទីក្រុងនៃរាជធានីខេត្តសម្រេចបាន៨០% (កើនឡើងពី ៦២% កាលពីប្រាំឆ្នាំមុន)។ របាយការណ៍បានបន្ថែមទៀតថា គិតត្រឹមឆ្នាំ២០១៥ ស្ថាប័នផ្គត់ផ្គង់ទឹកសាធារណៈ មាននៅរាជ

[44] <u>គី សុខលីម</u> ,សាលារាជធានីភ្នំពេញស្នើសុំរថយន្តក្រុង១៥ (ចុះផ្សាយនៅថ្ងៃ 01-11-2015, 4:00 pm) http://www.thmeythmey.com/index.php?page=detail&ctype=article&id=32543&lg=kh

[45] http://wmc.org.kh/archives/37000

[46] *Supra* note 10, at 30.

[47] Denise Shepherd-Johnson, *World Water Day: 6.3 million Cambodians lack access to safe water*, Press Release, UNICEF, (21 March 2014), at 1

ធានីភ្នំពេញ និងនៅតាមបណ្តាទីរួមខេត្តចំនួន៨ រួមមាន បាត់ដំបង កំពង់ចាម កំពង់ធំ កំពត ពោធិ៍សាត់ ស្វាយរៀង ព្រះសីហនុ និងសៀមរាប។[48]

លិខិតលេខ ១៤៩១/១៦ របស់ក្រសួងអភិវឌ្ឍន៍ជនបទបានឲ្យដឹងថា គិតពីឆ្នាំ២០១៣ ដល់ឆ្នាំ២០១៦ ក្រសួងសម្រេចបានការផ្គត់ផ្គង់ទឹកស្អាតដូចខាងក្រោម៖

-សាងសង់អណ្តូងលូថ្មី	បានចំនួន ១៩៩	និងជួសជុលអណ្តូងលូ	បានចំនួន ៩៨៣ អណ្តូង
-សាងសង់អណ្តូងស្នប់ថ្មី	បានចំនួន ៤៨៧៤	និងជួសជុលអណ្តូងលូ	បានចំនួន ៤៩៩៨ អណ្តូង
-សាងសង់អណ្តូងចម្រុះថ្មី	បានចំនួន ៦១	និងជួសជុលអណ្តូងលូ	បានចំនួន ៤៨៩ អណ្តូង
-សាងសង់ស្រះសហគមន៍	បានចំនួន ៣៩	និងស្តារស្រះទឹក	បានចំនួន ១២៩ ស្រះ
-សាងសង់ពាងទឹក			បានចំនួន ៨០ ២៨២
- សាងសង់អាងត្រងទឹកភ្លៀង			បានចំនួន ១៧៦។

សេចក្តីសន្និដ្ឋាន រដ្ឋាភិបាលបានសម្រេចខ្លះនូវការសន្យាថា «ដល់ឆ្នាំ២០១៨ ប្រជាជនចំនួន៨៥% រស់នៅរាជធានី/ខេត្ត និងប្រជាពលរដ្ឋចំនួន៦០ភាគរយ ដែលរស់នៅតាមបណ្តាឃុំ នឹងទទួលបានទឹកស្អាតដែលមានគុណភាពល្អ និងតំលៃសមរម្យសម្រាប់ប្រើប្រាស់» សម្រេចបានខ្លះ។

១២. ពីឆ្នាំ២០១៣ ដល់២០១៨ គឺពង្រីកការផ្គត់ផ្គង់អគ្គិសនីពីបណ្តាញជាតិឲ្យដល់ភូមិចំនួន៨០% នៃចំនួនភូមិទាំងអស់។[49]

រហូតមកត្រឹមឆ្នាំ២០១៣ មានប្រជាជនប្រមាណត្រឹមតែ៨% នៃប្រជាជនសរុបប្រមាណ១៥លាននាក់ ដែលបានប្រើប្រាស់ថាមពលអគ្គិសនី។ ក្នុងចំណោមអ្នកប្រើប្រាស់ថាមពលអគ្គិសនី ៥៤ភាគរយនៅទីប្រជុំជន និង១៣ភាគរយនៅតំបន់ជនបទ។[50] ការផ្គត់ផ្គង់អគ្គិសនីសរុបនៅកម្ពុជាក្នុងឆ្នាំ២០១៣ មានចំនួន៤លានគីឡូវ៉ាត់ម៉ោង។

	២០០៦	២០០៧	២០០៨	២០០៩	២០១០
ចំនួនអ្នកប្រើប្រាស់	358,270	415,141	487,426	552,521	672,709
កំណើន%ធៀបឆ្នាំចាស់	17.01	15.87	17.41	13.35	21.75
ថាមពលផ្គត់ផ្គង់, លាន kWh	1,203.199	1,516.730	1,858.364	2,076.990	2,514.80
កំណើន%ធៀបឆ្នាំចាស់	23.12	23.12	22.52	11.76	21.12
ថាមពលលក់, លាន kWh	1,057.158	1,057.158	1,664.395	1,853.495	2,254.039
កំណើន%ធៀបឆ្នាំចាស់	**23.16**	**23.16**	**23.37**	**11.36**	**21.61**
	២០១១	២០១២	២០១៣	២០១៤	២០១៥
ចំនួនអ្នកប្រើប្រាស់	810,984	992,597	1,198,844	1,424,735	1,859,204
កំណើន%ធៀបឆ្នាំចាស់	20.55	22.39	20.78	18.84	30.49
ថាមពលផ្គត់ផ្គង់, លាន kWh	2,848.326	3,527.42	4,051.59	4,861.41	6,015.35
កំណើន%ធៀបឆ្នាំចាស់	13.26	23.84	14.86	19.99	23.74
ថាមពលលក់, លាន kWh	2,572.737	3,265.81	3,552.59	4,144.12	5,205.34
កំណើន%ធៀបឆ្នាំចាស់	**14.14**	**26.94**	**8.78**	**16.65**	**25.61**

ទិន្នន័យអ្នកប្រើប្រាស់ថាមពលអគ្គសនី និងថាមពលអគ្គិសនីដែលបានលក់ (ប្រភព៖ របាយការណ៍វិស័យអគ្គិសនីឆ្នាំ២០១៥)

តាមការស្រាវជ្រាវរបស់ធនាគារអភិវឌ្ឍន៍អាស៊ី មកត្រឹមឆ្នាំ២០១៣នេះ កម្ពុជាអាចមានសក្តានុពលផលិតថាមពលអគ្គិសនីដែលដើរដោយកំលាំងវារីអគ្គិសនីបាន រហូតដល់ទៅ១០.០០០មេកាវ៉ាត់ ប៉ុន្តែបច្ចុប្បន្ននេះ កម្ពុជាអាចមានលទ្ធភាពទាញយកផលពីសក្តានុពលដ៏ធំនេះបានត្រឹមតែ២២,៥៧ មេកាវ៉ាត់ប៉ុណ្ណោះ ដើម្បីយកមកប្រើប្រាស់។ បើយោងតាមការសិក្សាស្រាវជ្រាវដដែលនេះបានឲ្យដឹងដែរថា កម្ពុជានឹងមានកំណើនថាមពលអគ្គិសនី ដែលបានពីគម្រោងទំនប់វារីអគ្គិសនីចំនួន២៨.៩% ក្នុងរវាងឆ្នាំ២០១០ ដល់ឆ្នាំ២០៣៥។

[48] https://goo.gl/gIsnvz
[49] *Supra* note 10, at 31.
[50] Cambodia Investment Guidebook, CDC, 2013, P. IV-2; http://www.cambodiainvestment.gov.kh/#fragment-3-tab, accessed on 25 November 2014.

លោកនាយករដ្ឋមន្ត្រីកម្ពុជានៅដើមឆ្នាំ២០១៤ នេះបានអះអាងបញ្ជាក់ថា នៅឆ្នាំ២០២០ កម្ពុជានឹងមានបណ្តាញអគ្គិសនីតភ្ជាប់ទៅគ្រប់ភូមិនៃប្រទេសកម្ពុជាទាំងមូល ហើយឆ្នាំ២០៣០ គ្រប់ផ្ទះទាំងអស់ទូទាំងប្រទេសនឹងមានថាមពលអគ្គិសនីប្រើប្រាស់។[51]

របាយការណ៍វិស័យអគ្គិសនីនៃព្រះរាជាណាចក្រកម្ពុជា របស់អាជ្ញាធរអគ្គិសនីកម្ពុជាចេញផ្សាយឆ្នាំ២០១៦ បានឲ្យដឹងថា គម្រោងផលិតអគ្គិសនីកំពុងសាងសង់គិតត្រឹមចុងឆ្នាំ២០១៥ មានចំនួន០៦ ដូចជា៖ គម្រោងសាងសង់១.ស្ថានីយវារីអគ្គីសនីស្ទឹងតាតៃ ២.រោងចក្រអគ្គិសនីដុតធ្យូងថ្មនៅខេត្តព្រះសីហនុ មានចំនួនពីរគម្រោង ៣.ស្ថានីយវារីអគ្គិសនីសេសាន ៤.ស្ថានីយវារីអគ្គិសនី ស្ទឹងជាយអារ៉ែង និង ៥.ស្ថានីយវារីអគ្គិសនីព្រៃកណ្ណាង។ របាយការណ៍បានបន្ថែមថា កម្ពុជាបានទិញអគ្គិសនីពីប្រទេសថៃ ប្រទេសវៀតណាម និងប្រទេសឡាវ។ គិតត្រឹមចុងឆ្នាំ២០១៥ គម្រោងសាងសង់ខ្សែបញ្ជូនតង់ស្យុងខ្ពស់កំពុងបន្តការសាងសង់មានដូចជា៖ ខ្សែបញ្ជូន ១.ពីខេត្តកំពង់ចាម ទៅខេត្តក្រចេះ ២.ពីខេត្តក្រចេះ ទៅខេត្តស្ទឹងត្រែង ៣.ពីអនុស្ថានីយ៍ស្ទឹងហាវ ទៅរាជធានីភ្នំពេញ និង៤.ពីអនុស្ថានីយ៧ (តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ) ទៅអនុស្ថានីយព្រៃវែង និងបាវិត។ គម្រោងសាងសង់ខ្សែបញ្ជូនទាំងអស់នេះគ្រោងនឹងបញ្ចប់រួចរាល់ និងដាក់ឲ្យដំណើរការនៅឆ្នាំ២០១៧។ ក្រៅពីខ្សែបញ្ជូនតង់ស្យុងខ្ពស់ ខ្សែបញ្ជូនតង់ស្យុងមធ្យមក៏ត្រូវបាន និងកំពុងអភិវឌ្ឍន៍នៅទីតាំងជាច្រើននៅក្នុងប្រទេសកម្ពុជា ដើម្បីផ្គត់ផ្គង់ថាមពលអគ្គិសនីដល់អ្នកកាន់អាជ្ញាប័ណ្ណ និងអ្នកប្រើប្រាស់។

បរិយាយ	ឯកតា	ទិន្នន័យឆ្នាំ២០១៤	ទិន្នន័យឆ្នាំ២០១៥	កំណើនថា %
ថាមពលផលិត	លាន គ.វ.ម	3,058.36	4,489.27	46.79
ថាមពលនាំចូលពីថៃ	លាន គ.វ.ម	523.56	307.39	(41.29)
ថាមពលនាំចូលពីវៀតណាម	លាន គ.វ.ម	1,265.72	1,200.39	(5.16)
ថាមពលនាំចូលពីឡាវ	លាន គ.វ.ម	13.77	18.31	32.96
ថាមពលនាំចូលសរុប	លាន គ.វ.ម	1,803.05	1,526.08	(15.36)
ថាមពលផ្គត់ផ្គង់សរុប	លាន គ.វ.ម	4,861.41	6,015.35	23.74
អានុភាពផលិតកម្ម	គ.វ	1,511,338	1,657,274	9.66
ចំនួនអតិថិជន	ចំនួន	1,424,735	1,859,204	30.49
ថាមពលលក់ឲ្យអ្នកប្រើប្រាស់	លាន គ.វ.ម	4,144.12	5,205.34	25.61
ការបាត់បង់មធ្យមជា %	ជាភាគរយ	14.75	13.47	

ទិន្នន័យសង្ខេបនៃវិស័យថាមពលអគ្គិសនីក្នុងប្រទេសកម្ពុជា (ប្រភព៖ របាយការណ៍វិស័យអគ្គិសនីកម្ពុជាឆ្នាំ២០១៥)

លេខកូដ	ឈ្មោះខេត្ត	ចំនួនភូមិសរុប	ចំនួនភូមិស្ថិតក្រោមការផ្គត់ផ្គង់អគ្គិសនី	គិតជាភាគរយ %
១	បន្ទាយមានជ័យ	661	518	78.37
២	បាត់ដំបង	799	639	79.97
៣	កំពង់ចាម	916	689	75.22
៤	កំពង់ឆ្នាំង	562	220	39.15
៥	កំពង់ស្ពឺ	1,358	913	67.23
៦	កំពង់ធំ	738	426	57.72
៧	កំពត	488	454	93.03
៨	កណ្តាល	912	869	95.29
៩	កោះកុង	117	52	44.44
១០	ក្រចេះ	250	109	43.60
១១	មណ្ឌលគីរី	90	20	22.22
១២	ភ្នំពេញ	900	863	95.88
១៣	ព្រះវិហារ	229	71	31.00
១៤	ព្រៃវែង	1,137	729	64.12
១៥	ពោធិ៍សាត់	501	449	89.62
១៦	រតនៈគីរី	240	50	20.83
១៧	សៀមរាប	924	564	61.04
១៨	ព្រះសីហនុ	111	101	90.99
១៩	ស្ទឹងត្រែង	128	34	26.56
២០	ស្វាយរៀង	690	183	26.52
២១	តាកែវ	1,118	959	85.78
២២	ឧត្តរមានជ័យ	254	91	35.83
២៣	កែប	18	16	88.89
២៤	ប៉ៃលិន	79	51	64.56
២៥	ក្នុងឃ្មុំ	853	581	68.11
	សរុប	14,073	9,651	68.57

ប្រមាណជា៦៨% នៃភូមិទូទាំងប្រទេសកំពុងទទួលបានការផ្គត់ផ្គង់អគ្គសនី គិតត្រឹមឆ្នាំ២០១៥។

[51] *Hun Sen says all villages to have electricity by 2020*, The Khmer Herald, A1.

ដូចមានបង្ហាញក្នុងតារាង ក្នុងចំណោមខេត្តរាជធានីទាំង២៥ មានខេត្តចំនួន.១០គឺខេត្តកំពង់ឆ្នាំង កោះកុង ក្រចេះ មណ្ឌលគិរី ព្រះវិហារ រតនគិរី ស្ទឹងត្រែង ស្វាយរៀង និងឧត្តរមានជ័យ ដែលមានភូមិតិចជាង៥0% ទទួលបានការផ្គត់ផ្គង់អគ្គិសនី។

របាយការណ៍របស់អាជ្ញាធរអគ្គិសនីកម្ពុជា បានឲ្យដឹងថា ក្នុងរយៈពេល៣ឆ្នាំ គឺឆ្នាំ២០១៣ ២០១៤ និងឆ្នាំ២០១៥ ការផ្គត់ផ្គង់អគ្គិសនីតាមភូមិ ដោយអ្នកកាន់អាជ្ញាប័ណ្ណមានការប្រែប្រួល ដូចបង្ហាញក្នុងតារាងខាងក្រោម៖



យោងតាមទិន្នន័យ ក្នុងតារាងនេះ ដើម្បីសម្រេចគោលនយោបាយ ដែលបានសន្យាខាងលើ ត្រឹមឆ្នាំ២០១៨ រាជរដ្ឋាភិបាល ត្រូវផ្គត់ផ្គង់អគ្គិសនីឲ្យប្រជាពលរដ្ឋប្រើប្រាស់តាមចំនួនប្រមាណ១១.៣០០ ភូមិ។[52]

បេសកកម្មនេះ ទំនងជាសម្រេចបានក្នុងកំរិតតិចតួចប៉ុណ្ណោះ ព្រោះថា ក្រៅពីទំហំនៃការផលិតថាមពលអគ្គិសនីសម្រាប់ប្រើប្រាស់ ការរៀបចំប្រព័ន្ធបណ្តាញចែកចាយ ឬហេដ្ឋារចនាសម្ព័ន្ធតភ្ជាប់ក៏ជាឧបសគ្គចំបងដើម្បីបំពេញគោលនយោបាយនេះផងដែរ ហើយម្យ៉ាងទៀត ការរីកចំរើនក្នុងការផ្គត់ផ្គង់អគ្គិសនីទៅតាមភូមិនានាមិនទាន់មានស្ថេរភាពព្រោះគេឃើញមានការកើនឡើង និងធ្លាក់ចុះ។

សេចក្ដីសន្និដ្ឋាន រាជរដ្ឋាភិបាលសម្រេចបានខ្លះចំពោះការសន្យាអំពីគោលនយោបាយ ពង្រីកការផ្គត់ផ្គង់ថាមពលអគ្គិសនីពីបណ្តាញជាតិ ដើម្បីចែកចាយឲ្យដល់ភូមិទូទាំងប្រទេស ក្នុងកំរិត៨0ភាគរយនៃភូមិទាំងអស់ក្នុងឆ្នាំ២០១៨ ។

១៣. ខិតខំសម្រេចគោលដៅទទួលទេសចរណ៍ពីក្រៅប្រទេសនៅឆ្នាំ២០១៥ ប្រមាណ៤,៥លាននាក់ ឆ្នាំ២០១៨ កើនដល់៦,១លាននាក់ រួមជាមួយទេសចរណ៍ក្នុងស្រុកប្រមាណ១0,៥លាននាក់។[53]

នៅកម្ពុជាវិស័យទេសចរណ៍ទាំងវប្បធម៌ និងធម្មជាតិបាន និងកំពុងរីកចំរើនជារៀងរាល់ឆ្នាំក្នុងទសវត្សចុងក្រោយ។ វិស័យទេសចរណ៍ បានចូលរួមចំណែកលើកស្ទួយកំរិតជីវភាពរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋដោយប្រយោល និងដោយផ្ទាល់ដែលស្របតាមគោលនយោបាយកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាល។

[52] របាយការណ៍អាជ្ញាធរអគ្គិសនីកម្ពុជាចេញផ្សាយឆ្នាំ២០១៥ វិស័យអគ្គិសនី នៃព្រះរាជាណាចក្រកម្ពុជា ទំព័រ៣២

[53] *Supra* note 10, at 38.

យោងតាមរបាយការណ៍ ដែលចេញផ្សាយដោយក្រសួងទេសចរណ៍ គិតត្រឹម១០ខែដើមឆ្នាំ២០១៦ កម្ពុជាទទួលបានភ្ញៀវទេសចរបរទេសបានចំនួន៣,៩២លាននាក់។ បើប្រៀបធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០១៥ ដែលចំនួនភ្ញៀវទេសចរបរទេសមានប្រមាណ៣,៧៥លាននាក់។ ផ្អែកលើទិន្នន័យខាងលើ ក្នុងរយៈ១០ខែ ភ្ញៀវទេសចរណ៍ឆ្នាំ២០១៦ កើនឡើងប្រមាណ៤,៣% ហើយកំណើននេះដូចគ្នានឹងកំណើនឆ្នាំ២០១៥ នៃរយៈពេលដូចគ្នា។ កំណើនភ្ញៀវទេសចរណ៍២ខែចុងក្រោយនៃឆ្នាំ២០១៥ មានចំនួន២២% បើប្រៀបធៀបនឹង១០ខែដើមឆ្នាំ។ ប្រសិនបើក្នុងរយៈពេល២ខែចុងក្រោយឆ្នាំ២០១៦ ភ្ញៀវទេសចរបរទេសកើនឡើង២២%ដូចគ្នានឹងឆ្នាំ២០១៥ នោះភ្ញៀវទេសចរណ៍បរទេសដែលចូលមកទស្សនាកម្ពុជានឹងមានចំនួន៤,៩៧លាននាក់ក្នុងរយៈពេល១២ខែនៃឆ្នាំ២០១៦។

International Tourist Arrivals to Cambodia

Months	2011	2012	2013	2014	2015	2016	Change (%)				
							12/11	13/12	14/13	15/14	16*/15
Q1	**778,467**	**995,210**	**1,172,072**	**1,267,922**	**1,307,836**	**1,342,477**	**27.8**	**17.8**	**8.2**	**3.1**	**2.6**
January	274,471	350,257	404,106	442,045	460,577	466,086	27.6	15.4	9.4	4.2	1.2
February	255,499	321,870	385,760	425,801	430,207	448,468	26.0	19.8	10.4	1.0	4.2
March	248,497	323,083	382,206	400,076	417,052	427,923	30.0	18.3	4.7	4.2	2.6
Q2	**606,562**	**761,442**	**920,527**	**933,446**	**994,154**	**1,018,455**	**25.5**	**20.9**	**1.4**	**6.5**	**2.4**
April	223,032	277,304	327,000	332,690	361,139	367,684	24.3	17.9	1.7	8.6	1.8
May	190,258	233,220	292,115	300,302	314,748	320,601	22.6	25.3	2.8	4.8	1.9
June	193,272	250,918	301,412	300,454	318,267	330,170	29.8	20.1	-0.3	5.9	3.7
Q3	**699,760**	**820,888**	**964,612**	**998,690**	**1,044,880**	**1,147,483**	**17.3**	**17.5**	**3.5**	**4.6**	**9.8**
July	239,527	284,282	338,761	340,091	364,325	395,761	18.7	19.2	0.4	7.1	8.6
August	250,429	293,859	342,064	347,211	366,096	406,214	17.3	16.4	1.5	5.4	11.0
September	209,804	242,747	283,787	311,388	314,459	345,508	15.7	16.9	9.7	1.0	9.9
Q4	**797,073**	**1,006,767**	**1,152,954**	**1,302,717**	**1,428,361**	**414,077**	**26.3**	**14.5**	**13.0**	**9.6**	
October	233,190	290,959	334,410	390,637	408,922	414,077	24.8	14.9	16.8	4.7	1.3
November	265,539	333,482	386,737	411,501	444,640		25.6	16.0	6.4	8.1	
December	298,344	382,326	431,807	500,579	574,799		28.1	12.9	15.9	14.8	
Total	**2,881,862**	**3,584,307**	**4,210,165**	**4,502,775**	**4,775,231**	**3,922,492**	**24.4**	**17.5**	**7.0**	**6.1**	**4.4**

ចំនួនទេសចរបរទេសមកទស្សនាកម្ពុជារយៈពេល១០ខែ ដើមឆ្នាំ២០១៦

ប្រភពពីនាយកដ្ឋានស្ថិតិ និងព័ត៌មានទេសចរណ៍

ក្នុងឆ្នាំ២០១៥ រាជរដ្ឋាភិបាលបានសម្រេចគោលដៅទេសចរបរទេសបានសន្យាថានឹងសម្រេចឲ្យចំនួន៤,៥លាននាក់ ដែលយោងលើទិន្នន័យរបស់នាយកដ្ឋានស្ថិតិ និងព័ត៌មានទេសចរណ៍កម្ពុជាទទួលបានភ្ញៀវទេសចរបរទេសចំនួន៤,៧លាននាក់ក្នុងឆ្នាំ២០១៥។

របាយការណ៍ក៏បានបង្ហាញថា ភ្ញៀវទេសចរបរទេសមកពីប្រទេសអាស៊ីចូលមកកម្ពុជាមានចំនួនច្រើនជាងគេ គឺប្រទេសវៀតណាមដែលជាប់ចំណាត់ថ្នាក់លេខ១ បន្ទាប់មកប្រទេសចិន និងកូរ៉េ។ តំបន់ទេសចរណ៍រាជធានីភ្នំពេញ និងតំបន់ជុំវិញរាជធានីភ្នំពេញ និងតំបន់សៀមរាបអង្គរត្រូវបានក្លាយជាតំបន់ទេសចរណ៍ដែលទាក់ទាញភ្ញៀវមកកំសាន្តមានចំនួនច្រើនជាងគេ។[54]

សេចក្ដីសន្និដ្ឋាន រាជរដ្ឋាភិបាលកម្ពុជាសម្រេចបានខ្លះនូវគោលនយោបាយ លើវិស័យទេសចរណ៍

[54] TOURISM STATISTICS REPORT October, 2016, MINISTRY OF TOURISM Statistics and Tourism Information Department, http://www.tourismcambodia.org/mot/index.php?view=statistic_report#comp

ក្នុងចំនួនភ្ញៀវទេសចរក្រៅប្រទេស ដោយសារផែនការទទួលភ្ញៀវទេសចរបរទេសចំនួន៤,៥លាននាក់ សម្រាប់ឆ្នាំ២០១៥បានសម្រេច ប៉ុន្តែសម្រាប់ការកំណត់ទិសដៅឆ្នាំ២០១៨ ដែលកំណត់ថា នឹងមានចំនួនភ្ញៀវទេសចរបរទេសកើនឡើងរហូតដល់ជាង៦លាននាក់ ប្រសិនបើភ្ញៀវទេសចរបរទេសរក្សាកំណើនថេរប្រមាណ៦%នៃឆ្នាំនីមួយ ចាប់ពីឆ្នាំ២០១៣ ដល់ឆ្នាំ២០១៦ កម្ពុជាទំនងជាមិនអាចសម្រេចទិសដៅបង្កើនកំណើនភ្ញៀវទេសចរបរទេសដូចបានគ្រោងទុកខាងលើនោះទេ។

១៤.បន្តកសាងអនុវិទ្យាល័យឲ្យបានគ្រប់ឃុំ(ឃុំមួយអនុវិទ្យាល័យមួយ) ដែលនៅមិនទាន់មានអនុវិទ្យាល័យ។[55]

តារាងពី៥· អនុវិទ្យាល័យ ថ្នាក់រៀន សិស្ស និង បុគ្គលិក តាមរាជធានី ខេត្ត

រាជធានី ខេត្ត	ចំនួន សាលារៀន	សាលារៀន ទទួលការលំបាក	ចំនួន ថ្នាក់រៀន	ចំនួន បន្ទប់រៀន	ថ្នាក់រៀន នៅតុងតូ	ចំនួនសិស្ស		សិស្សរៀនត្រូវថ្នាក់		បុគ្គលិកបង្រៀន		បុគ្គលិកមិនបង្រៀន		បុគ្គលិកសរុប	
						សរុប	ស្រី	សរុប	ស្រី	សរុប	ស្រី	សរុប	ស្រី	សរុប	ស្រី
បន្ទាយមានជ័យ	54	0	278	267	4	12 364	6 423	130	31	575	243	128	36	703	279
បាត់ដំបង	95	0	636	597	2	27 156	14 277	388	122	1 430	683	333	102	1 763	785
កំពង់ចាម	80	1	446	386	7	19 390	10 130	549	155	868	444	205	53	1 073	497
កំពង់ឆ្នាំង	60	0	317	286	11	14 621	7 799	183	60	580	254	81	23	661	277
កំពង់ស្ពឺ	70	0	401	360	0	19 844	9 957	108	26	986	344	121	14	1 107	358
កំពង់ធំ	69	1	351	319	7	14 989	8 205	318	134	705	319	146	35	851	354
កំពត	78	0	460	414	42	19 822	9 836	262	64	1 010	450	238	50	1 248	500
កណ្ដាល	101	1	681	629	7	28 064	14 255	625	163	1 590	803	255	50	1 845	853
កែប	4	0	28	28	0	1 014	499	46	13	86	31	18	2	104	33
តាកែវ	21	1	72	67	0	2 240	1 044	36	11	182	55	13	1	195	56
ក្រចេះ	41	0	204	200	9	8 820	4 689	125	37	528	276	86	29	614	305
មណ្ឌលគិរី	9	0	27	27	0	871	458	7	2	67	22	1	0	68	22
ឧត្តរមានជ័យ	25	0	127	122	0	5 906	3 090	139	46	242	90	34	6	276	96
ម៉ៃលិន	6	0	36	36	0	1 479	709	6	0	136	53	17	5	153	58
ភ្នំពេញ	32	0	311	228	0	12 858	6 213	369	122	1 083	536	96	17	1 179	553
ព្រះសីហនុ	19	0	114	110	0	4 438	2 138	105	31	315	119	40	10	355	129
ព្រះវិហារ	45	1	175	172	0	6 683	3 718	57	25	409	146	26	10	435	156
ព្រៃវែង	93	1	602	560	0	27 398	14 041	119	25	1 005	382	313	63	1 318	445
ពោធិ៍សាត់	44	0	272	265	0	10 758	5 564	203	40	717	278	109	21	826	299
រតនគិរី	12	0	55	52	0	2 540	1 129	48	14	136	54	13	4	149	58
សៀមរាប	93	2	528	450	54	24 535	13 643	772	280	738	418	138	44	876	462
ស្ទឹងត្រែង	21	0	75	73	0	2 401	1 268	34	9	233	85	24	5	257	90
ស្វាយរៀង	54	0	299	294	0	12 504	6 126	125	23	685	182	169	25	854	207
តាខ្មៅ	71	0	462	454	15	19 283	9 457	201	48	779	236	220	35	999	271
ត្បូងឃ្មុំ	54	0	260	244	0	13 013	7 013	161	59	385	158	53	7	438	165
ទូទាំងប្រទេស	1 251	8	7 217	6 640	158	312 991	161 681	5 116	1 540	15 470	6 661	2 877	647	18 347	7 308
- តំបន់ទីប្រជុំជន	132	1	1 061	919	24	42 953	21 588	1 193	365	3 042	1 528	434	133	3 476	1 661
- តំបន់ជនបទ	1 119	7	6 156	5 721	134	270 038	140 093	3 923	1 175	12 428	5 133	2 443	514	14 871	5 647

វិស័យអប់រំនៅកម្ពុជាមានការរីកចំរើនគួរឲ្យចាប់អារម្មណ៍ក្នុងរយៈពេលជាងពីរទសវត្សកន្លងមកនេះ។ ប៉ុន្តែតាមរយៈរបាយការណ៍ សន្ទស្សន៍ការអភិវឌ្ឍន៍មនុស្សជាតិ (Human Development Index) របស់អង្គការ UNPD ប្រចាំឆ្នាំ២០១៣ បានបង្ហាញឲ្យឃើញថា កម្ពុជាស្ថិតនៅក្នុងចំណាត់ថ្នាក់មធ្យម គឺស្ថិតក្នុងលេខរៀងទី១៤៣ ក្នុងចំណោមប្រទេស១៨៨ ដែលស្ទើរតែស្ថិតនៅក្នុងចំណាត់ថ្នាក់នៃការអភិវឌ្ឍន៍ជាតិកំរិតទាប។[56] របាយការណ៍បានបង្ហាញចំនួនសិស្សានុសិស្សចំណេះដឹងទូទៅថា សម្រាប់ឆ្នាំ២០១៥-២០១៦ ចំនួនសិស្សានុសិស្ស បានកើនឡើងប្រមាណ១% បើប្រៀបធៀបនឹងឆ្នាំ២០១៤-២០១៥។[57] ឆ្លងតាមលទ្ធផលនៃកំណែទម្រង់ក្នុងឆ្នាំ២០១៤ វិស័យអប់រំនៅថ្នាក់មធ្យមសិក្សាបានបញ្ជាក់ឲ្យឃើញថា គុណភាពអប់រំនៅកម្ពុជា គឺស្ថិតនៅក្នុងកំរិតទន់ខ្សោយខ្លាំង។ ដែលនេះជាហេតុផលមួយធ្វើឲ្យក្រសួងយកចិត្តទុកដាក់រឹតបន្តឹងការប្រលងមធ្យមសិក្សាទុតិយភូមិដែលបាន និងកំពុងអនុវត្តក្នុងពេញ០៣ឆ្នាំកន្លងមក។

ក្រៅពីគុណភាពអប់រំ ហេដ្ឋារចនាសម្ព័ន្ធអប់រំក៏នៅមានកំរិតនៅឡើយ ដែលនេះជាឧបសគ្គដ៏ចំបងរបស់កម្ពុជាក្នុងការអភិវឌ្ឍន៍ធនធានមនុស្ស។ របាយការណ៍របស់ក្រសួងអប់រំបានបង្ហាញថា ក្នុងឆ្នាំសិក្សា២០១៥-២០១៦ កម្ពុជានៅមានសាលាជួបការលំបាកចំនួន៣០០ ដែលបានធ្លាក់ចុះចំនួន១៦ បើធៀបនឹងឆ្នាំសិក្សា២០១៤-២០១៥។

រហូតមកដល់ឆ្នាំ២០១៦នេះ កម្ពុជាមានអគារសាលារៀនទូទាំងប្រទេសចំនួន១២៥០៥ ឬស្មើនឹង៨៤ ៨០៨ថ្នាក់រៀន មានសិស្សានុសិស្សចំនួន៣០០៩៦៣៦នាក់។ សាលារៀនសម្រាប់ថ្នាក់មត្តេយ្យមានប្រមាណជា៣៧០៦ សាលារៀន សាលាបឋមសិក្សាមានចំនួណ៧០៨៥សាលារៀន អនុវិទ្យាល័យ (ថ្នាក់ទី ៧-៩) មានចំនួន១២៥១សាលារៀន (ទីប្រជុំជន១៣២ តំបន់ជនបទ ១១១៩) វិទ្យាល័យ។[58]

កម្ពុជាមាន១៦៣៣ ឃុំ/សង្កាត់ (ទិន្នន័យឆ្នាំ២០១៣) ចំណែកចំនួនសាលារៀនសម្រាប់ថ្នាក់អនុវិទ្យាល័

---

[55] *Supra* note 10, at 42.

[56] *Work for HumanDevelopment*, Human Development Report 2015, Cambodia, The United Nations Development Programes (UNDP), at 211.

[57] របាយការណ៍ស្ថិតិ និងសូចនាករអប់រំ ២០១៥-២០១៦

[58] *Education Statistics & Indicators 2015-2016*, Ministry of Education Youth and Sports, Cambodia, table 1

យ រហូតមកដល់ឆ្នាំ២០១៦នេះ ទើបតែសាងសង់បានចំនួន១២៥១សាលារៀនប៉ុណ្ណោះ បើប្រៀបធៀបនឹងឆ្នាំ ២០១៥ មានការកើនឡើងសាលារៀនអនុវិទ្យាល័យចំនួន២។ ក្នុងនីតិកាលទី៥នេះ រាជរដ្ឋាភិបាលបានសន្យា ថា នឹងបន្តកសាងអនុវិទ្យាល័យឲ្យបានគ្រប់ឃុំ (ឃុំមួយអនុវិទ្យាល័យមួយ)។ ទោះជាយ៉ាងណាក៏ដោយ ការស ន្យារបស់រាជរដ្ឋាភិបាល គឺសម្រាប់រយៈពេលមួយអាណត្តិនៃនីតិកាលទី៥ តែបើមើលពីកំណើនចំនួនសាលាអនុ វិទ្យាល័យនៅឆ្នាំ២០១៦ ធៀបនឹងឆ្នា២០១៥ រាជរដ្ឋាភិបាលប្រហែលជាពិបាកនឹងជំនះលើបេសកកម្មនេះ បន្តិច។

សេចក្តីសន្និដ្ឋាន រាជរដ្ឋាភិបាលសម្រេចបានខ្លះនូវគោលយោបាយបន្តកសាងអនុវិទ្យាល័យ ឲ្យបានគ្រប់ ឃុំ (ឃុំមួយ អនុវិទ្យាល័យមួយ)។

១៥. រៀបចំគោលនយោបាយជាតិ ស្តីពីមុខរបរ និងការងារស្របទៅនឹងការវិវឌ្ឍន៍នៃសង្គម-សេដ្ឋកិច្ច។[59]

កាលពីឆ្នាំ២០១៤ តាមព័ត៌មានពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ គោលនយោបាយជាតិ ស្តីពីមុខរបរ និងការងារក្នុងស្ថិតនៅក្នុងដំណើរការបង្កើត ហើយក្រសួងបានកំណត់ត្រឹមចុងឆ្នាំ២០១៥ ដើម្បីឲ្យគោលនយោបាយនេះនឹងត្រូវបានបង្កើតឲ្យរួចរាល់។ ក្រសួងការងារបានទទួលគោលការណ៍ ពីរាជរដ្ឋា ភិបាល និងបានទទួលសេចក្តីសម្រេចពីទីស្តីការគណៈរដ្ឋមន្ត្រី ដើម្បីបង្កើតគណៈកម្មការអន្តរក្រសួង ដែលមា នសមាសភាពមកពីក្រសួង អង្គការ សមាគម តំណាងសហជីព និយោជកដែលពាក់ព័ន្ធក្នុងវិស័យការងារធ្វើ ការសិក្សា បង្កើតគោលនយោបាយនេះ។

នៅឆ្នាំ២០១៥នេះ គោលនយោបាយជាតិ ស្តីពីមុខរបរ និងការងារត្រូវបានប្រជុំសម្រេចក្នុងកិច្ចប្រជុំ គណៈរដ្ឋមន្ត្រីថ្ងៃទី០៤ ខែកញ្ញា។ គោលនយោបាយនេះបង្កើត បន្ទាប់ពីរាជរដ្ឋាភិបាលបានដាក់ចេញនូវគោលន យោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្មឆ្នាំ២០១៥-២០២៥។ នៅថ្ងៃទី២២ ខែតុលា ឆ្នាំ២០១៥ គោលនយោបា យជាតិ ស្តីពីមុខរបរ និងការងារត្រូវដាក់ឲ្យអនុវត្តជាផ្លូវការ។

ក្នុងឆ្នាំ២០១៦ គេមិនទាន់ឃើញរាជរដ្ឋភិបាល និងស្ថាប័នពាក់ព័ន្ធយកគោលនយោបាយដែលបានបង្កើ ត ហើយនេះទៅអនុវត្តន៍ដើម្បីឆ្លើយតបនឹងតម្រូវការការងារជាក់ស្តែងរបស់ប្រជាពលរដ្ឋ។ កង្វះទីផ្សារការងារក្នុ ងស្រុក និងប្រាក់កម្រៃនៃកម្លាំងពលិកម្មមិនសមស្របនឹងការចំណាយក្នុងជីវភាពប្រចាំថ្ងៃ នៅតែជាបញ្ហាចំបងក្នុ ងសង្គមកម្ពុជា។ បញ្ហានេះធ្វើឲ្យកម្លាំងពលិកម្មកម្ពុជាបាន និងកំពុងធ្វើចំណាកស្រុករហូតដល់ខ្វះកម្លាំងពលកម្ម សម្រាប់ផ្គត់ផ្គង់ក្នុងស្រុក។ ម្យ៉ាងសិស្ស និស្សិតដែលបានបញ្ចប់ការសិក្សាភាគច្រើនបាន និងកំពុងធ្វើការងារដែ លខុសពីជំនាញសិក្សារបស់ខ្លួន។

សេចក្តីសន្និដ្ឋានក្នុងការអនុវត្តន៍គោលនយោបាយក្នុងឆ្នាំទី៣នេះ រាជរដ្ឋាភិបាលបានសម្រេចនូវការរៀប ចំគោលនយោបាយជាតិ ស្តីពីមុខរបរ និងការងារ ស្របទៅនឹងការវិវឌ្ឍន៍នៃសង្គម-សេដ្ឋកិច្ច។

១៦. ការដាក់ឲ្យដំណើរការរបបប្រាក់សោធននិវត្តន៍ សម្រាប់កម្មករ និយោជិតក្នុងវិស័យឯកជនឲ្យទទួលបាន របបប្រាក់សោធននិវត្តន៍ដូចមន្ត្រីរាជការដែរ ចាប់ពីឆ្នាំ២០១៥។[60]

រាជរដ្ឋាភិបាលបាន និងកំពុងអនុវត្តប្រព័ន្ធរបបសន្តិសុខសង្គម ក៏ប៉ុន្តែដំណើរការនេះនៅមានភាពស្មុគ ស្មាញ និងការផ្តល់សេវានៅមានភាពមិនច្បាស់លាស់។

[59] *Supra* note 10, at 46.
[60] *Ibid.*

អនុក្រឹត្យ ស្តីពីបេឡាជាតិរបបសន្តិសុខសង្គមលេខ១៦អនក្រ-បក ចុះថ្ងៃទី០២ ខែមីនា ឆ្នាំ២០០៧ ការងារធានារ៉ាប់រងហានិភ័យការងារក៏ត្រូវបានបង្កើត ហើយគេឃើញមានដំណើរការអនុវត្តន៍របបធានារ៉ាប់រងហានិភ័យការងារផងដែរ។ ក្រោយមក គេឃើញមានរបបសន្តិសុខសង្គមមួយទៀត ដែលត្រូវបានបញ្ញត្តិក្នុងច្បាប់ ស្តីពីការងារដែរ គឺរបបថែទាំសុខភាព ហើយនៅថ្ងៃទី០៦ ខែមករា ឆ្នាំ២០១៦ រាជរដ្ឋាភិបាលបង្កើតរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពនេះ តាមរយៈអនុក្រឹត្យលេខ០១ អ.ន.ក្រ.ប.ក។

របបសន្តិសុខសង្គមមួយទៀត គឺរបបប្រាក់សោធននិវត្តន៍សម្រាប់កម្មករ និយោជិតក្នុងវិស័យឯកជន នៅក្នុងឆ្នាំ២០១៦នេះ កំពុងត្រូវបានសិក្សា និងរៀបចំដាក់ឲ្យដំណើរការ ហើយគ្រោងនឹងចាប់ផ្តើមដាក់ឲ្យដំណើរការនៅឆ្នាំ២០១៧។

រាជរដ្ឋាភិបាលនីតិកាលទី៥ បានសន្យាក្នុងគោលនយោបាយរបស់ខ្លួនថា នឹងដាក់ឲ្យដំណើរការរបបប្រាក់សោធននិវត្តន៍សម្រាប់កម្មករ និយោជិតក្នុងវិស័យឯកជនឲ្យទទួលបានរបបប្រាក់សោធននិវត្តន៍ ដូចមន្ត្រីរាជការដែលចាប់ពីឆ្នាំ២០១៥។ រាជរដ្ឋាភិបាលមិនទាន់បានដាក់ឲ្យដំណើរការរបបប្រាក់សោធននិវត្តន៍ សម្រាប់កម្មករ និយោជិតក្នុងវិស័យឯកជន។

សេចក្តីសន្និដ្ឋាន រាជរដ្ឋាភិបាលមិនសម្រេចនូវការសន្យា ការដាក់ឲ្យដំណើរការរបបប្រាក់សោធននិវត្តន៍សម្រាប់កម្មករ និយោជិតក្នុងវិស័យឯកជនឲ្យទទួលបានរបបប្រាក់សោធននិវត្តន៍ដូចមន្ត្រីរាជការដែរ ចាប់ពីឆ្នាំ២០១៥ នោះទេ។

២. ការផ្តល់ពិន្ទុការបំពេញ/អនុវត្តន៍គោលនយោបាយ

ការផ្តល់ពិន្ទុលើការបំពេញ ឬអនុវត្តគោលនយោបាយមិនមានសូចនាករច្បាស់លាស់ ត្រូវបានធ្វើឡើងដោយប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតបានផ្តល់ពិន្ទុវាយតម្លៃ។ ប្រជាពលរដ្ឋដែលមានសិទ្ធិបោះឆ្នោតនៅ១៨រាជធានីខេត្ត ដែលមានចំនួនសរុបប្រមាណ៨២៩នាក់ (៤០%ជាស្ត្រី) បានផ្តល់ពិន្ទុលើការបំពេញ ឬអនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៥ ឆ្នាំ២០១៦ ដែលជាឆ្នាំទី៣។

ការបំពេញ/អនុវត្តន៍គោលនយោបាយចំនួន៣៣ចំណុច ដែលមិនមានសូចនាករច្បាស់លាស់ ត្រូវបានឲ្យប្រជាពលរដ្ឋផ្តល់ពិន្ទុដោយប្រើប្រាស់ម៉ាស៊ីនផ្តល់ពិន្ទុ តាមអញ្ញត្តិដូចខាងក្រោម៖

អញ្ញត្តិ	តម្លៃ	ភាគរយនៃការពេញចិត្ត
១	មិនពេញចិត្តទាល់តែសោះ ឬពេញចិត្តតិចតួច	០-២០%
២	ពេញចិត្តខ្លះ	២១%-៤០%
៣	ពេញចិត្តមធ្យម ឬពេញចិត្ត៣ក់កណ្តាល	៤១%-៦០%
៤	ពេញចិត្តច្រើន	៦១%-៨០%
៥	ពេញចិត្តស្ទើរតែទាំងស្រុង ឬពេញចិត្តទាំងស្រុង	៨១%-១០០%

ក. វិស័យទី១៖ការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ

ក្រមិតនៃការពេញចិត្ត	**លើកទី១**[61] (%)	**លើកទី២**[62] (%)	**លទ្ធផលមធ្យម**[63]
1.មិនពេញចិត្តទាល់តែសោះ ឬពេញចិត្តតិចតួច	20.34	23.26	21.80
2.ពេញចិត្តខ្លះ	34.55	36.11	35.33
3.ពេញចិត្តមធ្យម ឬពេញចិត្តពាក់កណ្តាល	24.81	24.79	24.80
4.ពេញចិត្តច្រើន	14.57	10.33	12.45
5.ពេញចិត្តស្ទើរតែទាំងស្រុង ឬពេញចិត្តទាំងស្រុង	5.72	5.51	5.62

ពិន្ទុនៃការពេញចិត្តជាមធ្យមនៃវិស័យទី១ (Mean)[64]	លើកទី១	លើកទី២	លទ្ធផលមធ្យម
	2.51	2.39	2.45

ខ. វិស័យទី២៖ ការពង្រឹងរដ្ឋបាលសាធារណៈ វិមជ្ឈការ និងវិសហមជ្ឈការ ការពង្រឹងផ្នែកច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងការប្រឆាំងពើពុករលួយ

ក្រមិតនៃការពេញចិត្ត	**លើកទី១**[65] (%)	**លើកទី២**[66] (%)	**លទ្ធផលមធ្យម**[67]
1.មិនពេញចិត្តទាល់តែសោះ ឬពេញចិត្តតិចតួច	20.89	24.31	22.60
2.ពេញចិត្តខ្លះ	30.59	33.37	31.98
3.ពេញចិត្តមធ្យម ឬពេញចិត្តពាក់កណ្តាល	28.47	27.92	28.19
4.ពេញចិត្តច្រើន	13.16	10.64	11.90
5.ពេញចិត្តស្ទើរតែទាំងស្រុង ឬពេញចិត្តទាំងស្រុង	6.90	3.76	5.33

ពិន្ទុនៃការពេញចិត្តជាមធ្យមនៃវិស័យទី២ (Mean)[68]	លើកទី១	លើកទី២	លទ្ធផលមធ្យម
	2.55	2.36	2.45

[61] ប្រជាពលរដ្ឋផ្តល់ពិន្ទុផ្អែកលើព័ត៌មាន ឬចំណេះដឹងផ្ទាល់ខ្លួន

[62] ប្រជាពលរដ្ឋផ្តល់ពិន្ទុផ្អែកលើព័ត៌មាន ឬចំណេះដឹងផ្ទាល់ខ្លួន និងព័ត៌មានដែលទទួលបានពីវាគ្មិន (ក្រោយពេលពិភាក្សា)

[63] លទ្ធផលមធ្យមនៃការផ្តល់ពិន្ទុលើកទី១ និងលើកទី២

[64] 1.00 ដល់ 1.50: មិនពេញចិត្តទាល់តែសោះ ឬពេញចិត្តតិចតួច, 1.51 ដល់ 2.50: ពេញចិត្តខ្លះ, 2.51 ដល់ 3.50: ពេញចិត្តមធ្យម ឬពេញចិត្តពាក់កណ្តាល, 3.51 ដល់ 4.50: ពេញចិត្តច្រើន, 4.51 ដល់ 5.00: ពេញចិត្តស្ទើរតែទាំងស្រុង ឬពេញចិត្តទាំងស្រុង

[65] ប្រជាពលរដ្ឋផ្តល់ពិន្ទុផ្អែកលើព័ត៌មាន ឬចំណេះដឹងផ្ទាល់ខ្លួន

[66] ប្រជាពលរដ្ឋផ្តល់ពិន្ទុផ្អែកលើព័ត៌មាន ឬចំណេះដឹងផ្ទាល់ខ្លួន និងព័ត៌មានដែលទទួលបានពីវាគ្មិន (ក្រោយពេលពិភាក្សា)

[67] លទ្ធផលមធ្យមនៃការផ្តល់ពិន្ទុលើកទី១ និងលើកទី២

[68] 1.00 ដល់ 1.50: មិនពេញចិត្តទាល់តែសោះ ឬពេញចិត្តតិចតួច, 1.51 ដល់ 2.50: ពេញចិត្តខ្លះ, 2.51 ដល់ 3.50: ពេញចិត្តមធ្យម ឬពេញចិត្តពាក់កណ្តាល, 3.51 ដល់ 4.50: ពេញចិត្តច្រើន, 4.51 ដល់ 5.00: ពេញចិត្តស្ទើរតែទាំងស្រុង ឬពេញចិត្តទាំងស្រុង

គ. វិស័យទី3៖ ការអភិវឌ្ឍន៍សេដ្ឋកិច្ច

កម្រិតនៃការពេញចិត្ត	**លើកទី១**[69] (%)	**លើកទី២**[70] (%)	**លទ្ធផលមធ្យម**[71]
1.មិនពេញចិត្តទាល់តែសោះឬពេញចិត្តតិចតួច	15.13	19.41	17.27
2.ពេញចិត្តខ្លះ	31.37	34.67	33.02
3.ពេញចិត្តមធ្យម ឬពេញចិត្តពាក់កណ្តាល	30.97	29.42	30.20
4.ពេញចិត្តច្រើន	16.28	12.18	14.23
5.ពេញចិត្តស្ទើរតែទាំងស្រុង ឬពេញចិត្តទាំងស្រុង	6.25	4.33	5.29

ពិន្ទុនៃការពេញចិត្តជាមធ្យមនៃវិស័យទី៣ (Mean)[72]	លើកទី១	លើកទី២	លទ្ធផលមធ្យម
	2.67	2.47	2.57

ឃ. វិស័យទី4៖ ការអភិវឌ្ឍន៍វិស័យអប់រំ សុខាភិបាល ការងារ វប្បធម៌ និងសង្គមកិច្ច

កម្រិតនៃការពេញចិត្ត	**លើកទី១**[73] (%)	**លើកទី២**[74] (%)	**លទ្ធផលមធ្យម**[75]
1.មិនពេញចិត្តទាល់តែសោះ ឬពេញចិត្តតិចតួច	12.76	18.66	15.71
2.ពេញចិត្តខ្លះ	30.31	32.61	31.46
3.ពេញចិត្តមធ្យម ឬពេញចិត្តពាក់កណ្តាល	32.31	31.42	31.86
4.ពេញចិត្តច្រើន	17.00	13.46	15.23
5.ពេញចិត្តស្ទើរតែទាំងស្រុង ឬពេញចិត្តទាំងស្រុង	7.62	3.85	5.74

ពិន្ទុនៃការពេញចិត្តជាមធ្យមនៃវិស័យទី៤ (Mean)[76]	លើកទី១	លើកទី២	លទ្ធផលមធ្យម
	2.76	2.51	2.64

[69] ប្រជាពលរដ្ឋផ្តល់ពិន្ទុផ្អែកលើព័ត៌មាន ឬចំណេះដឹងផ្ទាល់ខ្លួន

[70] ប្រជាពលរដ្ឋផ្តល់ពិន្ទុផ្អែកលើព័ត៌មាន ឬចំណេះដឹងផ្ទាល់ខ្លួន និងព័ត៌មានដែលទទួលបានពីវាគ្មិន (ក្រោយពេលពិភាក្សា)

[71] លទ្ធផលមធ្យមនៃការផ្តល់ពិន្ទុលើកទី១ និងលើកទី២

[72] 1.00 ដល់ 1.50: មិនពេញចិត្តទាល់តែសោះ ឬពេញចិត្តតិចតួច, 1.51 ដល់ 2.50: ពេញចិត្តខ្លះ, 2.51 ដល់ 3.50: ពេញចិត្តមធ្យម ឬពេញចិត្តពាក់កណ្តាល, 3.51 ដល់ 4.50: ពេញចិត្តច្រើន, 4.51 ដល់ 5.00: ពេញចិត្តស្ទើរតែទាំងស្រុង ឬពេញចិត្តទាំងស្រុង

[73] ប្រជាពលរដ្ឋផ្តល់ពិន្ទុផ្អែកលើព័ត៌មាន ឬចំណេះដឹងផ្ទាល់ខ្លួន

[74] ប្រជាពលរដ្ឋផ្តល់ពិន្ទុផ្អែកលើព័ត៌មាន ឬចំណេះដឹងផ្ទាល់ខ្លួន និងព័ត៌មានដែលទទួលបានពីវាគ្មិន (ក្រោយពេលពិភាក្សា)

[75] លទ្ធផលមធ្យមនៃការផ្តល់ពិន្ទុលើកទី១ និងលើកទី២

[76] 1.00 ដល់ 1.50: មិនពេញចិត្តទាល់តែសោះ ឬពេញចិត្តតិចតួច, 1.51 ដល់ 2.50: ពេញចិត្តខ្លះ, 2.51 ដល់ 3.50: ពេញចិត្តមធ្យម ឬពេញចិត្តពាក់កណ្តាល, 3.51 ដល់ 4.50: ពេញចិត្តច្រើន, 4.51 ដល់ 5.00: ពេញចិត្តស្ទើរតែទាំងស្រុង ឬពេញចិត្តទាំងស្រុង

ង. គោលនយោបាយទាំង៤វិស័យ៖

កម្រិតនៃការពេញចិត្ត	**លើកទី១**[77] (%)	**លើកទី២**[78] (%)	**លទ្ធផលមធ្យម**[79]
1.មិនពេញចិត្តទាល់តែសោះ ឬពេញចិត្តតិចតួច	12.78	21.41	19.35
2.ពេញចិត្តខ្លះ	31.70	34.19	32.95
3.ពេញចិត្តមធ្យម ឬពេញចិត្តពាក់កណ្តាល	29.14	28.39	28.76
4.ពេញចិត្តច្រើន	15.25	11.65	13.45
5.ពេញចិត្តស្ទើរតែទាំងស្រុង ឬពេញចិត្តទាំងស្រុង	6.62	4.36	5.49

ពិន្ទុនៃការពេញចិត្តជាមធ្យមនៃទាំង០៤វិស័យ (Mean)[80]	លើកទី១	លើកទី២	លទ្ធផលមធ្យម
	2.62	2.43	2.53

ច. លទ្ធផលជាមធ្យមនៃការពេញចិត្ត ចំពោះការអនុវត្តន៍/បំពេញគោលនយោបាយរបស់រាជរដ្ឋាភិបាលឆ្នាំ២០១៦៖

ទិន្នន័យខាងក្រោមបង្ហាញពីកំរិតនៃការពេញចិត្ត ពេញចិត្តខ្លះ និងមិនពេញចិត្តចំពោះវិស័យនីមួយៗនៃការអនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងឆ្នាំទី៣។ តម្លៃនៃការ**ពេញចិត្ត** គឺជាការបូកបញ្ចូលតម្លៃនៃការផ្តល់ពិន្ទុអញ្ញត្តិទី៤ (ពេញចិត្តច្រើន) និងទី៥(ពេញចិត្តស្ទើរទាំងស្រុង ឬទាំងស្រុង) ហើយតម្លៃនៃការ**ពេញចិត្តខ្លះ** គឺជាការបូកបញ្ចូលតម្លៃនៃការផ្តល់ពិន្ទុអញ្ញត្តិទី២ (ពេញចិត្តខ្លះ) និងទី៣(ពេញចិត្តមធ្យម ឬពាក់កណ្តាល)។ ចំណែកឯតម្លៃនៃការ**មិនពេញចិត្ត** គឺជាតម្លៃនៃការផ្តល់ពិន្ទុអញ្ញត្តិទី១(មិនពេញចិត្តទាល់តែសោះ ឬពេញចិត្តតិចតួច)។

❖វិស័យ៖ ការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ

មានប្រជាពលរដ្ឋចំនួន១៨,០៦%ពេញចិត្ត ៦០,១៣%ពេញចិត្តខ្លះ និង២១,៨០%មិនពេញចិត្ត។ ពិន្ទុជាមធ្យមគឺ២.៤៥ នេះមានន័យ បើវាយតម្លៃជារួមក្នុងចំណោមពិន្ទុ១ ដល់៥ ប្រជាពលរដ្ឋបានផ្តល់ពិន្ទុ២,៤៥ (**ពេញចិត្តខ្លះ**)។



[77] ប្រជាពលរដ្ឋផ្តល់ពិន្ទុផ្អែកលើព័ត៌មាន ឬចំណេះដឹងផ្ទាល់ខ្លួន

[78] ប្រជាពលរដ្ឋផ្តល់ពិន្ទុផ្អែកលើព័ត៌មាន ឬចំណេះដឹងផ្ទាល់ខ្លួន និងព័ត៌មានដែលទទួលបានពីវាគ្មិន (ក្រោយពេលពិភាក្សា)

[79] លទ្ធផលមធ្យមនៃការផ្តល់ពិន្ទុលើកទី១ និងលើកទី២

[80] 1.00 ដល់ 1.50: មិនពេញចិត្តទាល់តែសោះ ឬពេញចិត្តតិចតួច, 1.51 ដល់ 2.50: ពេញចិត្តខ្លះ, 2.51 ដល់ 3.50: ពេញចិត្តមធ្យម ឬពេញចិត្តពាក់កណ្តាល, 3.51 ដល់ 4.50: ពេញចិត្តច្រើន, 4.51 ដល់ 5.00: ពេញចិត្តស្ទើរតែទាំងស្រុង ឬពេញចិត្តទាំងស្រុង

❖**វិស័យ៖ ការពង្រឹងរដ្ឋបាលសាធារណៈ វិមជ្ឈការ និងវិសហមជ្ឈការ ការពង្រឹងផ្នែកច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងការប្រឆាំងអំពំពើពុករលួយ**



កំរិតពិន្ទុជាមធ្យម=2.45/5
(ពេញចិត្តខ្លះ)

ប្រជាពលរដ្ឋចំនួន១៧,២៣%ពេញចិត្ត ៦០,១៧%ពេញចិត្តខ្លះ និង២២.៦០%មិនពេញចិត្ត។ ពិន្ទុមធ្យមគឺ២,៤៥ នៃពិន្ទុសរុប៥ មានន័យថា ប្រជាពលរដ្ឋ**ពេញចិត្តខ្លះ**តែប៉ុណ្ណោះចំពោះលទ្ធផលនៃការបំពេញ/អនុវត្តន៍គោលនយោបាយវិស័យនេះ។

❖ **វិស័យ៖ ការអភិវឌ្ឍន៍សេដ្ឋកិច្ច**



ប្រជាពលរដ្ឋចំនួន១៩,៥២%ពេញចិត្ត ៦៣,២១% ពេញចិត្តខ្លះ និង១៧,២៧%មិនពេញចិត្ត។ វិស័យនេះទទួលបានពិន្ទុមធ្យមពីប្រជាពលរដ្ឋ ២,៥៧ នៃពិន្ទុសរុប៥ (**ពេញចិត្តពាក់កណ្តាល/មធ្យម**)។

កំរិតពិន្ទុជាមធ្យម=2.57/5
(ពេញចិត្តពាក់ណ្តាល/មធ្យម)

❖ **វិស័យ៖ ការអភិវឌ្ឍន៍វិស័យអប់រំ សុខាភិបាល ការងារ វប្បធម៌ និងសង្គមកិច្ច**



កំរិតពិន្ទុជាមធ្យម=2.64/5
(ពេញចិត្តពាក់ណ្តាល/មធ្យម)

ប្រជាពលរដ្ឋចំនួន២០,៩៧%ពេញចិត្ត ៦៣,៣២%ពេញចិត្តខ្លះ និង១៥,៧១%មិនពេញចិត្ត។ វិស័យនេះទទួលបានពិន្ទុមធ្យម២,៦៤ នៃពិន្ទុសរុប៥ គឺប្រជាពលរដ្ឋ**ពេញចិត្តពាក់កណ្តាល/មធ្យម**។

❖ **គោលនយោបាយរាជរដ្ឋាភិបាលនីតិកាលទី៥ (ទាំងបួនវិស័យ)**



លទ្ធផលនៃការបំពេញ/អនុវត្តន៍គោលនយោបាយនីតិកាលទី៥ ត្រូវបានប្រជាពលរដ្ឋចំនួន១៨,៩៤%ពេញចិត្ត ៦១,៧១%ពេញចិត្តខ្លះ និង១៩,៣៥% មិនពេញចិត្ត ហើយប្រជាពលរដ្ឋបានផ្តល់ពិន្ទុមធ្យម ២,៥៣ នៃពិន្ទុសរុប៥។

កំរិតពិន្ទុជាមធ្យម=2.53/5
(ពេញចិត្តពាក់ណ្តាល/មធ្យម)

តារាងបង្ហាញពីការផ្តល់ពិន្ទុការបំពេញ/អនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាល

ល.រ	វិស័យនៃគោលនយោបាយ	១ %មិនព	២ %ពេ	៣ %ពេញ
០១	ការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ	21.80	60.13	18.06
០២	ការពង្រឹងរដ្ឋបាលសាធារណៈ វិមជ្ឈការ និងវិសហមជ្ឈការ ការពង្រឹងផ្នែកច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងការប្រឆាំងអំពំពើពុករលួយ	22.60	60.17	17.23
០៣	ការអភិវឌ្ឍន៍សេដ្ឋកិច្ច	17.27	63.21	19.52
០៤	ការអភិវឌ្ឍន៍វិស័យអប់រំ សុខាភិបាល ការងារ វប្បធម៌ និងសង្គមកិច្ច	`15.71	63.32	20.97
០៥	គោលនយោបាយរាជរដ្ឋាភិបាលនីតិកាលទី៥ (ទាំងបួនវិស័យ)	19.35	61.71	18.94

លទ្ធផលវាយតម្លៃជារួមបានបង្ហាញថា ការអនុវត្តន៍គោលនយោបាយសម្រាប់ឆ្នាំទី៣ (២០១៦) របស់រាជរដ្ឋាភិបាលទី៥ ដែលរដ្ឋសភាបានអនុម័តថវិកាចំនួនប្រមាណ៤.៣៦៥លានដុល្លារសហរដ្ឋអាមេរិក មានប្រជាពលរដ្ឋចំនួនប្រមាណ១៩%ពេញចិត្ត ប្រមាណ៦២%ពេញចិត្តខ្លះ និងប្រមាណ១៩%មិនពេញចិត្ត។

ដូចគ្នានឹងឆ្នាំ២០១៥ដែរ រាជរដ្ឋាភិបាលក្នុងឆ្នាំ២០១៦ ផ្តល់អាទិភាពចំណាយខ្ពស់ទៅលើវិស័យចំនួនពីរ គឺវិស័យសេដ្ឋកិច្ច និងសង្គមកិច្ច បើប្រៀបធៀជាមួយវិស័យផ្សេងទៀត។ ថវិកាចំណាយលើវិស័យសេដ្ឋកិច្ច និងសង្គមកិច្ច ភាគច្រើនត្រូវបានយកទៅបែងចែកទៅក្រសួងពាក់ព័ន្ធដូចជា៖ ក្រសួងរ៉ែ និងថាមពល ក្រសួងពាណិជ្ជកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងទេសចរណ៍ និងក្រសួងសិប្បកម្ម ឧស្សាហកម្ម ក្រសួងសុខាភិបាល ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងវប្បធម៌ និងវិចិត្រសិល្ប: ក្រសួងសង្គមកិច្ច អតីតយុវជន និងនីតិសម្បទា ក្រសួងធម្មការ និងសាសនា ក្រសួងកិច្ចការនារី និងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវ:ជាដើម។ ការបំពេញ/អនុវត្តន៍គោលនយោបាយលើវិស័យទាំងពីរនេះត្រូវបានប្រជាពលរដ្ឋពេញចិត្តក្នុងកំរិតពាក់កណ្តាល/មធ្យម (Mean=២,៥៧/៥ និង ២,៦៤/៥)។

ចំណែកឯវិស័យផ្សេងមួយទៀត ដែលរាជរដ្ឋាភិបាលបានគ្រោងចំណាយថវិកាជាតិមានចំនួន១៦,២៩% ច្រើនបន្ទាប់នោះ គឺវិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ។ ថវិកាត្រូវបានផ្តល់ទៅក្រសួងការពារជាតិ ក្រសួងមហាផ្ទៃផ្នែកសន្តិសុខសាធារណៈ និងក្រសួងយុត្តិធម៌ផងដែរ។ លទ្ធផលនៃការពេញចិត្តរបស់ប្រជាពលរដ្ឋ ក្នុងការអនុវត្តន៍គោលនយោបាយការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ គឺមិនល្អប្រសើរឡើយ ពីព្រោះចំនួនប្រជាពលរដ្ឋបានផ្តល់ពិន្ទុពេញចិត្តខ្លះ ហើយវិស័យការពារជាតិ សន្តិសុខ និងសណ្តាប់

[81] តម្លៃនៃការផ្តល់ពិន្ទុអញ្ញត្តិទី១ (មិនពេញចិត្តទាល់តែសោះ ឬពេញចិត្តតិចតួច)

[82] ផលបូកតម្លៃនៃការផ្តល់ពិន្ទុអញ្ញត្តិទី ២(ពេញចិត្តខ្លះ) និងទី៣(ពេញចិត្តមធ្យម ឬពាក់កណ្តាល)

[83] ផលបូកបញ្ចូល តម្លៃនៃការផ្តល់ពិន្ទុអញ្ញត្តិទី៤(ពេញចិត្តច្រើន) និងទី៥(ពេញចិត្តស្ទើរទាំងស្រុង ឬទាំងស្រុង)

ធ្នាប់សាធារណៈត្រូវបានប្រជាពលរដ្ឋពេញចិត្តខ្លះដែរ (Mean=២,៤៥/៥)។

VIII. សេចក្តីសន្និដ្ឋាន

រាជរដ្ឋាភិបាលនៃរដ្ឋសភានីតិកាលទី៥ ដែលដឹកនាំដោយគណបក្សប្រជាជនកម្ពុជា បានសម្រេចការបំពេញ/អនុវត្តន៍គោលនយោបាយចំនួន០៦ (៣៧%) នៃ១៦គោលនយោបាយ ដែលមានសូចនាករច្បាស់លាស់រួមមានដូចជា៖ កំណើនសេដ្ឋកិច្ច៧%ក្នុងមួយឆ្នាំ ការកាត់បន្ថយភាពក្រីក្នុងអត្រា០១%ក្នុងមួយឆ្នាំ ការបញ្ឈប់ការផ្តល់សម្បទានដីសេដ្ឋកិច្ច ការកសាងគោលនយោបាយជាតិ ស្តីពីលំនៅដ្ឋាន ការរៀបចំគោលនយោបាយដឹកជញ្ជូនទីក្រុង និងការបង្កើតគោលនយោបាយជាតិ ស្តីពីមុខរបរ និងការងារ។

ចំណែកឯគោលនយោបាយចំនួន០៧ រាជរដ្ឋាភិបាលអនុវត្ត ឬ/និងសម្រេចបានខ្លះ។ គោលនយោបាយទាំងនោះមានដូចជា ការនាំអង្ករចេញឲ្យបាន០១លានតោន ការរក្សាផ្ទៃនេសាទទឹកសាប ការចុះបញ្ជីដីធ្លីប្រជាពលរដ្ឋទទួលសេវាទឹកស្អាត ការពង្រីកការផ្គត់ផ្គង់អគ្គិសនីពីបណ្តាញជាតិឲ្យដល់ភូមិ គោលដៅចំនួនទេសចរណ៍ពីក្រៅប្រទេសឆ្នាំ២០១៨ និងការបន្តកសាងអនុវិទ្យាល័យឲ្យបានគ្រប់ឃុំ។ ចំពោះគោលដៅចំនួនទេសចរណ៍ពីក្រៅប្រទេស រាជរដ្ឋាភិបាលបានសម្រេចគោលដៅដែលបានកំណត់ក្នុងឆ្នាំ២០១៥រួមកហើយ។ ដោយសារតែគោលដៅក្នុងដំណាក់កាលទី២ រាជរដ្ឋាភិបាលបានកំណត់ដល់ឆ្នាំ២០១៨ ដូចនេះយើងអាចសន្និដ្ឋានបានថាសម្រាប់គោលដៅដំណាក់ទី២ រាជរដ្ឋាភិបាលសម្រេចបានខ្លះក្នុងឆ្នាំ២០១៦។

ប៉ុន្តែគោលនយោបាយចំនួន០៣ រាជរដ្ឋាភិបាលបានអនុវត្ត តែមិនអាចសម្រេចបាន ឬបានតិចតួចតាមការសន្យារបស់ខ្លួន។ គោលនយោបាយទាំងនោះមាន ដូចជាគោលនយោបាយការរក្សាផ្ទៃដីដែលគ្របដណ្តប់ដោយព្រៃឈើ ការកែលម្អផ្លូវលំជនបទ៣០០ ទៅ៤០០គីឡូម៉ែត្រក្នុង១ឆ្នាំ និងការដាក់ឲ្យដំណើរការរបបប្រាក់សោធននិវត្តន៍សម្រាប់កម្មករ និយោជិតក្នុងវិស័យឯកជន។

សម្រាប់ឆ្នាំទី៣នេះ រាជរដ្ឋាភិបាលសម្រេចបាននូវការបំពេញ/អនុវត្តន៍គោលនយោបាយដែលមានសូចនាករច្បាស់លាស់របស់ចំនួន០៦ ដូចគ្នានឹងឆ្នាំ២០១៥ដែរ។ គោលនយោបាយគោលដៅចំនួនទេសចរណ៍ពីក្រៅប្រទេសឆ្នាំ២០១៨ ត្រូវបានបំពេញ/អនុវត្តសម្រេចបានខ្លះ ខណៈដែលគោលនយោបាយជាតិ ស្តីពីលំនៅដ្ឋានសម្រេចបានក្នុងឆ្នាំ២០១៦នេះ។

ចំណែកការផ្តល់ពិន្ទុលើលទ្ធផលនៃការបំពេញ/អនុវត្តន៍គោលនយោបាយ មិនមានសូចនាករច្បាស់លាស់របស់រាជរដ្ឋាភិបាល ដោយប្រជាពលរដ្ឋនៅ១៤រាជធានី/ខេត្ត លើវិស័យទាំង០៤រួមមាន៖ វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ វិស័យការពង្រឹងរដ្ឋបាលសាធារណៈ វិមជ្ឈការ និងវិសហមជ្ឈការ ការពង្រឹងផ្នែកច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងការប្រឆាំងអំពើពុករលួយ វិស័យការអភិវឌ្ឍន៍សេដ្ឋកិច្ច និងវិស័យការអភិវឌ្ឍន៍វិស័យអប់រំ សុខាភិបាល ការងារ វប្បធម៌ និងសង្គមកិច្ច បើធៀបការផ្តល់ពិន្ទុលើកទី១ ពិន្ទុនៃការពេញចិត្តជាមធ្យម នៅក្នុងការផ្តល់ពិន្ទុលើកទី២ធ្លាក់ចុះ។ ក្រោយពីទទួលបានព័ត៌មានពីវាគ្មិននូវការបំពេញ/អនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាល ប្រជាពលរដ្ឋប្រែប្រួលការវាយតម្លៃរបស់ខ្លួនកាន់តែអវិជ្ជមាន លើការ បំពេញ/អនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៥ឆ្នាំទី៣។

គោលនយោបាយរាជរដ្ឋាភិបាលនីតិកាលទី៥ ដឹកនាំដោយគណបក្សប្រជាជនកម្ពុជា និងចំណាយថវិកាជាតិប្រមាណ៤.៣៦៥លានដុល្លារសហរដ្ឋអាមេរិក ដើម្បីបំពេញ/អនុវត្តន៍ក្នុងឆ្នាំទី៣នៃនីតិកាលទី៥ កន្លងមក

នេះ មានប្រជាពលរដ្ឋនៅ១៤ខេត្ត/រាជធានី ដែលចូលរួមផ្តល់ពិន្ទុចំនួនប្រមាណ១៩%ពេញចិត្ត ប្រមាណ៦២% ពេញចិត្តខ្លះ និងប្រមាណ១៩%មិនពេញចិត្ត ចំពោះការបំពេញ/អនុវត្តន៍គោលនយោបាយឆ្នាំទី៣នេះ។

ឧបសម្ព័ន្ធ

- **វិធីសាស្ត្រ និងទំហំនៃរបាយការណ៍**

របាយការណ៍ ស្តីពីការឃ្លាំមើល និងការផ្តល់ពិន្ទុលើលើលទ្ធផលនៃការបំពេញ/អនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៥ ឆ្នាំទី៣មានចំនួនពីរផ្នែក ដែលកើតចេញពីការវិភាគលើទិន្នន័យ និងព័ត៌មាន និងការផ្តល់ពិន្ទុ។ ផ្នែកទី១នៃរបាយការណ៍នេះ ផ្អែកលើព័ត៌មាន ឬទិន្នន័យដែលមានស្រាប់មកពីប្រព័ន្ធផ្សព្វផ្សាយរបាយការណ៍បឋមរបស់អង្គការជាតិ និងអន្តរជាតិ សារព័ត៌មានជាតិ និងអន្តរជាតិ ព្រមទាំងស្ថាប័នជាតិ និងអន្តរជាតិផ្សេងៗដែលពាក់ព័ន្ធនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាលអាណត្តិទី៥។ គោលនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី០៥ ដែលមានសូចនាករច្បាស់លាស់ត្រូវបានវិភាគ និងវាយតម្លៃ។

សម្រាប់មួយផ្នែកផ្សេងទៀតនៃរបាយការណ៍នេះ គឺការរកឃើញនៃការផ្តល់ពិន្ទុលើការបំពេញ/អនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាល។ វេទិកាម្ចាស់ឆ្នោតចំនួន១៤ ត្រូវបានរៀបចំឡើងនៅក្នុងខេត្ត/រាជធានីផ្សេងៗគ្នា ដែលមានប្រជាពលរដ្ឋនៃវិស័យនានាចូលរួម ដើម្បីផ្តល់ពិន្ទុលើលទ្ធផលនៃការបំពេញ/អនុវត្តន៍គោលនយោបាយ ដែលមិនមានសូចនាករច្បាស់លាស់របស់រាជរដ្ឋាភិបាល។ ការបំពេញ/អនុវត្តន៍គោលនយោបាយចំនួន៣៣ចំណុច ដែលមិនមានសូចនាករច្បាស់លាស់ ត្រូវបានឲ្យប្រជាពលរដ្ឋផ្តល់ពិន្ទុ ដោយប្រើប្រាស់ម៉ាស៊ីនផ្តល់ពិន្ទុតាមអញ្ញត្តិដូចខាងក្រោម៖

អញ្ញត្តិ	**តម្លៃ**	**ភាគរយនៃការពេញចិត្ត**
១	មិនពេញចិត្តទាល់តែសោះ ឬពេញចិត្តតិចតួច	០-២០%
២	ពេញចិត្តខ្លះ	២១%-៤០%
៣	ពេញចិត្តមធ្យម ឬពេញចិត្តពាក់កណ្តាល	៤១%-៦០%
៤	ពេញចិត្តច្រើន	៦១%-៨០%
៥	ពេញចិត្តស្ទើរតែទាំងស្រុង ឬពេញចិត្តទាំងស្រុង	៨១%-១០០%

ប្រជាពលរដ្ឋបានធ្វើការផ្តល់ពិន្ទុចំនួនពីរលើក ចំពោះការលទ្ធផលនៃការបំពេញ/អនុវត្តន៍គោលនយោបាយ។ ការផ្តល់ពិន្ទុលើកទី១ ផ្អែកលើព័ត៌មាន ឬចំណេះដឹងរបស់ប្រជាពលរដ្ឋផ្ទាល់ ចំណែកឯការផ្តល់ពិន្ទុលើកទី២ ផ្អែកលើព័ត៌មាន ឬចំណេះដឹងរបស់ប្រជាពលរដ្ឋ រួមទាំងព័ត៌មានដែលបានផ្តល់ជូនដោយវាគ្មិនតំណាងអង្គការសង្គមស៊ីវិល និងអ្នកជំនាញឯករាជ្យដែលធ្វើការពាក់ព័ន្ធនឹងការតាមដាន ការអនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាល។

- **តារាងបង្ហាញពីការផ្តល់ពិន្ទុ និងការប្រៀបធៀបការបំពេញ/អនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាល**

ល.រ	វិស័យនៃគោលនយោបាយ	ឆ្នាំ	[84] %មិនព	[85] %ពេញ	[86] %ពេញ
០១	ការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ	2015 (24 ខេត្ត/រាជធានី)	13.31	58.11	28.58
		2015 (14 ខេត្ត/រាជធានី)	16.59	56.74	26.66
		2016 (14 ខេត្ត/រាជធានី)	21.80	60.13	18.06
០២	ការពង្រឹងរដ្ឋបាលសាធារណៈ វិមជ្ឈការ និងវិសហមជ្ឈការ ការពង្រឹងផ្នែកច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងការប្រឆាំងអំពំពើពុករលួយ	2015 (24 ខេត្ត/រាជធានី)	13.28	60.42	26.29
		2015 (14 ខេត្ត/រាជធានី)	15.64	62.20	22.14
		2016 (14 ខេត្ត/រាជធានី)	22.60	60.17	17.23
០៣	ការអភិវឌ្ឍន៍សេដ្ឋកិច្ច	2015 (24 ខេត្ត/រាជធានី)	10.86	66.66	22.48
		2015 (14 ខេត្ត/រាជធានី)	13.76	66.77	19.47
		2016 (14 ខេត្ត/រាជធានី)	17.27	63.21	19.52
០៤	ការអភិវឌ្ឍន៍វិស័យអប់រំ សុខាភិបាល ការងារ វប្បធម៌ និងសង្គមកិច្ច	2015 (24 ខេត្ត/រាជធានី)	9.93	62.73	27.33
		2015 (14 ខេត្ត/រាជធានី)	13.02	62.37	24.61
		2016 (14 ខេត្ត/រាជធានី)	`15.71	63.32	20.97
០៥	គោលនយោបាយរាជរដ្ឋាភិបាលនីតិកាលទី៥ (ទាំងបួនវិស័យ)	2015 (24 ខេត្ត/រាជធានី)	11.84	61.98	26.17
		2015 (14 ខេត្ត/រាជធានី)	14.75	62.02	23.22
		2016 (14 ខេត្ត/រាជធានី)	19.35	61.71	18.94

[84] តម្លៃនៃការផ្តល់ពិន្ទុអញ្ញត្តិទី១ (មិនពេញចិត្តទាល់តែសោះ ឬពេញចិត្តតិចតួច)

[85] ផលបូកតម្លៃនៃការផ្តល់ពិន្ទុអញ្ញត្តិទី ២(ពេញចិត្តខ្លះ) និងទី៣(ពេញចិត្តមធ្យម ឬពាក់កណ្តាល)

[86] ផលបូកបញ្ចូល តម្លៃនៃការផ្តល់ពិន្ទុអញ្ញត្តិទី៤(ពេញចិត្តច្រើន) និងទី៥(ពេញចិត្តស្មើរទាំងស្រុង ឬទាំងស្រុង)

- **កំណែទម្រង់សំខាន់ៗទាំង ៣ ប្រចាំឆ្នាំ ២០១៦**

ដោយ មូលនិធិអាស៊ី (The Asia Foundation)
សារព័ត៌មានភ្នំពេញប៉ុស្ត៍

https://goo.gl/gIsnvz

ថ្ងៃច័ន្ទ ទី១៩ ខែធ្នូ ឆ្នាំ២០១៦

គំនិតផ្តួចផ្តើមចងក្រងបញ្ជីកំណែទម្រង់ (គ.ច.ប) គឺជាវេទិកាមួយដឹកនាំដោយអ្នកជំនាញមួយក្រុមដែលធ្វើការតាមដាន និងពិនិត្យមើលកិច្ចខិតខំប្រឹងប្រែងកំណែទម្រង់របស់រាជរដ្ឋាភិបាលកម្ពុជា។ គំនិតផ្តួចផ្តើមចងក្រងបញ្ជីកំណែទម្រង់នេះបានជ្រើសរើសយកកំណែទម្រង់ចំនួនបីនៅក្នុងវិស័យអប់រំហិរញ្ញវត្ថុ និងគុណភាពទឹកស្អាតជាកំណែទម្រង់សំខាន់ដែលមានសក្តានុពលបំផុតប្រចាំនៅឆ្នាំ ២០១៦ ។

គំនិតផ្តួចផ្តើមចងក្រងបញ្ជីកំណែទម្រង់បានវាយតម្លៃលើកំណែទម្រង់ដែលកើតឡើងនៅក្នុងក្រសួងចំនួន ១៧ ក្នុងឆ្នាំ ២០១៦។

ដំណើរការនៃការជ្រើសរើសកំណែទម្រង់នេះចាប់ផ្តើមដោយក្រុមការងាររបស់ គ.ច.ប បានធ្វើការស្រាវជ្រាវរកឯកសារដែលពាក់ព័ន្ធនឹងកំណែទម្រង់បន្ទាប់មកពិភាក្សាជាមួយមន្ត្រីបច្ចេកទេសតាមក្រសួងនានាមុននឹងបញ្ជូនលទ្ធផលនៃការស្រាវជ្រាវទៅក្រុមប្រឹក្សាយោបល់របស់ គ.ច.ប។

ក្រុមប្រឹក្សាយោបល់របស់ គ.ច.ប គឺជាអ្នកជំនាញលើវិស័យចំនួនបីដែលរួមមានវិស័យសង្គមកិច្ច វិស័យរដ្ឋបាលសាធារណៈ និងវិស័យសេដ្ឋកិច្ច។

ក្រុមប្រឹក្សាយោបល់នេះជាអ្នកដែលពិនិត្យឡើងវិញនូវបញ្ជីកំណែទម្រង់ និងធ្វើការជ្រើសរើសកំណែទម្រង់សំខាន់ៗប្រចាំឆ្នាំ។

គំនិតផ្តួចផ្តើមចងក្រងបញ្ជីកំណែទម្រង់ត្រូវបានផ្តួចផ្តើមឡើងកាលពីឆ្នាំ ២០១៥ ដោយអង្គការមូលនិធិអាស៊ីដើម្បីពង្រីកការយល់ដឹងរបស់សាធារណជនអំពីកំណែទម្រង់ដែលមានសក្តានុពលធ្វើឲ្យសេវាសាធារណៈក្នុងប្រទេសកម្ពុជាមានភាពប្រសើរឡើង។ បញ្ជីកំណែទម្រង់ដែលបានចងក្រងដោយ គ.ច.ប អាចរកបាននៅលើគេហទំព័រ៖ www.reforminventory.wikispaces.com។

ផែនការសកម្មភាពគោលនយោបាយស្តីពីគ្រូបង្រៀន

ផ្តោតលើការអភិវឌ្ឍសមត្ថភាពរបស់គ្រូបង្រៀនការសម្រេចចិត្តរបស់ក្រសួងអប់រំ យុវជន និងកីឬាក្នុងការធ្វើកំណែទម្រង់ការប្រឡងមធ្យមសិក្សាទុតិយភូមិបានបន្តផ្តល់លទ្ធផលវិជ្ជមានជាមួយនឹងអត្រាសិស្សប្រឡងជាប់កើនឡើងពី ៥៥,៩ ភាគរយក្នុងឆ្នាំ ២០១៥ ទៅ ៦២,២ ភាគរយក្នុងឆ្នាំ ២០១៦។

ស្របពេលជាមួយគ្នានេះដែរក្រសួងបានដាក់ចេញនូវផែនការសកម្មភាពគោលនយោបាយស្តីពីគ្រូបង្រៀនដែលជាកំណែទម្រង់យ៉ាងហ្មត់ចត់ និងមានលក្ខណៈជាប្រព័ន្ធដោយត្រូវបានបង្កើតឡើងដើម្បីអភិវឌ្ឍគុណភាពវិស័យអប់រំទូទាំងប្រទេស។

ផែនការនេះត្រូវបានបង្កើតឡើងក្រោមការយល់ឃើញថាការលើកកម្ពស់លទ្ធផលនៃការរៀនសូត្ររបស់សិស្ស ត្រូវផ្សារភ្ជាប់ជាមួយនឹងសមត្ថភាពរបស់គ្រូបង្រៀនលើមុខវិជ្ជាដែលគាត់បង្រៀន និងសមត្ថភាពរបស់គ្រូបង្រៀនក្នុងការវាយតម្លៃ និងសម្របទៅតាមតម្រូវការផ្សេងៗរបស់សិស្ស។

កម្មវិធីមួយក្នុងចំណោមកម្មវិធីជាច្រើនដែលត្រូវបានរៀបចំឡើងដើម្បីលើកកម្ពស់លទ្ធផលនៃការរៀនសូត្ររបស់សិស្សគឺកម្មវិធីវិក្រឹតការគ្រូបង្រៀនដែលក្នុងឆ្នាំ ២០១៥ បានផ្តល់អត្ថប្រយោជន៍ដល់មនុស្សចំនួន ៤៥៤៤ នាក់ដែលជាមន្ត្រីអប់រំ នាយកសាលា គ្រូអនុវិទ្យាល័យ និងបឋមសិក្សា។ នេះបើយោងតាមផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ ២០១៧ សម្រាប់វិស័យអប់រំ។ តួលេខនេះបានកើនឡើងជិតទ្វេដងក្នុងឆ្នាំ ២០១៦ នេះហើយត្រូវបានរំពឹងថានឹងកើនឡើងរហូតដល់ ២៣ ១៦៨ នាក់នៅឆ្នាំ ២០១៧។

ក្រសួងបានដាក់បញ្ចូលមតិស្តីពីវិធីសាស្ត្របណ្តុះបណ្តាលគ្រូបង្រៀនប្រកបដោយប្រសិទ្ធភាពរបស់សង្គមស៊ីវិលចូលទៅក្នុងប្រព័ន្ធវិក្រឹតការគ្រូបង្រៀនជាតិដែលនឹងត្រូវរៀបចំស្របជាមួយនឹងការបណ្តុះបណ្តាល ការបង្កើនវិជ្ជាជីវៈ ការលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុ និងការដំឡើងតំណែងប្រកបដោយតម្លាភាពសម្រាប់វិជ្ជាជីវៈអប់រំ។

ការកែសម្រួលឡើងវិញនូវរបបពន្ធ

រដ្ឋាភិបាលបានធ្វើវិសោធនកម្មរបបពន្ធសម្រាប់សហគ្រាសដោយលុបបំបាត់នូវរបបម៉ៅការ និងរៀបចំឡើងវិញនូវរចនាសម្ព័ន្ធពន្ធរបបពិត។ ការផ្លាស់ប្តូរនេះគឺជាផ្នែកមួយនៃច្បាប់ស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុឆ្នាំ ២០១៦ ដែលត្រូវបានប្រកាសឲ្យប្រើប្រាស់កាលពីថ្ងៃទី ១៧ ខែធ្នូឆ្នាំ ២០១៥ និងត្រូវបានបញ្ជាក់បន្ថែមដោយប្រកាសលេខ ១៨១៩ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

កន្លងមកសហគ្រាសជាច្រើនបានគណនាកាតព្វកិច្ចពន្ធរបស់ខ្លួនតាមការប៉ាន់ប្រមាណចំនួនប្រាក់ចំណូល និងចំណាយជាជាងតួលេខពិតប្រាកដ។ គោលនយោបាយកែសម្រួលថ្មី (របបពិត) តម្រូវឲ្យសហគ្រាសរួមទាំងស្ថាប័នមិនរកប្រាក់ចំណេញ សមាគម និងអង្គការសប្បុរសធម៌ដែលមានចំណូលមធ្យមប្រចាំឆ្នាំច្រើនជាង ២៥០ លានរៀល (ប្រមាណជា ៦២ ៥០០ ដុល្លារ) ធ្វើការបង់អាករលើតម្លៃបន្ថែម (VAT) ប្រកាសពន្ធប្រចាំខែ និងប្រចាំឆ្នាំប្រមូល និងបង់ពន្ធកាត់ទុករក្សាទុកបញ្ជីគណនេយ្យឲ្យបានត្រឹមត្រូវព្រមទាំងធ្វើសវនកម្មពន្ធ។ អាជីវកម្មត្រូវបានចាត់ជាប្រភេទតូចមធ្យម ឬធំដោយផ្អែកលើកត្តាជាច្រើនក្នុងនោះក៏រួមបញ្ចូលនូវកត្តាប្រាក់ចំណូលផងដែរ។

ក្រុមហ៊ុនត្រូវតែចុះឈ្មោះជាអ្នកបង់ពន្ធខ្នាតមធ្យម ឬធំដោយមិនគិតពីទំហំនៃប្រាក់ចំណូលនោះទេ។អត្ថប្រយោជន៍នៃកំណែទម្រង់មួយនេះរួមមានការរក្សាកំណត់ត្រាបានត្រឹមត្រូវជាងមុនការរាយការណ៍សកម្មភាពហិរញ្ញវត្ថុបានល្អជាងមុនហើយនៅពេលដែលដាក់វារួមបញ្ចូលគ្នាជាមួយនឹងវិធានការផ្សេងទៀតរបស់អគ្គនាយកដ្ឋានពន្ធដារទើបវានឹងជួយបង្កើនថវិការដ្ឋបានកាន់តែច្រើនថែមទៀត។ ជាក់ស្តែងថ្មីៗនេះអគ្គនាយកដ្ឋានពន្ធដារបានរាយការណ៍អំពីកំណើនចំណូលពន្ធចំនួន ២០,២ ភាគរយនៅក្នុងរយៈពេលដប់ខែដំបូងនៃឆ្នាំ ២០១៦ បើប្រៀបធៀបទៅនឹងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។

ការផ្គត់ផ្គង់ទឹក ស្អាតក្នុងទីក្រុង

កំណែទម្រង់ទីបីដែលគួរឲ្យចាប់អារម្មណ៍ និងហាក់ដូចជាមិនសូវបានដឹងជាសាធារណៈគឺជាការងាររបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្មក្នុងការពង្រីកការគ្របដណ្តប់គុណភាពសេវាកម្ម និងនិរន្តរភាពហិរញ្ញវត្ថុនៃការផ្គត់ផ្គង់ទឹកស្អាតនៅតាមទីក្រុង។

គោលដៅរបស់ក្រសួងឧស្សាហកម្ម និងសិប្បកម្មគឺធ្វើយ៉ាងណាឲ្យប្រជាជននៅតំបន់ទីក្រុងមួយរយភាគរយទទួលបានទឹកស្អាតដែលមានសុវត្ថិភាពមានតម្លៃសមរម្យ និងមាននិរន្តរភាពត្រឹមឆ្នាំ ២០២៥។

ក្នុងពេលបច្ចុប្បន្នការផ្គត់ផ្គង់ទឹកស្អាតនេះសម្រេចបាន ៨០ ភាគរយរួចទៅហើយ (កើនឡើងពី ៦២ ភាគរយកាលពីប្រាំឆ្នាំមុន) ដោយយកភាពជោគជ័យដែលបានអនុវត្តនៅរាជធានីភ្នំពេញទៅអនុវត្តនៅតាមបណ្តាខេត្តនានា។

គិតត្រឹមឆ្នាំ ២០១៥ ស្ថាប័នផ្គត់ផ្គង់ទឹកសាធារណៈទាំងអស់នៅរាជធានីភ្នំពេញ និងនៅតាមបណ្តាទីរួមខេត្តធំៗទាំង ៨ នៃខេត្តបាត់ដំបង កំពង់ចាម កំពង់ធំ កំពត ពោធិ៍សាត់ ស្វាយរៀង ព្រះសីហនុ និងសៀមរាប បានរាយការណ៍អំពីប្រាក់ចំណេញលើសពីការកំណត់របស់ខ្លួន។ បើពិនិត្យមើលកាលពីមុនឆ្នាំ ២០១៣ វិញមានតែរាជធានីភ្នំពេញ និងទីរួមខេត្តសៀមរាបប៉ុណ្ណោះដែលអាចធ្វើបែបនេះបាន។

ភាពជោគជ័យនេះទទួលបានតាមរយៈការកាត់បន្ថយចំណាយ និងការបង្កើនប្រសិទ្ធភាពប្រតិបត្តិការ។ លើសពីនេះទៀតក្រសួងឧស្សាហកម្ម និងសិប្បកម្មបានធ្វើការកែលម្អប្រព័ន្ធផ្តល់អាជ្ញាប័ណ្ណរបស់ខ្លួនដែលជំរុញឲ្យមានការកើនឡើងនូវចំនួនក្រុមហ៊ុនផ្គត់ផ្គង់ទឹកឯកជនដែលមានអាជ្ញាប័ណ្ណ។ សព្វថ្ងៃនេះសេវាទឹកស្អាតនៅតាមទីក្រុងរបស់ប្រទេសកម្ពុជាបានដើរលឿនជាងប្រទេសអភិវឌ្ឍន៍មួយចំនួនទៅទៀត។

សមិទ្ធផលនេះសម្រេចបានដោយសារតែការដឹកនាំរបស់រដ្ឋាភិបាល និងការប្រើប្រាស់ហិរញ្ញប្បទានរបស់ម្ចាស់ជំនួយដ៏មានប្រសិទ្ធភាពនៅក្នុងវិស័យនេះ។

សេចក្តីសន្និដ្ឋាន

គំនិតផ្តួចផ្តើមចងក្រងបញ្ជីកំណែទម្រង់ ឬ គ.ច.ប បានមើលឃើញសញ្ញាណវិជ្ជមានថាបីឆ្នាំបន្ទាប់ពីការបោះឆ្នោតឆ្នាំ ២០១៣ កំណែទម្រង់សំខាន់ៗកំពុងតែដំណើរការទៅមុខ។

កំណែទម្រង់ដែលអាចមានសក្តានុពលផ្សេងទៀតរួមមាន៖ សេចក្តីព្រាងច្បាប់អំពីបរិស្ថាន អភិបាលកិច្ចពហុភាគីនៅក្នុងវិស័យឧស្សាហកម្ម២ និងការពង្រឹងវិជ្ជាជីវៈសុខាភិបាលតាមរយៈការអនុវត្តច្បាប់ថ្មីស្តីពីការគ្រប់គ្រងអ្នកប្រកបវិជ្ជាជីវៈសុខាភិបាល។

កំណែទម្រង់វិស័យរដ្ឋបាលសាធារណៈនៅថ្នាក់ក្រោមជាតិដែលអាចមានសក្តានុពលរួមមាន៖ ការធានាឲ្យបានថាក្រុង និងស្រុក/ខណ្ឌទទួលបានមូលនិធិគ្រប់គ្រាន់ដើម្បីផ្តល់សេវាជូនប្រជាពលរដ្ឋ ការកែលម្អការផ្តល់សេវារដ្ឋបាលជូនប្រជាពលរដ្ឋដោយការបង្កើតការិយាល័យច្រកចេញចូលតែមួយនៅគ្រប់ស្រុក/ខណ្ឌទាំងអស់ និងការបង្កើនការយល់ដឹង និងការចូលរួមរបស់ប្រជាពលរដ្ឋតាមរយៈការអនុវត្តផែនការគណនេយ្យភាពសង្គម។

គំនិតផ្តួចផ្តើមចងក្រងបញ្ជីកំណែទម្រង់ប្តេជ្ញាបន្តតាមដានកិច្ចខិតខំប្រឹងប្រែងកំណែទម្រង់ និងពង្រីកវិសាលភាពការងាររបស់ខ្លួនទៅកាន់ក្រសួងផ្សេងបន្ថែមទៀត។ គ.ច.ប ជឿជាក់ថាការខិតខំប្រឹងប្រែងជាបន្តរបស់រាជរដ្ឋាភិបាលនឹងអាចធ្វើឲ្យប្រជាពលរដ្ឋទទួលបាននូវសេវាសាធារណៈប្រសើរជាងមុន។

ក្រុមប្រឹក្សាយោបល់របស់ «គំនិតផ្តួចផ្តើមចងក្រងបញ្ជីកំណែទម្រង់» មានតំណាងមកពីសភាពាណិជ្ជកម្មអាមេរិកនៅកម្ពុជាវិទ្យាស្ថានកម្ពុជាដើម្បីកិច្ចសហប្រតិបត្តិការ និងសន្តិភាព សម្ព័ន្ធភាពកម្ពុជាដើម្បីចំណូលធនធាន ខុមហ្ស្រ្ទេលគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជាក្រុមហ៊ុន DFDL ពាណិជ្ជកម្មអឺរ៉ុបនៅកម្ពុជា កិច្ចសហប្រតិបត្តិអាល្លឺម៉ង់ប្រចាំកម្ពុជា ទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុនប្រចាំកម្ពុជា

ក្រុមហ៊ុនដៃគូជាយុទ្ធសាស្ត្រមេគង្គ ភាពជាដៃគូអប់រំនៃអង្គការក្រៅរដ្ឋាភិបាល វេទិកានៃអង្គការមិនមែនរដ្ឋាភិបាលស្តីពីកម្ពុជា អង្គការ OXFAM អង្គការ PACT សម្ព័ន្ធសុខភាពកុមារ និងសុខភាពបន្តពូជ អង្គការតម្លាភាពកម្ពុជា មូលនិធិអង្គការសហប្រជាជាតិដើម្បីកុមារប្រចាំកម្ពុជា អង្គការយូ.អ.ស៊ុ. និងអ្នកជំនាញមកពីទីភ្នាក់ងារទ្វេភាគី ស្ថាប័នពហុភាគី អង្គការក្រៅរដ្ឋាភិបាល និងមកពីវិស័យឯកជនដទៃទៀត។

- **លក្ខណៈគោលនយោបាយ និងគោលនយោបាយរាជរដ្ឋាភិបាល នីតិកាលទី៥ (សង្ខេប)**

សម្រាប់នីតិកាលទី៥នេះ រាជរដ្ឋាភិបាលនីតិកាលទី៥នៃរដ្ឋសភា ដែលបានបង្កើតឡើងនៅថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ បានដាក់ចេញ និងប្រកាសគោលនយោបាយរបស់ខ្លួន ដោយបានបែងចែងជា០៤វិស័យធំ ៗ រួមមាន៖

1. ការការពារជាតិសន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ
2. ការពង្រឹងរដ្ឋបាលសាធារណៈ វិមជ្ឈការ និងវិសហមជ្ឈការ ការពង្រឹងផ្នែកច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងការប្រឆាំងអំពើពុករលួយ
3. ការអភិវឌ្ឍន៍សេដ្ឋកិច្ច
4. ការអភិវឌ្ឍន៍វិស័យអប់រំ សុខាភិបាល ការងារ វប្បធម៌ និងសង្គមកិច្ច។

ក្នុងវិស័យទាំងបួន(០៤)នោះ គេឃើញមានចំណុចតូចៗជាច្រើន ដែលរាជរដ្ឋាភិបាលបានសន្យាថា នឹងសម្រេចឲ្យបាន ឬបន្តអនុវត្តក្នុងនីតិកាលទី៥នេះ ប៉ុន្តែចំណុចការសន្យាទាំងនោះ មិនត្រូវបានកំណត់ជាចំនួនជាក់លាក់នោះទេ ផ្ទុយពីកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៤ ដែលគេសង្កេតឃើញថា ប្រជាពលរដ្ឋ ជាពិសេសម្ចាស់ឆ្នោតងាយស្រួលក្នុងស្វែងយល់ និងយល់ដឹងពីគោលនយោបាយរបស់រាជរដ្ឋាភិបាល ព្រោះកម្មវិធីនយោបាយនោះបានកំណត់ពីចំនួនគោលនយោបាយច្បាស់លាស់។

ក្នុងកម្មវិធីនយោរបស់រាជរដ្ឋាភិបាលនីតិកាលទី៥ ដែលមានបួន (០៤) វិស័យ គេឃើញមានគោលនយោបាយច្រើនចំណុច ដែលរាជរដ្ឋាភិបាលអាណត្តិទី៥នេះបានសន្យាក្នុងការអនុវត្តន៍ ប៉ុន្តែភាគច្រើននៃគោលនយោបាយទាំងនោះ គ្មានសូចនាករច្បាស់លាស់នោះទេ ពោលគឺគោលនយោបាយទាំងនោះ មិនបានបង្ហាញពីសកម្មភាពការអនុវត្តន៍អ្វីមួយច្បាស់លាស់ ដោយមានគោលដៅ ពេលវេលា ឬមានចំនួនកំណត់ច្បាស់លាស់ ឬប្រៀបធៀបទៅនឹងអត្រាណាមួយច្បាស់លាស់នោះទេ។ គោលនយោបាយនីតិកាលទី៥នេះ មិនមានបង្ហាញចំណុចច្បាស់លាស់នោះទេ ខុសពីគោលនយោបាយក្នុងនីតិកាលទី៤ ដែលខុមប្រ្ទែលរកឃើញថា គោលនយោបាយនោះ បានបង្ហាញចំណុចច្បាស់លាស់ ធ្វើឲ្យមានភាពងាយស្រួលក្នុងការវាស់វែង និងផ្តល់ពិន្ទុ។ មានតែគោលនយោបាយ១៦ចំណុចតែប៉ុណ្ណោះ មានសូចនាករច្បាស់លាស់នៅក្នុងវិស័យទី០៣ និងទី០៤តែប៉ុណ្ណោះ។ សម្រាប់គោលនយោបាយដែលគ្មានសូចនាករច្បាស់លាស់៣៣ចំណុចខុមប្រ្ទែលបានធ្វើការប្រមូលទិន្នន័យ និងព័ត៌មានទាំងនោះ ដើម្បីឲ្យប្រជាពលរដ្ឋជាម្ចាស់ឆ្នោតបោះឆ្នោតផ្តល់ពិន្ទុ។ ខាងក្រោមនេះជាគោលនយោបាយសង្ខេបរបស់រាជរដ្ឋាភិបាលតាមវិស័យនីមួយៗ៖

ការការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ

នៅក្នុងវិស័យការការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ រាជរដ្ឋាភិបាលដាក់ចេញនូវវិធានការគោលនយោបាយសំខាន់ៗដូចខាងក្រោម៖

១.ការការពាជាតិ

- ពង្រឹងកិច្ចការពារអធិបតេយ្យជាតិនៃព្រះរាជាណាចក្រកម្ពុជា លើដែនដីគោក ដែនកោះ ផ្ទៃក្នុងសមុទ្រ តំបន់ឥដ្ឋាប់ តំបន់សេដ្ឋកិច្ចផ្តាច់មុខ ខ្ពង់រាបបាតសមុទ្រ និងដែនអាកាសដោយយកចិត្តទុកដាក់លើការកសាងផែនការយុទ្ធសាស្ត្រការពារជាតិ ពង្រឹងទីតាំងឈរជើងរបស់កងឯកភាពជួរមុខ កសាងទីតាំងបង្អ

ក ប្រព័ន្ធការពារ ប្រព័ន្ធទំនាក់ទំនងបញ្ជា ប្រព័ន្ធគាំទ្រផ្លូវគមនាគមន៍។ល។ ដែលជាមូលដ្ឋានគ្រឹះដ៏រឹងមាំ សម្រាប់កិច្ចការពារជាតិ។

- ពង្រឹងការតស៊ូតាមផ្លូវច្បាប់នៅតុលាការអន្តរជាតិ ដើម្បីការពារអធិបតេយ្យរបស់កម្ពុជានៅតំបន់ប្រាសាទព្រះវិហារ លើកទឹកចិត្តប្រជាពលរដ្ឋតាំងទីលំនៅ កសាងភូមិស្ថានតាមព្រំដែន ដោយផ្សារភ្ជាប់នឹងការរឹតចំណងមិត្តភាព និងកិច្ចសហប្រតិបត្តិការជាមួយប្រទេសជិតខាង ដើម្បីកសាងព្រំដែនជាតំបន់សន្តិភាព សន្តិសុខ សហប្រតិបត្តិការ និងអភិវឌ្ឍន៍ពិតប្រាកដ។

- បន្តការអនុវត្តន៍កងយោធពលខេមរភូមិន្ទ ឲ្យស្របទៅនឹងការរីកចម្រើនប្រទេសជាតិ និងពិភពលោក ជាកងកម្លាំងដែលមានឧត្តមគតិស្មោះត្រង់ដាច់ខាតចំពោះជាតិមាតុភូមិ គោរពស្រឡាញ់ប្រជាពលរដ្ឋ មានឆន្ទៈប្រយុទ្ធប្តូរផ្តាច់ និងសមត្ថភាពគ្រប់គ្រាន់នៅក្នុងការការពារឯករាជ្យ សន្តិភាព អធិបតេយ្យ បូរណភាពទឹកដី និងសមិទ្ធផលនៃសង្គមជាតិបានរឹងមាំ ហើយចូលរួមសកម្មក្នុងដំណើរការអភិវឌ្ឍន៍ប្រទេសជាតិ។

- បន្តអភិវឌ្ឍន៍ធនធានមនុស្សក្នុងវិស័យការពារជាតិ តាមរយៈបង្កើនគុណភាពហ្វឹកហ្វឺននៅតាមសាលាហ្វឹកហ្វឺន ពង្រឹងសមត្ថភាពសាស្ត្រាចារ្យ កសាងជួរនាយទាហានវ័យក្មេងដែលជ្រើសរើសចេញពីសិស្ស និស្សិត និងពង្រឹងកិច្ចសហប្រតិបត្តិការជាមួយបណ្តាប្រទេសជាមិត្ត ដើម្បីពង្រឹងការបណ្តុះបណ្តាលយោធិនអាជីព។

- បន្តពង្រឹងខ្សែរយៈចាត់តាំង នៅក្នុងជួរកងទ័ពនៅគ្រប់ថ្នាក់ ដើម្បីធានាប្រសិទ្ធភាពនៃការគ្រប់គ្រងកម្លាំង និងបន្តលើកកម្ពស់សុខមាលភាពកងទ័ព ធានាការផ្តល់ភស្តុភារ ហិរញ្ញវត្ថុ និងសម្ភារៈបច្ចេកទេសគ្រប់ប្រភេទដល់កងទ័ពឲ្យបានល្អប្រសើរ ជាពិសេសចំពោះបណ្តាកងឯកភាពឈរជើងនៅខ្សែត្រៀមជួរមុខ និងកងការពារដែនកោះ។

- ពង្រឹង ពង្រីកទំនាក់ទំនង និងសហប្រតិបត្តិការអន្តរជាតិ សម្រាប់ការអភិវឌ្ឍន៍កងយោធពលខេមរភូមិន្ទ លើគ្រប់ផ្នែក និងបន្តចូលរួមក្នុងបេសកកម្មរក្សាសន្តិភាពពិភពលោក ក្នុងក្របខ័ណ្ឌកងរក្សាសន្តិភាពនៃអង្គការសហប្រជាជាតិ។

២. សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ

- ការពារសន្តិសុខជាតិ ប្រឆាំងដាច់ខាតរាល់អំពើដែលនាំទៅដល់ការបង្កអស្ថិរភាពនយោបាយ ការបង្កជម្លោះប្រដាប់អាវុធជាតិ ឬជាមួយប្រទេសជិតខាង និងមិនអនុញ្ញាតឲ្យប្រើប្រាស់ទឹកដីកម្ពុជាដើម្បីប្រឆាំងនឹងប្រទេសជិតខាង បង្ការដាច់ខាតមិនឲ្យកើតមានការគំរាម បំផ្លិចបំផ្លាញទ្រព្យសម្បត្តិអាយុជីវិត ឬមហន្តរាយដែលបង្កឡើងដោយអំពើភេរវកម្ម។

- បន្តពង្រឹងវិធានការគ្រប់គ្រងសង្គម ដោយគួបផ្សំនឹងការបង្កើនកិច្ចសហប្រតិបត្តិការជាមួយបណ្តាប្រទេសក្នុងតំបន់ និងពិភពលោកដើម្បីបង្ការ ទប់ស្កាត់ និងបង្ក្រាបមិនឲ្យមានក្រុមសង្គមងងឹតកើតមាននៅកម្ពុជា ព្រមទាំងការយកចិត្តទុកដាក់ស្រាវជ្រាវ ស៊ើបអង្កេត មិនទុកឲ្យមានខ្សែរយៈបណ្តាញឧក្រិដ្ឋជនឆ្លងដែនធ្វើសកម្មភាពបាន ឬប្រើប្រាស់កម្ពុជាជាភូមិសាស្ត្រគេចខ្លួនពីសំណាញ់ច្បាប់នៃប្រទេសក្រៅ។

- លើកកម្ពស់ចលនាមហាជនចូលរួមការពារសន្តិសុខ សុវត្ថិភាពនៅក្នុងមូលដ្ឋានឲ្យបានក្លៀវក្លា ដើម្បីពង្រឹងខឿនសន្តិសុខជាតិឲ្យកាន់តែរឹងមាំ តាមរយៈការបន្តជម្រុញចលនានៃការអនុវត្តន៍ គោលនយោបាយ «ភូមិ-ឃុំមានសុវត្ថិភាព» ឲ្យកាន់តែមាននិរន្តរភាព និងសកម្មនៅគ្រប់មូលដ្ឋានទូទាំងប្រទេស ព្រមទាំងពង្រឹងវិធានការទបស្កាត់ និងបង្ក្រាបបទល្មើសព្រហ្មទណ្ឌគ្រប់ប្រភេទ ដើម្បីបង្កភាពកក់ក្តៅក្នុងការរស់នៅ និងប្រកបមុខរបររបស់ប្រជាជន។
- បន្តផ្តោតការយកចិត្តទុកដាក់ លើការរៀបចំសណ្តាប់ធ្នាប់សាធារណៈឲ្យបានល្អប្រសើរ ស្របតាមស្ថានភាពប្រទេសជាតិ ដែលកំពុងមានការរីកចម្រើន ដោយយកចិត្តទុកដាក់គ្រប់គ្រងកត្តាជាមូលដ្ឋាននានា ក្នុងការធានាសណ្តាប់ធ្នាប់ និងសុវត្ថិភាពសង្គម។
- បន្តពង្រឹងការគ្រប់គ្រងជនបរទេសគ្រប់ប្រភេទនៅកម្ពុជា មិនទុកឲ្យមានមុខសញ្ញាគ្រោះថ្នាក់ ឬមុខសញ្ញាហាមឃាត់នានាអាចជ្រៀតចូលបាន បន្តជម្រុញការដោះស្រាយបញ្ហាជនអន្តោប្រវេសន៍ និងគ្រប់គ្រងអន្តោប្រវេសន៍ឲ្យមានប្រសិទ្ធភាព ព្រមទាំងដោះស្រាយអំពើល្មើសច្បាប់របស់ជនបរទេសយ៉ាងម៉ឹងម៉ាត់តាមច្បាប់ជាតិ និងអន្តរជាតិ។
- បន្តលើកកម្ពស់ សមត្ថភាពបំពេញភារកិច្ចរបស់កងកម្លាំងនគរបាលជាតិឲ្យកាន់តែមានវិជ្ជាជីវៈ ប្រកបដោយប្រសិទ្ធភាព ការទទួលខុសត្រូវ សីលធម៌ គុណធម៌ និងក្លាយជាស្ថាប័នបម្រើប្រយោជន៍ដ៏ស្មោះត្រង់ និងជាបង្អែកដែលជាទីទុកចិត្តកក់ក្តៅរបស់សង្គមជាតិ។

ការពង្រឹងរដ្ឋបាលសាធារណៈ: វិមជ្ឈការ និងវិសហមជ្ឈការ ការពង្រឹង ផ្នែកច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងការប្រឆាំងអំពើពុករលួយ

៣. ក្នុងការពង្រឹងរដ្ឋបាលសាធារណៈ: វិមជ្ឈការ និងវិសហមជ្ឈការ ការពង្រឹងផ្នែកច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងការប្រឆាំងអំពើពុករលួយ រាជរដ្ឋាភិបាលនឹងផ្តោតការយកចិត្តទុកដាក់លើវិធានការដូចតទៅ៖

- បន្តអនុវត្តការកែទម្រង់រដ្ឋបាលសាធារណៈ សំដៅឲ្យរដ្ឋបាលសាធារណៈ កាន់តែមានការឆ្លើយតបប្រកបដោយប្រសិទ្ធភាព ប្រសិទ្ធផល និងជំនឿទុកចិត្ត ហើយលើកកម្ពស់វប្បធម៌សាធារណៈ ឆន្ទៈម្ចាស់ការ ភក្តីភាព និងមនសិការវិជ្ជាជីវៈរបស់មន្ត្រីរាជការដើម្បីប្រែក្លាយរដ្ឋបាលសាធារណៈ ទៅជាអ្នកផ្តល់សេវាសាធារណៈដ៏មានប្រសិទ្ធភាព និងដែលបម្រើប្រជាជនបានកាន់តែល្អប្រសើរឡើង។

- បន្តផ្តោតលើការអនុវត្តន៍យុទ្ធសាស្ត្រទាំង៣នៃកម្មវិធីជាតិកែទម្រង់រដ្ឋបាល គឺ៖ (១). ការពង្រឹងគុណភាព និងប្រសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ (២). ការអភិវឌ្ឍន៍សមត្ថភាព ការកែលម្អការគ្រប់គ្រង និងការអភិវឌ្ឍន៍ធនធានមនុស្ស និងប្រព័ន្ធគ្រប់គ្រងគុណផលការងារ និង (៣). ការកែទម្រង់ប្រព័ន្ធបៀវត្ស និងប្រាក់បន្ថែមផ្សេងៗដើម្បីពង្រឹងប្រសិទ្ធភាពការងារ ព្រមទាំងការពង្រឹងក្របខ័ណ្ឌ និងការពង្រាយមន្ត្រីរាជការស៊ីវិល។

៤. ការអនុវត្តន៍ឲ្យកាន់តែស៊ីជម្រៅនូវការកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ តាមរយៈការពង្រឹងរដ្ឋបាល ថ្នាក់ក្រោមជាតិគ្រប់ថ្នាក់ គ្រប់ស្ថាប័ន និងប្រព័ន្ធគ្រប់គ្រង បន្តអភិវឌ្ឍន៍ធនធានមនុ

ស្ស ការផ្ទេរមុខងារ និងធនធាន ព្រមទាំងប្រព័ន្ធថវិកា ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិ ការកសាងសមត្ថភាពសំដៅធានាឲ្យរដ្ឋបាលថ្នាក់ក្រោមជាតិបំពេញការងារ ដោយមានការចូលរួម គណនេយ្យភាព តម្លាភាព និងការឆ្លើយតបក្នុងការ ផ្តល់សេវាសាធារណៈ សម្រាប់ការអភិវឌ្ឍន៍មូលដ្ឋាន និងការចូលរួមកាត់បន្ថយភាពក្រីក្រ ដើម្បីរួមចំណែកអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ចជាតិប្រកបដោយចីរភាព។

៥. បន្តផ្តោតការយកចិត្តទុដាក់អនុវត្ត២ភ្លាត់តែស៊ីជម្រៅនូវការកែទម្រង់

ច្បាប់ និងប្រព័ន្ធយុត្តិធម៌ សំដៅជម្រុញការរៀបចំក្របខ័ណ្ឌច្បាប់ឲ្យមានប្រសិទ្ធភាព និងកាន់តែទទួលបានការជឿទុកចិត្ត ព្រមទាំងពង្រឹងសមត្ថភាពមិនលម្អៀងនៃស្ថាប័នតុលាការ ដែលជាកត្តាដ៏សំខាន់នៃដំណើការពង្រឹងនីតិរដ្ឋ ការបែងចែកអំណាចដាច់ពីគ្នា ការគោរពសិទ្ធិបុគ្គល និងការធានាភាពយុត្តិធម៌សម្រាប់ប្រជាពលរដ្ឋទូទៅ។ ដើម្បីសម្រេចទិសដៅនេះ បណ្តាសកម្មភាពសំខាន់នឹងត្រូវបានជម្រុញយ៉ាងសកម្មមានជាអាទិ៍ៈ (១). សម្រាប់ការកែទម្រង់ច្បាប់ គឺជម្រុញការកសាងច្បាប់ថ្មីៗតាមការចាំបាច់នៃការគ្រប់គ្រងរដ្ឋ និងស្របតាមដំណើរការបង្កើតសហគមន៍អាស៊ានឆ្នាំ២០១៥ ការពង្រឹងការអនុវត្តន៍ច្បាប់នានាជាធរមាន ឲ្យកាន់តែមានប្រសិទ្ធភាព ការបង្កើនការអប់រំផ្សព្វផ្សាយ និងបណ្តុះបណ្តាលមន្ត្រីអនុវត្តច្បាប់គ្រប់ថ្នាក់ និងប្រជាពលរដ្ឋឲ្យបានទូលំទូលាយ ក្នុងវិស័យច្បាប់ និង (២). សម្រាប់ការកែទម្រង់ប្រព័ន្ធយុត្តិធម៌ គឺជម្រុញការកសាងច្បាប់ពាក់ព័ន្ធនឹងស្ថាប័នតុលាការមានជាអាទិ៍ៈ ច្បាប់ ស្តីពីការរៀបចំអង្គការតុលាការ ច្បាប់ស្តីពីលក្ខន្តិកៈ ចៅក្រម និងព្រះរាជអាជ្ញា និងវិសោធនកម្មច្បាប់ ស្តីពីការរៀបចំ និងការប្រព្រឹត្តិទៅនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម។

- បន្តជម្រុញស្ថាប័នតុលាការ និងអយ្យការ តាមរយៈការបន្តខិតខំបង្កើនសមត្ថភាពរបស់ចៅក្រម ព្រះរាជអាជ្ញា និងមន្ត្រីតុលាការ ព្រមទាំងការបង្កើតរដ្ឋបាលតុលាការ តាមសាលាជម្រះក្តីគ្រប់ជាន់ថ្នាក់ ដើម្បីឲ្យមានការដោះស្រាយរឿងក្តី តាមនីតិវិធីជាធរមានបានកាន់តែឆាប់រហ័ស និងប្រកបដោយយុត្តិធម៌។
- បន្តពង្រឹងក្រមសីលធម៌ មនសិការ វិជ្ជាជីវៈ និងវិន័យ តាមរយៈការបណ្តុះបណ្តាលបឋម និងការបណ្តុះបណ្តាលនៅរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ រួមទាំងការចុះធ្វើអធិការកិច្ចនៅតាមសាលាជម្រះក្រីរបស់អង្គភាពអធិការកិច្ចនៃក្រុមប្រឹក្សាវិន័យនៃឧត្តមអង្គចៅក្រម។
- បន្តជម្រុញការដោះស្រាយវិវាទក្រៅប្រព័ន្ធតុលាការ ដើម្បីកាត់បន្ថយចំនួនសំណុំរឿង ដែលមិនចាំបាច់នៅក្នុងតុលាការ និងកាត់បន្ថយភាពស្មុគ្រស្មាញនៅក្នុងសង្គម បន្តជម្រុញការកសាងអគារ និងបំពាក់សំភារៈសម្រាប់សាលាជម្រះក្តីឲ្យមានស្តង់ដារ ដើម្បីផ្តល់លទ្ធភាពទទួលបានយុត្តិធម៌ សម្រាប់ប្រជាជនគ្រប់រូប។

៦. បន្តប្រយុទ្ធប្រឆាំងអំពើពុករលួយ

តាមរយៈការពង្រឹង និងការបង្កើនប្រសិទ្ធភាពនៃការអនុវត្តន៍វិធានការលើកស្ទួយទាំង៣ គឺការអប់រំដើម្បីឲ្យម្នាក់ៗ ទាំងអ្នកដើមចម និងអ្នកទទួលផលមិនប្រព្រឹត្តអំពើពុករលួយ ការបង្ការទប់ស្កាត់ ដើម្បីម្នាក់ៗមិនអាចប្រព្រឹត្តអំពើពុករលួយ និងការបង្ក្រាបបទល្មើលបញ្ជូនទៅតុលាការដើម្បីឲ្យម្នាក់ៗ មិនហ៊ានប្រព្រឹត្តអំពើពុករលួយ។

- ពង្រឹងអភិបាលកិច្ចល្អ និងនីតិរដ្ឋ ព្រមទាំងរក្សាភាពស្អាតស្អំ និងយុត្តិធម៌របស់មន្ត្រីដើម្បីធានាបាននូវការលើកកម្ពស់ប្រសិទ្ធភាពនៃសេវាគ្រប់បែបយ៉ាង ដែលជាកត្តាចាំបាច់ក្នុងការអប់រំខ្លួន សង្គមជាតិ និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន។
- បន្តអនុវត្តឲ្យបានសកម្ម និងមានលទ្ធផលខ្ពស់ ក្នុងការលុបបំបាត់ការយកកម្រៃសេវាខុសច្បាប់នៅរដ្ឋបាលថ្នាក់ក្រោមជាតិនៅក្រសួងស្ថាប័ន មន្ទីរ និងការិយាល័យនានា គឺមិនមានការទារលុយតាមកន្លែងធ្វើការ តាមផ្សារ តាមដងផ្លូវ តាមដងទន្លេ ឬច្រកព្រំដែនដើម្បីបំបាត់ឱកាស និងរារាំងអំពុករលួយ។

ការអភិវឌ្ឍន៍សេដ្ឋកិច្ច

ក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ច រាជរដ្ឋាភិបាលកម្ពុជាមានវិធានការការពារគោលនយោបាយសំខាន់ៗដូចតទៅ៖

៧.ការគ្រប់គ្រងម៉ាក្រូសេដ្ឋកិច្ច ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ

- បន្តរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងកំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយចីរភាព ក្នុងបរិការណ៍អតិផរណាមានកម្រិតទាប និងអាចគ្រប់គ្រងបាន ហើយអត្រាប្តូរប្រាក់មានស្ថិរភាពដើម្បីធានាបរិស្ថាន អនុគ្រោះសម្រាប់ការអភិវឌ្ឍន៍ ការកាត់បន្ថយភាពក្រីក្រ និងការធ្វើសមាហរណកម្មក្នុងតំបន់ និងពិភពលោក។
- ខិតខំសម្រេចឲ្យបាននូវកំណើនសេដ្ឋកិច្ចជាមធ្យម៧%ក្នុងមួយឆ្នាំ ដើម្បីធ្វើឲ្យប្រទេសកម្ពុជា អាចចេញផុតពីប្រទេសមានចំណូលទាប ឈានឡើងជាប្រទេសមានចំណូលមធ្យមកម្រិត យ៉ាងយូរនៅឆ្នាំ២០១៨ និងក្លាយជាមានចំណូលកម្រិតមធ្យម កម្រិតខ្ពស់នៅឆ្នាំ២០៣០។ ជាមួយនេះ គោលដៅអភិវឌ្ឍន៍សហស្សវត្សឆ្នាំ២០១៥របស់កម្ពុជា និងគោលដៅកាត់បន្ថយអត្រានៃភាពក្រីក្រជាង១%ក្នុងមួយឆ្នាំ ក៏ត្រូវសម្រេចឲ្យបាន ក្នុងនោះរួមទាំង ការខិតខំរួមចំណែកធ្វើឲ្យសម្រេចបាននូវគោលដៅសហគមន៍សេដ្ឋកិច្ចអាស៊ានឆ្នាំ២០១៥។ ទន្ទឹមនឹងនេះ ការរីកចម្រើនខាងសេដ្ឋកិច្ចត្រូវតែធានានូវកាលានុវត្តភាព ការចូលរួម និងការទទួលផលដោយសមធម៌ សម្រាប់ប្រជាពលរដ្ឋគ្រប់ស្រទាប់។
- បន្តអនុវត្តគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈសមស្រប គួបផ្សំនឹងគោលនយោបាយរូបិយវត្ថុដ៏ប្រយ័ត្នប្រយែងប្រកបដោយប្រសិទ្ធភាព។
- បន្តការខិតខំធ្វើពិពិធកម្មមូលដ្ឋានកំណើនសេដ្ឋកិច្ច ដោយឈរលើមូលដ្ឋានភាពប្រកួតប្រជែងនៃសេដ្ឋកិច្ចកម្ពុជា និងការផ្សារភ្ជាប់សេដ្ឋកិច្ចកម្ពុជាជាមួយបណ្តាផលិតផលក្នុងតំបន់ ក្នុងនោះយកចិត្តទុកដាក់ជាពិសេសលើការបន្តអនុវត្តគោលនយោបាយអភិវឌ្ឍន៍វិស័យឧស្សាហកម្ម កម្មន្តសាល និងកសិ-ឧស្សាហកម្ម ព្រមទាំងការអនុវត្តន៍ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យទេសចរណ៍ឆ្នាំ២០១២- ឆ្នាំ២០២០។
- បន្តជម្រុញការអនុវត្តន៍កម្មវិធី កែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដើម្បីសម្រេចបាននូវប្រព័ន្ធហិរញ្ញវត្ថុសាធារណៈមួយ ដែលមានលក្ខណៈស្តង់ដារអន្តរជាតិ សំដៅធ្វើឲ្យប្រព័ន្ធនេះក្លាយជាឧបករណ៍អភិវឌ្ឍន៍មួយដ៏មានប្រសិទ្ធភាព ក្នុងការជម្រុញកំណើនសេដ្ឋកិច្ច ធានាសមធម៌ យុត្តិធម៌សង្គម ធានាទ្រទ្រង់ប្រតិបត្តិការរដ្ឋ និងការផ្តល់សេវាសាធារណៈ ព្រមទាំងរួមចំណែករក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងស្ថិរភាពហិរញ្ញវត្ថុ។

៨. បន្តខិតខំជម្រុញការប្រមូលថវិកាជាតិ

ទាំងចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធឲ្យមានកំណើនជារៀងរាល់ឆ្នាំ។ ខាងផ្នែកចំណាយ គឺបន្តផ្តល់អាទិភាពលើវិស័យសេដ្ឋកិច្ច សង្គមកិច្ច ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ការបង្កើនសមត្ថភាព និងការលើកកម្ពស់ជីវភាពរបស់មន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធដោយផ្សារភ្ជាប់ចំណាយសំរាប់វិស័យនីមួយៗ ទៅនឹងគណនេយ្យភាពនៃសមិទ្ធកម្មនៅក្នុងវិស័យនោះ។ ទន្ទឹមនេះការគ្រប់គ្រងការប្រមូលចំណូល និងការចាត់ចែងចំណាយ ត្រូវផ្តោតការយកចិត្តទុកដាក់លើប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព គួបផ្សំជាមួយនឹងការបន្តយកចិត្តទុកដាក់ខ្ពស់ជានិច្ច ក្នុងការគ្រប់គ្រងបំណុលសាធារណៈឲ្យស្ថិតក្នុងលទ្ធភាពទ្រទ្រង់នៃសេដ្ឋកិច្ចជាតិ។

- បន្តខិតខំបង្កើនអតិរេកចរន្ត ដើម្បីធានាដល់តម្រូវការវិនិយោគសាធារណៈ និងសេវាបំណុល ព្រមទាំងបង្កលក្ខណៈដល់ការសន្សំទុនបម្រុងរបស់រដ្ឋ។

៩. បន្តអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ

សំដៅកសាងប្រព័ន្ធហិរញ្ញវត្ថុមួយចំនួនដ៏រឹងមាំ មានការគ្រប់គ្រង និងការត្រួតពិនិត្យសមស្របមានលក្ខណៈប្រកួតប្រជែង និងសមាហរណកម្ម ព្រមទាំងមានតម្លាភាព និងប្រសិទ្ធភាព ជាពិសេសផ្អែកលើគោលការណ៍ទីផ្សារដែលបម្រើឲ្យការកៀងគរ និងបែងចែកធនធានប្រកបដោយប្រសិទ្ធភាព តាមរយៈការបន្តជម្រុញការអនុវត្តន៍យុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ មិនមែនធនាគារសំដៅគាំទ្រដល់ពិពិធកម្មសេដ្ឋកិច្ច នវានុវត្តន៍ និងភាពប្រកួតប្រជែងនៃសេដ្ឋកិច្ចកម្ពុជា ជាពិសេសវិស័យកសិ-ឧស្សាហកម្ម និងកម្មន្តសាល ក៏ដូចលទ្ធភាពទទួលបានសេវាហិរញ្ញវត្ថុសំរាប់សហគ្រាសធុនតូច មធ្យម និងសម្រាប់ប្រជាជនទូទៅ ព្រមទាំងជម្រុញការធ្វើសមាហរណកម្មហិរញ្ញវត្ថុជាមួយបណ្តាប្រទេសក្នុងតំបន់អាស៊ាន។

- បន្តអនុវត្តគោលនយោបាយរូបិយវត្ថុ ប្រកបដោយភាពទន្ទឹម និងប្រុងប្រយ័ត្នដែលរួមចំណែកដល់ការរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងបង្កើនបរិស្ថានអំណោយផលដល់ការអភិវឌ្ឍន៍។
- បន្តរក្សារបបអត្រាប្តូរប្រាក់អណ្តែតមានការគ្រប់គ្រង ដើម្បីរក្សាស្ថិរភាពប្រាក់រៀល ពង្រឹងជំនឿទុកចិត្តរបស់សាធារណជន និងវិនិយោគមកលើប្រាក់រៀល ជំរុញការប្រើប្រាស់ប្រាក់រៀលលើមូលដ្ឋានស្ថិរភាពតម្លៃប្រាក់រៀល និងកាត់បន្ថយដុល្លារូបនីយកម្ម។
- បន្តពង្រឹងប្រព័ន្ធធនាគារឲ្យកាន់តែមានប្រសិទ្ធភាព សមាហរណកម្ម និងការប្រកួតប្រជែង តាមរយៈការបង្កើនប្រសិទ្ធភាពនៃការត្រួតពិនិត្យ ការគ្រប់គ្រងហានិភ័យ សន្ធនីយភាព ហានិភ័យឥណទាន និងហានិភ័យទីផ្សារដោយអនុលោមតាមស្តង់ដារអន្តរជាតិ។
- បន្តពង្រឹងប្រព័ន្ធមីក្រូហិរញ្ញវត្ថុឲ្យកាន់តែមានភាពរឹងមាំ មានប្រសិទ្ធភាព និងបម្រើផលប្រយោជន៍នៃស្រទាប់ប្រជាជនក្រីក្រ ជាមួយនឹងតម្លៃសេវាហិរញ្ញវត្ថុសមស្របដែលអាចទទួលយកបាន។
- បន្តជម្រុញការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុមិនមែនធនាគារដូចជា៖ វិស័យធានារ៉ាប់រង វិស័យសោធន៍ វិស័យមូលបត្រ និងវិស័យអចលនទ្រព្យជាដើម។

១០. ភាពជាដៃគូក្នុងការអភិវឌ្ឍន៍

- បន្តពង្រឹងភាពជាដៃគូជាមួយសហគមន៍ដៃគូសហប្រតិបត្តិការអភិវឌ្ឍន៍ វិស័យឯកជន និងសង្គមស៊ីវិល ដោយឈរលើគោលការណ៍ជាមូលដ្ឋានដែលមានចរិតសកល និងធានាភាពជាម្ចាស់របស់រដ្ឋ ក្នុងការដឹកនាំការអភិវឌ្ឍន៍ប្រទេសជាតិ។

- ពង្រឹង និងពង្រីកសហប្រតិបត្តិការជាមួយអង្គការមិនមែនរដ្ឋាភិបាល និងសមាគមនានាដែលត្រូវបានបង្កើតឡើងដោយស្របច្បាប់ ហើយធ្វើប្រតិបត្តិការដោយឈរលើគោលការណ៍អភិបាលកិច្ចល្អ និងនីតិរដ្ឋ ដើម្បីចូលរួមក្នុងដំណើរការអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ច ការលើកកម្ពស់លទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្ស ព្រមទាំងចូលរួមតាមដានការអនុវត្តន៍គោលនយោបាយផងដែរ។
- បន្តពង្រឹងយន្តការវេទិកានៃកិច្ចសហប្រតិបត្តិការអភិវឌ្ឍន៍កម្ពុជា វេទិការាជរដ្ឋាភិបាល និងវិស័យឯកជន និងវេទិការាជរដ្ឋាភិបាលជាមួយអង្គការមិនមែនរដ្ឋាភិបាល ហើយជម្រុញឲ្យវេទិកាទាំងនេះ ក្លាយជាវេទិកានៃការអភិវឌ្ឍន៍កម្ពុជា ដែលជាយន្តការសម្រាប់ឲ្យរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ទាំងអស់ចូលរួមពិភាក្សារាល់បញ្ហាដែលពាក់ព័ន្ធនឹងការអភិវឌ្ឍន៍ ទាំងវិស័យសាធារណៈ ទាំងវិស័យឯកជន។

១១.កសិកម្ម

- បន្តអភិវឌ្ឍន៍វិស័យកសិកម្មឲ្យក្លាយជាផ្នែកនាំមុខមួយ ដែលមានប្រៀបខ្លាំងពិតប្រាកដ ដើម្បីធ្វើជាមូលដ្ឋានដ៏រឹងមាំនៃកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព ធានាសន្តិសុខស្បៀង បង្កើនការងារ និងប្រាក់ចំណូលសម្រាប់ប្រជាជន ពិសេសប្រជាជននៅជនបទ ហើយរួមចំណែកដល់ការការពារបរិស្ថាន និងធនធានធម្មជាតិប្រកបដោយចីរភាព។ ដើម្បីសម្រេចគោលដៅនេះ ការអនុវត្តន៍នូវបណ្តាកម្មវិធីសំខាន់ៗមួយចំនួនត្រូវផ្តោតការយកចិត្តទុកដាក់ ក្នុងនោះរួមមានការបញ្ចូលបច្ចេកវិទ្យាក្នុងវិស័យកសិកម្ម ការបង្កើនផលិតភាព និងពិពិធកម្មកសិកម្ម ទាំងការដាំដុះ និងការចញ្ចឹម ការជម្រុញការចូលទីផ្សារអន្តរជាតិនៃផលិតផលកសិកម្មរបស់កម្ពុជា ការគ្រប់គ្រង និងការអភិវឌ្ឍន៍ធនធានជលផល និងការការពារ និងគ្រប់គ្រងធនធានព្រៃឈើប្រកបដោយចីរភាព។
- បន្តខិតខំសម្រេចនូវគោលនយោបាយ ជម្រុញផលិតកម្មស្រូវ និងការនាំចេញអង្ករឲ្យបាន១លានតោន នៅឆ្នាំ២០១៥ សំដៅប្រែក្លាយកម្ពុជាទៅជាប្រទេសផលិតស្បៀងនាំមុខមួយនៅលើពិភពលោក។
- រក្សាផ្ទៃនេសាទទឹកសាប សម្រាប់ប្រជាជនធ្វើនេសាទជាលក្ខណៈគ្រួសារ ពង្រឹងតំបន់អភិរក្សបង្កើនការការពារធនធានជលផល លុបបំបាត់បទល្មើសនេសាទគ្រប់រូបភាព និងជម្រុញការអភិវឌ្ឍន៍វារីវប្បកម្ម រួមនិងការបន្តពង្រឹង និងពង្រឹងសហគមន៍នេសាទ។
- រក្សាដីដែលគ្របដណ្តប់ដោយព្រៃឈើ ដោយត្រូវបង្កើនការការពារធនធានព្រៃឈើ ពិសេសការពង្រឹងការអនុវត្តន៍ច្បាប់ ស្តីពីព្រៃឈើ ការទប់ស្កាត់ បង្ក្រាបបទល្មើសព្រៃឈើ ជម្រុញការដាំដើមឈើឡើងវិញ និងបង្កើនសមត្ថភាពសហគមន៍ព្រៃឈើ នៅលើមូលដ្ឋានធានាចីរភាព និងប្រសិទ្ធភាពគ្រប់គ្រង។
- បន្តផ្តោតការយកចិត្តទុកដាក់ ជម្រុញការអភិវឌ្ឍន៍ដំណាំកៅស៊ូឲ្យរីកចម្រើនទាំងបរិមាណ និងគុណភាពឲ្យក្លាយទៅជាវិស័យដ៏មានសក្តានុពល និងភាពប្រកួតប្រជែង តាមរយៈការពង្រីកការដាំដុះកៅស៊ូប្រកបដោយទិន្នផលខ្ពស់ ដោយបន្តអនុវត្តយុទ្ធសាស្ត្រសម្រាប់ការអភិវឌ្ឍន៍កៅស៊ូធម្មជាតិ នៅឆ្នាំ២០១១-២០២០ សំដៅធ្វើឲ្យផ្ទៃដីដាំកៅស៊ូកើនឡើងដល់៣០ម៉ឺនហិកតា និងមានបរិមាណផលិតផលពី២៥ម៉ឺនតោននៅឆ្នាំ២០២០។ ទន្ទឹមនេះ យុទ្ធសាស្ត្រអភិវឌ្ឍន៍កៅស៊ូធម្មជាតិនឹងផ្តោតលើការធានាគុណភាព និងផលិតភាពនៃការដាំដុះកៅស៊ូ ការសិក្សាលទ្ធភាពប្រើប្រាស់សក្តានុពលដីទំនេរ ដែលអាចដាំកៅស៊ូបាន ការជំរុញការដាំដុះកៅស៊ូគ្រួសារ ការជំរុញចម្ការកៅស៊ូឧស្សាហកម្មដើម្បីធ្វើជាស្នូលនៃការអភិវឌ្ឍន៍ចម្ការកៅស៊ូគ្រួសារ និងការជម្រុញតម្លៃឲ្យបានខ្ពស់។

- បញ្ឈប់ការផ្តល់សម្បទានដីសេដ្ឋកិច្ច។ ជាមួយគ្នានេះ ដីសម្បទានសេដ្ឋកិច្ចនឹងត្រូវបានធ្វើសន្និធិ ហើយការគ្រប់គ្រងប្រភេទដីនេះនឹងត្រូវបានពង្រឹងឲ្យបានត្រឹមត្រូវ តាមច្បាប់លិខិតបទដ្ឋាន និងកិច្ចសន្យាជាពិសេស តាមរយៈការបង្កើនយន្តការចុះពិនិត្យផ្ទៀងផ្ទាត់ជាប្រចាំ នូវសកម្មភាពវិនិយោគរបស់ក្រុមហ៊ុនទទួលដីសម្បទាននានា ដែលចុះកិច្ចសន្យាជាមួយរាជរដ្ឋាភិបាល ដើម្បីធានាដល់កិច្ចដំណើរការនៃសកម្មភាពវិនិយោគផង និងទប់ស្កាត់នូវភាពអសកម្មផ្សេងៗ ដែលអាចកើតមានទាក់ទងនឹងដីសម្បទានផង។

ដីធ្លី និងសំណង់

១២. បន្តអនុវត្តការកែទម្រង់ដីធ្លី

ដែលផ្តោតលើការងាររដ្ឋបាលដីធ្លី ការរៀបចំដែនដី និងនគរូបនីយកម្ម ការបែងចែកដីធ្លី និងការអភិវឌ្ឍន៍វិស័យសំណង់ដើម្បីការពារសិទ្ធិលើដីធ្លីរបស់ប្រជាជន ព្រមទាំងការគ្រប់គ្រងការប្រើប្រាស់ធនធានធម្មជាតិ និងដីរដ្ឋប្រកបដោយតម្លាភាព សមធម៌ ចីរភាព និងប្រសិទ្ធភាព។

- បន្តអនុវត្តគោលនយោបាយ មិនយកពន្ធលើដីធ្លីបង្កបង្កើនផលរបស់កសិករជាលក្ខណៈគ្រួសារ។
- បន្តជម្រុញការចុះបញ្ជី និងការផ្តល់កម្មសិទ្ធិដីធ្លី ទាំងដីរដ្ឋ និងដីឯកជន និងដីសហគមន៍ ដើម្បីធានាសុវត្ថិភាពនៃការកាន់កាប់ដីធ្លី ដោយជម្រុញល្បឿននៃការចុះបញ្ជីដីធ្លី សំដៅឈានទៅរកសម្រេចឲ្យបាន ១០០% នូវការចុះបញ្ជីដីធ្លី តាមផែនការនៃបទបញ្ជាលេខ០១របស់រាជរដ្ឋាភិបាលជិត២លានហិកតា នៅរវាងឆ្នាំ២០១៤ ក្នុងក្របខ័ណ្ឌនៃការអនុវត្តន៍ «នយោបាយចាស់-សកម្មភាពថ្មីលើវិស័យដីធ្លី» និងសម្រេចឲ្យបាន៧០% ដល់ឆ្នាំ២០១៨ លើបរិមាណក្បាលដី ដែលត្រូវចុះបញ្ជីសរុប៦ ទៅ៧លានក្បាលដីដីនៅទូទាំងប្រទេស។
- បន្តខិតខំកាត់បន្ថយ និងឈានទៅលុបបំបាត់ឲ្យបាន ភាពអនាធិបតេយ្យរំលោភកាន់កាប់ដីគ្រប់ប្រភេទ ដោយខុសច្បាប់ ទប់ស្កាត់ការប្រមូលដីទុកមិនប្រើប្រាស់ ឬមិនធ្វើអាជីវកម្ម ដោះស្រាយទំនាស់ដីធ្លីប្រកបដោយតម្លាភាព និងយុត្តិធម៌ ដោយពង្រឹងការប្រតិបត្តិឲ្យបានត្រឹមត្រូវតាមក្របខណ្ឌគតិយុត្តិជាធរមាន ព្រមទាំងឆ្លើយតបទៅនឹងគោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការនៃការងារដីធ្លី។
- ជំរុញការកំណត់ព្រំប្រទល់រដ្ឋបាលថ្នាក់ក្រោមជាតិ និងកសាងយុទ្ធសាស្ត្រជាតិនៃការអភិវឌ្ឍន៍ទីក្រុង ទីប្រជុំជន និងតំបន់ឆ្នេរ។
- បន្តធានាការគ្រប់គ្រង ការការពារ និងការប្រើប្រាស់ដី និងធនធានធម្មជាតិប្រកបដោយតម្លាភាព និងប្រសិទ្ធភាព ដើម្បីរក្សានិរន្តរភាពបរិស្ថាន និងការអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ចប្រកបដោយសមធម៌ ទាំងនៅទីប្រជុំជន និងជនបទ ព្រមទាំងទប់ស្កាត់វិវាទនៃការប្រើប្រាស់ដី ដោយពង្រឹងការអនុវត្តន៍តាមច្បាប់ ស្តីពីការរៀបចំដែនដី និងនគរូបនីយកម្ម ច្បាប់សំណង់ ក្របខ័ណ្ឌយុទ្ធសាស្ត្រនៃគោលនយោបាយដីធ្លី គោលនយោបាយវិមជ្ឈការ និងវិសហមជ្ឈការ និងអភិបាលកិច្ចល្អ។
- កសាងគោលនយោបាយជាតិ ស្តីពីលំនៅដ្ឋាន ដើម្បីដោះស្រាយលំនៅដ្ឋានជូនប្រជាជនក្រីក្រសំរាប់ការរស់នៅប្រកបដោយសុវត្ថិភាព សុខមាលភាព និងជាសុកភាពថ្លៃថ្នូរ។

- បន្តបែងចែក និងប្រើប្រាស់ដីរដ្ឋសម្រាប់គោលបំណងឯកជន និងសាធារណៈប្រកបដោយតម្លាភាព និងសមធម៌ ឆ្លើយតបទៅនឹងតម្រូវការដីរបស់ប្រជាជនទូទៅ ជាពិសេសប្រជាជនក្រីក្រ យុទ្ធជនពិការ គ្រួសារយុទ្ធជនពលី អតីតៈកងកម្លាំងប្រដាប់អាវុធ និងគ្រួសារដែលគ្មានដី ខ្វះដី ហើយត្រូវការដីពិតប្រាកដ តាមរយៈកម្មវិធីសម្បទានសង្គមកិច្ច និងការធ្វើប្រទានកម្មដោយធានាឲ្យបាននូវសមធម៌ ស្ថិរភាពសង្គម សន្តិសុខស្បៀង និងការសម្រួលដល់ការវិនិយោគ។
- បន្តលៀនផ្តល់ដីសម្បទានសង្គមកិច្ច នៅលើមូលដ្ឋាននៃសន្និធិរដ្ឋក្នុងការអនុវត្តន៍ «នយោបាយចាស់-សកម្មភាពថ្មីលើវិស័យដីធ្លី» សម្រាប់គោលដៅនេះ។
- ទប់ស្កាត់ការកើតឡើងមានទៀតនូវភាពមិនប្រក្រតីនៃការទន្ទ្រានកាន់កាប់ដីរដ្ឋ។
- បន្តជម្រុញការបោសសម្អាតមីន និងយុទ្ធភណ្ឌមិនទាន់ផ្ទុះ និងអនុវត្តការបែងចែកដីដែលបានបោសសំអាតរួចជូនប្រជាជនដែលខ្វះខាតដីប្រកបដោយសមធម៌។

១៣. បន្តពង្រឹងការគ្រប់គ្រង និងការអភិវឌ្ឍន៍វិស័យសំណង់

ដែលជាសរសរស្តម្ភមួយនៃកំណើនសេដ្ឋកិច្ច និងកំពុងមានការរីកចម្រើនយ៉ាងខ្លាំង ដោយផ្តោតលើការជំរុញវិនិយោគក្នុងវិស័យសំណង់ ការកសាងច្បាប់ ការកំណត់ស្តង់ដារសំណង់ និងពន្លឿនរយៈពេលចេញលិខិតអនុញ្ញាតសាងសង់ជូនប្រជាជន។

ឧស្សាហកម្ម សិប្បកម្ម និងធនធានរ៉ែ

១៤. បន្តអភិវឌ្ឍន៍វិស័យឧស្សាហកម្ម

កម្មន្តសាល សិប្បកម្មប្រកបដោយចីរភាព ដែលមានលក្ខណៈចម្រុះសម្បូរបែប មានការទទួលខុសត្រូវខាងបរិស្ថាន និងសង្គមខ្ពស់ ហើយពង្រីកបាននូវអន្តរកម្មសេដ្ឋកិច្ច រវាងផ្នែកកែច្នៃកម្មន្តសាលជាមួយវិស័យកសិកម្ម ពាណិជ្ជកម្ម និងសេវាកម្មដើម្បីជម្រុញសមាហរណកម្មសេដ្ឋកិច្ច ខ្សែសង្វាក់តម្លៃ និងភាពប្រកួតប្រជែងរបស់កម្ពុជានៅក្នុងតំបន់ និងពិភពលោក។ ឆ្លងតាមការជម្រុញការអភិវឌ្ឍន៍ឧស្សាហកម្មសេដ្ឋកិច្ច នឹងត្រូវបានអនុវត្តជាជំហានៗ ដែលនឹងនាំកម្ពុជាឈានទៅដល់ដំណាក់កាលថ្មីនៃពិពិធកម្មមូលដ្ឋានសេដ្ឋកិច្ច តាមរយៈការប្រើប្រាស់បណ្តាលក្ខខណ្ឌអំណោយផល និងឧត្តមភាពប្រៀបធៀបរបស់កម្ពុជាប្រកបដោយប្រសិទ្ធភាព។

- បន្តផ្តោតការខិតខំថែមទៀត លើការពង្រឹងភាពអំណោយផលិតផលនៃបរិស្ថានវិនិយោគ ការជម្រុញការអភិវឌ្ឍន៍តំបន់សេដ្ឋកិច្ចពិសេស ការលើកកម្ពស់ផលិតភាព និងសហគ្រិនភាពរបស់សហគ្រាសធុនតូច និងមធ្យម ការពង្រីកលទ្ធភាពទទួលបានបច្ចេកវិជ្ជាជឿនលឿន ការបណ្តុះបណ្តាលជំនាញ និងវិជ្ជាជីវៈ ព្រមទាំងការលើកកម្ពស់ការងារស្តង់ដារូបនីយកម្ម ការវាយតម្លៃភាពអនុលោម និងមាត្រាសាស្ត្រ។ ទិសដៅជាសារវន្តនៃគោលនយោបាយនៃការអភិវឌ្ឍន៍ឧស្សាហកម្មនៅពេលខាងមុខនេះ គឺជាការច្បាមយកតម្លៃបន្ថែមឲ្យបានកាន់តែច្រើននៅក្នុងវិស័យសំខាន់ៗ ដែលមានសម្រាប់រួមមាន៖ វិស័យកសិសិកម្ម។

១៥. អភិវឌ្ឍន៍ធនធានរ៉ែ ប្រេងភាត និងឧស្ម័ន

ដើម្បីប្រែក្លាយធនធាននេះឲ្យទៅជាប្រភពថ្មីមួយទៀតនៃកំណើនសេដ្ឋកិច្ចរបស់កម្ពុជា។

- លើកទឹកចិត្តឲ្យវិស័យឯកជនវិនិយោគ លើការសិក្សាស្រាវជ្រាវ និងការធ្វើអាជីវកម្មធនធានទាំងនោះ តាមច្បាប់ជាធរមាន ដោយយកចិត្តទុកដាក់សំខាន់លើសុវត្ថិភាព សុខមាលភាព ព្រមទាំងការការពារ

បរិស្ថាន និងសង្គម បន្តរៀបចំ និងធ្វើបច្ចុប្បន្នភាពបទប្បញ្ញត្តិ និងលិខិតបទដ្ឋាននានាដែលទាក់ទងនឹងធនធានរ៉ែ ប្រេងកាត និងឧស្ម័នដើម្បីធានាការអភិវឌ្ឍន៍ធនធាននេះប្រកបដោយប្រសិទ្ធភាព និងមានការទទួលខុសត្រូវខ្ពស់។ ទន្ទឹមនេះ ចំណូលដែលបានមកពីធនធានរ៉ែ ប្រេងកាត និងឧស្ម័នត្រូវបានគ្រប់គ្រង និងប្រើប្រាស់ប្រកបដោយប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព ដោយផ្សារភ្ជាប់ជាមួយកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត

១៦. ហេដ្ឋារចនាសម្ព័ន្ធគមនាគមន៍

- បន្តបង្កើនការស្តារ ការសាងសង់ និងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនប្រកបដោយគុណភាពសម្រាប់បម្រើឲ្យការដឹកជញ្ជូនពហុរូបភាព គឺទាំងការដឹកជញ្ជូនផ្លូវគោក ផ្លូវដែក ផ្លូវទឹក កំពង់ផែ និងការដឹកជញ្ជូនផ្លូវអាកាសដែលតភ្ជាប់រវាងគ្រប់តំបន់នៅទូទាំងប្រទេស តភ្ជាប់ជាមួយបណ្តាប្រទេសក្នុងតំបន់ និងពិភពលោក ដើម្បីធានាការធ្វើដំណើរគ្រប់ច្រកល្អក និងការផ្តល់សេវាដឹកជញ្ជូនបានគ្រប់គ្រាន់ គ្រប់រដូវកាលប្រកបដោយផាសុកភាព សណ្តាប់ធ្នាប់ ប្រសិទ្ធភាព និងមានតម្លៃទាប។
- បន្តផ្តល់អាទិភាពខ្ពស់ដល់ការស្តារ និងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធផ្លូវថ្នល់គ្រប់ប្រភេទ ទាំងផ្លូវជាតិ ផ្លូវខេត្ត និងផ្លូវជនបទ។ ក្នុងនោះខិតខំកែលម្អផ្លូវលំជនបទជាជំហានៗ ពីផ្លូវក្រាលក្រួសក្រហមទៅជាផ្លូវក្រាលកៅស៊ូ ឬផ្លូវបេតុងឲ្យបានពី៣០០ ទៅ៤០០គីឡូម៉ែត្រក្នុង១ឆ្នាំ តាមស្តង់ដារឯកភាពជាតិមួយ។
- បន្តពង្រឹងរាល់វិធានការដ៏ម៉ឺងម៉ាត់ ដើម្បីធានាការគ្រប់គ្រងការងារថែទាំផ្លូវថ្នល់ឲ្យមានប្រសិទ្ធភាព ទន្ទឹមនឹងការបន្តស្តារ និងការអភិវឌ្ឍន៍ផ្លូវ។
- បន្តលើកទឹកចិត្តជម្រុញការចូលរួមពីវិស័យឯកជន ក្នុងការវិនិយោគលើការអភិវឌ្ឍន៍ និងថែរក្សាហេដ្ឋារចនាសម្ព័ន្ធ ព្រមទាំងសេវាដឹកជញ្ជូន។
- លើកកម្ពស់ប្រសិទ្ធភាពគ្រប់គ្រង មធ្យោបាយដឹកជញ្ជូនគ្រប់ប្រភេទ ឲ្យមានលក្ខណៈសម្បត្តិខាងបច្ចេកទេសគ្រប់គ្រាន់ ដើម្បីធ្វើចរាចរណ៍នៅលើផ្លូវសាធារណៈ។
- ផ្សព្វផ្សាយអប់រំដល់ប្រជាជនទូទៅ ឲ្យបានយល់ដឹងច្បាស់អំពីច្បាប់ចរាចរណ៍ ហើយចូលរួមអនុវត្តយ៉ាងសកម្ម ដើម្បីធានាសុវត្ថិភាពចរាចរណ៍ និងការគោរពថែរក្សាទ្រព្យសម្បត្តិសាធារណៈ។
- រៀបចំគោលនយោបាយដឹកជញ្ជូនទីក្រុង ជាពិសេស រាជធានីភ្នំពេញសម្រាប់រយៈពេលមធ្យម និងរយៈពេលវែង ដើម្បីពង្រីកហេដ្ឋារចនាសម្ព័ន្ធ កសាងមធ្យោបាយដឹកជញ្ជូន ដើម្បីរួមជាប្រយោជន៍សំរាប់ដោះស្រាយបញ្ហាកកស្ទះ និងពង្រឹងសណ្តាប់ធ្នាប់ចរាចរណ៍ទីក្រុង ដែលកាន់តែមានភាពលំបាកស្មុគស្មាញឡើងពីមួយថ្ងៃ ទៅមួយថ្ងៃ ដោយសារកំណើនប្រជាជន និងកំណើនយ៉ាងលឿននៃបរិមាណយានយន្តគ្រប់ប្រភេទ។
- បន្តស្តារឡើងវិញនូវបណ្តាញផ្លូវដែកនៅកម្ពុជាដែលមានស្រាប់ គឺបណ្តាញពាយ័ព្យទិស និរតីទិសដើម្បីពង្រឹងវិសាលភាពនៃការដឹកជញ្ជូនទំនិញ អ្នកដំណើរ និងការដឹកជញ្ជូនឆ្លងកាត់ព្រំដែន ព្រមទាំងធ្វើសមាហរណកម្មផ្លូវដែកកម្ពុជា ទៅជាបណ្តាញផ្លូវដែកតំបន់អាស៊ាន និងមហាអនុតំបន់មេគង្គ។
- ពង្រឹងយន្តការគ្រប់គ្រង និងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនទាំងពីរជាលក្ខណៈតំបន់ និងអន្តរ

ជាតិប្រកបដោយប្រសិទ្ធភាព មានការប្រកួតប្រជែងដោយស្មើភាព ធានាបរិស្ថានទន្លេ និងសមុទ្របានល្អ ព្រមទាំងធ្វើឲ្យកាន់តែប្រសើរនូវតួនាទីរបស់កំពង់ផែ ក្នុងការសម្របសម្រួលពាណិជ្ជកម្មចរាចរណ៍ទំនិញ និងទេសចរណ៍។

- បន្តស្តារ និងអភិវឌ្ឍន៍អាកាសយានដ្ឋានជាតិ អន្តរជាតិ និងប្រព័ន្ធនាំផ្លូវអាកាសនៃព្រះរាជាណាចក្រកម្ពុជា លើកកម្ពស់ការពង្រឹងសុវត្ថិភាព សន្តិសុខអាកាសចរណ៍ និងការពារបរិស្ថាន ដើម្បីបង្កើនផលប្រយោជន៍ខាងសេដ្ឋកិច្ច ជម្រុញវិស័យពាណិជ្ជកម្ម ទេសចរណ៍ និងធ្វើឲ្យមានសង្គមតិភាពជាមួយគោលនយោបាយដឹកជញ្ជូនផ្លូវអាកាស ថ្នាក់ដឹកនាំតំបន់ អនុតំបន់ និងអន្តរជាតិ។

១៧. ធនធានទឹក

- បន្តលើកកម្ពស់ការគ្រប់គ្រង ថែរក្សា និងប្រើប្រាស់ធនធានទឹកប្រកបដោយប្រសិទ្ធភាព មាននិរន្តរភាព និងរក្សាបាននូវប្រព័ន្ធអេកូឡូស៊ី ដើម្បីផ្តល់លទ្ធភាពដល់ជនគ្រប់រូប ក្នុងការប្រើប្រាស់ទឹកដែលមានអនាម័យ សុវត្ថិភាព និងតម្លៃសមស្របសម្រាប់ផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃបានគ្រប់គ្រាន់ ធានាការគ្រប់គ្រង និងបែងចែកទឹកឲ្យមានសមភាព សម្រាប់ការអភិវឌ្ឍន៍វិស័យកសិកម្ម ឧស្សាហកម្ម សេវា និងសកម្មភាពសេដ្ឋកិច្ចផ្សេងៗទៀត ធានាការគ្រប់គ្រងបរិមាណ និងគុណភាពទឹកទាំងទឹកលើដី ទាំងទឹកក្រោមដី ហើយកាត់បន្ថយឲ្យបានជាអតិបរមា នូវគ្រោះគំរាមដល់អាយុជីវិត និងការរស់នៅប្រចាំថ្ងៃរបស់ប្រជាពលរដ្ឋពីគ្រោះមហន្តរាយដែលបង្កឡើងដោយទឹក។
- ពង្រឹងការគ្រប់គ្រងធនធានទឹក ដោយជម្រុញឲ្យមានការគោរពកិច្ចព្រមព្រៀងអន្តរប្រទេស លើការគ្រប់គ្រងទឹកទន្លេមេគង្គ និងចាត់ទុកទឹកជាទ្រព្យសម្បត្តិសាធារណៈដែលត្រូវគោរព និងការពារ។
- បន្តផ្តល់អាទិភាពលើការស្តារ កសាង ថែទាំ និងគ្រប់គ្រងហេដ្ឋារចនាសម្ព័ន្ធស្រោចស្រពដែលត្រូវតែមានប្រសិទ្ធភាពសេដ្ឋកិច្ច ហើយត្រូវធានាបាននូវផលនៃការវិនិយោគក្នុងនោះរួមមាន៖ អាងស្តុកទឹកប្រឡាយ ទឹកសំណង់ទ្វារទឹក លូទឹក ប្រឡាយនាំដីល្បាប់ ប្រព័ន្ធដោះទឹក ទំនប់ការពារទឹកជំនន់ ការការពារទឹកប្រៃ និងស្ថានីយ៍បូមទឹកដើម្បីបង្កើនផល ពង្រីកវារីវប្បកម្ម កាត់បន្ថយមហន្តរាយដែលបណ្តាលមកពីគ្រោះទឹកជំនន់ និងគ្រោះរាំងស្ងួត ព្រមទាំងសម្រួលដល់ការធ្វើដំណើររបស់ប្រជាជន។
- ពង្រឹងការអនុវត្តន៍ច្បាប់ ស្តីពីការគ្រប់គ្រងធនធានទឹក ច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ និងបទប្បញ្ញត្តិពាក់ព័ន្ធដើម្បីទប់ស្កាត់រាល់សកម្មភាព ឬគម្រោងសាងសង់នានាដែលអាចធ្វើឲ្យប៉ះពាល់មកលើធនធានទឹក ក៏ដូជាប្រព័ន្ធអេកូឡូស៊ី រាំងស្ពាត់ និងមានវិធានការម៉ឹងម៉ាត់ចំពោះសកម្មភាពចាក់លុបបំពេញដី ការជីកថ្មី ឬការរំលោភលើផ្លូវទឹកទន្លេ ស្ទឹង បឹងបួរ ព្រៃក ឬតំបន់ទំនាបសមុទ្រ និងទីលិចទឹកជាប្រចាំដែលគ្មានច្បាប់អនុញ្ញាត ហើយអាចធ្វើឲ្យប៉ះពាល់មកលើធនធានទឹក ក៏ដូចជាប្រព័ន្ធអេកូឡូស៊ី និងបរិស្ថាន។
- បន្តធ្វើសមាហរណកម្មកម្ពុជាជាមួយសហគមន៍អន្តរជាតិក្នុងវិស័យទឹក ដើម្បីជម្រុញកិច្ចសហប្រតិបត្តិការ និង ការយោគយល់ជាអន្តរជាតិក្នុងវិស័យនេះ សហការពេញទំហឹងជាមួយបណ្តាប្រទេសជិតខាង ដែលមានព្រំប្រទល់ជាប់នឹងកម្ពុជា ព្រមទាំងជាមួយប្រទេសក្នុងតំបន់ ដើម្បីសម្រេចគោលបំណងនៃកិច្ចព្រមព្រៀងមេគង្គឆ្នាំ១៩៩៥ ស្តីពីកិច្ចសហប្រតិបត្តិការក្នុងការអភិវឌ្ឍន៍អាងទន្លេមេគង្គប្រកបដោយចីរភាព។

១៨. ទឹកស្អាត

- ជម្រុញការអភិវឌ្ឍន៍ និងវិចារណកម្មការគ្រប់គ្រងវិស័យផ្គត់ផ្គង់ទឹកស្អាត សម្រាប់ប្រើប្រាស់ក្នុងជីវភាពរបស់ប្រជាជន និងផលិតកម្ម សេវាប្រកបដោយគុណភាព ប្រសិទ្ធភាព និងថ្លៃសមរម្យដើម្បីរួមចំណែកលើកកម្ពស់សុខុមាលភាព ជាពិសេសកាត់បន្ថយកង្វះទឹកស្អាតប្រើប្រាស់សម្រាប់ប្រជាជនដែលរស់នៅក្នុងតំបន់ទីប្រជុំជន ជាយក្រុង និងជនបទ។ ទន្ទឹមនេះ គោលដៅក្នុងការផ្គត់ផ្គង់ទឹកស្អាត គឺដល់ឆ្នាំ២០១៨ ប្រជាជនចំនួន៨៥%ដែលរស់នៅរាជធានី ខេត្ត និងប្រជាជនចំនួន៦០% ដែលរស់នៅតាម បណ្តាឃុំបានទទួលសេវាទឹកស្អាត ដែលមានគុណភាពល្អ និងថ្លៃសមរម្យប្រើប្រាស់ តាមរយៈការពង្រីកសមត្ថភាពផលិត និងការផ្គត់ផ្គង់ទឹកស្អាតនៅរាជធានី ខេត្ត និងពង្រីកការចូលរួមរបស់វិស័យឯកជនក្នុងការវិនិយោគលើវិស័យផ្គត់ផ្គង់ទឹកស្អាត។

១៩. ថាមពល

- បន្តអភិវឌ្ឍន៍វិស័យថាមពល ដើម្បីធានាការផ្គត់ផ្គង់ថាមពលដែលមានស្ថិរភាព ការជឿទុកចិត្ត និងថ្លៃសមរម្យសម្រាប់បម្រើជីវភាពរស់នៅរបស់ប្រជាជន ការផ្តល់សេវានានាដល់សង្គម និងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិដោយផ្តោតលើទិសដៅធំៗ២ គឺបន្តសាងសង់ស្ថានីយផលិតអគ្គិសនីក្នុងស្រុក និងធ្វើសមាហរណកម្មប្រព័ន្ធថាមពលកម្ពុជា ទៅក្នុងថាមពលរបស់តំបន់អាស៊ាន និងមហាអនុតំបន់ទន្លេមេគង្គ សំដៅបង្កើតប្រភពថាមពលឲ្យបានគ្រប់គ្រាន់ និងមានស្ថិរភាពសម្រាប់កម្ពុជា។
- បន្តអភិវឌ្ឍន៍បណ្តាញបញ្ជូនអនុស្ថានីយ បណ្តាញបញ្ជូនរង និងបណ្តាញចែកចាយអគ្គិសនីឲ្យបានឆាប់បានគ្របដណ្តប់ទូទាំងប្រទេស ដើម្បីបញ្ជូនថាមពលដែលមានស្ថិរភាព និងថ្លៃសមរម្យទៅផ្គត់ផ្គង់ដល់លំនៅស្ថានប្រជាជន និងទីតាំងបម្រើសកម្មភាពសង្គម និងសេដ្ឋកិច្ច។
- បន្តជម្រុញការធ្វើពិពិធកម្មថាមពល ក្នុងនោះរួមមាន ការបង្កើតប្រភពថាមពលស្អាត និងប្រភពថាមពលកកើតឡើងវិញ ការពង្រឹងសន្តិសុខថាមពល ការខិតខំកាត់បន្ថយឲ្យបានជាអតិបរមានូវផលប៉ះពាល់លើបរិស្ថានធម្មជាតិ និងសង្គមក្នុងដំណើរការផលិតថាមពល។
- បន្តអនុវត្តតួនាទីនាំមុខរបស់រដ្ឋ ក្នុងការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់អគ្គិសនី ជាមួយគ្នានេះគាំទ្រ និងលើកទឹកចិត្តដល់ការចូលរួមរបស់វិស័យឯកជនក្នុងការវិនិយោគ និងធ្វើអាជីវកម្មផ្តល់សេវាអគ្គិសនីដែលគោរពតាមការកំណត់នៃច្បាប់ បទបញ្ញត្តិ ស្តង់ដារ និងនីតិវិធីជាធរមាន ពិសេសការអនុវត្តន៍ថ្លៃលក់អគ្គិសនីឲ្យបានត្រឹមត្រូវតាមច្បាប់អគ្គិសនី ដើម្បីការពារផលប្រយោជន៍ និងភាពយុត្តិធម៌ទាំងសំរាប់អ្នកផលិត អ្នកបញ្ជូន អ្នកចែកចាយ និងអ្នកប្រើប្រាស់។
- ជម្រុញដំណើរការអគ្គិសនីភារូយកម្មជនបទ តាមរយៈគោលដៅនៃវិស័យថាមពលពីឆ្នាំ២០១៣ ដល់ឆ្នាំ២០១៨ គឺពង្រីកការផ្គត់ផ្គង់អគ្គិសនីពីបណ្តាញជាតិ ឲ្យដល់ភូមិចំនួន៨០%នៃចំនួនភូមិទាំងអស់ និងដោះស្រាយការផ្គត់ផ្គង់អគ្គិសនីដោយវិធីផ្សេងៗទៀត ឲ្យបាន១០%នៃចំនួនភូមិទាំងអស់ លើគោលដៅ ១០០%នៃភូមិនៅឆ្នាំ២០២០ ហើយរហូតដល់ឆ្នាំ២០៣០ មាន៧០%នៃគ្រួសារទាំងអស់មានអគ្គិសនីដែលមានគុណភាពដូចអគ្គិសនីពីបណ្តាញជាតិប្រើប្រាស់។
- ខិតខំរកលទ្ធភាពជួយប្រជាជនក្រីក្រនៅតំបន់ជនបទ អាចប្រើប្រាស់អគ្គិសនីពីបណ្តាញផ្គត់ផ្គង់ ទាំងលទ្ធភាពភ្ជាប់ចរន្តពីបណ្តាញ ទាំងថ្លៃអគ្គិសនី។

២០. បច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍

- បន្តអភិវឌ្ឍន៍ប្រព័ន្ធប្រៃសណីយ៍ និងទូរគមនាគមន៍ ព្រមទាំងបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ឲ្យមានលក្ខណៈទំនើប មានគុណភាពខ្ពស់ ស្របតាមស្តង់ដារអន្តរជាតិ មានថ្លៃសមរម្យ និងមានសេវាគ្របដណ្តប់នៅទូទាំងប្រទេស ដែលប្រជាជនទូទៅអាចប្រើប្រាស់ និងទទួលបានផលប្រយោជន៍គ្រប់ៗគ្នាពីសេវាកម្មនេះ។
- បន្តលើកទឹកចិត្តវិនិយោគឯកជន ធ្វើទំនើបបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ ជំរុញការប្រកួតប្រជែងដោយយុត្តិធម៌ក្នុងទីផ្សារសេវាប្រៃសណីយ៍ និងទូរគមនាគមន៍ ដោយផ្អែកលើច្បាប់ និងលិខិតបទដ្ឋាននានា ទប់ស្កាត់ការធ្វើអាជីវកម្មផ្តាច់មុខក្នុងវិស័យប្រៃសណីយ៍ និងវិស័យបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ ដោយចាត់ទុកវិស័យទាំងពីរជាទំនិញ និងសេវាសាធារណៈផង និងជាទ្រព្យសម្បត្តិសាធារណៈផង។
- បន្តពង្រីកការកសាងហេដ្ឋារចនាសម្ព័ន្ធឆ្អឹងខ្នង បណ្តាញខ្សែកាបអុបទិចប្រកបដោយសុវត្ថិភាព និងជឿទុកចិត្តឲ្យបានដល់គ្រប់ខេត្ត ដើម្បីពង្រីកវិសាលភាព និងរក្សាចីរភាពនៃសេវាបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍។
- បន្តអភិវឌ្ឍន៍ប្រព័ន្ធរដ្ឋបាលគ្រប់គ្រងអេឡិចត្រូនិច ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងជំរុញការបណ្តុះបណ្តាលមន្ត្រីរាជការ សិស្ស និស្សិតលើវិស័យបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ បង្កើនវិសាលភាព និងគុណភាពនៃបណ្តាញផ្សព្វផ្សាយ ទាំងការផ្សាយក្នុងប្រទេស និងក្រៅប្រទេស។

២១. ការអភិវឌ្ឍន៍ជនបទ

- បន្តខិតខំធ្វើឲ្យកាន់តែប្រសើរឡើងនូវប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធជនបទ
  តាមរយៈការបន្តកសាងផ្លូវជនបទការរៀបចំឲ្យមានដំណើរការនៃប្រព័ន្ធគ្រប់គ្រង និងថែទាំផ្លូវជនបទ ដោយមានការចូលរួមរបស់សហ គមន៍មូលដ្ឋាន ជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់លំដាប់ថ្នាក់ ជាពិសេសការកែលម្អផ្លូវជនបទជាជំហានៗពីផ្លូវក្រាលក្រួសក្រហម មកជាផ្លូវក្រាលកៅស៊ូ ឬផ្លូវបេតុង។
- បន្តខិតខំសម្រេចគោលដៅឆ្នាំ២០១៨ ដើម្បីឲ្យប្រជាជននៅជនបទចំនួន៦០% បានទទួលសេវាផ្គត់ផ្គង់ទឹកស្អាត ហើយនៅឆ្នាំ២០២៥ ប្រជាជនគ្រប់រូបដែលរស់នៅក្នុងសហគមន៍ជនបទ ត្រូវមានសេវាផ្គត់ផ្គង់ទឹកស្អាត និងអនាម័យគ្រប់គ្រាន់ ព្រមទាំងរស់នៅក្នុងបរិស្ថានដែលមានអនាម័យប្រកបដោយចីរភាព។
- បន្តអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ ដើម្បីកែលម្អ លើកកម្ពស់ជីវភាពប្រជាជននៅជនបទ និងកាត់បន្ថយការធ្វើចំណាកស្រុកស្វែងរកការងារ តាមរយៈការជំរុញវិស័យឥណទានជនបទ ដើម្បីផ្តល់សេវាប្រាក់កម្ចីដែលមានអត្រាការប្រាក់សមរម្យជូនប្រជាជននៅជនបទ ការបង្កើតកម្មវិធីបណ្តុះបណ្តាលជំនាញមូលដ្ឋាន ការជំរុញការអភិវឌ្ឍន៍សិប្បកម្ម សហគ្រាស និងមុខជំនាញខ្នាតគ្រួសារ ខ្នាតតូច និងមធ្យម ដោយយកចិត្តទុកដាក់ផ្តល់បច្ចេកទេសជំនាញ និងការយល់ដឹងអំពីការបង្កើតមុខរបរ ព្រមទាំងការខិតខំពង្រីកទីផ្សារសម្រាប់ផលិតផលជនបទ។
- បន្តអភិវឌ្ឍន៍តំបន់ដែលមានជនជាតិដើមភាគតិចរស់នៅ ឲ្យមានការរីកចម្រើនខាងសេដ្ឋកិច្ច សង្គមកិច្ច និងវប្បធម៌ ធានាសិទ្ធិពេញលេញរបស់បងប្អូនជនជាតិដើមភាគតិច ក្នុងការចូលរួមធ្វើសេចក្តីសំរេចនានា ដើម្បីកសាងគោលនយោបាយជាតិ ធានាសិទ្ធិទទួលបាននូវការការពារដោយច្បាប់ និងវិធានការសង្គមនានា ដែលឆ្លើយតបទៅនឹងតម្រូវការចាំបាច់សំរាប់ការរស់នៅប្រកបដោយភាពថ្លៃថ្នូរ ព្រមទាំងការគោរពចំពោះទំនៀមទម្លាប់ ប្រពៃណីល្អ និងភាសារបស់បងប្អូនជនជាតិ។

២២. ពាណិជ្ជកម្ម

- បន្តជំរុញការអភិវឌ្ឍន៍វិស័យពាណិជ្ជកម្ម តាមរយៈការធ្វើពិពិធកម្មទីផ្សារនាំចេញ និងការបង្កើនល្បឿនសមាហរណកម្មទៅក្នុងក្របខណ្ឌពាណិជ្ជកម្មសេរីសំខាន់ៗក្នុងតំបន់ និងពិភពលោក ជាពិសេសបណ្តាប្រទេសក្នុងសមាគមអាស៊ាន ស្របតាមទិសដៅធ្វើឲ្យសំរេចសហគមន៍អាស៊ានឆ្នាំ២០១៥ និងបណ្តាប្រទេសជាសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោក។ ឆ្លងតាមការអនុវត្តន៍ទិសដៅនេះ កម្ពុជានឹងទទួលបានអត្ថប្រយោជន៍សំរាប់ការជំរុញកំណើនសេដ្ឋកិច្ច និងផ្តល់ឱកាសដល់កម្ពុជា ក្នុងការរួមចំណែកកសាងគោលនយោបាយសេដ្ឋកិច្ចតំបន់ និងពិភពលោក ដើម្បីឲ្យការធ្វើពាណិជ្ជកម្មក្នុងតំបន់ និងពិភពលោកមានលក្ខណៈយុត្តិធម៌ សមធម៌ និងតម្លាភាព។
- បន្តពង្រីកទំនាក់ទំនងពាណិជ្ជកម្មអន្តរជាតិ ដើម្បីផ្សារភ្ជាប់ទីផ្សារក្នុងប្រទេស ជាមួយនឹងទីផ្សារក្រៅប្រទេស លើកកម្ពស់ការអភិវឌ្ឍន៍សមត្ថភាពផលិត និងផ្គត់ផ្គង់ ជំរុញការវិនិយោគ និងការនាំចេញទំនិញដោយផ្តោតលើការបង្កើនគុណភាពផលិតផលក្នុងស្រុក ព្រមទាំងការបង្កើតបន្ថែមមុខរបរ និងមុខទំនិញថ្មីៗសំរាប់នៃចេញសំដៅរក្សាលំនឹងនៃជញ្ជីងពាណិជ្ជកម្ម បញ្ចៀសវិបត្តិទីផ្សារ ដោះស្រាយការងារ និងបង្កើនចំណូលរបស់ប្រជាជន។
- ផ្តោតការយកចិត្តទុកដាក់ជាប្រចាំ លើការរក្សាស្ថិរភាពថ្លៃទំនិញនៅលើទីផ្សារ បន្តធ្វើកិច្ចអន្តរាគមន៍លើទីផ្សារ ពិសេសចំពោះបណ្តាមុខទំនិញជាយុទ្ធសាស្ត្រ ដូចជា ស្រូវ អង្ករ ប្រេងឥន្ធនៈ អគ្គិសនី ទឹក និងបណ្តាមុខទំនិញផ្សេងៗទៀត ដែលត្រូវការប្រើប្រាស់ចាំបាច់សំរាប់ជីវភាពប្រចាំថ្ងៃរបស់ប្រជាជន ដោយចាត់វិធានការរាំងខ្ទប់បាតុភាពស្តុកទំនិញលក់តម្លើងថ្លៃ ឬការលក់បំប៉ោងថ្លៃ ដែលនាំឲ្យប៉ះពាល់ដល់ជីវភាពរស់នៅរបស់ប្រជាជន។
- បង្កលក្ខណៈងាយស្រួលឲ្យផលិតផល និងទំនិញធ្វើចរាចរបានដោយសេរីនៅគ្រប់ទីកន្លែង ដោយឈរលើគោលការណ៍ប្រកួតប្រជែងដោយស្មើភាព តាមថ្លៃទីផ្សារ ពិសេសយកចិត្តទុកដាក់ការពារថ្លៃទំនិញកសិផលរបស់ប្រជាកសិករ និងជំនះបាតុភាពដែលនាំឲ្យកកស្ទះទំនិញកសិផល ការបន្ទោកបង្ហាប់ថ្លៃកសិផល និងការរាំងស្ទះការដឹងជញ្ជូន។
- ខិតខំរក្សាទីផ្សារដែលមានស្រាប់ និងបន្តចរចាបើកច្រកទីផ្សារជាមួយប្រទេសជាដៃគូពាណិជ្ជកម្មនានា ដើម្បីជំរុញឲ្យទំនិញ និងសេវារបស់កម្ពុជាដណ្តើមបានទីផ្សារកាន់តែទូលំទូលាយថែមទៀត។
- បន្តចូលរួមយ៉ាងសកម្ម ជាមួយបណ្តាប្រទេសនៃសមាគមអាស៊ាន ក្នុងការបង្កើតតំបន់ពាណិជ្ជកម្មសេរីជាមួយបណ្តាប្រទេសធំៗ ក្នុងពិភពលោក ដើម្បីពង្រីកទីផ្សារឲ្យបានជាអតិបរមា។
- ខិតខំពង្រឹង និងពង្រីកលក្ខណៈសម្បត្តិនានា សំដៅពង្រឹងសមត្ថភាពប្រកួតប្រជែងរបស់កម្ពុជា នៅក្នុងទីផ្សារក្រៅប្រទេស។
- ការពារ និងលើកតម្កើងកម្មសិទ្ធិបញ្ញាដែលជាប្រភេទកម្មសិទ្ធិ ឬទ្រព្យសម្បត្តិមួយដ៏មានតម្លៃដូចជា៖ តម្លៃទ្រព្យសម្បត្តិខាងបញ្ញាដែលទាក់ទងទៅនឹងស្នាដៃតក្កកម្ម ការរកឃើញថ្មីនៃវិទ្យាសាស្ត្រ ការអភិវឌ្ឍន៍បច្ចេកវិទ្យា គំនូសឧស្សាហកម្ម ម៉ាក និងពាណិជ្ជកម្មជាដើម។

- បន្តលើកស្ទួយផលិតផលសម្គាល់ភូមិសាស្ត្រ ផលិតផលដែលបង្ហាញនូវមរតកវប្បធម៌ ប្រពៃណីដែលជាស្នាដៃរបស់ផលិតករខ្មែរ។
- ពង្រឹងការអនុវត្តន៍ច្បាប់ ស្តីពីការគ្រប់គ្រងគុណភាព សុវត្ថិភាពលើផលិតផលទំនិញ និងសេវា ទប់ស្កាត់សកម្មភាពប្រកួតប្រជែងមិនស្មោះត្រង់ រាំងស្ទាត់ការផលិត និងការចែកចាយផលិតផលក្លែងក្លាយ និងផលិតផលគ្មានគុណភាព ឬខូចគុណភាព ដើម្បីការពារផលប្រយោជន៍របស់ធុរជន វិនិយោគិន លើកទឹកចិត្តពាណិជ្ជករ ផលិតករឲ្យធ្វើប្រតិបត្តិការពាណិជ្ជកម្មដោយស្មើភាព និងការពារផលប្រយោជន៍របស់ប្រជាជន ដែលជាអ្នកប្រើប្រាស់ផលិតផលទំនិញ ឬសេវាពិសេសទប់ស្កាត់ការនាំចូលទំនិញប្រើប្រាស់រួចដែលប៉ះពាល់ធ្ងន់ធ្ងរដល់បរិស្ថាន។
- បន្តជំរុញចលនា «ភូមិមួយ-ផលិតផលមួយ» ដោយឈរលើគោលលការណ៍បីយ៉ាង គឺជំរុញឲ្យប្រជាជនផលិតស្របតាមលក្ខខណ្ឌភូមិសាស្ត្រ និងលក្ខខណ្ឌទីផ្សារក្នុងប្រទេស និងក្រៅប្រទេស ផលិតឲ្យបានច្រើន ផលិតផលមានគុណភាពល្អលក់ឲ្យដាច់ ហើយបានថ្លៃខ្ពស់ និងប្រើប្រាស់គំនិតច្នៃប្រឌិត ទេពកោសល្ស ភាពប៉ិនប្រសប់របស់ប្រជាជនតាមមូលដ្ឋាន ដែលនឹងជួយបង្កើតមុខរបរបន្ថែម រួមចំណែកបង្កើនចំណូល លើកកម្ពស់កម្រិតជីវភាពរស់នៅ។

២៣. ការអភិវឌ្ឍន៍វិស័យឯកជន និងការទាក់ទាញការវិនិយោគ

- បន្តទាក់ទាញការវិនិយោគផ្ទាល់ពីបរទេស និងជំរុញការវិនិយោគក្នុងស្រុក ជាពិសេសតាមរយៈការលើកកម្ពស់សហគ្រាសធុនតូច និងមធ្យម និងការជំរុញសហគ្រិនភាពដើម្បីបង្កើនល្បឿននៃការអភិវឌ្ឍន៍ធ្វើពិពិធកម្មសេដ្ឋកិច្ច និងបង្កើតការងារ។
- បន្តកសាងអភិបាលកិច្ចសាជីវកម្មល្អ ដែលជាប្រការចាំបាច់សម្រាប់ការប្រកួតប្រជែងផង សំរាប់ភាពរឹងមាំ និងភាពរីកដុះដាលនៃវិស័យឯកជនខ្លួនឯងផង ព្រមទាំងសំរាប់ពង្រឹងវប្បធម៌គណនេយ្យភាព ចំពោះសង្គមផង ពិសេសក្នុងការបំពេញកាតព្វកិច្ចពន្ធ និងអាករ។
- បន្តការខិតខំធ្វើឲ្យបរិស្ថានវិនិយោគ និងធុរកិច្ចនៅកម្ពុជាកាន់តែមានភាពអំណោយផល និងល្អប្រសើរ ព្រមទាំងធ្វើឲ្យកម្ពុជាក្លាយជាគោលដៅវិនិយោគមួយដែលមានភាពកាន់តែទាក់ទាញ នៅក្នុងតំបន់ដែលនឹងបង្កើនបាននូវភាពប្រកួតប្រជែង និងផលិតភាពកាន់តែខ្ពស់សំរាប់កម្ពុជា។
- បន្តពង្រឹងអភិក្រមបើកចំហសំរាប់ការអភិវឌ្ឍន៍វិស័យឯកជន និងការទាក់ទាញវិនិយោគ សំដៅពង្រីកច្រកចូលទៅកាន់ទីផ្សារតំបន់ និងអន្តរជាតិ។
- រៀបចំឲ្យកាន់តែប្រសើរឡើងនូវរបបវិនិយោគឯកជន ដើម្បីផ្តល់ការលើកទឹកចិត្តសមស្រប និងចំគោលដៅ ដែលឆ្លើយតបទៅនឹងសំណូមពរនៃការអភិវឌ្ឍន៍រយៈពេលវែង។
- ធានាបរិស្ថានវិនិយោគ និងធុរកិច្ចប្រកបដោយភាពអំណោយផលសំរាប់ទទួលការវិនិយោគ ទាំងក្នុងប្រទេស និងពីក្រៅប្រទេស តាមរយៈការបន្តដាក់ចេញនូវបណ្តាវិធានការសំខាន់ៗ សំដៅផ្តោតលើការធានាស្ថិរភាពនយោបាយ សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ការធានាស្ថិរភាព និងភាពគង់មត់នៃបរិស្ថានម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ការសម្រួលពាណិជ្ជកម្ម និងការសម្រួលធុរកិច្ចមានជាអាទិ៍ៈ

ការកាត់បន្ថយការិយាធិបតេយ្យ ការអនុវត្តន៍យន្តការ «ច្រកចេញ-ចូលតែមួយ» ការលុបបំបាត់ចំណាយក្រៅផ្លូវការជាដើម។

- បន្តជំរុញការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងការអនុវត្តន៍វិធានការនានា សំដៅកាត់បន្ថយថ្លៃដឹកជញ្ជូន និងថ្លៃអគ្គិសនី ព្រមទាំងបន្តជំរុញការរៀបចំកម្មវិធីបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈដែលឆ្លើយតបទៅនឹងតម្រូវការទីផ្សារ។

២៤. ទេសចរណ៍

- បន្តអភិវឌ្ឍន៍វិស័យទេសចរណ៍កម្ពុជា ជាទេសចរណ៍វប្បធម៌ និងធម្មជាតិប្រកបដោយគុណភាព និងចីរភាពដោយប្រកាន់ខ្ជាប់នូវទស្សនៈ «ការអភិវឌ្ឍន៍បម្រើឲ្យការអភិរក្ស និងការអភិរក្សបម្រើការអភិវឌ្ឍន៍» ដើម្បីចូលរួមទ្រទ្រង់កំណើនសេដ្ឋកិច្ច លើកស្ទួយជីវភាពរបស់ប្រជាជន និងរួមចំណែកយ៉ាងសំខាន់ដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចបៃតង ជានិន្នាការរួមនៃពិភពលោក។ ក្នុងដំណាក់កាលនេះ ចាំបាច់ត្រូវតែមានការអនុវត្តន៍ទន្ទឹមគ្នានូវការខិតខំបង្កើតសមត្ថភាពប្រកួតប្រជែង និងការធានាចីរភាព ដែលកើតចេញពីការអភិវឌ្ឍន៍វិស័យទេសចរណ៍ ព្រមជាមួយនេះ ក៏ត្រូវយកឲ្យបានផងនូវកាលានុវត្តនភាពថ្មីនៃការអភិវឌ្ឍន៍ទេសចរណ៍ក្នុងតំបន់ និងពិភពលោក។

- ខិតខំសម្រេចគោលដៅទទួលទេសចរណ៍ ពីក្រៅប្រទេសនៅឆ្នាំ២០១៥ ប្រមាណ៤,៥លាននាក់ ឆ្នាំ២០១៨ កើនដល់៦,១លាននាក់ រួមជាមួយទេសចរណ៍ក្នុងស្រុកប្រមាណ១០,៥លាននាក់ ដែលអាចបង្កើតការងារដោយផ្ទាល់ជិត៧សែននាក់។
- បន្ទាប់ពីអភិវឌ្ឍន៍ អភិរក្ស ការពារ និងកែលម្អឲ្យសម្រេចបាននូវទីកន្លែងដែលមានសម្បត្តិវប្បធម៌ និងធនធានធម្មជាតិ ដែលជាគោលដៅទេសចរណ៍របស់ជាតិ ក្នុងនោះត្រូវយកចិត្តទុកដាក់ការគ្រប់គ្រង និងអភិវឌ្ឍន៍គោលដៅទេសចរណ៍សំខាន់ៗរបស់ជាតិ ប្រកបដោយស្មារតីទទួលខុសត្រូវ និងប្រុងប្រយ័ត្នខ្ពស់ ព្រមទាំងខិតខំជម្រុញការវិនិយោគ ក្នុងវិស័យទេសចរណ៍ និងបង្កើតផលិតផលទេសចរណ៍ថ្មីៗ ប្រកបដោយគុណភាពថែមទៀត។
- បន្តខិតខំថែរក្សាឲ្យបានល្អនូវរាល់គុណតម្លៃនៃសម្បត្តិមរតក និងធនធានរបស់ជាតិ ដើម្បីទ្រទ្រង់សកម្មភាពទេសចរណ៍យូរអង្វែង សំរាប់មនុស្សជំនាន់ក្រោយៗទៀត។
- ផ្តោតការយកចិត្តទុកដាក់លើតម្លៃរបស់ប្រជាជនមូលដ្ឋាន សហគមន៍នីមួយៗ និងជម្រុញឲ្យមានការចែករំលែកបទពិសោធន៍ល្អៗ ប្រកបដោយគុណភាពដល់ភ្ញៀវទេសចរណ៍ និងប្រជាជនជាមូលដ្ឋាន ព្រមទាំងផ្តល់សេវាប្រកបដោយគុណភាព ដើម្បីបង្កើនកម្រិតនៃការពេញចិត្តរបស់ភ្ញៀវទេសចរណ៍ ក្នុងការទស្សនាកម្សាន្ត និងទាក់ទាញឲ្យមានការផ្សព្វផ្សាយបន្ត ព្រមទាំងការវិលត្រឡប់មកទស្សនាជាថ្មីទៀត។
- បន្តជំរុញឲ្យបណ្តាភាគីពាក់ព័ន្ធទទួលផលប្រយោជន៍ ពីវិស័យទេសចរណ៍ ប្រកបដោយសមធម៌ ពោលគឺបង្កើនអត្ថប្រយោជន៍សេដ្ឋកិច្ចជាអតិបរមា កាត់បន្ថយផលប៉ះពាល់ជាអវិជ្ជមាននៃវិស័យទេសចរណ៍មកលើសេដ្ឋកិច្ច សង្គម វប្បធម៌ និងបរិស្ថាន និងកាត់បន្ថយការធ្លុះធ្លាយក្នុងវិស័យទេសចរណ៍ឲ្យកាន់តែតិចគឺត្រឹម១៥% នៅរយៈពេល៥ឆ្នាំខាងមុខ។
- ចូលរួមអនុវត្តទិសដៅនៃការអភិវឌ្ឍន៍បៃតង តាមរយៈការបន្តជំរុញចលនាប្រឡងប្រណាំងទីក្រុងស្អាត

ទីក្រុងបៃតង រមណីយដ្ឋានស្អាត រមណីយដ្ឋានបៃតង និងការចាប់យកទស្សនាទានថ្មីៗនៃភាពបៃតង និងភាពស្អាត ដោយបំផុសចលនា និងសកម្មភាពប្រើប្រាស់បច្ចេកវិជ្ជាបៃតង ដូចជាការប្រើអគ្គិសនីពីថាមពលកើតឡើងវិញ ការបង្កើនអនាម័យ ការដាំដើមឈើជាដើម។

- ខិតខំរកទីផ្សារទេសចរណ៍ដែលមានស្រាប់ និងពង្រឹងទីផ្សារថ្មីៗទៀត ពិសេសទីផ្សារក្នុងតំបន់ បង្កើនការផ្សព្វផ្សាយទេសចរណ៍តាមគ្រប់រូបភាព ជំរុញការតភ្ជាប់ និងសម្រួលការធ្វើដំណើរទេសចរណ៍ក្នុងតំបន់ ព្រមទាំងពង្រឹងការធានាសន្តិសុខ សុវត្ថិភាពដល់ទេសចរណ៍ និងអ្នកដំណើរនៅគ្រប់ទីកន្លែង។
- បង្កើនការចូលរួមពីគ្រប់ភាគី ដែលពាក់ព័ន្ធទាំងអស់ទាំងរដ្ឋ ឯកជន ប្រជាជន និងដៃគូអភិវឌ្ឍន៍ក្នុងការជំរុញវិស័យទេសចរណ៍កម្ពុជា។
- បន្តយកទុកដាក់ពង្រឹង និងពង្រីកបណ្តាសហគមន៍ទេសចរណ៍មូលដ្ឋាន ដើម្បីលើកទឹកចិត្តប្រជាជនឲ្យចូលរួមអភិវឌ្ឍន៍វិស័យយទេសចរណ៍ ការពារបរិស្ថាន ការពារធនធានវប្បធម៌ និងធម្មជាតិ។

២៥. បរិស្ថាន

- បន្តការថែរក្សា ការពារជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ី ការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាពទាំងនៅដែនគោក ទាំងនៅដែនសមុទ្រដើម្បីជាប្រយោជន៍ដល់ប្រជាជនទូទៅ ទាំងពេលបច្ចុប្បន្ន ទាំងពេលអនាគត និងដើម្បីឆ្លើយតបចំពោះការអភិវឌ្ឍន៍ឧស្សាហកម្ម ដែលបញ្ចេញធាតុពុលកាន់តែច្រើន និងការប្រែប្រួលអាកាសធាតុជាសកល នៅពេលបច្ចុប្បន្ន ព្រមទាំងដើម្បីធានាដល់ការលូតលាស់នៃសង្គមសេដ្ឋកិច្ច និងការលើកកម្ពស់សុខមាភាពសាធារណៈ។
- បន្តបង្កើនកិច្ចការពារគុណភាពបរិស្ថាន និងអភិរក្សធនធានធម្មជាតិឲ្យមានចីរភាព ក្នុងប្រព័ន្ធអេកូឡូស៊ីតាមរយៈការជំរុញការអភិវឌ្ឍន៍សេដ្ឋកិច្ចបៃតង ដោយមានការចូលរួមពីគ្រប់មជ្ឈដ្ឋាន ជាពិសេសការចូលរួមរបស់សហគមន៍នៅមូលដ្ឋាន និងតាមរយៈការពង្រឹងស្ថាប័ន និងក្របខ័ណ្ឌច្បាប់ដែលពាក់ព័ន្ធនឹងកិច្ចការពារបរិស្ថាន។
- បន្តធ្វើសមាហរណកម្មបរិស្ថាន ទៅក្នុងផែនការអភិវឌ្ឍន៍សង្គមសេដ្ឋកិច្ច ព្រមទាំងពង្រឹង និងពង្រឹងកិច្ចសហប្រតិបត្តិការអន្តរជាតិលើវិស័យបរិស្ថាន ទាំងក្នុងក្របខ័ណ្ឌតំបន់ និងអន្តរជាតិ។
- បន្តពង្រឹងច្បាប់ ស្តីពីបរិស្ថាន សំដៅថែរក្សាតំបន់ការពារធម្មជាតិ ទប់ស្កាត់រាល់សកម្មភាពបំផ្លាញគុណភាពបរិស្ថាន និងបញ្ចៀសគ្រោះមហន្តរាយនានា។
- យកចិត្តទុកដាក់វាយតម្លៃឲ្យបានហ្មត់ចត់នូវប៉ះពាល់បរិស្ថាន ក្នុងការអនុវត្តន៍គំរោងអភិវឌ្ឍន៍នានា ដើម្បីធានាការប្រើប្រាស់ធនធានធម្មជាតិ សម្រាប់ការអភិវឌ្ឍន៍សង្គម សេដ្ឋកិច្ចប្រកបដោយចីរភាព។
- ពង្រឹងការគ្រប់គ្រងដីសម្បទានក្នុងតំបន់ប្រើប្រាស់ ប្រកបដោយចីរភាព សំរាប់គំរោងវិនិយោគអភិវឌ្ឍន៍ សំដៅការពារ ទប់ស្កាត់ការរុករានយកដីព្រៃនៃតំបន់ស្នូល និងតំបន់អភិរក្ស ហើយមួយផ្នែកទៀតជួយផ្តល់បច្ចេកទេសដល់ប្រជាសហគមន៍ដែលរស់នៅក្បែរនោះ។
- ជំរុញការអភិវឌ្ឍន៍ទេសចរណ៍ធម្មជាតិ ដែលជួយដល់ការថែរក្សាបរិស្ថាន និងធនធានធម្មជាតិ។
- បង្កើនការត្រួតពិនិត្យ និងកាត់បន្ថយការបំពុលបរិស្ថានដែលរួមមាន ការគ្រប់គ្រងសំណល់រឹងសារធាតុប្រ

កបដោយគ្រោះថ្នាក់ ការត្រួតពិនិត្យ និងបង្កើនគុណភាពខ្យល់ ការត្រួតពិនិត្យ និងទប់ស្កាត់ការបំពុលទឹក និងដី ព្រមទាំងការបំពុលសោតារម្មណ៍ និងចក្ខុអារម្មណ៍។

ការអភិវឌ្ឍន៍វិស័យអប់រំ សុខាភិបាល ការងារ វប្បធម៌ និងសង្គមកិច្ច

- នៅក្នុងកិច្ចការអភិវឌ្ឍន៍វិស័យអប់រំ សុខាភិបាល ការងារ វប្បធម៌ និងសង្គមកិច្ច អប់រំ និងកីឡា រាជរដ្ឋាភិបាលមានវិធានការគោលនយោបាយសំខាន់ៗ ដូចតទៅ៖

អប់រំ និងកីឡា

២៦. បន្ថកសាង និងអភិវឌ្ឍន៍ធនធានមនុស្ស

លើគ្រប់ផ្នែកប្រកបដោយគុណភាព និងមានគុណធម៌ល្អប្រពៃ ដែលឆ្លើយតបទៅនឹងសំណូមពរនៃការអភិវឌ្ឍន៍សង្គម សេដ្ឋកិច្ចដើម្បីកសាងកម្ពុជាឲ្យក្លាយជាសង្គមរីកចម្រើន ជឿនលឿន ដែលផ្អែកលើមូលដ្ឋានចំណេះដឹងលើគ្រប់វិស័យ រួមទាំងខាងវិទ្យាសាស្ត្រ បច្ចេកទេស និងចំណេះធ្វើ ហើយដើរស្របជាមួយនឹងការរីកចម្រើននៃបណ្តាប្រទេសនោក្នុងតំបន់ និងពិភពលោក។

- បន្តលើកកម្ពស់គោលការណ៍ «អប់រំសម្រាប់ទាំងអស់គ្នា» តាមរយៈការធានានូវលទ្ធភាពបានសេវាអប់រំប្រកបដោយសមធម៌ ដែលផ្តល់ឱកាសស្មើៗគ្នាដល់កុមារ និងយុវជនកម្ពុជាទាំងអស់បានទទួលការអប់រំមូលដ្ឋានក្នុងប្រព័ន្ធ និងការអប់រំក្រៅប្រព័ន្ធ។ ការអនុវត្តន៍គោលការណ៍នេះត្រូវផ្សារភ្ជាប់នឹងការអប់រំមនសិការស្នេហាជាតិ ការអប់រំអំពីប្រវត្តិសាស្ត្រ ការអប់រំវប្បធម៌ សន្តិភាព ការគោរពសិទ្ធិ និងសេចក្តីថ្លៃថ្លូររបស់មនុស្ស ការគោរពគោលការណ៍សេរីភាពប្រជាធិបតេយ្យ និងយុត្តិធម៌សង្គម ការប្រឆាំងនឹងអំពើហិង្សា ការប្រយុទ្ធប្រឆាំងនឹងការប្រើប្រាស់គ្រឿងញៀន និងការរើងអើងគ្រប់រូបភាព។
- បន្តជំរុញការកសាងសាលារៀនឲ្យដល់ភូមិ កាត់បន្ថយការចំណាយរបស់មាតាបិតាសិស្ស បង្កើនថវិកាចំណាយសម្រាប់គ្រឹះស្ថានសិក្សា ពង្រាយគ្រូបង្រៀនឲ្យដល់គ្រប់ទីកន្លែង ពង្រឹងអន្តេវាសិកដ្ឋាន បំផុសចលនាជាតិ និងពង្រីកការចូលរួមពីវិស័យឯកជន ព្រមទាំងដៃគូអភិវឌ្ឍន៍នានាដើម្បីអភិវឌ្ឍន៍វិស័យអប់រំ។
- បន្តកសាងអនុវិទ្យាល័យឲ្យបានគ្រប់ឃុំ ដែលនៅមិនទាន់មានអនុវិទ្យាល័យ និងខិតខំឲ្យមានអនុវិទ្យាល័យច្រើនជាងមួយ នៅក្នុងឃុំធំៗដែលមានសិស្សច្រើនស្របតាមភូមិសាស្ត្រ។
- បង្កើនគុណភាព និងប្រសិទ្ធភាពនៃសេវាអប់រំនៅគ្រប់កម្រិតសិក្សា និងការបណ្តុះបណ្តាលបច្ចេកទេសនិងមុខជំនាញទាំងក្នុងគ្រឹះស្ថានរដ្ឋ ទាំងគ្រឹះស្ថានឯកជន ឲ្យស្របតាមកម្រិតស្តង់ដារអន្តរជាតិ និងតម្រូវការអភិវឌ្ឍន៍របស់ប្រទេស តាមរយៈការពង្រឹងការងារបណ្តុះបណ្តាល និងវិក្រឹតការគ្រូបង្រៀន ការកែលំអកម្មវិធីសិក្សា ការធ្វើអធិការកិច្ច និងពង្រឹងសមត្ថភាពគ្រប់គ្រង ការលើកទឹកចិត្តគ្រូបង្រៀនក្នុងការបង្កើនសមត្ថភាពគ្រូបង្រៀន ការពង្រឹងគុណភាពក្នុងការប្រឡងបញ្ចប់កម្រិតសិក្សានីមួយៗ ការសិក្សាភាសាបរទេសដែលចាំបាច់ ការកែលម្អលក្ខខណ្ឌនៃការសិក្សា ការបង្កើនបណ្ណាល័យ មន្ទីរពិសោធន៍ និងការបង្កើនការផ្គត់ផ្គង់សម្ភារៈសិក្សាជាដើម។
- បន្តអភិវឌ្ឍន៍ស្ថាន និងកសាងសមត្ថភាពរបស់មន្ត្រីអប់រំ ដោយបន្តការកសាងច្បាប់ និងលិខិតបទដ្ឋាននានាដែលពាក់ព័ន្ធវិស័យអប់រំ ពង្រឹងរចនាសម្ព័ន្ធការងារ និងបណ្តុះបណ្តាលជំនាញដល់មន្ត្រីអប់រំសំដៅអភិបាលកិច្ចល្អនៅគ្រាប់ថ្នាក់។

២៧. បន្តអភិវឌ្ឍន៍វិស័យកីឡា

រួមទាំងកីឡាជនពិការទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិឲ្យមានការរីកចម្រើន ស្របជាមួយនឹងការរីកចម្រើននៃវិស័យកីឡា ក្នុងតំបន់ដោយពង្រឹងការអនុវត្តន៍គោលនយោបាយជាតិអភិវឌ្ឍន៍វិស័យអប់រំកាយ និងកីឡាឲ្យមានប្រសិទ្ធភាពខ្ពស់ សំដៅរួមចំណែកដល់ការលើកកម្ពស់សុខភាពប្រជាជន ពង្រឹងសាមគ្គីភាព និងត្រៀមលក្ខណៈសម្បត្តិឲ្យបានល្អដើម្បីចូលរួម និងទទួលរៀបចំព្រឹត្តិការណ៍កីឡាធំៗជាលក្ខណៈអន្តរជាតិនានានៅពេលខាងមុខដូចជា អាស៊ានហ្គេមជាដើម។

២៨. សុខាភិបាល

- បន្តយកចិត្តទុកដាក់អភិវឌ្ឍន៍វិស័យអប់រំសុខាភិបាល សំដៅធ្វើឲ្យកាន់តែប្រសើរឡើងនូវសុខភាពប្រជាជនដែលជាមូលដ្ឋានគន្លឹះមួយនៃការអភិវឌ្ឍន៍ធនធានមនុស្ស និងការអភិវឌ្ឍន៍សង្គម សេដ្ឋកិច្ច តាមរយៈការផ្តល់សេវាសុខភិបាលប្រកបដោយប្រសិទ្ធភាព គុណភាព សមធម៌ និងមានចីរភាពដល់ប្រជាជនទូទៅ ពិសេសប្រជាជនក្រីក្រងាយរងគ្រោះ និងប្រជាជនរស់នៅជនបទ។
- ការខិតខំកាតបន្ថយឲ្យបានជាអតិបរមានូវការស្លាប់របស់មាតាទារក និងកុមារ កាត់បន្ថយការឈឺ និងស្លាប់ដោយសារជម្ងឺឆ្លងនឹងជម្ងឺមិនឆ្លងរ៉ាំរ៉ៃ ព្រមទាំងការពង្រឹង និងពង្រីកនូវប្រព័ន្ធសុខាភិបាលឲ្យកាន់តែប្រសើរឡើង។ ដើម្បីសម្រេចគោលដៅនេះ រាជរដ្ឋាភិបាលបន្តផ្តោតការយកចិត្តទុកដាក់ជំរុញអនុវត្តឲ្យមានប្រសិទ្ធភាពខ្ពស់លើបណ្តាកម្មវិធីសំខាន់ៗ រួមមាន៖ (១).កម្មវិធីសុខភាពបន្តពូជ សុខភាពមាតាទារកនិងកុមារ អាហាររូបត្ថម្ភ និងការអប់រំសុខភាព ក្នុងខិតខំបង្កើនអត្រាគ្របដណ្តប់នៃការផ្តល់លើថ្នាំបង្ការគ្រប់មុខ និងវ៉ាក់សាំងដល់កុមារ រួមទាំងការបញ្ចូលវ៉ាក់សាំងថ្មី និងការទប់ស្កាត់មិនឲ្យកើតមានតទៅទៀតនៅជម្ងឺកញ្ជ្រឹល និងជម្ងឺតេតាណុសលើទារក (២). កម្មវិធីប្រយុទ្ធ និងជម្ងឺឆ្លង ជាពិសេសជម្ងឺអេដស៍ របេង គ្រុនចាញ់ គ្រុនឈាម និងជម្ងឺមិនឆ្លងរ៉ាំរ៉ៃ ក្នុងនោះខិតខំលុបបំបាត់ជម្ងឺគ្រុនចាញ់ឲ្យបានទាំងស្រុងនៅត្រឹមឆ្នាំ២០២៥ ព្រមទាំងយកចិត្តទុកដាក់ព្យាបាលអ្នកប្រើប្រាស់សារធាតុញៀន និង (៣). កម្មវិធីពង្រឹង និងពង្រីកប្រព័ន្ធសុខាភិបាលនៅគ្រប់ថ្នាក់ប្រកបដោយវិជ្ជាជីវៈ។
- បន្តពង្រីកវិសាលភាពនៃសុខាភិបាលសារធាណៈឲ្យកាន់តែខិតជិតប្រជាជន ដោយបន្តពង្រីកហេដ្ឋារចនាសម្ព័ន្ធរូបវន្តនៃវិស័យនេះ ដូចជាការសង់អគារមន្ទីរពេទ្យបង្អែក មណ្ឌលសុខាភាព ប ុ ស្តិ៍សុខភាព និងបង្កើតបន្ទប់រង់ចាំឲ្យបានច្រើនថែមទៀត ពង្រីកសកម្មភាពចុះផ្តល់សេវាសុខភាពតាមភូមិឃុំ ពង្រឹងយន្តការលើកលែងការបង់ថ្លៃសេវាពិនិត្យ និងព្យាបាលជម្ងឺសម្រាប់ប្រជាជនក្រីក្រ តាមរយៈការពង្រីកមូលនិធិសមធម៌ ការបង់ថ្លៃជួល ប្រព័ន្ធធានារ៉ាប់រងសុខភាពតាមសហគមន៍ និងរបបសន្តិសុខសង្គម។
- ពង្រឹងការផ្គត់ផ្គង់ឱសថឲ្យបានដល់គោលដៅ តាមរបបកំណត់ក្នុងថវិកាប្រចាំឆ្នាំ ព្រមទាំងបង្កើនការវិនិយោគលើឧបករណ៍បរិក្ខារពេទ្យ និងបច្ចេកវិជ្ជាទំនើបនៅមន្ទីរបង្អែកថ្នាក់ជាតិ និងខេត្ត។
- ពង្រឹងសមត្ថភាពជំនាញ និងក្រមសីលធម៌វិជ្ជាជីវៈរបស់មន្ត្រីបុគ្គលិកសុខាភិបាលគ្រប់ជាន់ថ្នាក់ ដើម្បីផ្តល់សេវាជូនប្រជាជនប្រកបដោយភាពថ្លៃថ្នូរ រាក់ទាក់ យកចិត្តទុកដាក់ និងព្យាបាលអ្នកជម្ងឺគ្រប់រូបដោយគ្មានការរើសអើង។

- បន្តពង្រឹងការគ្រប់គ្រងវិស័យឯកជន ដើម្បីឈានទៅដល់ការលុបបំបាត់ឱសថក្លែងក្លាយ សេវាឯកជនខុសច្បាប់ និងធានាការប្រកបអាជីវៈកម្មសេវាឱសថ និងសេវាសុខភាពឲ្យប្រព្រឹត្តទៅក្រោមលក្ខខណ្ឌច្បាប់។
- បន្តលើកកម្ពស់ការចូលរួមរបស់សហគមន៍ និងភាពជាដៃគូរវាងវិស័យសាធារណៈ និងវិស័យឯកជនដើម្បីបង្កើនការវិនិយោគក្នុងវិស័យសុខាភិបាល ទាំងផ្នែកហេដ្ឋារចនាសម្ព័ន្ធ ធនធានមនុស្ស ការផ្តល់សេវាសុខភាព និងការងារស្រាវជ្រាវជាដើម ព្រមទាំងរួមចំណែកពង្រឹងអន្តរាគមន៍សុខភាពសាធារណៈ។

២៩. ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បន្តអភិវឌ្ឍន៍ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ដែលតម្រង់ទិសលើការធ្វើឲ្យប្រជាជនមានការងារធ្វើ មានមុខរបរសមរម្យ ត្រឹមត្រូវ និងថ្លៃថ្លូ ការការពារសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់និយោជក និងកម្មករ និយោជិត ព្រមទាំងការកសាង និងលើកកម្ពស់សមត្ថភាពបច្ចេកទេស និងវិជ្ជាជីវៈឲ្យរីកចម្រើនស្របតាមបទដ្ឋានអន្តរជាតិ។
- បន្តលើកកម្ពស់លក្ខខណ្ឌការងារឲ្យបានកាន់តែប្រសើរឡើង ដោយពង្រឹងការអនុវត្តន៍ច្បាប់ ស្តីពីការងារ បទដ្ឋានគតិយុត្តិនានា និងអនុសញ្ញាអន្តរជាតិខាងការងារ។
- បន្តពង្រឹងការអនុវត្តន៍សេរីភាពសហជីព និងអង្គការវិជ្ជាជីវៈ ប្រឆាំងការរើសអើងសហជីព និងអង្គការវិជ្ជាជីវៈ ជំរុញការកសាងច្បាប់ ស្តីពីសហជីព និងច្បាប់ស្តីពីការបង្កើតតុលាការងារ។
- ពង្រឹកសុខដុមនីយកម្មក្នុងទំនាក់ទំនងវិជ្ជាជីវៈ រវាងកម្មករ និយោជិត និងនិយោជក ព្រមទាំងពង្រឹងប្រព័ន្ធសុខភាព និងសុវត្ថិភាពការងារនៅតាមសហគ្រាស និងគ្រឹះស្ថាននានាឲ្យបានល្អប្រសើរ។
- បន្តការជំរុញតំឡើងប្រាក់ឈ្នួល ការផ្តល់ប្រាក់ឧបត្ថម្ភ និងប្រាក់អត្ថប្រយោជន៍នានាដល់កម្មករ និយោជិត។
- ខិតខំធ្វើឲ្យមានតុល្យភាពរវាងតម្រូវការ និងការផ្គត់ផ្គង់នៅក្នុងទីផ្សារពលកម្ម។
- យកចិត្តទុកដាក់ទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារក្រោមអាយុកំណត់នៅតាមសហគ្រាស។
- រៀបចំគោលនយោបាយជាតិ ស្តីពីមុខរបរ និងការងារ ស្របទៅនឹងការវិឌ្ឍន៍នៃសង្គម សេដ្ឋកិច្ច។
- ពង្រឹងប្រព័ន្ធផ្សព្វផ្សាយ និងយន្តការសេវារកការងារធ្វើ ស្របច្បាប់សម្រាប់ពលកម្មកម្ពុជា ទាំងនៅក្នុងប្រទេស និងក្រៅប្រទេស។ ទន្ទឹមនេះ យកចិត្តទុកដាក់រក្សាតុល្យភាពកម្លាំងពលកម្មសម្រាប់ទីផ្សារការងារក្នុងស្រុក។
- បង្កើនការការពារពលករខ្មែរ ដែលត្រូវបានបញ្ជូនទៅធ្វើការនៅបរទេស ទន្ទឹមនឹងការគ្រប់គ្រងកម្លាំងពលករបរទេស ដែលធ្វើការនៅក្នុងព្រះរាជាណាចក្រកម្ពុជា ស្របតាមច្បាប់ជាតិ និងគោលការណ៍ សមាហរណកម្មរបស់សមាគមអាស៊ាន។
- ជំរុញការអនុវត្តន៍ច្បាប់ ស្តីពីរបបសន្តិសុខសង្គមសម្រាប់ជនទាំងឡាយដែលស្ថិតនៅក្រោមច្បាប់ ស្តីពីការងារ ក្នុងនោះរួមមាន ការបន្តពង្រឹង និងពង្រីករបបធានារ៉ាប់រងហានិភ័យការងារឲ្យបានគ្របដណ្តប់ទូទាំងប្រទេស ការដាក់ឲ្យដំណើរការរបបធានារ៉ាប់រងហានិភ័យការងារឲ្យបានគ្របដណ្តប់ទូទាំងប្រទេស

ការដាក់ឲ្យដំណើរការរបបសោធននិវត្តន៍សម្រាប់កម្មករ និយោជិតក្នុងវិស័យឯកជនឲ្យទទួលបានរបបប្រាក់សោធននិវត្តន៍ដូចមន្ត្រីរាជការដែរ ចាប់ពីឆ្នាំ២០១៥។

- បន្តអភិវឌ្ឍន៍ធនធានមនុស្សលើផ្នែកបច្ចេកទេស ឲ្យឆ្លើយតបទៅនឹងសំណូមពរនៃការអភិវឌ្ឍន៍សង្គមសេដ្ឋកិច្ច ដោយជំរុញការអប់រំ និងបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ប្រកបដោយគុណភាពប្រសិទ្ធភាព និងស្របតាមតម្រូវទីផ្សារការងារ។
- ពង្រីកបណ្តាលក្ខខណ្ឌអនុគ្រោះប្រជាជន ជាពិសេសស្ត្រីទាប់យុវវ័យឱ្យបានទទួលការបណ្តុះបណ្តាលជំនាញរយៈពេលខ្លី ឬមធ្យមប្រកបដោយសមធម៌តាមគ្រប់រូបភាព ដើម្បីមានលទ្ធភាពបង្កើតមុខរបរដោយខ្លួនឯង ឬរកការងារធ្វើនៅតាមរោងចក្រ សហគ្រាស ការដ្ឋាននានា ឬទៅធ្វើការដោយស្របច្បាប់នៅក្រៅប្រទេស។
- ផ្តោតការយកចិត្តទុកដាក់លើការសំរបសំរួលឲ្យស៊ីចង្វាក់គ្នា រវាងវិស័យអប់រំ និងវិស័យបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ។
- ជំរុញការកសាងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈឲ្យមាននៅគ្រប់ខេត្ត ដែលអាចផ្តល់ការបណ្តុះបណ្តាលនៅតាមសហគមន៍ ព្រមទាំងរួមចំណែកដល់ទិសដៅ «ភូមិមួយ/ផលិតផលមួយ»។
- ពង្រឹកលទ្ធភាពបង្កើតអន្តេវាសិកដ្ឋាននៅតាមគ្រឹះស្ថានអប់រំ និងបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ សម្រាប់សិស្ស និស្សិត សិក្ខាកាមដែលមានលំនៅឆ្ងាយៗស្នាក់នៅ។
- លើកទឹកចិត្តការចូលរួមនៃវិស័យឯកជន និងអង្គការមិនមែនរដ្ឋាភិបាល ក្នុងការពង្រីកកម្មវិធីបណ្តុះបណ្តាលវិជ្ជាជីវៈ និងបច្ចេកទេសសមស្របឲ្យកាន់តែមានវិសាលភាព ឆ្លើយតបទៅនឹងតម្រូវការសង្គម។

៣០. វប្បធម៌ ជំនឿ សាសនា

- បន្តការលើកកម្ពស់ការអភិរក្ស និងអភិវឌ្ឍន៍វប្បធម៌ធម្មជាតិ ដើម្បីថែរក្សាការពារបេតិកភណ្ឌវប្បធម៌ជាតិទាំងរូបិយ និងឲ្យស្ថិតស្ថេរគង់វង្សយូរអង្វែង បង្កើតផលិតផលវប្បធម៌ឲ្យបានកាន់តែច្រើន ហើយចូលរួមសកម្មភាពក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ និងកែលម្អជីវភាពប្រជាជន ស្របតាមអត្ថន័យវប្បធម៌ជាសេដ្ឋកិច្ច។
- បន្តផ្តោតលើសកម្មភាពសំខាន់ៗជាអាទិភាព គឺការថែរក្សា និងអភិវឌ្ឍន៍តំបន់បេតិកភណ្ឌ ឲ្យមាននិរន្តរភាព ការថែទាំ និងការអភិរក្សប្រាសាទបុរាណនានា ការជំរុញឲ្យកម្ពុជាក្លាយជាមជ្ឈមណ្ឌលមួយនៃការផ្សព្វផ្សាយសិល្ប: ទស្សនីយភាព ការផ្សព្វផ្សាយផលិតផលសូនរូប និងសិល្ប:សិប្បកម្ម ការពង្រីកសកម្មភាពវប្បធម៌លើគ្រប់ជំនាញ និងការខិតខំពង្រីកទីផ្សារវប្បធម៌ឲ្យកាន់តែលូតលាស់ ទាំងក្នុងប្រទេស និងក្រៅប្រទេសដែលនឹងជំរុញថែមទៀតដល់ផលិតផលវប្បធម៌ខ្មែរ។
- បង្កើនការងារអប់រំ ពិសេសការអប់រំស្រទាប់យុវជន និងកុមារឲ្យយល់ដឹងច្បាប់អំពីតម្លៃដ៏វិសេសវិសាលនៃវប្បធម៌ ប្រពៃណី និងទំនៀមទម្លាប់ខ្មែរដែលជាអត្តសញ្ញាណរបស់ជាតិ ហើយចូលរួមថែរក្សាលើកតំកើងអភិវឌ្ឍន៍វប្បធម៌ជាតិ និងកាត់បន្ថយឥទ្ធិពលវប្បធម៌វិជ្ជមានពីបរទេស។
- បង្កើនការផ្លាស់ប្តូរសកម្មភាពវប្បធម៌សិល្ប: ជាមួយបណ្តាប្រទេសជាតិដើម្បីសន្តិភាព សុខដុមនីយកម្ម និងការអភិវឌ្ឍន៍។

- ថែរក្សា និងអភិវឌ្ឍន៍វប្បធម៌ ប្រពៃណី ទំនៀមទម្លាប់ល្អ និងភាសារបស់បងប្អូនជនជាតិដើមភាគតិច។
- បន្តគោរពសេរីភាពខាងជំនឿ និងសាសនាលើកស្ទួយព្រះពុទ្ធសាសនាដែលជាសាសនារបស់រដ្ឋ ជាពិសេសការបន្តពង្រឹងពុទ្ធិកសិក្សានៅគ្រប់កម្រិត ការបោះពុម្ពផ្សាយគម្ពីរ ដីកា ក្បួនច្បាប់នានា និងកិច្ចប្រតិបត្តិធម្មវិន័យ ទន្ទឹមនេះ គាំទ្រសកម្មភាពនៃសាសនាផ្សេងៗទៀតក្នុងសង្គម។
- ពង្រឹងសុខដុមនីយកម្ម រវាងសាសនិកនៃគ្រប់សាសនា ប្រឆាំងការរើសអើង បែងចែកក្នុងចំណោមប្រជាជនដែលបណ្តាលមកពីភាពខុសគ្នាខាងសាសនា សំដៅប្រែក្លាយសក្តានុពលរបស់សាសនាទាំងអស់ទៅជាកម្លាំងជំរុញការអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ច ពង្រឹងសន្តិភាព ថែរក្សាប្រពៃណីជាតិ និងលើកកម្ពស់តម្លៃសីលធម៌។
- រាំងស្ទាត់ការយកសាសនាទៅធ្វើអាជីវកម្ម និងបង្កជាវិបត្តិសាសនា។

៣១. សង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

- បន្តអភិវឌ្ឍន៍វិស័យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាឲ្យកាន់តែមានវិសាលភាពទូលំទូលាយ រួមចំណែកធ្វើឲ្យសុខុមាលភាពរបស់ប្រជាជនមានស្ថានភាពកាន់តែប្រសើរឡើង ដោយមានសេវាសង្គមកិច្ចគ្រប់គ្រាន់សម្រាប់ជួយជនរងគ្រោះ និងជនងាយរងគ្រោះគ្រប់ប្រភេទ មានប្រព័ន្ធសន្តិសុខសង្គមរឹងមាំ និងទូលំទូលាយសម្រាប់ធានារ៉ាប់រងចំពោះហានិភ័យសង្គមជាយថាហេតុ ហើយធ្វើឲ្យសេវាសង្គមកិច្ចកាន់តែនៅកៀកប្រជាជន ព្រមទាំងមានការចូលរួមដ៏សកម្មពីប្រជាជន។
- ជំរុញការបង្កើនអន្តរាគមន៍សង្គមកិច្ច ដើម្បីជួយប្រជាជនក្រីក្រងាយរងគ្រោះ និងជួយជនរងគ្រោះមហន្តរាយផ្សេងៗ តាមរយៈការលើកម្ពស់សន្តិសុខស្បៀង បន្តពង្រឹង និងពង្រីកកម្មវិធីសង្គ្រោះបន្ទាន់សម្រាប់ប្រជាជនក្រីក្រងាយរងគ្រោះ ទប់ស្កាត់ទុរគតភាព និងការធ្វើចំណាកស្រុកដោយប្រថុយប្រថាន។
- ពង្រឹងកម្មវិធីដោះស្រាយបញ្ហាជនអនាថា ជំរុញការប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស និងការជួយជនរងគ្រោះដោយអំពើជួញដូរមនុស្ស យកចិត្តទុកដាក់ងអភិវឌ្ឍន៍សហគមន៍ប្រជាជនក្រីក្រឲ្យបានទទួលកាលានុវត្តភាពសម្រាប់កែលម្អជីវភាព។
- ខិតខំបង្កើតប្រព័ន្ធសន្តិសុខសង្គមឲ្យបានទូលំទូលាយ គ្របដណ្តប់គ្រប់ស្រទាប់ប្រជាជន និងគ្រប់មជ្ឈដ្ឋាន ធ្វើជាស្នូលនៃសំណាញ់សុវត្ថិភាពសង្គម និងជំរុញការអនុម័តច្បាប់ ស្តីពីរបបសន្តិសុខសង្គមសំរាប់ប្រជាជនកម្ពុជា។
- លើកកម្ពស់ការអនុវត្តន៍ការងារយុវនីតិសម្បទា និងការអនុវត្តន៍កម្មវិធីយុត្តិធម៌អនីតិជន តាមរយៈការពង្រឹង និងការព្យាបាលស្តារនីតិសម្បទាសម្រាប់ជួយជនរងគ្រោះ ដែលប្រើប្រាស់សារធាតុញៀនតាមមណ្ឌល ព្រមជាមួយនោះ លើកទឹកចិត្តការព្យាបាល និងស្តារនីតិសម្បទាជនរងគ្រោះដែលប្រើប្រាស់បំពានសារធាតុញៀននៅតាមសហគមន៍។
- បន្តអនុវត្តគោលនយោបាយជាតិ ចំពោះជនពិការ ជំរុញកិច្ចការពារលើកកម្ពស់សុខុមាលភាពជនពិការ តាមអនុសញ្ញាអង្គការសហប្រជាជាតិ ស្តីពីសិទ្ធិជនពិការ និងការអនុវត្តន៍ច្បាប់ ស្តីពីកិច្ចការពារលើកកំពស់សិទ្ធិជនពិការ ផ្តល់សេវាស្តារលទ្ធភាពពលកម្ម ដោយមិនបង់ថ្លៃសម្រាប់ជនពិការក្រីក្រ ពង្រីកសេវា

សហគមន៍ អនុវត្តគោលនយោបាយឧបត្ថម្ភជនពិការក្រីក្រតាមសហគមន៍ និងបង្កើនការចូលរួមរបស់ជនពិការក្នុងគ្រប់សកម្មភាព។

- បន្តអនុវត្តគោលនយោបាយជាតិសម្រាប់មនុស្សចាស់ ដោយយកចិត្តទុកដាក់ជំរុញការអនុវត្តន៍កម្មវិធីអភិវឌ្ឍន៍មនុស្សចាស់តាមសហគមន៍ និងកម្មវិធីថែទាំមនុស្សចាស់តាមគ្រួសារឲ្យកាន់តែប្រសើរ ពង្រឹងសកម្មភាពសហគមន៍មនុស្សចាស់នៅតាមឃុំ-សង្កាត់ លើកទឹកចិត្តចំពោះការបង្កើតកម្មវិធីមនុស្សធម៌នានា ដើម្បីជួយដល់ជនចាស់ជរា ជំរុញការរៀបចំ និងដំណើរការសេវាជនចាស់ជរាដើម្បីបណ្តុះបណ្តាលភ្នាក់ងារផ្តល់សេវាថែទាំចាស់ជរា។
- បន្តអនុវត្តគោលនយោបាយជាតិ ចំពោះអតីតយុទ្ធជន និងអតីតមន្ត្រីរាជការស៊ីវិលឲ្យកាន់តែមានប្រសិទ្ធភាព តាមរយៈការអនុវត្តន៍គោលនយោបាយរដ្ឋ ទទួលបន្ទុកបង់ប្រាក់វិភាគទាន៦%នៃប្រាក់បៀវត្សជួសមន្ត្រីរាជការស៊ីវិលសម្រាប់ទ្រទ្រង់បេឡាជាតិសន្តិសុខសង្គម សម្រាប់មន្ត្រីរាជការស៊ីវិល និងរដ្ឋបង់ប្រាក់វិភាគទានតាមការកំណត់ ជួសកងកម្លាំងប្រដាប់អាវុធសម្រាប់ទ្រទ្រង់បេឡាជាតិអតីតយុទ្ធជន។
- ពង្រឹងបេឡាជាតិសន្តិសុខសង្គមសម្រាប់មន្ត្រីរាជការស៊ីវិល បេឡាជាតិសម្រាប់អតីតយុទ្ធជន និងមូលនិធិជនពិការ ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលមានលក្ខណៈហិរញ្ញវត្ថុ មិនមែនធនាគារជាគ្រឹះស្ថានសោធនសម្រាប់ផ្តល់សេវាសន្តិសុខសង្គមផង និងអនុវត្តយុទ្ធសាស្ត្រជាតិនៃហិរញ្ញវត្ថុផង។
- បន្តអនុវត្តគោលនយោបាយផ្តល់សម្បទានដីសង្គមកិច្ច កសាងលំនៅដ្ឋានជូនកងកម្លាំងប្រដាប់អាវុធ និងគ្រួសារដែលមានតម្រូវការពិតប្រាកដ ព្រមទាំងបង្កើតគំរោងជាច្រើនថែមទៀត ដើម្បីកែលម្អជីវភាពយោធិន និងអតីតយុទ្ធជន។
- ពង្រឹងភាពជាដៃគូជាមួយអង្គការមិនមែនរដ្ឋាភិបាលជាតិ និងអន្តរជាតិ ព្រមទាំងសប្បុរសជនដើម្បីពង្រឹកស្មារតីសាមគ្គីធម៌នៅក្នុងសង្គម ការពារប្រភពធនធានថវិកា សម្ភារៈបច្ចេកទេសសំរាប់បំរើឲ្យសំណូមពរនៃការងារសង្គមកិច្ច និងការជួយដល់ជនក្រីក្រងាយរងគ្រោះ។

៣២. ស្ត្រី និងកុមារ

- បន្តពង្រឹងស្ថានភាព និងតួនាទីដ៏សំខាន់របស់ស្ត្រីក្នុងសង្គម លើកស្ទួយសីលធម៌ និងតម្លៃរបស់ស្ត្រីខ្មែរ លុបបំបាត់រាល់ទស្សនៈមើលស្រាលតួនាទីរបស់ស្ត្រី សំដៅទៅលើកកម្ពស់ការចូលរួមរបស់ស្ត្រីឲ្យកាន់ទូលំទូលាយ និងខ្លាំងក្លាថែមទៀតនៅក្នុងការកសាងការពារមាតុភូមិ។
- បន្តលើកកម្ពស់សមធម៌យេនឌ័រ ជំរុញភាពអង់អាចរបស់ស្ត្រីក្នុងសេដ្ឋកិច្ច ដោយជំរុញការបណ្តុះបណ្តាលបំពាក់បំប៉ន់ជំនាញបច្ចេកទេស និងផ្តល់កាលានុភាពដល់ស្ត្រី ក្នុងការពង្រឹងមុខរបប បង្កើនចំណូល និងកសាងសហគ្រិនភាព បង្កើនឱកាសរៀនសូត្រសម្រាប់ស្ត្រី និងក្មេងស្រី ពិសេសនៅកម្រិតមធ្យមសិក្សាទុតិយភូមិ និងឧត្តមសិក្សា។
- ពង្រឹងលទ្ធភាព ក្នុងការទទួលបានសេវាសុខាភិបាលប្រកបដោយគុណភាពសម្រាប់ស្ត្រី និងស្រី ជាពិសេសនៅតំបន់ជនបទ។
- ជំរុញកម្មវិធីអប់រំសីលធម៌សង្គម តម្លៃស្ត្រី និងគ្រួសារខ្មែរ សំដៅពង្រឹកវប្បធម៌អហឹង្សា ការកសាងគ្រួសារ និងសហគមន៍ប្រកបដោយសុភមង្គល។

- ពង្រឹងការអនុវត្តន៍ច្បាប់ ស្តីពីការទប់ស្កាត់អំពើហឹង្សាក្នុងគ្រួសារ និងកិច្ចការពារជនរងគ្រោះ និងច្បាប់ស្តីពីការជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ ពិសេសការអនុវត្តន៍ផែនការជាតិ ស្តីពីការទប់ស្កាត់អំពើហឹង្សាលើស្ត្រីដើម្បីលុបបំបាត់នូវឥរិយាបថអំពើហឹង្សាលើស្ត្រី។
- បន្តបង្កើនសមាមាត្រការចូលរួមរបស់ស្ត្រីឲ្យបានកាន់តែច្រើនឡើង ក្នុងស្ថាប័នជាតិគ្រប់ជាន់ថ្នាក់ ដើម្បីឲ្យស្ត្រីបានចូលកាន់តែសកម្ម ក្នុងការធ្វើសេចក្តីសម្រេចនានា ក៏ដូចជាក្នុងការកសាងផែនការអភិវឌ្ឍន៍ និងអភិបាលកិច្ចទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។
- បន្តផ្តល់អាទិភាពលើការអភិវឌ្ឍន៍សុខុមាលភាពកុមារឲ្យកាន់តែប្រសើរ ដោយជំរុញការផ្សព្វផ្សាយ និងអនុវត្តយ៉ាងហ្មត់ចត់នូវអនុសញ្ញាអន្តរជាតិ ស្តីពីសិទ្ធកុមារ ពិសេសធានាឲ្យកុមារបានទទួលពិតប្រាកដនូវសិទ្ធិជាមូលដ្ឋានទាំងបួនរបស់កុមារ គឺ«សិទ្ធិរស់រានមានជីវិត សិទ្ធិទទួលបានការអភិវឌ្ឍន៍ សិទ្ធិទទួលបានការការពារ និងសិទ្ធិចូលរួមរបស់កុមារ។
- បន្តខិតខំសម្រេចនូវគោលដៅអភិវឌ្ឍន៍សហស្សវត្សររបស់កម្ពុជា ដែលពាក់ព័ន្ធនឹងកុមារ តាមរយៈការពង្រឹងការអនុវត្តន៍នយោបាយថែទាំជំនួសចំពោះកុមារ ការថែទាំកុមារតាមគ្រួសារ និងសហគមន៍ ការបង្កើនការគ្រប់គ្រង និងគុណនៃការថែទាំកុមារនៅតាមមណ្ឌល ទាំងមណ្ឌលរដ្ឋ និងមណ្ឌលនៃអង្គការមិនមែនរដ្ឋាភិបាល ការអនុវត្តន៍ម៉ឹងម៉ាត់នូវអនុសញ្ញាអន្តរជាតិ និងច្បាប់ជាធរមានដើម្បីរកគ្រួសារល្អសម្រាប់កុមារនៅក្នុងប្រទេស និងអន្តរប្រទេស រាំងស្កាត់ការធ្វើអាជីវកម្មតាមគ្រប់រូបភាព។

៣៣. យុវជន

- បន្តជំរុញការអភិវឌ្ឍន៍យុវជនឲ្យមានការរីកចម្រើនគ្រប់ផ្នែក ទាំងខាងចំណេះដឹង ចំណេះធ្វើ សុខភាពកាយសម្បទាន និងមានសីលធម៌រស់នៅថ្លៃថ្នូរ ចៀសផុតពីអំពើអបាយមុខ និងអំពើហឹង្សា ហើយប្តេជ្ញាឈ្នះក្នុងការបំពេញរាល់ភារកិច្ចរបស់ខ្លួន តាមរយៈ(១).ការបន្តការលើកកម្ពស់ការអប់រំ និងបណ្តុះបណ្តាលមុខជំនាញវិជ្ជាជីវៈ ចំណេះដឹងវិទ្យាសាស្ត្រ បច្ចេកទេស និងកម្មវិធីបំណិនជីវិតដល់យុវជន ពិសេសយុវជនមិនសូវមានលទ្ធភាព យុវជនងាយរងគ្រោះ និងយុវជនពិការឲ្យមានសមត្ថភាព និងកាលានុវត្តភាពនិងក្នុងការបង្កើតមុខរបរ ឬស្វែងរកការងារធ្វើក្នុងទីផ្សារពលកម្ម ដែលកំពុងតែមានការរីកចម្រើន (២).ការបង្កើនការអប់រំ ការថែទាំ និងផ្តល់សេវាសុខភាពប្រកបដោយគុណភាព និងសមធម៌ដល់យុវជន ពង្រឹងសកម្មភាពសិល្ប: កីឡា ការកម្សាន្តសម្រាប់យុវជនសំដៅពង្រឹងកាយសម្បទាន សុខភាព និង សាមគ្គីភាពក្នុងជួរយុវជន យុវនារី (៣). ការបន្តការពារសន្តិសុខ សុវត្ថិភាព និងយុត្តិធម៌សម្រាប់យុវជនយកចិត្តទុកដាក់បញ្ចូលតំរូវការរបស់យុវជន ទៅក្នុងផែនការអភិវឌ្ឍន៍គ្រប់កម្រិត ពង្រឹងការបណ្តុះបណ្តាលភាពជាអ្នកដឹកនាំ និងជំរុញការអនុវត្តន៍ជាជំហានៗនូវទិសដៅយុវភាវូបនីយកម្ម ក្នុងផ្តល់ការទទួលខុសត្រូវនៅគ្រប់លំដាប់ថ្នាក់យុវជន ដើម្បីឲ្យយុវជនកាន់តែពង្រីកនូវឱកាស និងសមត្ថភាពរបស់ខ្លួនក្នុងការអភិវឌ្ឍន៍ប្រទេស។ (៤). ការលើកទឹកចិត្ត ពង្រឹងចលនាស្ម័គ្រចិត្តរបស់យុវជនចូលរួមក្នុងសកម្មភាពកសាងយុត្តិធម៌ក្នុងសង្គម ការទប់ស្កាត់បាតុភាពអសកម្មតាមសហគមន៍ និងសកម្មភាពផ្សេងៗទៀត ដើម្បីបម្រើផលប្រយោជន៍ប្រជាជននៅតាមមូលដ្ឋាន ក៏ដូចផលប្រយោជន៍សាធារណៈ (៥). ការជំរុញចលនាកាយវិទ្ធនៅតាមសាលាបឋមសិក្សា អនុវិទ្យាល័យ និងវិទ្យាល័យដើម្បីរួមចំណែកបង្កលក្ខណៈឲ្យសមាជិកកាយវិទ្ធគ្រប់រូបក្លាយជាពលរដ្ឋ ដែលមានការរីកចម្រើនពេញលេញ ទាំងកាយសម្បទា ចំណេះដឹង និងបញ្ញាស្មារតី

មានការទទួលខុសត្រូវចំពោះខ្លួនឯង ចំពោះគ្រួសារ និងសង្គម ហើយចូលរួមក្នុងសកម្មភាពនានា ដែលផ្តល់ប្រយោជន៍ដល់សហគមន៍ សង្គមជាតិ និងអន្តរជាតិ (៦). ការជំរុញចលនាយុវជនកាកបាទក្រហម ដើម្បីពង្រឹង និងពង្រីកស្មារតីមនុស្សធម៌ឲ្យបានទូលំទូលាយក្នុងមហាជន តាមគោលការណ៍របស់កាកបាទក្រហម និងអឌ្ឍចន្ទក្រហមអន្តរជាតិ ព្រមទាំងចូលរួមក្នុងសកម្មភាពនានា ដូចជាការអប់រំយុវជន អប់រំបញ្ញាសុខភាព អំពីសុវត្ថិភាព ចរាចរណ៍ និងការរក្សាអនាម័យនៅតាមមូលដ្ឋានជាដើម។

- **ទម្រង់សំនួរផ្តល់ពិន្ទុលើលទ្ធផល នៃការបំពេញ/អនុវត្តន៍គោលនយោបាយ មិនមានសូចនាករច្បាស់លាស់របស់រាជរដ្ឋាភិបាល**

វេទិកាម្ចាស់ឆ្នោត

ស្តីពី

ការផ្តល់ពិន្ទុលើលទ្ធផលនៃការបំពេញ/អនុវត្តន៍គោលនយោបាយ

របស់រាជរដ្ឋាភិបាលនីតិកាលទី៥នៃរដ្ឋសភា (ឆ្នាំទី៣)

ទម្រង់សំណួរសម្រាប់ការផ្តល់

សូមធ្វើការវាយតម្លៃដោយដាក់ពិន្ទុពីលេខ១ ដល់៥ លើចំណុចនីមួយៗ

១= មិនពេញចិត្តទាល់តែសោះ ឬពេញចិត្តតិចតួច (0-២0%) ២= ពេញចិត្តខ្លះ (២១%-៤0%),

៣= ពេញចិត្តមធ្យម ឬពេញចិត្តពាក់កណ្តាល (៤១%-៦0%) ៤= ពេញចិត្តច្រើន (៦១%-៨0%),

៥= ពេញចិត្តស្ទើរតែទាំងស្រុង ឬពេញចិត្តទាំងស្រុង (៨១%-១00%)

ក្រមសំណួរផ្តល់ពិន្ទុលើអនុវត្តន៍

កម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលអាណត្តិទី៥

មិនមានសូចនាករច្បាស់លាស់ និងគោលនយោបាយសង្ខេបរួម

វិស័យ៖ ការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ	
១	តើអ្នកពេញចិត្តការបំពេញ/អនុវត្តន៍គោលនយោបាយរបស់រដ្ឋាភិបាល លើការពង្រឹងកិច្ចការពារអធិបតេយ្យជាតិ និងការចាត់ចែងកងកំលាំងប្រដាប់អាវុធក្នុងកំរិតណា? **១.** 0-២0% **២.** ២១%-៤0% **៣.** ៤១%-៦0% **៤.** ៦១%-៨0% **៥.**៨១%-១00%
	<u>គោលនយោបាយសង្ខេបរួម៖</u> ពង្រឹងកិច្ចការពារអធិបតេយ្យជាតិ នៃព្រះរាជាណាចក្រកម្ពុជាលើដែនដីគោក ដែនកោះ ផ្នែកក្នុងសមុទ្រ តំបន់ឥណ្ឌាប់ តំបន់សេដ្ឋកិច្ចផ្តាច់មុខ ខ្ពង់រាបបាតសមុទ្រ និងដែនអាកាស។
២.	តើអ្នកពេញចិត្តការបំពេញ/អនុវត្តន៍គោលនយោបាយ រក្សាសន្តិសុខជាតិ និងសង្គម និងការដោះស្រាយបញ្ហាអន្តោប្រវេសន៍ខុសច្បាប់របស់រដ្ឋាភិបាលក្នុងកំរិតណា? **១.** 0-២0% **២.** ២១%-៤0% **៣.** ៤១%-៦0% **៤.** ៦១%-៨0% **៥.**៨១%-១00%
	<u>គោលនយោបាយសង្ខេបរួម៖</u> ការពារសន្តិសុខជាតិ ប្រឆាំងដាច់ខាតរាល់អំពើដែលនាំទៅដល់ ការបង្កអស្ថិរភាពនយោបាយ ការបង្កជម្លោះប្រដាប់អាវុធជាតិ ឬជាមួយប្រទេសជិតខាង និងមិនអនុញ្ញាតឲ្យប្រើប្រាស់ទឹកដីកម្ពុជា ដើម្បីប្រឆាំងនឹងប្រទេសជិតខាង បង្ការដាច់ខាតមិនឲ្យកើតមានការគំរាម បំផ្លិចបំផ្លាញទ្រព្យសម្បត្តិអាយុជីវិត ឬមហន្តរាយដែលបង្កឡើងដោយអំពើភេរវកម្ម។
វិស័យ៖ ការពង្រឹងរដ្ឋបាលសាធារណៈ វិមជ្ឈការ និងវិសហមជ្ឈការ ការព្រឹងផ្នែកច្បាប់ និងប្រព័ន្ធយុត្តិធម៌ និងការប្រឆាំងអំពើពុករលួយ	
៣.	តើអ្នកពេញចិត្តលើការបំពេញ/អនុវត្តន៍គោលនយោបាយកែទម្រង់រដ្ឋបាលសាធារណៈ ឬសេវាកម្មរដ្ឋបាល

	សាធារណៈរបស់រដ្ឋាភិបាលកម្ពុជាក្នុងកំរិតណាមួយ? **១.** ០-២០% **២.** ២១%-៤០% **៣.** ៤១%-៦០% **៤.** ៦១%-៨០% **៥.**៨១%-១០០%
	<u>គោលនយោបាយសង្ខេបរួម៖</u> លើកកម្ពស់វប្បធម៌សាធារណៈ ឆន្ទៈម្ចាស់ការ ភក្តីភាព និងមនសិការវិជ្ជាជីវៈរបស់មន្ត្រីរាជការ ដើម្បីប្រែក្លាយរដ្ឋបាលសាធារណៈ ទៅជាអ្នកផ្តល់សេវាសាធារណៈដ៏មានប្រសិទ្ធភាព និងដែលបម្រើប្រជាជនបានកាន់តែល្អប្រសើរឡើង។
៤.	តើអ្នកពេញចិត្ត ការបំពេញ/អនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា លើកំណែទម្រង់វិមជ្ឈការ វិសហមជ្ឈការនៅថ្នាក់ក្រោមជាតិកំរិតណា? **១.** ០-២០% **២.** ២១%-៤០% **៣.** ៤១%-៦០% **៤.** ៦១%-៨០% **៥.**៨១%-១០០%
	<u>គោលនយោបាយសង្ខេបរួម៖</u> ពង្រឹងរដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់ថ្នាក់ គ្រប់ស្ថាប័ន និងប្រព័ន្ធគ្រប់គ្រង បន្តអភិវឌ្ឍន៍ធនធានមនុស្ស ការផ្ទេរមុខងារ និងធនធាន ព្រមទាំងប្រព័ន្ធថវិកា ហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិ។
៥.	តើអ្នកពេញចិត្តការបំពេញ/អនុវត្តន៍គោលយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា លើការកែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ក្នុងកំរិតណា? **១.** ០-២០% **២.** ២១%-៤០% **៣.** ៤១%-៦០% **៤.** ៦១%-៨០% **៥.** ៨១%-១០០%
	<u>គោលនយោបាយសង្ខេបរួម៖</u> ជម្រុញការរៀបចំក្របខ័ណ្ឌច្បាប់ឲ្យមានប្រសិទ្ធភាព និងកាន់តែទទួលបានការជឿទុកចិត្ត ព្រមទាំងពង្រឹងសមត្ថភាពមិនលម្អៀងនៃស្ថាប័នតុលាការ ដែលជាកត្តាដ៏សំខាន់នៃដំណើរការពង្រឹងនីតិរដ្ឋ ការបែងចែកអំណាចដាច់ពីគ្នា ការគោរពសិទ្ធិបុគ្គល និងការធានាភាពយុត្តិធម៌សម្រាប់ប្រជាពលរដ្ឋទូទៅ។
៦.	តើអ្នកពេញចិត្តលើបំពេញ/អនុវត្តន៍គោលយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា លើការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ក្នុងកំរិតណា? **១.** ០-២០% **២.** ២១%-៤០% **៣.** ៤១%-៦០% **៤.** ៦១%-៨០% **៥.** ៨១%-១០០%
	<u>គោលនយោបាយសង្ខេបរួម៖</u> ពង្រឹង និងការបង្កើនប្រសិទ្ធភាពនៃការអនុវត្តវិធានការលើកស្ទួយទាំង៣ គឺការអប់រំដើម្បីឲ្យម្នាក់ៗ ទាំងអ្នកដើមចម និងអ្នកទទួលផលមិនប្រព្រឹត្តអំពើពុករលួយ ការបង្ការទប់ស្កាត់ដើម្បីម្នាក់ៗមិនអាចប្រព្រឹត្តអំពើពុករលួយ និងការបង្ក្រាបបទល្មើលបញ្ជូនទៅតុលាការដើម្បីឲ្យម្នាក់ៗមិនហ៊ានប្រព្រឹត្តអំពើពុករលួយ។
<u>វិស័យ៖ ការអភិវឌ្ឍន៍សេដ្ឋកិច្ច</u>	
៧.	តើអ្នកពេញចិត្តនឹងការបំពេញ/អនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាលកម្ពុជា លើការបន្តរក្សាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងកំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយចីរភាពក្នុងកំរិតណា? **១.** ០-២០% **២.** ២១%-៤០% **៣.** ៤១%-៦០% **៤.** ៦១%-៨០% **៥.** ៨១%-១០០%
	<u>គោលនយោបាយសង្ខេបរួម៖</u> បន្តអនុវត្តគោលនយោបាយម៉ាក្រូសេដ្ឋកិច្ច និងគោលនយោបាយហិរញ្ញវត្ថុសាធារណៈសមស្រប គួបផ្សំនឹងគោលនយោបាយរូបិយវត្ថុដ៏ប្រយ័ត្នប្រយែងប្រកបដោយប្រសិទ្ធភាព និងបន្តការខិតខំធ្វើពិពិធកម្មមូលដ្ឋានកំណើនសេដ្ឋកិច្ច ដោយឈរលើមូលដ្ឋានភាពប្រកួតប្រជែងនៃសេដ្ឋកិច្ចកម្ពុជា និងការផ្សារភ្ជាប់សេដ្ឋកិច្ចកម្ពុជា ជាមួយបណ្តាផលិតផលក្នុងតំបន់។
៨.	តើអ្នកពេញចិត្តក្នុងកំរិតណា ចំពោះការបំពេញ/អនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាល លើការប្រមូលថវិកាជាតិ និងផ្តល់អាទិភាពចំណាយលើវិស័យសេដ្ឋកិច្ច សង្គមកិច្ច ហេដ្ឋារចនាសម្ព័ន្ធ ការបង្កើនសមត្ថភាព និងការលើកកម្ពស់ជីវភាពរបស់មន្ត្រី រាជការ និងកងកម្លាំងប្រដាប់អាវុធ?

	១. ០-២០% **២.** ២១%-៤០% **៣.** ៤១%-៦០% **៤.** ៦១%-៨០% **៥.** ៨១%-១០០%
	<u>គោលនយោបាយសង្ខេបរួមៈ</u> បន្តខិតខំជម្រុញការប្រមូលថវិកាជាតិ ទាំងចំណូលសារពើពន្ធ និងមិនមែនសារពើពន្ធឲ្យមានកំណើនជារៀងរាល់ឆ្នាំ។ ទន្ទឹមនេះ ការគ្រប់គ្រងការប្រមូលចំណូល និងការចាត់ចែងចំណាយត្រូវផ្តោតការយកចិត្តទុកដាក់លើប្រសិទ្ធភាព តម្លាភាព និងគណនេយ្យភាព គួបផ្សំជាមួយនឹងការបន្តយកចិត្តទុកដាក់ខ្ពស់ជានិច្ចក្នុងការគ្រប់គ្រងបំណុលសាធារណៈឲ្យស្ថិតក្នុងលទ្ធភាពទ្រទ្រង់នៃសេដ្ឋកិច្ចជាតិ។
៩.	តើអ្នកពេញចិត្តក្នុងកំរិតណា ចំពោះការបំពេញ/អនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាល លើការអភិវឌ្ឍន៍វិស័យហិរញ្ញវត្ថុ ដោយរក្សាស្ថិរភាពប្រាក់រៀល និងជម្រុញការប្រើប្រាស់ប្រាក់រៀលលើមូលដ្ឋានស្ថិរភាពតម្លៃប្រាក់រៀល និងកាត់បន្ថយការប្រើប្រាស់ប្រាក់ដុល្លារ? **១.** ០-២០% **២.** ២១%-៤០% **៣.** ៤១%-៦០% **៤.** ៦១%-៨០% **៥.**៨១%-១០០%
	<u>គោលនយោបាយសង្ខេបរួមៈ</u> កសាងប្រព័ន្ធហិរញ្ញវត្ថុមួយចំនួនដ៏រឹងមាំ មានការគ្រប់គ្រង និងការត្រួតពិនិត្យសមស្រប មានលក្ខណៈប្រកួតប្រជែង និងសមាហរណកម្ម ព្រមទាំងមានតម្លាភាព និងប្រសិទ្ធភាព ជាពិសេសផ្អែកលើគោលការណ៍ទីផ្សារដែលបម្រើឲ្យការកៀងគរ និងបែងចែកធនធានប្រកបដោយប្រសិទ្ធភាព។
១០.	តើអ្នកពេញចិត្ត ការបំពេញ/អនុវត្តន៍គោលនយោបាយសហប្រត្តិការអភិវឌ្ឍន៍ រវាងរាជរដ្ឋាភិបាលកម្ពុជា និងវិស័យឯកជន សង្គមស៊ីវិល ឬអង្គការអន្តរជាតិក្នុងកំរិតណា? **១.** ០-២០% **២.** ២១%-៤០% **៣.** ៤១%-៦០% **៤.** ៦១%-៨០% **៥.**៨១%-១០០%
	<u>គោលនយោបាយសង្ខេបរួមៈ</u> ពង្រឹង និងពង្រីកសហប្រតិបត្តិការជាមួយអង្គការមិនមែនរដ្ឋាភិបាល និងសមាគមនានា ដែលត្រូវបានបង្កើតឡើងដោយស្របច្បាប់ ហើយធ្វើប្រតិបត្តិការដោយឈរលើគោលការណ៍អភិបាលកិច្ចល្អ និងនីតិរដ្ឋដើម្បីចូលរួមក្នុងដំណើរការអភិវឌ្ឍន៍សង្គម-សេដ្ឋកិច្ច ការលើកកម្ពស់លទ្ធិប្រជាធិតេយ្យ និងការគោរពសិទ្ធិមនុស្ស ព្រមទាំងចូលរួមតាមដានការអនុវត្តន៍គោលនយោបាយផងដែរ។
១១.	តើអ្នកពេញចិត្តការបំពេញ/អនុវត្តន៍ គោលនយោបាយរបស់រាជរដ្ឋាភិបាល លើការអភិវឌ្ឍន៍វិស័យកសិកម្ម ក្នុងកំរិតណា? **១.** ០-២០% **២.** ២១%-៤០% **៣.** ៤១%-៦០% **៤.** ៦១%-៨០% **៥.** ៨១%-១០០%
	<u>គោលនយោបាយសង្ខេបរួមៈ</u> បន្តអភិវឌ្ឍន៍វិស័យកសិកម្មឲ្យក្លាយជាផ្នែកនាំមុខមួយ ដែលមានប្រៀបខ្លាំងពិតប្រាកដ ដើម្បីធ្វើជាមូលដ្ឋានដ៏រឹងមាំនៃកំណើនសេដ្ឋកិច្ចប្រកបដោយចីរភាព ធានាសន្តិសុខស្បៀង បង្កើនការងារ និងប្រាក់ចំណូលសម្រាប់ប្រជាជន ពិសេសប្រជាជននៅជនបទ ហើយរួមចំណែកដល់ការការពារបរិស្ថាន និងធនធានធម្មជាតិប្រកបដោយចីរភាព។
១២.	តើអ្នកពេញចិត្តការបំពេញ/អនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាល លើកំណែទម្រង់ដីធ្លី និងការដោះស្រាយបញ្ហាដីធ្លី ក្នុងកំរិតណា? **១.** ០-២០% **២.** ២១%-៤០% **៣.** ៤១%-៦០% **៤.** ៦១%-៨០% **៥.**៨១%-១០០%
	<u>គោលនយោបាយសង្ខេបរួមៈ</u> បន្តអនុវត្តការកែទម្រង់ដីធ្លី ដែលផ្តោតលើការងាររដ្ឋបាលដីធ្លី ការរៀបចំដែនដី និងនគរូបនីយកម្ម ការបែងចែកដីធ្លី និងការអភិវឌ្ឍន៍វិស័យសំណង់ ដើម្បីការពារសិទ្ធិលើដីធ្លីរបស់ប្រជាជន ព្រមទាំងការគ្រប់គ្រងការប្រើប្រាស់ធនធានធម្មជាតិ និងដីរដ្ឋប្រកបដោយតម្លាភាព សមធម៌ ចីរភាព និងប្រសិទ្ធភាព។

១៣.	តើអ្នកពេញចិត្ត ការបំពេញ/អនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាលលើការគ្រប់គ្រង និងការអភិវឌ្ឍន៍វិស័យសំណង់ ក្នុងកំរិតណា? **១.** ០-២០% **២.** ២១%-៤០% **៣.** ៤១%-៦០% **៤.** ៦១%-៨០% **៥** ៨១%-១០០%
	<u>គោលនយោបាយសង្ខេបរួមៈ</u> ជម្រុញវិនិយោគក្នុងវិស័យសំណង់ ការកសាងច្បាប់ ការកំណត់ស្តង់ដារសំណង់ និងពន្លឿនរយៈពេលចេញលិខិតអនុញ្ញាតសាងសង់ជូនប្រជាជន។
១៤.	តើអ្នកពេញចិត្តការបំពេញ/អនុវត្តន៍គោលនយោបាយអភិវឌ្ឍន៍ វិស័យឧស្សាហកម្ម កម្មន្តសាល(ដោយម៉ាស៊ីន) និងសិប្បកម្ម ក្នុងកំរិតណា? **១.** ០-២០% **២.** ២១%-៤០% **៣.** ៤១%-៦០% **៤.** ៦១%-៨០% **៥.** ៨១%-១០០%
	<u>គោលនយោបាយសង្ខេបរួមៈ</u> បន្តអភិវឌ្ឍន៍វិស័យឧស្សាហកម្មកម្មន្តសាល សិប្បកម្មប្រកបដោយចីរភាព ដែលមានលក្ខណៈចម្រុះ សម្ព្ធរបៃបមានការទទួលខុសត្រូវខាងបរិស្ថាន និងសង្គមខ្ពស់ ហើយពង្រីកបាននូវអន្តរកម្មសេដ្ឋកិច្ច រវាងផ្នែកកែច្នៃកម្មន្តសាលជាមួយវិស័យកសិកម្ម ពាណិជ្ជកម្ម និងសេវាកម្ម ដើម្បីជម្រុញសមាហរណកម្មសេដ្ឋកិច្ច ខ្សែសង្វាក់តម្លៃ និងភាពប្រកួតប្រជែងរបស់កម្ពុជានៅក្នុងតំបន់ និងពិភពលោក។
១៥.	តើអ្នកពេញចិត្តការបំពេញ/អនុវត្តន៍គោលរបស់នយោបាយរដ្ឋាភិបាលលើការអភិវឌ្ឍន៍ធនធានរ៉ែ ប្រេងកាត និងឧស្ម័ន ក្នុងកំរិតណា? **១.** ០-២០% **២.** ២១%-៤០% **៣.** ៤១%-៦០% **៤.** ៦១%-៨០% **៥.** ៨១%-១០០%
	<u>គោលនយោបាយសង្ខេបរួមៈ</u> លើកទឹកចិត្តឲ្យវិស័យឯកជនវិនិយោគលើការសិក្សាស្រាវជ្រាវ និងការធ្វើអាជីវកម្មធនធានទាំងនោះ តាមច្បាប់ជាធរមាន ដោយយកចិត្តទុកដាក់សំខាន់លើសុវត្ថិភាព សុខមាលភាព ព្រមទាំងការការពារបរិស្ថាន និងសង្គមបន្តរៀបចំ និងធ្វើបច្ចុប្បន្នភាពបទប្បញ្ញត្តិ និងលិខិតបទដ្ឋាននានាដែលទាក់ទងនឹងធនធានរ៉ែ ប្រេងកាត និងឧស្ម័ន ដើម្បីធានាការអភិវឌ្ឍន៍ធនធាននេះប្រកបដោយប្រសិទ្ធភាព និងមានការទទួលខុសត្រូវខ្ពស់។
១៦.	តើអ្នកពេញចិត្តការបំពេញ/អនុវត្តន៍គោលនយោបាយបង្កើនការស្តារ ការសាងសង់ និងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូនផ្លូវគោក ផ្លូវដែក ផ្លូវទឹក កំពង់ផែ និងផ្លូវអាកាស ក្នុងកំរិតណា? **១.** ០-២០% **២.** ២១%-៤០% **៣.** ៤១%-៦០% **៤.** ៦១%-៨០% **៥.**៨១%-១០០%
	<u>គោលនយោបាយសង្ខេបរួមៈ</u> បន្តបង្កើនការស្តារ ការសាងសង់ និងការអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន ប្រកបដោយគុណភាពសម្រាប់បម្រើឲ្យការដឹកជញ្ជូនពហុរូបភាព ដែលតភ្ជាប់រវាងគ្រប់តំបន់នៅទូទាំងប្រទេស តភ្ជាប់ជាមួយបណ្តាប្រទេសក្នុងតំបន់ និងពិភពលោកដើម្បីធានាការធ្វើដំណើរគ្រប់ច្រកល្លក និងការផ្តល់សេវាដឹកជញ្ជូនបានគ្រប់គ្រាន់គ្រប់រដូវកាលប្រកបដោយផាសុកភាព សណ្តាប់ធ្នាប់ ប្រសិទ្ធភាព និងមានតម្លៃទាប។
១៧.	តើអ្នកពេញចិត្តការបំពេញ/អនុវត្ត៍គោលនយោបាយលើកកម្ពស់ការគ្រប់គ្រង ថែរក្សា និងប្រើប្រាស់ធនធានទឹក និងការរក្សាបាននូវប្រព័ន្ធអេកូឡូស៊ី ក្នុងកំរិតណា? **១.** ០-២០% **២.** ២១%-៤០% **៣.** ៤១%-៦០% **៤.** ៦១%-៨០% **៥.** ៨១%-១០០%
	<u>គោលនយោបាយសង្ខេបរួមៈ</u> បន្តលើកកម្ពស់ការគ្រប់គ្រង ថែរក្សា និងប្រើប្រាស់ធនធានទឹកប្រកបដោយប្រសិទ្ធភាព មាននិរន្តរភាព និងរក្សាបាននូវប្រព័ន្ធអេកូឡូស៊ី ដើម្បីផ្តល់លទ្ធភាពដល់ជនគ្រប់រូបក្នុងការប្រើប្រាស់ទឹកដែលមានអនាម័យ សុវត្ថិភាព និងតម្លៃសមស្របសម្រាប់ផ្គត់ផ្គង់ជីវភាពប្រចាំថ្ងៃបានគ្រប់គ្រាន់។ ធានាការគ្រប់គ្រង និងបែងចែកទឹកឲ្យមានសមភាពសម្រាប់ការអភិវឌ្ឍន៍វិស័យកសិកម្ម ឧស្សាហកម្ម សេវា និងសកម្មភាពសេដ្ឋកិច្ចផ្សេង

	។ទៀត។
១៨.	តើអ្នកពេញចិត្តការបំពេញ/អនុវត្ត៍គោលនយោបាយ ផ្គត់ផ្គង់ទឹកស្អាត ដោយបណ្តាញរដ្ឋ និងឯកជនរបស់រដ្ឋាភិបាលកម្ពុជា ក្នុងកំរិតណា? **១.** ០-២០% **២.** ២១%-៤០% **៣.** ៤១%-៦០% **៤.** ៦១%-៨០% **៥.** ៨១%-១០០%
	<u>គោលនយោបាយសង្ខេបរួម៖</u> ជម្រុញការអភិវឌ្ឍន៍ និងវិចារណកម្មការគ្រប់គ្រងវិស័យផ្គត់ផ្គង់ទឹកស្អាត សម្រាប់ប្រើប្រាស់ក្នុងជីវភាពរបស់ប្រជាជន និងផលិតកម្ម សេវាប្រកបដោយគុណភាព ប្រសិទ្ធភាព និងថ្លៃសមរម្យដើម្បីរួមចំណែកលើកកម្ពស់សុខុមាលភាព ជាពិសេសកាត់បន្ថយកង្វះទឹកស្អាតប្រើប្រាស់សម្រាប់ប្រជាជន ដែលរស់នៅក្នុងតំបន់ទីប្រជុំជនជាយក្រុង និងជនបទ។
១៩.	តើអ្នកពេញចិត្តការបំពេញ/អនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាលលើការអភិវឌ្ឍន៍ វិស័យថាមពល ដើម្បីធានាការផ្គត់ផ្គង់ថាមពលដែលមានស្ថិរភាព ការជឿទុកចិត្ត និងថ្លៃសមរម្យ ក្នុងកំរិតណា? **១.** ០-២០% **២.** ២១%-៤០% **៣.** ៤១%-៦០% **៤.** ៦១%-៨០% **៥.** ៨១%-១០០%
	<u>គោលនយោបាយសង្ខេបរួម៖</u> បន្តអភិវឌ្ឍន៍វិស័យថាមពល ដើម្បីធានាការផ្គត់ផ្គង់ថាមពលដែលមានស្ថិរភាព ការជឿទុកចិត្ត និងថ្លៃសមរម្យ សម្រាប់បម្រើជីវភាពរស់នៅរបស់ប្រជាជន។
២០.	តើអ្នកពេញចិត្តការបំពេញ/អនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាល លើការអភិវឌ្ឍន៍ប្រព័ន្ធប្រៃសណីយ៍ និងទូរគមនាគមន៍ ព្រមទាំងបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ ក្នុងកំរិតណា? **១.** ០-២០% **២.** ២១%-៤០% **៣.** ៤១%-៦០% **៤.** ៦១%-៨០% **៥.**៨១%-១០០%
	<u>គោលនយោបាយសង្ខេបរួម៖</u> បន្តអភិវឌ្ឍន៍ប្រព័ន្ធប្រៃសណីយ៍ និងទូរគមនាគមន៍ ព្រមទាំងបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ឲ្យមានលក្ខណៈទំនើប មានគុណភាពខ្ពស់ស្របតាមស្តង់ដារអន្តរជាតិ មានថ្លៃសមរម្យ និងមានសេវាគ្របដណ្តប់នៅទូទាំងប្រទេសដែលប្រជាជនទូទៅអាចប្រើប្រាស់ និងទទួលបានផលប្រយោជន៍គ្រប់ៗគ្នាពីសេវាកម្មនេះ។
២១.	តើអ្នកពេញចិត្តកំរិតណា ចំពោះការបំពេញ/អនុវត្តន៍គោលនយោបាយ បន្តកសាងផ្លូវជនបទ ការជំរុញវិស័យឥណទាន ការអភិវឌ្ឍន៍សិប្បកម្ម សហគ្រាស និងមុខជំនាញគ្រួសារខ្នាតតូច និងមធ្យម ព្រមទាំងពង្រីកទីផ្សារសម្រាប់ផលិតផលជនបទ? **១.** ០-២០% **២.** ២១%-៤០% **៣.** ៤១%-៦០% **៤.** ៦១%-៨០% **៥.** ៨១%-១០០%
	<u>គោលនយោបាយសង្ខេបរួម៖</u> បន្តខិតខំធ្វើឲ្យកាន់តែប្រសើរឡើងនូវប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធជនបទ តាមរយៈការបន្តកសាងផ្លូវជនបទ ការរៀបចំឲ្យមានដំណើរការនៃប្រព័ន្ធគ្រប់គ្រង និងថែទាំផ្លូវជនបទ ដោយមានការចូលរួមរបស់សហគមន៍មូលដ្ឋានជាមួយរដ្ឋបាលថ្នាក់ក្រោមជាតិគ្រប់លំដាប់ថ្នាក់ ជាពិសេសការកែលម្អផ្លូវជនបទជាជំហានៗ ពីផ្លូវក្រាលក្រួសក្រហម មកជាផ្លូវក្រាលកៅស៊ូ ឬផ្លូវបេតុង។
២២.	តើអ្នកពេញចិត្តការបំពេញ/អនុវត្តន៍គោលនយោបាយអភិវឌ្ឍន៍ វិស័យពាណិជ្ជកម្ម តាមរយៈការធ្វើការធ្វើឲ្យសំបូរបែបទីផ្សារនាំចេញ និងការបង្កើនល្បឿនសមាហរណកម្មទីផ្សារសេរីសំខាន់ៗ ក្នុងកំរិតណា? **១.** ០-២០% **២.** ២១%-៤០% **៣.** ៤១%-៦០% **៤.** ៦១%-៨០% **៥.** ៨១%-១០០%
	<u>គោលនយោបាយសង្ខេបរួម៖</u> បន្តជំរុញការអភិវឌ្ឍន៍វិស័យពាណិជ្ជកម្ម តាមរយៈការធ្វើពិពិធកម្មទីផ្សារនាំចេញ និងការបង្កើនល្បឿនសមាហរណកម្ម ទៅក្នុងក្របខណ្ឌពាណិជ្ជកម្មសេរីសំខាន់ៗក្នុងតំបន់ និងពិភពលោក ជាពិសេសបណ្តាប្រទេសក្នុងសមាគមអាស៊ាន ស្របតាមទិសដៅធ្វើឲ្យសម្រេចសហគមន៍អាស៊ានឆ្នាំ២០១៥ និងបណ្តាប្រទេសជាសមាជិកនៃ

	អង្គការពាណិជ្ជកម្មពិភពលោក។
២៣.	តើអ្នកពេញចិត្តការបំពេញ/អនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាល លើការទាក់ទាញការវិនិយោគផ្ទាល់ពីបរទេស និងជំរុញការវិនិយោគក្នុងស្រុក ក្នុងកំរិតណា? **១.** ០-២០% **២.** ២១%-៤០% **៣.** ៤១%-៦០% **៤.** ៦១%-៨០% **៥.** ៨១%-១០០%
	<u>គោលនយោបាយសង្ខេបរួម៖</u> បន្តទាក់ទាញការវិនិយោគផ្ទាល់ពីបរទេស និងជំរុញការវិនិយោគក្នុងស្រុក ជាពិសេសតាមរយៈការលើកកម្ពស់សហគ្រាសធុនតូច និងមធ្យម និងការជំរុញសហគ្រិនភាព ដើម្បីបង្កើនល្បឿននៃការអភិវឌ្ឍន៍ ធ្វើពិពិធកម្មសេដ្ឋកិច្ច និងបង្កើតការងារ។
២៤.	តើអ្នកពេញចិត្តការបំពេញ/អនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាល លើការអភិវឌ្ឍន៍វិស័យទេសចរណ៍កម្ពុជា ជាទេសចរណ៍វប្បធម៌ និងធម្មជាតិក្នុងកំរិតណា? **១.** ០-២០% **២.** ២១%-៤០% **៣.** ៤១%-៦០% **៤.** ៦១%-៨០% **៥.** ៨១%-១០០%
	<u>គោលនយោបាយសង្ខេបរួម៖</u> បន្តអភិវឌ្ឍន៍វិស័យទេសចរណ៍កម្ពុជា ជាទេសចរណ៍វប្បធម៌ និងធម្មជាតិប្រកបដោយគុណភាព និងចីរភាពដោយប្រកាន់ខ្ជាប់នូវទស្សនៈ «ការអភិវឌ្ឍន៍បម្រើឲ្យការអភិរក្ស និងការអភិរក្សបម្រើការអភិវឌ្ឍន៍» ដើម្បីចូលរួមទ្រទ្រង់កំណើនសេដ្ឋកិច្ច លើកស្ទួយជីវភាពរបស់ប្រជាជន និងរួមចំណែកយ៉ាងសំខាន់ដល់ការអភិវឌ្ឍន៍សេដ្ឋកិច្ចបៃតងជានិន្នាការរួមនៃភិភពលោក។
២៥.	តើអ្នកពេញចិត្តការបំពេញ/អនុវត្តន៍គោលនយោបាយ ការថែរក្សា ការពារជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ីការប្រើប្រាស់ធនធានធម្មជាតិ ក្នុងកំរិតណា? **១.** ០-២០% **២.** ២១%-៤០% **៣.** ៤១%-៦០% **៤.** ៦១%-៨០% **៥.**៨១%-១០០%
	<u>គោលនយោបាយសង្ខេបរួម៖</u> បន្តការថែរក្សា ការពារជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ី ការប្រើប្រាស់ធនធានធម្មជាតិប្រកបដោយចីរភាពទាំងនៅដែនគោក ទាំងនៅដែនសមុទ្រដើម្បីជាប្រយោជន៍ដល់ប្រជាជនទូទៅ ទាំងពេលបច្ចុប្បន្ន ទាំងពេលអនាគត និងដើម្បីឆ្លើយតបចំពោះការអភិវឌ្ឍន៍ឧស្សាហកម្មដែលបញ្ចេញធាតុពុលកាន់តែច្រើន និងការប្រែប្រួលអាកាសធាតុជាសកលនៅពេលបច្ចុប្បន្ន ព្រមទាំងដើម្បីធានាដល់ការលូតលាស់នៃសង្គម សេដ្ឋកិច្ច និងការលើកកម្ពស់សុខុមាលភាពសាធារណៈ។
<u>វិស័យ៖ ការអភិវឌ្ឍន៍វិស័យអប់រំ សុខាភិបាល ការងារ វប្បធម៌ និងសង្គមកិច្ច</u>	
២៦.	តើអ្នកពេញចិត្តការបំពេញ/អនុវត្តន៍គោលនយោបាយអភិវឌ្ឍន៍ធនធានមនុស្សលើគ្រប់ផ្នែក រួមទាំងខាងវិទ្យាសាស្ត្រ បច្ចេកទេស និងចំណេះធ្វើក្នុងកំរិតណា? **១.** ០-២០% **២.** ២១%-៤០% **៣.** ៤១%-៦០% **៤.** ៦១%-៨០% **៥.**៨១%-១០០%
	<u>គោលនយោបាយសង្ខេបរួម៖</u> បន្តកសាង និងអភិវឌ្ឍន៍ធនធានមនុស្សលើគ្រប់ផ្នែកប្រកបដោយគុណភាព និងមានគុណធម៌ល្អប្រពៃដែលឆ្លើយតបទៅនឹងសំណូមពរនៃការអភិវឌ្ឍន៍សង្គម សេដ្ឋកិច្ច ដើម្បីកសាងកម្ពុជាឲ្យក្លាយជាសង្គមរីកចម្រើន ជឿនលឿន ដែលផ្អែកលើមូលដ្ឋានចំណេះដឹងលើគ្រប់វិស័យ រួមទាំងខាងវិទ្យាសាស្ត្របច្ចេកទេស និងចំណេះធ្វើ ហើយដើរស្របជាមួយនឹងការរីកចម្រើននៃបណ្តាប្រទេសនៅក្នុងតំបន់ និងពិភពលោក។
២៧.	តើអ្នកពេញចិត្តការបំពេញ/អនុវត្តន៍គោលនយោបាយអភិវឌ្ឍន៍វិស័យកីឡា រួមទាំងកីឡាជនពិការ ទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិក្នុងកំរិតណា? **១.** ០-២០% **២.** ២១%-៤០% **៣.** ៤១%-៦០% **៤.** ៦១%-៨០% **៥.**៨១%-១០០%
	<u>គោលនយោបាយសង្ខេបរួម៖</u>

	ពង្រឹងការអនុវត្តគោលនយោបាយជាតិអភិវឌ្ឍន៍វិស័យអប់រំកាយ និងកីឡាឲ្យមានប្រសិទ្ធភាពខ្ពស់ សំដៅរួមចំណែកដល់ការលើកកម្ពស់សុខភាពប្រជាជន ពង្រឹងសាមគ្គីភាព និងត្រៀមលក្ខណៈសម្បត្តិឲ្យបានល្អដើម្បីចូលរួម និងទទួលរៀបចំព្រឹត្តិការណ៍កីឡាធំៗជាលក្ខណៈអន្តរជាតិនានានៅពេលខាងមុខដូចជា អាស៊ានហ្គេមជាដើម។
២៨.	តើអ្នកពេញចិត្តការបំពេញ/អនុវត្តន៍គោលនយោបាយអភិវឌ្ឍន៍វិស័យសុខាភិបាល ដោយយកចិត្តទុកដាក់ពិសេសប្រជាជនក្រីក្រងាយរងគ្រោះ និងប្រជាជនរស់នៅជនបទក្នុងកំរិតណា? **១.** ០-២០% **២.** ២១%-៤០% **៣.** ៤១%-៦០% **៤.** ៦១%-៨០% **៥.** ៨១%-១០០%
	<u>គោលនយោបាយសង្ខេបរួម៖</u> ផ្តល់សេវាសុខាភិបាលប្រកបដោយប្រសិទ្ធភាព គុណភាព សមធម៌ និងមានចីរភាពដល់ប្រជាជនទូទៅ ពិសេសប្រជាជនក្រីក្រងាយរងគ្រោះ និងប្រជាជនរស់នៅជនបទ។
២៩.	តើអ្នកពេញចិត្តការបំពេញ/អនុវត្តន៍គោលនយោបាយអភិវឌ្ឍន៍ការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងការកសាងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈឲ្យមាននៅគ្រប់ខេត្តក្នុងកំរិតណា? **១.** ០-២០% **២.** ២១%-៤០% **៣.** ៤១%-៦០% **៤.** ៦១%-៨០% **៥.** ៨១%-១០០%
	<u>គោលនយោបាយសង្ខេបរួម៖</u> តម្រង់ទិសលើការធ្វើឲ្យប្រជាជនមានការងារធ្វើ មានមុខរបរសមរម្យ ត្រឹមត្រូវ និងថ្លៃថ្នូរ ការការពារសិទ្ធិ និងផលប្រយោជន៍ស្របច្បាប់របស់និយោជក និងកម្មករ និយោជិត ព្រមទាំងការកសាង និងលើកកម្ពស់សមត្ថភាពបច្ចេកទេស និងវិជ្ជាជីវៈឲ្យរីកចម្រើនស្របតាមបទដ្ឋានអន្តរជាតិ។
៣០.	តើអ្នកពេញចិត្តការបំពេញ/អនុវត្តន៍គោលនយោបាយលើកកម្ពស់ការអភិរក្ស និងអភិវឌ្ឍន៍វប្បធម៌ធម្មជាតិ សេរីភាពខាងជំនឿ និងសាសនាក្នុងកំរិតណា? **១.** ០-២០% **២.** ២១%-៤០% **៣.** ៤១%-៦០% **៤.** ៦១%-៨០% **៥.**៨១%-១០០%
	<u>គោលនយោបាយសង្ខេបរួម៖</u> ថែរក្សាការពារបេតិកភណ្ឌវប្បធម៌ជាតិ ទាំងរូបិយ និងឲ្យស្ថិតស្ថេរគង់វង្សយូរអង្វែង បង្កើតផលិតផលវប្បធម៌ឲ្យបានកាន់តែច្រើន ហើយចូលរួមសកម្មភាពក្នុងការអភិវឌ្ឍន៍សេដ្ឋកិច្ចជាតិ និងកែលម្អជីវភាពប្រជាជនស្របតាមអត្ថន័យ វប្បធម៌ជាសេដ្ឋកិច្ច។
៣១.	តើអ្នកពេញចិត្តក្នុងកំរិតណា ចំពោះការបំពេញ/អនុវត្តន៍គោលនយោបាយអភិវឌ្ឍន៍វិស័យសង្គមកិច្ច អតីតយុទ្ធ និងយុវនីតិសម្បទា ដោយយកចិត្តទុកដាក់ចំពោះជនពិការ មនុស្សចាស់ អតីតយុទ្ធជន និងអតីតមន្ត្រីរាជការស៊ីវិល? **១.** ០-២០% **២.** ២១%-៤០% **៣.** ៤១%-៦០% **៤.** ៦១%-៨០% **៥.**៨១%-១០០%
	<u>គោលនយោបាយសង្ខេបរួម៖</u> ធ្វើឲ្យមានសុខុមាលភាពប្រជាជនមានស្ថានភាពកាន់តែប្រសើរឡើង ដោយមានសេវាសង្គមកិច្ចគ្រប់គ្រាន់សម្រាប់ជួយជនរងគ្រោះ និងជនងាយរងគ្រោះគ្រប់ប្រភេទ មានប្រព័ន្ធសន្តិសុខសង្គមរឹងមាំ និងទូលំទូលាយ សម្រាប់ធានារ៉ាប់រងចំពោះហានិភ័យសង្គម។
៣២.	តើអ្នកពេញចិត្តការបំពេញ/អនុវត្តន៍គោលនយោបាយពង្រឹងស្ថានភាព និងតួនាទីរបស់ស្ត្រីក្នុងសង្គម និងលើកស្ទួយសីលធម៌ និងតម្លៃរបស់ស្ត្រីខ្មែរ និងគោលនយោបាយឲ្យកុមារទទួលបានពិតប្រាកដនូវសិទ្ធិជាមូលដ្ឋានក្នុងកំរិតណា? **១.** ០-២០% **២.** ២១%-៤០% **៣.** ៤១%-៦០% **៤.** ៦១%-៨០% **៥.** ៨១%-១០០%
	<u>គោលនយោបាយសង្ខេបរួម៖</u> បន្តលើកកម្ពស់សមធម៌យេនឌ័រ ជំរុញភាពអង់អាចរបស់ស្ត្រីក្នុងសេដ្ឋកិច្ច ដោយជំរុញការបណ្តុះបណ្តាលបំពាក់

	បំប៉ងជំនាញបច្ចេកទេស និងផ្តល់កាលានុភាពដល់ស្ត្រីក្នុងពង្រឹងមុខរបរ បង្កើនចំណូល និងកសាងសហគ្រិនភាព បង្កើនឱកាសរៀនសូត្រសម្រាប់ស្ត្រី និងក្មេងស្រី ពិសេសនៅកម្រិតមធ្យមសិក្សាទុតិយភូមិ និងឧត្តមសិក្សា។ ជំរុញការផ្សព្វផ្សាយ និងអនុវត្តយ៉ាងហ្មត់ចត់នូវអនុសញ្ញាអន្តរជាតិ ស្តីពីសិទ្ធកុមារ ពិសេសធានាឲ្យកុមារបានទទួលពិតប្រាកដនូវសិទ្ធិជាមូលដ្ឋានទាំងបួនរបស់កុមារ គឺ«សិទ្ធិរស់រានមានជីវិត សិទ្ធិទទួលបានការអភិវឌ្ឍន៍ សិទ្ធិបានការការពារ និងសិទ្ធិចូលរួមរបស់កុមារ»។
៣៣.	តើអ្នកពេញចិត្តការបំពេញ/អនុវត្តន៍គោលនយោបាយអភិវឌ្ឍន៍យុវជន ខាងចំណេះដឹង ចំណេះធ្វើ សុខភាពកាយសម្បទាន និងមានសីលធម៌រស់នៅថ្លៃថ្នូរក្នុងកំរិតណា? **១.** ០-២០% **២.** ២១%-៤០% **៣.** ៤១%-៦០% **៤.** ៦១%-៨០% **៥.** ៨១%-១០០%
	<u>គោលនយោបាយសង្ខេបរួម៖</u> បន្តការលើកកម្ពស់ការអប់រំ និងបណ្តុះបណ្តាលមុខជំនាញវិជ្ជាជីវៈ បង្កើនការអប់រំ ការថែទាំ និងផ្តល់សេវាសុខភាព បន្តការពារសន្តិសុខ សុវត្ថិភាព និងយុត្តិធម៌សម្រាប់យុវជន ពង្រឹងចលនាស្មគ្រចិត្តរបស់យុវជនចូលរួមក្នុងសកម្មភាពកសាងយុត្តិធម៌ក្នុងសង្គម និងចលនាកាយវិទ្ធនៅតាមសាលាបឋមសិក្សា អនុវិទ្យាល័យ និង វិទ្យាល័យ និងចលនាយុវជនកាកបាទក្រហម។
ការផ្តល់ពិន្ទុជារួមលើការបំពេញ/អនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៥នៃរដ្ឋសភា សម្រាប់ឆ្នាំទី2	
៣៤.	តើអ្នកពេញចិត្តការបំពេញ/អនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៥ ក្នុងកំរិតណា? **១.** ០-២០% **២.** ២១%-៤០% **៣.** ៤១%-៦០% **៤.** ៦១%-៨០% **៥.** ៨១%-១០០%

- **តារាងប្រៀបធៀបលទ្ធផលជាមធ្យមនៃការផ្តល់ពិន្ទុលើកទី១ និងទី២ ចំពោះការអនុវត្តន៍/បំពេញគោលនយោបាយ របស់រាជរដ្ឋាភិបាលឆ្នាំ២០១៥ និងឆ្នាំ២០១៦ នៃខេត្ត/រាជធានីនីមួយៗ**

វិស័យ	រាជធានី/ខេត្ត	ឆ្នាំ	1.មិនពេញចិត្តទាល់តែសោះ ឬពេញចិត្តតិចតួច (%)	2.ពេញចិត្តខ្លះ (%)	3.ពេញចិត្តមធ្យម ឬពេញចិត្តពាក់កណ្តាល (%)	4.ពេញចិត្តប្រៃ (%)	5.ពេញចិត្តស្រឡាំងតែទាំងស្រុង ឬពេញចិត្តទាំងស្រុង (%)
និងស	១. បន្ទាយមានជ័យ	2015	0.00	13.25	41.20	38.25	7.35
		2016	9.09	47.73	27.27	11.36	4.55
	២. កំពង់ឆ្នាំង	2015	16.45	30.20	16.25	23.40	13.75
		2016	11.58	21.79	20.81	23.93	21.90
	៣. កំពង់ស្ពឺ	2015	10.00	25.00	38.30	23.35	3.35
		2016	9.73	33.81	48.52	7.94	0.00
	៤. កំពង់ធំ	2015	0.00	24.00	52.00	12.00	12.00
		2016	28.20	49.20	17.40	3.48	1.72
	៥. កណ្តាល	2015	2.10	16.70	37.50	27.10	16.65
		2016	21.49	53.70	23.62	1.19	0.00
	៦. ភ្នំពេញ	2015	55.02	24.92	13.72	4.42	1.90
		2016	44.90	38.90	12.65	3.14	0.41
	៧. ព្រះសីហនុ	2015	24.40	43.45	26.40	5.70	0.00
		2016	36.93	43.30	11.32	2.81	5.63
	៨. ព្រះវិហារ	2015	40.90	31.80	18.20	4.50	4.50
		2016	55.68	25.00	14.77	3.41	1.14
សន្តិ	៩. ព្រៃវែង	2015	14.84	14.83	39.72	18.15	12.46
		2016	14.84	14.83	39.72	18.15	12.46
	១០. រតនគិរី	2015	11.50	44.20	22.90	9.90	11.50
ការ		2016	28.04	35.91	14.80	12.52	8.74
	១១. សៀមរាប	2015	8.20	18.55	28.15	28.45	16.60
		2016	6.72	22.30	28.25	33.99	8.75
	១២. ស្វាយរៀង	2015	6.90	25.75	39.95	25.50	1.90
		2016	9.48	31.79	26.21	28.26	4.27
	១៣. តាកែវ	2015	3.80	44.25	38.50	11.55	1.90
		2016	10.73	35.46	35.37	13.04	5.39
	១៤. ត្បូងឃ្មុំ	2015	50.95	38.05	7.85	1.55	1.60
		2016	17.80	40.92	26.55	11.05	3.68

វិស័យ	រាជធានី/ខេត្ត	ឆ្នាំ	1.មិនពេញចិត្តទាល់តែសោះ ឬពេញចិត្តតិចតួច (%)	2.ពេញចិត្តខ្លះ (%)	3.ពេញចិត្តមធ្យម ឬពេញចិត្តពាក់កណ្តាល (%)	4.ពេញចិត្តច្រើន (%)	5.ពេញចិត្តស្រឡះតែទាំងស្រុង ឬពេញចិត្តទាំងស្រុង (%)
	១. បន្ទាយមានជ័យ	2015	1.45	14.70	44.10	30.90	8.85
		2016	5.76	37.30	41.93	9.23	5.78
	២. កំពង់ឆ្នាំង	2015	6.95	42.10	25.40	25.55	0.00
		2016	16.08	23.60	21.38	22.37	16.57
	៣. កំពង់ស្ពឺ	2015	11.65	46.70	16.65	23.35	1.65
		2016	12.53	38.08	43.61	5.78	0.00
	៤. កំពង់ធំ	2015	0.00	22.00	52.00	20.00	6.00
		2016	20.28	45.87	23.10	6.07	4.68
	៥. កណ្តាល	2015	0.00	25.00	45.80	25.00	4.15
		2016	34.93	30.86	26.09	7.50	0.63
	៦. ភ្នំពេញ	2015	57.85	22.91	11.94	3.64	3.66
		2016	49.21	34.86	12.61	3.16	0.16
	៧. ព្រះសីហនុ	2015	24.50	35.65	30.25	9.55	0.00
		2016	27.40	48.08	15.87	8.65	0.00
	៨. ព្រះវិហារ	2015	36.35	50.00	4.50	4.50	4.50
		2016	60.23	22.16	11.36	5.68	0.57
	៩. ព្រៃវែង	2015	2.10	14.60	27.10	33.35	22.90
		2016	14.95	13.49	36.39	19.24	15.93
	១០. រតនគិរី	2015	11.45	45.85	21.40	11.40	9.90
		2016	22.27	37.24	20.93	11.21	8.35
	១១. សៀមរាប	2015	2.15	28.45	34.45	28.65	6.25
		2016	8.04	24.62	32.02	23.80	11.53
	១២. ស្វាយរៀង	2015	3.45	34.35	43.55	18.60	0.00
		2016	18.06	32.85	28.19	16.38	4.51
	១៣. តាកែវ	2015	3.80	50.00	38.50	5.75	1.90
		2016	14.13	24.46	47.83	11.41	2.17
	១៤. ត្បូងឃ្មុំ	2015	57.20	39.65	3.15	0.00	0.00
		2016	12.53	34.23	33.42	16.09	3.74

វិស័យ	រាជធានី/ខេត្ត	ឆ្នាំ	1.មិនពេញចិត្តទាល់តែសោះ ឬពេញចិត្តតិចតួច (%)	2.ពេញចិត្តខ្លះ (%)	3.ពេញចិត្តមធ្យម ឬពេញចិត្តពាក់កណ្តាល (%)	4.ពេញចិត្តច្រើន (%)	5.ពេញចិត្តស្ទើរតែទាំងស្រុង ឬពេញចិត្តទាំងស្រុង (%)
ការអ	១. បន្ទាយមានជ័យ	2015	0.00	8.80	58.80	32.35	0.00
		2016	5.49	34.95	40.69	13.18	5.69
	២. កំពង់ឆ្នាំង	2015	7.00	39.70	30.10	23.15	0.00
		2016	8.43	27.91	24.62	21.64	17.40
	៣. កំពង់ស្ពឺ	2015	16.65	48.30	25.00	8.35	1.65
		2016	17.19	39.88	35.95	6.53	0.45
	៤. កំពង់ធំ	2015	0.00	24.00	56.00	12.00	8.00
		2016	18.18	41.37	26.98	10.04	3.44
	៥. កណ្តាល	2015	2.10	27.10	41.70	29.15	0.00
		2016	17.13	38.98	37.24	5.73	0.92
	៦. ភ្នំពេញ	2015	44.91	30.45	14.17	5.31	5.14
		2016	41.17	34.00	18.44	5.48	0.91
	៧. ព្រះសីហនុ	2015	16.95	41.35	36.05	3.75	1.90
		2016	24.71	43.87	20.98	9.83	0.61
	៨. ព្រះវិហារ	2015	29.55	52.30	13.60	0.00	4.50
		2016	56.68	26.98	11.83	4.28	0.24
	៩. ព្រៃវែង	2015	0.00	12.50	27.10	39.60	20.85
		2016	5.56	14.76	36.94	26.32	16.43
	១០. រតនគិរី	2015	9.90	45.80	26.25	13.10	4.95
		2016	14.83	37.03	32.95	10.60	4.60
	១១. សៀមរាប	2015	0.00	32.80	34.70	32.50	0.00
		2016	3.24	22.47	34.50	28.85	10.94
	១២. ស្វាយរៀង	2015	1.70	42.05	43.40	12.85	0.00
		2016	11.23	34.56	29.35	20.40	4.45
	១៣. តាកែវ	2015	1.90	59.65	25.00	13.45	0.00
		2016	7.54	30.44	39.17	18.60	4.25
	១៤. ត្បូងឃ្មុំ	2015	61.95	34.80	3.25	0.00	0.00
		2016	10.40	35.06	33.10	17.75	3.69

វិស័យ	រាជធានី/ខេត្ត	ឆ្នាំ	1.មិនពេញចិត្តទាល់តែសោះ ឬពេញចិត្តតិចតួច (%)	2.ពេញចិត្តខ្លះ (%)	3.ពេញចិត្តមធ្យម ឬពេញចិត្តពាក់កណ្តាល (%)	4.ពេញចិត្តច្រើន (%)	5.ពេញចិត្តស្ទើរតែទាំងស្រុង ឬពេញចិត្តទាំងស្រុង (%)
និងស	១. បន្ទាយមានជ័យ	2015	0.00	7.35	50.00	32.35	10.30
		2016	5.97	34.54	40.97	14.65	3.87
	២. កំពង់ឆ្នាំង	2015	9.50	28.60	28.60	30.95	2.40
		2016	8.20	26.37	27.65	22.45	15.32
	៣. កំពង់ស្ពឺ	2015	15.00	48.35	23.30	11.65	1.65
		2016	17.82	38.74	36.26	5.06	2.12
	៤. កំពង់ធំ	2015	0.00	18.00	58.00	20.00	4.00
		2016	19.95	39.25	34.55	3.78	2.47
	៥. កណ្តាល	2015	0.00	16.65	45.85	37.50	0.00
		2016	11.27	33.09	44.92	8.52	2.20
១	៦. ភ្នំពេញ	2015	44.84	29.68	14.48	4.73	6.31
		2016	31.03	38.32	22.68	6.63	1.34
១	៧. ព្រះសីហនុ	2015	15.75	37.40	33.30	9.70	3.85
		2016	22.12	40.63	23.56	12.26	1.44
	៨. ព្រះវិហារ	2015	20.55	69.7	4.75	0.00	5.05
		2016	55.57	26.64	13.90	3.60	0.30
	៩. ព្រៃវែង	2015	0.00	12.85	19.10	40.30	27.70
		2016	5.32	15.03	29.64	31.67	18.33
	១០. រតនគិរី	2015	9.85	45.75	23.05	13.10	8.25
		2016	11.36	37.06	32.68	12.99	5.89
	១១. សៀមរាប	2015	2.15	28.15	38.80	28.95	1.90
		2016	3.26	21.29	33.75	31.61	10.08
	១២. ស្វាយរៀង	2015	5.15	32.80	33.05	28.95	0.00
		2016	9.09	32.28	34.36	19.10	5.18
	១៣. តាកែវ	2015	3.85	40.40	42.30	9.60	3.85
		2016	12.81	25.25	39.28	17.72	4.94
	១៤. ត្បូងឃ្មុំ	2015	55.60	34.90	8.00	1.55	0.00
		2016	6.17	31.92	31.90	23.16	6.86

វិស័យ	រាជធានី/ខេត្ត	ឆ្នាំ	1.មិនពេញចិត្តទាល់តែសោះ ឬពេញចិត្តតិចតួច (%)	2.ពេញចិត្តខ្លះ (%)	3.ពេញចិត្តមធ្យម ឬពេញចិត្តពាក់កណ្តាល (%)	4.ពេញចិត្តច្រើន (%)	5.ពេញចិត្តស្ទើរតែទាំងស្រុង ឬពេញចិត្តទាំងស្រុង (%)
	១. បន្ទាយមានជ័យ	2015	0.36	11.03	48.53	33.46	6.63
		2016	6.58	38.63	37.72	12.11	4.97
	២. កំពង់ឆ្នាំង	2015	9.98	35.15	25.09	25.76	4.04
		2016	11.07	24.92	23.61	22.60	17.80
	៣. កំពង់ស្ពឺ	2015	13.33	42.09	25.81	16.68	2.08
		2016	14.32	37.63	41.08	6.33	0.64
	៤. កំពង់ធំ	2015	0.00	22.00	54.50	16.00	7.50
		2016	21.65	43.92	25.51	5.84	3.08
	៥. កណ្តាល	2015	1.05	21.36	42.71	29.69	5.20
		2016	21.21	39.15	32.97	5.73	0.94
	៦. ភ្នំពេញ	2015	50.66	26.99	13.58	4.52	4.25
ផ្ទៃ		2016	41.58	36.52	16.60	4.60	0.71
	៧. ព្រះសីហនុ	2015	20.40	39.46	31.50	7.18	1.44
		2016	27.79	43.97	17.93	8.39	1.92
	៨. ព្រះវិហារ	2015	31.84	50.95	10.26	2.25	4.64
		2016	57.04	25.19	12.97	4.24	0.56
	៩. ព្រៃវែង	2015	1.05	13.11	23.54	37.69	24.63
គោ		2016	10.17	14.53	35.67	23.84	15.79
	១០. រតនគិរី	2015	10.68	45.40	23.40	11.88	8.65
		2016	19.12	36.81	25.34	11.83	6.90
	១១. សៀមរាប	2015	3.13	26.99	34.03	29.64	6.19
		2016	5.32	22.67	32.13	29.56	10.32
	១២. ស្វាយរៀង	2015	4.30	33.74	39.99	21.48	0.48
		2016	11.96	32.87	29.53	21.04	4.60
	១៣. តាកែវ	2015	3.34	48.58	36.08	10.09	1.91
		2016	11.30	28.90	40.41	15.19	4.19
	១៤. ត្បូងឃ្មុំ	2015	56.43	36.85	5.56	0.78	0.40
		2016	11.72	35.53	31.24	17.01	4.49

- **រូបភាពសកម្មភាពវេទិកាម្ហាស់ឆ្លាត**

សកម្មភាព៖ វាគ្មិនកំពុងបង្ហាញចំណាប់អារម្មណ៍ និងព័ត៌មានអំពីការបំពេញ/អនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាល

សកម្មភាព៖ អ្នកចូលរួមកំពុងបង្ហាញចំណាប់អារម្មណ៍ និងព័ត៌មានអំពីការបំពេញ/អនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាល

សកម្មភាព៖ អ្នកចូលរួមកំពុងបង្ហាញចំណាប់អារម្មណ៍ និងព័ត៌មានអំពីការបំពេញ/អនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាល

សកម្មភាព៖ អ្នកចូលរួមកំពុងផ្តល់ពិន្ទុ និងការបង្ហាញអំពីលទ្ធផលនៃការបំពេញ/អនុវត្តន៍គោលនយោបាយរបស់រាជរដ្ឋាភិបាល



- **តារាងព័ត៌មានទំនាក់ទំនងរបស់ក្រសួង និងរដ្ឋលេខាធិការដ្ឋាននៃរាជរដ្ឋាភិបាលនីតិកាលទី៥ (ឆ្នាំទី៣)**

ល.រ	ស្ថាប័ន	រដ្ឋមន្ត្រី និង ព័ត៌មានផ្ទាល់ខ្លួន	ទំនាក់ទំនង	អាសយដ្ឋាន
១	ទីស្តីការគណៈរដ្ឋមន្ត្រី	**ឯ. សុខ អាន** កំរិតវប្បធម៌៖ គ្មានព័ត៌មាន ទូរស័ព្ទ/ទូរសារ៖(៨៥៥)២៣ ៨៨០ ៦២៨	ទូរស័ព្ទ៖ +៨៥៥ - (0)២៣- ២១២ -៤៩០ អ៊ីម៉ែល៖ info@presscm.gov.kh , pressocm@gmail.com	អាសយដ្ឋាន៖ #41 មហាវិថី សហព័ន្ធរុស្សុី រាជធានីភ្នំពេញ គេហទំព័រ៖ www.pressocm.gov.kh
២	ក្រសួងមហាផ្ទៃ	**ឯ. ស ខេង** កំរិតវប្បធម៌៖ សញ្ញាប័ត្រផ្នែកវិទ្យាសាស្ត្រនយោបាយ ទូរស័ព្ទ៖(៨៥៥)១២ ៨៥៨ ៨៥៨	ទូរស័ព្ទ / ទូរសារ៖ (៨៥៥)២៣ ៧២១៩០៥, (៨៥៥)២៣ ៧២៦០៥២/៧២១១៩០ E-Mail: moi@interior.gov.kh	អាសយដ្ឋាន៖ #២៧៥ មហាវិថីព្រះនរោត្តម,រាជធានីភ្នំពេញ គេហទំព័រ៖ http://www.interior.gov.kh/
៣	ក្រសួងការពារជាតិ	**ឯ. ទៀ បាញ់** កំរិតវប្បធម៌៖គ្មានព័ត៌មាន ទូរស័ព្ទ៖ គ្មានព័ត៌មាន	ទូរស័ព្ទ / ទូរសារ៖ +៨៥៥(២៣) ៨៨៣ ២៧៤ អ៊ីម៉ែល: generalsec@mod.gov.kh	អាសយដ្ឋាន៖ សង្កាត់មិត្តភាព , ខណ្ឌ ៧មករា, រាជធានី ភ្នំពេញ គេហទំព័រ៖ http://www.mod.gov.kh
៤	ក្រសួងការបរទេស	**ឯ. ប្រាក់ សុខុន** កំរិតវប្បធម៌៖ សញ្ញា ប័ត្រនៃមជ្ឈមណ្ឌលសិក្សាផ្នែក ការទូត និងយុទ្ធសាស្ត្រ ទូរស័ព្ទ៖ គ្មានព័ត៌មាន	ទូរស័ព្ទ៖ (៨៥៥) ២៣ ២១៤ ៤៤១ / ២១៦ ១២២ ទូរសារ៖ ៖ (៨៥៥) ២៣ ២១៦ ១៤៤ / ២១៦ ១៤១	អាសយដ្ឋាន៖ អគារលេខ០៣ វិថី សម្តេចហ៊ុនសែន រាជធានី ភ្នំពេញ គេហទំព័រ៖ www.mfaic.gov.kh

			អ៊ីម៉ែលៈ mfaic@mfa.gov.kh	
៥	ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ	**ឯ. អូន ព័ន្ធមុន្នីរ័ត្ន** កំរិតវប្បធម៌ៈ បណ្ឌិតទស្សនៈវិជ្ជា ទូរស័ព្ទៈ គ្មានព័ត៌មាន	ទូរស័ព្ទៈ +(៨៥៥) ២៣ - ៧២៤ ៦៦៤ ទូរសារៈ គ្មានព័ត៌ មាន អ៊ីម៉ែលៈ admin@mef.gov.kh	អាសយដ្ឋានៈ អគារលេខ ៦០ ផ្លូវលេខ ៩២ សង្កាត់ វត្តភ្នំខណ្ឌ ដូនពេញ រាជធានី ភ្នំពេញ គេហទំព័រៈ www.mef.gov.kh
៦	ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ	ឯ. **វេន សាខុន** កំរិតវប្បធម៌ៈ គ្មានព័ត៌មាន ទូរស័ព្ទៈ គ្មានព័ត៌មាន	ទូរស័ព្ទៈ (855) 23 726 128 / 23 726 129 ទូរសារៈ(855) 23 217 320 អ៊ីម៉ែលៈ info@maff.gov.kh	អាស័យដ្ឋានៈ លេខ 200 មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ គេហទំព័រៈ http://www.maff.gov.kh/
៧	ក្រសួងអភិវឌ្ឍន៍ជនបទ	**ឯ. . អ៊ីក រ៉ាប៊ីន** កំរិតវប្បធម៌ៈគ្មានព័ត៌មាន ទូរស័ព្ទៈ គ្មានព័ត៌មាន	ទូរស័ព្ទលេខៈ គ្មានព័ត៌ មាន ទូរសារលេខៈគ្មានព័ត៌ មាន អ៊ីម៉ែលៈ គ្មានព័ត៌មាន	អាសយដ្ឋានៈ ផ្លូវលេខ ១៦៩)ឆេកូឆ្លូវ៉ាគី (កាច់ជ្រុង ផ្លូវ សហព័ន្ធរុស្ស៊ី,រាជធានីភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា។ គេហទំព័រៈ www.mrd.gov.kh
៨	ក្រសួងពាណិជ្ជកម្ម	**ឯ. ប៉ាន សូរស័ក្តិ** កំរិតវប្បធម៌ៈគ្មានព័ត៌មាន ទូរស័ព្ទៈ គ្មានព័ត៌មាន	ទូរស័ព្ទ/ ទូរសារៈ (៨៥៥) ២៣ ៨៦៦ ៤៦៩ អ៊ីម៉ែលៈ គ្មានព័ត៌មាន	អាសយដ្ឋានៈ ឡូត៍ លេខ១៩-៦១, វិថីក្រសួងពាណិជ្ជកម្ម)ផ្លូវលេខ១១៣បេ (, ភូមិទឹកថ្លា, សង្កាត់ទឹកថ្លា, ខណ្ឌសែនសុខ, ភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា គេហទំព័រៈ http://www.moc.gov.kh/

៩	ក្រសួងឧស្សាហកម្ម	**ឯ. ចម ប្រសិទ្ធ** កំរិតវប្បធម៌៖គ្មានព័ត៌មាន ទូរស័ព្ទ៖ គ្មានព័ត៌មាន	ទូរស័ព្ទ៖ គ្មានព័ត៌មាន អ៊ីម៉ែល៖ គ្មានព័ត៌មាន	អាសយដ្ឋាន៖ អគារលេខ ៤៥, មហាវិថីព្រះនរោត្តម, ភ្នំពេញ គេហទំព័រ៖ http://www.mih.gov.kh/
១០	ក្រសួងរ៉ែ និងថាមពល	**ឯ. ស៊ុយ សែម** កំរិតវប្បធម៌៖គ្មានព័ត៌មាន ទូរស័ព្ទ៖ គ្មានព័ត៌មាន	ទូរស័ព្ទ៖ (៨៥៥) ២៣ ២១៩ ៥៧៨ ទូរសារ៖ (៨៥៥) ២៣ ២១៩ ៥៨៤ អ៊ីម៉ែល៖ info@mme.gov.kh	អាសយដ្ឋាន៖ អគារលេខ ៧៩-៨៩, វិថីប៉ាស្ទ័រ (៥១) សង្កាត់ផ្សារថ្មី៣ ខណ្ឌដូនពេញ រាជធានីភ្នំពេញ គេហទំព័រ៖ http://www.mme.gov.kh/
១១	ក្រសួងដែនការ	**ឯ. ឆាយ ថន** កំរិតវប្បធម៌៖គ្មានព័ត៌មាន ទូរស័ព្ទ៖ គ្មានព័ត៌មាន	ទូរស័ព្ទ៖ (៨៥៥)២៣ ៧២០ ៩០១ អ៊ីម៉ែល៖ គ្មានព័ត៌មាន	អាសយដ្ឋាន៖ អគារលេខ ៣៨៦ មហាវិថី ព្រះមុនីវង្ស រាជធានី ភ្នំពេញ គេហទំព័រ៖ www.mop.gov.kh
១២	ក្រសួងអប់រំ យុវជន និងកីឡា	**ឯ. ហង់ ជួនណារ៉ុន** កំរិតវប្បធម៌៖ បណ្ឌិតសេដ្ឋកិច្ចអន្តរជាតិ ទូរស័ព្ទ៖ (៨៥៥)១២ ៨៤៣ ៨៨៩ (៨៥៥)២៣ ២១៧ ២៥០	ទូរស័ព្ទ៖ (៨៥៥)២៣ ២១០ ១៨៧ (៨៥៥)២៣ ២១៧ ២៥៣ (៨៥៥)២៣ ៤២៦ ៩៥១ ទូរសារ៖ (៨៥៥) ២៣ ២១៧ ២៥០ / ២១២ ៥១២ អ៊ីម៉ែល៖ info@moeys.gov.kh crsmeys@camnet.com.kh	អាសយដ្ឋាន៖ អគារលេខ ៨០ មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា គេហទំព័រ៖ http://www.moeys.gov.kh/

១៣	ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា	**ឯ. វង សូត** កំរិតវប្បធម៌៖ គ្មានព័ត៌មាន ទូរស័ព្ទ៖ គ្មានព័ត៌មាន	ទូរស័ព្ទ/ទូរសារ៖ គ្មានព័ត៌មាន អ៊ីម៉ែល៖ គ្មានព័ត៌មាន	អាសយដ្ឋាន៖ អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស សង្កាត់ចឹងត្របែក ខណ្ឌចំការមក រាជធានីភ្នំពេញ គេហទំព័រ៖ http://www.mosvy.gov.kh
១៤	ក្រសួងរៀបចំដែនដីនគរូបនីយកម្ម និងសំណង់	**ឯ. ជា សុផារ៉ា** កំរិតវប្បធម៌៖ គ្មានព័ត៌មាន ទូរស័ព្ទ៖ គ្មានព័ត៌មាន	ទូរស័ព្ទ/ទូរសារ៖ គ្មានព័ត៌មាន អ៊ីម៉ែល៖ គ្មានព័ត៌មាន	អាស័យដ្ឋាន៖ អគារលេខ ៧៨៨ មហាវិថីព្រះមុនីវង្ស រាជធានីភ្នំពេញ គេហទំព័រ៖http://www.mlmupc.gov.kh
១៥	ក្រសួងបរិស្ថាន	**ឯ. សាយ សំអាល់** កំរិតវប្បធម៌៖ គ្មានព័ត៌មាន ទូរស័ព្ទ៖ គ្មានព័ត៌មាន	ទូរស័ព្ទ៖(+855) 23 213 908 (+855) 23 220 369 ទូរសារ: 023 212 540 អ៊ីម៉ែល៖ info@moe.gov.kh	អាស័យដ្ឋាន៖ អគារមរតកតេជោ ដីឡូលេខ៥០៣ ផ្លូវកៅស៊ូអមមាត់ទន្លេបាសាក់ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន ភ្នំពេញ គេហទំព័រ៖ http://www.moe.gov.kh
១៦	ក្រសួងធនធានទឹក និងឧតុនិយម	**ឯ. លឹម គានហោ** កំរិតវប្បធម៌៖ គ្មានព័ត៌មាន ទូរស័ព្ទ៖ គ្មានព័ត៌មាន	ទូរស័ព្ទ៖ (៨៥៥) ២៣ ២១៦ ៦៧០ អ៊ីម៉ែល៖ គ្មានព័ត៌មាន	អាសយដ្ឋាន៖ ផ្លូវព្រះមុនីវង្ស សង្កាត់ផ្សារដលុមថ្ងូ ខណ្ឌចំការមន រាជធានីភ្នំពេញ គេហទំព័រ៖ http://www.mowram.gov.kh
១៧	ក្រសួងព័ត៌មាន	**ឯ. ខៀវ កាញារីទ្ធ** កំរិតវប្បធម៌៖ សាលាជាតិផ្នែករដ្ឋបាល និងការទូត ទូរស័ព្ទ៖ (៨៥៥)២៣ ៤៣០ ៧០០	ទូរស័ព្ទ៖(+៨៥៥) ២៣ ៧២ ៤១ ៥៩ អ៊ីម៉ែល៖info@information.gov.kh	អាសយដ្ឋាន៖ #62 មហាវិថី ព្រះមុនីវង្ស រាជធានីភ្នំពេញ គេហទំព័រ៖ http://www.information.gov.kh/

១៨	ក្រសួងយុត្តិធម៌	**ឯ. អង្គ រង្ស៎ រ៉ូឌ្ឍនា** កំរិតវប្បធម៌៖ គ្មានព័ត៌មាន ទូរស័ព្ទ៖ គ្មានព័ត៌មាន	ទូរស័ព្ទ៖ គ្មានព័ត៌មាន អ៊ីម៉ែល៖ គ្មានព័ត៌មាន	អាសយដ្ឋាន៖ អគារលេខ ២៤០ មហាវិថីសុធារស រាជធានីភ្នំពេញ គេហទំព័រ: មិនមានព័ត៌មាន
១៩	ក្រសួងទំនាក់ទំនងជួយរដ្ឋសភា និងព្រឹទ្ធសភា និងអធិការកិច្ច	**ជ.ំ ម៉ែន សំអន** កំរិតវប្បធម៌៖ គ្មានព័ត៌មាន ទូរស័ព្ទ៖ គ្មានព័ត៌មាន	ទូរស័ព្ទលេខ) :855(23 221 417)855(23 213 571 ទូរសារលេខ) :855(23 221 416 អ៊ីមែល : info@monasri.gov.kh	អាស័យដ្ឋាន៖ អគារលេខ ១២៦ ផ្លូវលេខ ៣ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ គេហទំព័រ : www.monasri.gov.kh
២០	ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍	**ឯ. ក្រាំ អ៊ីវតឹក** កំរិតវប្បធម៌៖ បណ្ឌិត វិស្វករ នៅសាកលវិទ្យាល័យនៃប្រទេសបារាំង ទូរស័ព្ទ៖ គ្មានព័ត៌មាន	ទូរស័ព្ទ :(៨៥៥) ២៣ ៧២៤ ៨០៩ (៨៥៥)២៣ ៤២៨ ២៤៦ អ៊ីម៉ែល :info@mptc.gov.kh	អាសយដ្ឋាន: ផ្លូវកែងលេខ ១៣ និង ១០២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ គេហទំព័រ: www.mptc.gov.kh
២១	ក្រសួងសុខាភិបាល	**ឯ. ម៉ម ប៊ុនហេង** កំរិតវប្បធម៌៖ គ្មានព័ត៌មាន ទូរស័ព្ទ៖ គ្មានព័ត៌មាន	ទូរស័ព្ទ៖ (៨៥៥)២៣ ៧២ ២៨ ៧៣ ទូរសារ៖ (៨៥៥)២៣ ៤២៦ ៨៤១	អាសយដ្ឋាន៖ អគារលេខ ១៥១-១៥៣ មហាវិថីកម្ពុជាក្រោម រាជធានីភ្នំពេញ គេហទំព័រ: មិនមានព័ត៌មាន (មិនដំណើរការ)
២២	ក្រសួងសាធារណការ និង	**ឯ. ស៊ុន ចាន់ថុល**	ទូរស័ព្ទ៖ (៨៥៥)២៣ ៤២៧ ៨៤៥	អាសយដ្ឋាន៖ មហាវិថីព្រះនរោត្តមកែងផ្លូវ១០៦

	ដឹកជញ្ជូន	កំរិតវប្បធម៌៖ គ្មានព័ត៌មាន ទូរស័ព្ទ៖ គ្មានព័ត៌មាន	អ៊ីម៉ែល៖ info@mpwt.gov.kh	រាជធានីភ្នំពេញ គេហទំព័រ៖ http://www.mpwt.gov.kh
២៣	ក្រសួងវប្បធម៌ និងវិចិត្រសិល្ប:	**ជំ. ភឿង សកុណា** កំរិតវប្បធម៌៖ បណ្ឌិតវិទ្យាសាស្ត្រអាហារ (អតិសុខុម) ។ សាកលវិទ្យាល័យ Bourgogne ប្រទេសបារាំង។ អ៊ីម៉ែល៖phoeurng.sackona@mcfa.gov.kh , sackonap@gmail.com ទូរស័ព្ទ៖ គ្មានព័ត៌មាន	ទូរស័ព្ទ៖ +(៨៥៥(២៣ ២១៨ ១៤៨ អ៊ីម៉ែល៖ គ្មានព័ត៌មាន	អាស័យដ្ឋាន៖ មហាវិថីព្រះនរោត្តម លេខ២២៧ សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ គេហទំព័រ៖ http://www.mcfa.gov.kh/
២៤	ក្រសួងទេសចរណ៍	**ឯ. ថោង ខុន** កំរិតវប្បធម៌៖ បណ្ឌិតគ្រប់គ្រងទេសចរណ៍ (ផែនអេកូ ទេសចរណ៍) ពីសាកលវិទ្យាល័យ សេដ្ឋកិច្ចជាតិទីក្រុងហាណូយ អ៊ីម៉ែល៖thongkhon@mot.gov.kh thongkhon@gmail.com ទូរស័ព្ទ៖(855)23 885 018 (855)12 808 254	ទូរស័ព្ទ៖ (៨៥៥)២៣ ៨៨ ៤៩ ៧៤ អ៊ីម៉ែល៖ info@tourismcambodia.org	អាសយដ្ឋាន៖ ឡូតិ៍លេខ3A សង្កាត់វាលវង់ ខណ្ឌ7 មករា រាជធានីភ្នំពេញ គេហទំព័រ៖ www.mot.gov.kh www.tourismcambodia.org

២៥	ក្រសួងធម្មការ និងសាសនា	**ឯ. មិន យិន** កំរិតវប្បធម៌ៈ គ្មានព័ត៌មាន ទូរស័ព្ទៈ គ្មានព័ត៌មាន	ទូរស័ព្ទៈ គ្មានព័ត៌មាន អ៊ីម៉ែលៈ គ្មានព័ត៌មាន	អាសយដ្ឋានៈ វិថីព្រះស៊ីសុវត្ថិ ជ័យជំនះ ដូនពេញ រាជធានីភ្នំពេញ គេហទំព័រៈ មិនមានព័ត៌មាន(មិនដំណើរការ)
២៦	ក្រសួងកិច្ចការនារី	**ជំ.អ៊ីង កន្ថាផាវី** កំរិតវប្បធម៌ៈ គ្មានព័ត៌មាន ទូរស័ព្ទៈ គ្មានព័ត៌មាន	ទូរស័ព្ទៈ គ្មានព័ត៌មាន អ៊ីម៉ែលៈគ្មានព័ត៌មាន	អាសយដ្ឋានៈ ផ្លូវទ្រុងមាន់ រាជធានីភ្នំពេញ គេហទំព័រៈ មិនមានព័ត៌មាន(មិនដំណើរការ)
២៧	ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ	**ឯ. អ៊ិត សំហេង** កំរិតវប្បធម៌ៈ គ្មានព័ត៌មាន ទូរស័ព្ទៈ គ្មានព័ត៌មាន	ទូរស័ព្ទ: ០២៣ ៨៨ ៤៣ ៧៥ ទូរសារ: ០២៣ ៨៨ ៤៣ ៧៦ អ៊ីម៉ែល: គ្មានព័ត៌មាន	អាសយដ្ឋានៈ អគារលេខ ៣ មហាវិថីសហព័ន្ធរុស្សី សង្កាត់ទឹកល្អក់ ខណ្ឌទួលគោក រាជធានីភ្នំពេញ គេហទំព័រៈ http://www.mlvt.gov.kh/
២៨	ក្រសួងមុខងារសាធារណៈ	**ឯ. ពេជ្រ ប៊ុនធិន** កំរិតវប្បធម៌ៈ គ្មានព័ត៌មាន ទូរស័ព្ទៈ គ្មានព័ត៌មាន	ទូរស័ព្ទ/ទូរសារ ៖ +៨៥៥-២៣-៨៦៦៥០១/ ៨៦៦ ៥០៥ អ៊ីម៉ែលៈ admin@mcs.gov.kh	អាសយដ្ឋានៈផ្លូវវត្តអង្គតាមុិញភូមិគោកចំបក់ សង្កាត់ចោមចៅ ខ័ណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា គេហទំព័រៈ http://www.mcs.gov.kh
២៩	រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល	**ឯ. ម៉ៅ ហាវណ្ណាល់** កំរិតវប្បធម៌ៈ គ្មានព័ត៌មាន ទូរស័ព្ទៈ គ្មានព័ត៌មាន	ទូរស័ព្ទ/ទូរសារៈ (៨៥៥)២៣ ២១១ ០១៩ អ៊ីម៉ែលៈ sengvany@camnet.com.kh	អាសយដ្ឋានៈ អគារ៦២ ផ្លូវនរោត្តម រាជធានីភ្នំពេញ គេហទំព័រៈ http://www.civilaviation.gov.kh/

- អត្ថបទសារព័ត៌មានចុះផ្សាយអំពីរបាយការណ៍ៈ

ពលរដ្ឋខ្លះមិនសូវពេញចិត្តនឹងការអនុវត្តគោលនយោបាយរបស់រដ្ឋាភិបាលក្នុងឆ្នាំ២០១៦

ដោយ សឿង ភារៈ08/01/201708/01/2017

http://km.rfi.fr/cambodia/some-cambadian-are-not-satisfied-with-the-implementation-of-government-policies-08-01-2017

វេទិកាស្តីពីការផ្តល់ពិន្ទុលើការបំពេញគោលនយោបាយរបស់រដ្ឋាភិបាលនិ ីតិកាលទី៥ ឆ្នាំទី៣RFI

ក្រុមនិស្សិត និងសាធារណជនប្រមាណ៥០នាក់នៅថ្ងៃនេះ តាមរយៈការស្ទង់មតិមួយ បានបង្ហាញភាពមិនសូវពេញចិត្តទៅនឹងការអនុវត្តគោលនយោបាយរបស់រដ្ឋាភិបាលកម្ពុជាក្នុងឆ្នាំ២០១៦នេះ។ តាមរយៈការស្ទង់មតិ ដែលរៀបចំដោយអង្គការខុមហ្ស្រ្វេលនៅព្រឹកនេះ ក៏បានឲ្យដឹងទៀតថាគោលនយោបាយសំខាន់ៗមួយចំនួន ដែលពលរដ្ឋមិនពេញចិត្តរួមមានដូចជា គោលនយោបាយកសិកម្ម ការដោះស្រាយបញ្ហាដីធ្លី និងប្រព័ន្ធយុត្តិធម៌ជាដើម។

តាមរយៈការស្ទង់មតិបឋម ដែលធ្វើឡើងនៅព្រឹកថ្ងៃទី០៨ ខែមករានេះ បានបង្ហាញថាក្នុងចំណោមអ្នកចូលរួមប្រមាណ៤៥នាក់ ដែលមានកម្រិតចំណេះដឹងផ្សេងៗគ្នា មានតែ ២៤,៤ភាគរយ មិនពេញចិត្តទាល់តែសោះ ចំពោះការអនុវត្តគោលនយោបាយរបស់រាជរដ្ឋាភិបាលនីតិកាលទី៥ ឆ្នាំ២០១៦ ចំណែក៥៧,៨ ភាគរយ ទៀតពេញចិត្តខ្លះ និង១៧,៨ភាគរយពេញចិត្តមធ្យម។

គោលនយោបាយសំខាន់ៗ ដែលខុមហ្ស្រ្វេលលើកយកមកធ្វើការស្ទង់មតិរួមមាន ការពង្រឹងរដ្ឋបាល

សាធារណៈ វិមជ្ឈការ និងសហមជ្ឈការ ការពង្រឹងផ្នែកច្បាប់ ប្រព័ន្ធយុត្តិធម៌ ការប្រឆាំងអំពើពុករលួយ ការការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ការអភិវឌ្ឍសេដ្ឋកិច្ច ការអភិវឌ្ឍវិស័យអប់រំ សុខាភិបាល ការងារវប្បធម៌ និងសង្គមកិច្ចជាដើម។

ការស្ទង់មតិនេះបានបង្ហាញថាអ្នកចូលរួមទាំងនោះមិនសូវជាពេញចិត្តនឹងការអនុវត្តគោលនយោបាយ លើការកែទម្រង់ប្រព័ន្ធយុត្តិធម៌ ការប្រយុទ្ធប្រឆាំងអំពើពុករលួយ ការអភិវឌ្ឍវិស័យកសិកម្ម កំណែទម្រង់ដីធ្លី និងការដោះស្រាយបញ្ហាដីធ្លី ការអភិវឌ្ឍវិស័យសុខាភិបាលជាដើម។ ចំណែកគោលនយោបាយផ្សេងៗទៀត ដែលអ្នកចូលរួមបានផ្តល់ពិន្ទុល្អ ឬពេញចិត្តមានដូចជា គោលនយោបាយ អភិវឌ្ឍន៍វិស័យកីឡា ការបន្តកំណើនសេដ្ឋកិច្ច និងការផ្គត់ផ្គង់ទឹកស្អាតជាដើម។

សូមជម្រាបជូនថាការស្ទង់មតិនេះធ្វើឡើងក្នុងចំណោមសិស្ស និស្សិត និងសាធារណជន ប្រមាណ៤៥នាក់ ដែលចូលរួមក្នុងវេទិកានេះលើកទី១ ហើយក្រោយពេលកិច្ចពិភាក្សាចប់នឹងមានការស្ទង់មតិជាលើកទី២ លើសម្រង់សំនួរដដែល។ ក្រៅពីនេះខុមប្រ្ហែលក៏នឹងប្រមូលទិន្នន័យបែបនេះ ពីតាមបណ្តាខេត្តផ្សេងៗទៀតដែរហើយរបាយការណ៍ផ្លូវការនឹងត្រូវចេញផ្សាយនៅខែកុម្ភៈខាងមុខនេះ។

លោកបណ្ឌិតមាស នី អ្នកវិភាគនយោបាយ និងសង្គមដែលចូលរួមក្នុងវេទិកានោះដែរបានថ្លែងថាការអនុវត្តគោល នយោបាយក្នុងវិស័យខ្លះបានដំណើរការយ៉ាងរលូន ចំណែកវិស័យខ្លះទៀតបានដើរថយក្រោយ។ លោកបានលើកជាឧទាហរណ៍ ប្រព័ន្ធយុត្តិធម៌កម្ពុជាកំពុងតែដើរថយក្រោយច្រើន វិស័យកងទ័ពមេទ័ពបង្ហាញជំហរគាំទ្របក្សនយោបាយ និងការប្រឆាំងអំពើពុករលួយ ក៏ត្រូវបានមហាជនសង្ស័យច្រើនជុំវិញករណីរឿងអាស្រូវលោកកឹម សុខាកន្លងមក។ ប៉ុន្តែលោកបញ្ជាក់ថា ការអនុវត្តគោលនយោបាយនៅក្នុងវិស័យអប់រំវិស័យគមនាគមន៍វិញបានធ្វើឲ្យមានកំណែទម្រង់ច្រើន។

លោកផៃ ស៊ីផានអ្នកនាំពាក្យរដ្ឋាភិបាល បានចាត់ទុកការស្ទង់មតិនេះថាពិបាកនឹងវាយតម្លៃ ព្រោះការស្ទង់មតិមួយត្រូវផ្អែកលើកត្តាផ្សេងៗទៀតជាច្រើនរាប់ ទាំងកម្រិតវប្បធម៌ពលរដ្ឋឡើងទៅ។ ជុំវិញលទ្ធបឋមនៃការស្ទង់មតិនេះ លោកយល់ថា មានតែ២០ភាគរយជាងប៉ុណ្ណោះ ដែលមិនពេញចិត្តនឹងការអនុវត្តគោលនយោបាយរបស់រដ្ឋាភិបាល ហើយជាង៧០ភាគរយផ្សេងទៀត ជាអ្នកពេញចិត្តល្មមៗ និងពេញចិត្តទាំងអស់។ លោកបញ្ជាក់ថា បើតាមតួលេខនេះគឺរដ្ឋាភិបាលកម្ពុជាដើរចំផ្លូវហើយ។

ផលិតដោយ៖

ខុមហ្វ្រែល COMFREL

គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (ខុមហ្វ្រែល)

http://www.comfrel.org

ខ្លឹមសារក្នុងរបាយការណ៍ មិនឆ្លុះបញ្ចាំងពីទស្សនៈរបស់ម្ចាស់ជំនួយឡើយ។

រូបថតក្រុមមុខ៖ ដកស្រង់ពីគេហទំព័រ

ឧបត្ថម្ភដោយ៖

diakonia PEOPLE CHANGING THE WORLD

Oxfam

OPEN SOCIETY FOUNDATIONS